


# រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍

## កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួល វគ្គបណ្តុះបណ្តាលប្រតិបត្តិករទេសចរណ៍

Australian Aid

World Vision

## រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍

កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួលវគ្គបណ្ដុះបណ្ដាលប្រតិបត្តិករទេសចរណ៍

ISBN: 978-0-9925215-1-6
រក្សាសិទ្ធិ © ឆ្នាំ ២០១៤ ដោយអង្គការទស្សនៈពិភពលោកកម្ពុជា

សម្ភារនៅក្នុងឯកសារបោះពុម្ពផ្សាយនេះអាចយកទៅប្រើប្រាស់ និងកែសម្រួលបាន ឱ្យតែមានការបញ្ជាក់ប្រភពឯកសារត្រឹមត្រូវថា បានដកស្រង់ពីប្រភពឯកសារនេះ។ អ្នកអាចទាញយកឯកសារអេឡិចត្រូនិចពីគេហទំព័រ http://www.childsafetourism.org ឬ http://wvi.org/asiapacific/childsafetourism ។ សូមផ្ញើសំណួរ ឬយោបល់ត្រឡប់ទៅកាន់អ៊ីម៉ែល childsafetourism@wvi.org.

**រូបថត៖** រូបថតទាំងអស់គឺរក្សាសិទ្ធិដោយអង្គការទស្សនៈពិភពលោក។ រូបថតទំព័រមុខដោយ Matt Burns ។ រូបកុមារដែលប្រើក្នុងសម្ភារអប់រំនេះគ្រាន់តែជាការលម្អប៉ុណ្ណោះ គម្រោងកុមារភាពមិនយករូបពិតរបស់កុមាររងគ្រោះដោយការរំលោភបំពានមកប្រើទេ។ អង្គការទស្សនៈពិភពលោកធ្វើការដោយយោងតាមបទដ្ឋានការពារកុមារក្នុងការថតរូបរបស់កុមារ ។

**រចនាដោយ៖** Inís Communication. មានលំនាំតាមជាភាសាខ្មែរ កែសម្រួលដោយ រចនាឌីហ្សាញ

គម្រោងកុមារភាពគឺជាការផ្តួចផ្តើមគំនិតមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (ឆ្នាំ ២០១១-២០១៤)។




# រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍

## កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួល វគ្គបណ្ដុះបណ្ដាលប្រតិបត្តិករទេសចរណ៍

# សេចក្តីថ្លែងអំណរគុណ

ការបង្កើតកញ្ចប់ឧបករណ៍ ដែលដឹកនាំដោយ Ms Aarti Kapoor ប្រធានកម្មវិធី និង Ms Afrooz Kaviani នាយកបច្ចេកទេសនៅក្នុងគម្រោងកុមារភាព ផ្ទែកបង្ការនេះ មានការចូលរួមពីមនុស្ស និងអង្គការជាច្រើន។ សូមថ្លែងអំណរគុណចំពោះអ្នកពិគ្រោះយោបល់របស់យើងឈ្មោះ Ms Anita Dodds ដែលបានសរសេរសំណៅពង្រាងកញ្ចប់ឧបករណ៍ក្នុងឆ្នាំ ២០១២។ សូមថ្លែងអំណរគុណផងដែរចំពោះ លោក ផង់ ចិន្តា Mr Chalermrat Chaiprasert, Mr Chansamone Bouakhamvongsa, and Mr Nguyen Khanh Hoi អ្នកសម្របសម្រួលថ្នាក់ជាតិ របស់គម្រោងកុមារភាពផ្ទែកបង្ការក្នុងប្រទេសកម្ពុជា ថៃ ឡាវ និងប្រទេសវៀតណាម ដែលបានចូលរួមគំនិត ការអនុវត្តន៍សាកល្បង និងការសម្របសម្រួលថ្នាក់ជាតិទៅលើកញ្ចប់ឧបករណ៍អ្នកសម្របសម្រួលចាប់តាំងពីឆ្នាំ ២០១២-២០១៤។  សូមអរគុណផងដែរចំពោះគំនិត និងយោបល់ត្រលប់ដែលផ្តល់ដោយដៃគូរដ្ឋាភិបាលជាតិ ដៃគូឧស្សាហកម្ម ក៏ដូចជាដៃគូអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា។ សូមថ្លែងអំណរគុណចំពោះ Ms Verity Kowal  មន្ត្រីផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង ដែលបានជួយសរសេរបញ្ចប់ ទៅលើកញ្ចប់ឧបករណ៍វេទិកាពិភាក្សាសម្រាប់ការបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៤ នេះ។ សូមថ្លែងអំណរគុណផងដែរចំពោះ លោក ហ៊ីម ជា និង លោកស្រី សាយ សុម៉ាលី សមាជិកក្រុមការងារនៃ គម្រោងកុមារភាពផ្ទែកបង្ការ និង លោកស្រី ស៊ីម សុជាតា ជាទីប្រឹក្សា ដែលបានចូលរួមក្នុងការបង្កើតសម្ភារនេះឡើងជាភាសាខ្មែរ ។

# មាតិកា


អារម្ភកថា ..... iii

សារតា ..... v

គោលបំណងនៃកញ្ចប់ឧបករណ៍ ..... vi

របៀបប្រើប្រាស់កញ្ចប់ឧបករណ៍ ..... vii

ផ្នែកទី១៖ សេចក្តីផ្តើម ..... 1

តើនអ្នកណាអាចសម្របសម្រួលវគ្គបណ្តុះបណ្តាលនេះបាន ? ..... 3

តើនអ្នកណាគួរចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ? ..... 4

តើអ្វីខ្លះជាលទ្ធផលរំពឹងទុកថានឹងទទួលបានពីការរៀនសូត្រនេះ ? ..... 5

តើវគ្គបណ្តុះបណ្តាលនេះ គួរមានអ្នកចូលរួមប៉ុន្មាននាក់ ? ..... 5

តើវគ្គបណ្តុះបណ្តាលគួរមានរយៈពេលប៉ុន្មាន ? ..... 6

ចុះចំណែកវាគ្មិនវិញ ? ..... 7

ការជ្រើសរើសទីកន្លែង ..... 8

តើឧបករណ៍និងធនធានអ្វីខ្លះដែលត្រូវការ ? ..... 10

គោលការណ៍ណែនាំពិសេស សម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការការពារកុមារ ..... 12

វិធីសាស្រ្តបណ្តុះបណ្តាល ..... 13

នៅថ្ងៃបណ្តុះបណ្តាល ..... 14

*ការប្រើប្រាស់ស្លាយ* ..... 14

*ការប្រើប្រាស់កាតយកតាមខ្លួន* ..... 15

*ការប្រើប្រាស់ឯកសារចែកជូនក្នុងវគ្គបណ្តុះបណ្តាល* ..... 15

*សម្រាកពិសារអាហារសម្រន់* ..... 15

*ការវាយតម្លៃ* ..... 16

*វិញ្ញាបនប័ត្រ* ..... 17

**ផ្នែកទី២៖ ការណែនាំតាមរយៈស្លាយ** ..... **19**

តើត្រូវប្រើប្រាស់សេចក្តីណែនាំពីស្លាយទាំងនេះដោយរបៀបណា ..... 21

វគ្គទី ១៖ សេចក្តីផ្តើម ..... 22

វគ្គទី២៖ តើ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ពាក់ព័ន្ធនឹងខ្ញុំដូចម្តេចខ្លះ ..... 26

វគ្គទី៣ ៖ តើវិស័យទេសចរណ៍មានគ្រោះថ្នាក់អ្វីខ្លះចំពោះកុមារ ..... 35

វគ្គទី៤ ៖ តើសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍គឺអ្វី ..... 46

វគ្គទី៥ ៖ តើបុគ្គលម្នាក់ៗ អាចធ្វើដូចម្តេចខ្លះ ដើម្បីឱ្យកុមារមានសុវត្ថិភាពក្នុងវិស័យទេសចរណ៍ ? ..... 55

វគ្គទី ៦ ៖ តើអាជីវកម្មអាចធ្វើយ៉ាងណា ដើម្បីឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ ?
( សម្រាប់អ្នកគ្រប់គ្រង ម្ចាស់អាជីវកម្មតែប៉ុណ្ណោះ ) ..... 61

វគ្គទី៧ ៖ តើរដ្ឋាភិបាលអាចធ្វើយ៉ាងណាខ្លះ ដើម្បីឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ ?
( សម្រាប់តែមន្ត្រីរដ្ឋាភិបាល ) ..... 68

វគ្គទី៨ ៖ សន្និដ្ឋាន ..... 81

**ផ្នែកទី៣៖ ឧបសម្ព័ន្ធ** ..... **77**

ឧបសម្ព័ន្ធទី១៖ គំរូរបៀបវារៈនៃការបណ្តុះបណ្តាលមួយថ្ងៃពេញ ..... 87

ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន ..... 88

ឧបសម្ព័ន្ធទី៣៖ ទម្រង់បញ្ជីវត្តមានអ្នកចូលរួម ..... 103

ឧបសម្ព័ន្ធទី៤៖ សំណួរមុនចូលមេរៀន ..... 104

ឧបសម្ព័ន្ធទី៥៖ សំណួរក្រោយមេរៀន ..... 105

ឧបសម្ព័ន្ធទី៦ ៖ សេណារីយ៉ូករណីសិក្សា និងការសម្តែងពីបុគ្គលិកវិស័យទេសចរណ៍ ..... 106

ឧបសម្ព័ន្ធ ៧៖ សេណារីយ៉ូករណីសិក្សាអំពីអ្នកគ្រប់គ្រងផ្នែកទេសចរណ៍ ..... 111

ឧបសម្ព័ន្ធទី៨៖ ទម្រង់ទស្សនៈរបស់ខ្ញុំ ..... 113

ឧបសម្ព័ន្ធទី ៩៖ គំរូវិញ្ញាបនប័ត្រ ..... 115

ឧបសម្ព័ន្ធទី១០៖ គំរូវិភាគលទ្ធផលលើសំណួរមុនចូលមេរៀន និងសំណួរក្រោយមេរៀន ..... 116

ឧបសម្ព័ន្ធទី១១៖ ទម្រង់គំរូរបាយការណ៍ក្រោយការបណ្តុះបណ្តាល ..... 118

# អារម្ភកថា



វិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស។ នៅឆ្នាំ២០១៣ ព្រះរាជាណាចក្រកម្ពុជាបានទទួលស្វាគមន៍ដំណើរកំសាន្តរបស់ភ្ញៀវទេសចរអន្តរជាតិចំនួន ៤,២លាននាក់ ដោយចំនួននេះបានកើនឡើង ១៧,៥% បើធ្វើការប្រៀបធៀបទៅនឹងឆ្នាំ២០១២។ ការអភិវឌ្ឍវិស័យទេសចរណ៍កំពុងនាំមកនូវកាលានុវត្តភាពជាច្រើនសម្រាប់ប្រទេសកម្ពុជា និងសហគមន៍នានា ។

ក្នុងពេលជាមួយគ្នានេះ យើងក៏បានសង្កេតឃើញនូវចំណុចអវិជ្ជមាននៃទំនាក់ទំនងរវាងវិស័យទេសចរណ៍ និងការកេងប្រវ័ញ្ចលើកុមារ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងបានឃើញកុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់កុមារទាំងនោះ ត្រូវបានទាក់ទាញឲ្យចូលទៅកាន់ទីកន្លែងគោលដៅទេសចរណ៍ ដើម្បីរកប្រាក់ចំណូល។ ទាំងកុមារា និងកុមារី អាចធ្វើការនៅក្នុងឧស្សាហកម្មទេសចរណ៍នៅក្នុងលក្ខខណ្ឌដែលមិនអំណោយផលដល់សុវត្ថិភាព និងសុខុមាលភាពរបស់ខ្លួន។ កុមារដែលរកប្រាក់ចំណូលបានពីភ្ញៀវទេសចរ តាមរយៈការលក់វត្ថុអនុស្សាវរីយ៍ ឬការខាត់ស្បែកជើង ទំនងជាមិនសូវបានទៅសាលារៀនឡើយ។ កុមារទាំងនេះ ត្រូវប្រឈមមុខនឹងភាពងាយរងគ្រោះក្នុងកម្រិតខ្ពស់ នៅក្នុងការរំលោភបំពានលើរាងកាយ អារម្មណ៍ និងផ្លូវភេទ ។

នៅក្នុងអនុតំបន់ទន្លេមេគង្គ ទាំងកុមារា និងកុមារីគឺជាជនរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងក្នុងការធ្វើដំណើរ និងវិស័យទេសចរណ៍។ អ្នករំលោភបំពានផ្លូវភេទកុមារ មានគោលដៅទៅលើកុមារដែលធ្វើការនៅតាមចិញ្ចើមថ្នល់ ឬក្នុងវិស័យក្រៅប្រព័ន្ធ។ ក្រៅពីនេះ អ្នករំលោភបំពានអាចនឹងតម្រង់ឆ្ពោះទិសទៅរកកុមារងាយរងគ្រោះ តាមរយៈការបម្រើការងារនៅក្នុងសាលារៀន ឬសេវាថែទាំតាមមណ្ឌលសម្រាប់កុមារ។  ដោយពុំមានការពារសុវត្ថិភាពគ្រប់គ្រាន់ ជួនកាលឧស្សាហកម្មទេសចរណ៍ជួយសម្រួលឲ្យអ្នករំលោភបំពានចូលដល់កុមារា និងកុមារីងាយរងគ្រោះ ហើយអាចនឹងមានលទ្ធភាពធ្វើការកេងប្រវ័ញ្ចទៀតផង។

ការរំលោភបំពានផ្លូវភេទកុមារនៅក្នុងការធ្វើដំណើរ និងក្នុងវិស័យទេសចរណ៍ គឺជាបាតុភូតសកលមួយដែលបានរីករាលដាលពីទ្វីបអាមេរិកទៅទ្វីបអាហ្វ្រិច អាស៊ីប៉ាស៊ីហ្វិក និងទ្វីបអឺរ៉ុប។  គ្មានប្រទេសណាមួយមានភាពស៊ាំឡើយ។ នៅពេលវិស័យទេសចរណ៍មានការរីកចម្រើនឆាប់រហ័សក្នុងតំបន់  យើងត្រូវតែធ្វើការឆ្លើយតប និងដាក់ចេញនូវវិធានការសុវត្ថិភាពឲ្យអនុវត្ត ដើម្បីការពារសិទ្ធិកុមារពីការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទ។

តាមរយៈគម្រោងកុមារភាព រដ្ឋាភិបាលអូស្ត្រាលី បានបង្កើតឲ្យមានការវិនិយោគមួយយ៉ាងសំខាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងទម្រង់នៃការកេងប្រវ័ញ្ចន៍ដ៏ជាក់លាក់នេះនៅក្នុងអនុតំបន់ទន្លេមេគង្គ។ គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលបានចំណាយប្រាក់៧,៥លានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងការធ្វើដំណើរ និងវិស័យទេសចរណ៍ក្នុងអនុតំបន់ទន្លេមេគង្គ (២០១១-២០១៤)។ គម្រោងកុមារភាពពឹងផ្អែកលើការជួយឧបត្ថម្ភក្នុងរយៈពេលវែង របស់ប្រទេសអូស្ត្រាលីសម្រាប់កម្មវិធីនានាដើម្បីការពារ និងទប់ស្កាត់ការរំលោភបំពានកុមារឲ្យបានកាន់តែប្រសើរឡើង ។

គម្រោងកុមារភាព បាននាំមកនូវកិច្ចសហប្រតិបត្តិការគ្នារវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម ដើម្បីឆ្លើយតបទៅនឹងបញ្ហាដ៏ធ្ងន់ធ្ងរនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍។ គម្រោងនេះដំណើរការនៅក្នុងប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសថៃ និងប្រទេសវៀតណាម។ គម្រោងនេះប្រើប្រាស់ទាំងវិធីការពារ និងវិធីទប់ស្កាត់ ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការទស្សនៈពិភពលោកកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយ សហគមន៍នានា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារកុមារា និងកុមារីឲ្យរួចផុតពីការក្លាយខ្លួនជាជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទទាំងនៅក្នុងការធ្វើដំណើរ និងក្នុងវិស័យទេសចរណ៍។

ទេសចរណ៍ដែលមានការទទួលខុសត្រូវ គឺជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្រវិស័យទេសចរណ៍របស់ប្រទេសកម្ពុជា។ ទេសចរណ៍ដែលមានការទទួលខុសត្រូវ រួមមានទាំងការទទួលស្គាល់ហានិភ័យរបស់កុមារនៅក្នុងវិស័យទេសចរណ៍ និងចាត់វិធានការនានាដើម្បីបន្ថយគ្រោះថ្នាក់ឲ្យនៅមានកម្រិតតិចតួចបំផុត។ វិស័យទេសចរណ៍មានឥទ្ធិពលដោយផ្ទាល់ទៅលើបរិយាកាសទេសចរណ៍ និងសក្តានុពលចំពោះអត្ថប្រយោជន៍ដ៏ធំធេងពីការអនុវត្តនានាដែលជួយថែរក្សាសុវត្ថិភាពកុមារ និងចូលរួមចំណែកឆ្ពោះទៅកាន់ទេសចរណ៍ដែលមានការទទួលខុសត្រូវ។

ហេតុនេះហើយ **រក្សាសុវត្ថិភាពកុមារពីការរំលោភបំពាន៖ កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលប្រតិបត្តិករទេសចរណ៍** មានតម្លៃគួរត្រូវបោះពុម្ពមែន។ សៀវភៅនេះផ្តល់នូវការណែនាំទូលំទូលាយ និងសម្ភារឧបទេសផ្សេងៗដែលអាចឲ្យអ្នកសម្របសម្រួលប្រើប្រាស់ ដើម្បីរៀបចំការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ ចាប់ពីបុគ្គលិកអនុវត្តផ្ទាល់រហូតដល់អ្នកគ្រប់គ្រង និងមន្ត្រីរដ្ឋាភិបាល។ ការបណ្តុះបណ្តាលមានសារៈសំខាន់ណាស់ សម្រាប់អ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ ដែលទាក់ទងនឹងគុណភាពវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនសម្រាប់ទេសចរណ៍ដែលមានការទទួលខុសត្រូវ។

តាមរយៈគម្រោងកុមារភាព និងក្នុងភាពជាដៃគូជាមួយអង្គការទស្សនៈពិភពលោក ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា បានយកគំនិតនានានៅក្នុងសៀវភៅណែនាំនេះមកប្រើប្រាស់រួចហើយ ដើម្បីអប់រំ និងផ្តល់អំណាចដល់អ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំសង្ឃឹមថា ដោយមានការបោះពុម្ពផ្សព្វផ្សាយជាផ្លូវការនេះសៀវភៅនេះ នឹងផ្តល់អំណាចដល់អ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ទាំងឡាយនូវចំណេះដឹង និងជំនាញនានា ដើម្បីថែរក្សាការពារឧស្សាហកម្មទេសចរណ៍ និងជាពិសេសការពារកុមាររបស់យើងឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទជាមិនខាន។

ខ្ញុំសូមលើកទឹកចិត្តឲ្យមានការប្រើប្រាស់ដ៏ទូលំទូលាយនូវអត្ថបទបោះពុម្ពនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលអូស្ត្រាលី និងអង្គការទស្សនៈពិភពលោកសម្រាប់ការវិនិយោគ និងការបំពេញការងារដ៏ល្អប្រពៃរបស់ខ្លួន ។

**ប្រធានគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**

**ហោ សារុន**

អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍

# សារតា

គម្រោងកុមារភាព គឺជាការផ្តួចផ្តើមគំនិតមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីប្រយុទ្ធប្រឆាំងការរំលោភបំពានផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ នៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (ឆ្នាំ២០១១-២០១៤)។ គម្រោងកុមារភាព កសាងបន្ថែមលើការគាំទ្ររយៈពេលវែងរបស់ប្រទេសអូស្ត្រាលី ចំពោះកម្មវិធីនានា ដើម្បីការពារកុមារ និងទប់ស្កាត់ការរំលោភបំពានលើកុមារ ឲ្យកាន់តែបានប្រសើរថែមទៀត។ គម្រោងកុមារភាព ជាការរួបរួមគ្នារបស់អង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកគ្រឿងញៀន និងឧក្រិដ្ឋកម្ម។ កម្មវិធីនេះប្រើប្រាស់វិធីសាស្ត្រពីរ គឺវិធីសាស្ត្របង្ការ និងការពារ។

អង្គការទស្សនៈពិភពលោក កំពុងធ្វើជាដៃគូជាមួយរដ្ឋាភិបាល និងសហគមន៍ ដើម្បីបង្ការកុំឱ្យកុមារក្លាយជាជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ តាមរយៈការប្រើប្រាស់ព័ត៌មានការប្រាស្រ័យទាក់ទង និងការអប់រំ អង្គការទស្សនៈពិភពលោក មានបំណងបំពាក់ចំណេះដឹង និងជំនាញ ដល់សមាជិកសហគមន៍ អាជីវកម្ម និងមន្ត្រីរដ្ឋាភិបាល ដើម្បីធ្វើឱ្យបរិស្ថានទេសចរណ៍ទាំងមូលកាន់តែមានសុវត្ថិភាពសម្រាប់កុមារ។

ដោយកសាងបន្ថែមលើការឆ្លើយតបជាងពីរទស្សវត្សរ៍កន្លងមកលើបញ្ហានេះ កម្មវិធីសិក្សាស្តីពី រក្សាសុវត្ថិភាពកុមារពីការរំលោភបំពាននៅក្នុងវិស័យទេសចរណ៍ ផ្តល់នូវវិធីសាស្ត្រសិក្សាដែលមានបច្ចុប្បន្នភាព និងវិធីសាស្ត្រពេញលេញមួយ ដើម្បីឆ្លើយតបនឹងគ្រោះថ្នាក់ចំពោះកុមារនៅក្នុងបរិស្ថានទេសចរណ៍។ មានអ្នកចូលរួមប្រមាណជិតពីរពាន់នាក់ ដែលបានចូលរួមវគ្គសិក្សានៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម បានទទួលអត្ថប្រយោជន៍ពីកម្មវិធីសិក្សារបស់វគ្គបណ្តុះបណ្តាលនេះ។ ដោយហេតុថា វិស័យទេសចរណ៍នៅក្នុងតំបន់នេះបន្តរីកចម្រើនយ៉ាងឆាប់រហ័ស ហើយមានឱកាសជាច្រើនសម្រាប់ចំណូល និងការអភិវឌ្ឍន៍ ហេតុនេះ ភាគីពាក់ព័ន្ធចាំបាច់ត្រូវមានលទ្ធភាពទទួលបានដំបូន្មានជាក់ស្តែងថា តើពួកគេអាចធ្វើយ៉ាងណាដើម្បីធ្វើសកម្មភាពការពារកុមារនៅក្នុងដែននៃឥទ្ធិពលរបស់ខ្លួន។ វិស័យទេសចរណ៍ ជះឥទ្ធិពលដោយផ្ទាល់ខ្លាំងបំផុតលើបរិស្ថានទេសចរណ៍ និងមានសក្តានុពលក្នុងការទទួលបានអត្ថប្រយោជន៍យ៉ាងធំធេងពីការអនុវត្តការងារក្នុងលក្ខណៈដែលជួយរក្សាសុវត្ថិភាពកុមារ និងចូលរួមវិភាគទានឆ្ពោះទៅបង្កើតឱ្យមានទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ។

# គោលបំណងនៃកញ្ចប់ឧបករណ៍

កញ្ចប់ឧបករណ៍នេះ ផ្តល់ឱ្យអ្នកសម្របសម្រួលនូវការណែនាំ និងឧបករណ៍ងាយស្រួលអនុវត្តជាច្រើន ដើម្បីរៀបចំអនុវត្តការបណ្តុះបណ្តាលស្តីពី រក្សាសុវត្ថិភាពកុមារពីការរំលោភបំពាននៅក្នុងវិស័យទេសចរណ៍ សម្រាប់ភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍។ សម្ភារទាំងនេះ ត្រូវបានកែសម្រួលឱ្យងាយស្រួលសម្រាប់អ្នកចូលរួមដែលមកពីវិស័យនានា ទាំងអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ  និងក្រៅប្រព័ន្ធ ព្រមទាំងអ្នកធ្វើការនៅកម្រិតផ្សេងៗគ្នា ដោយរួមមានចាប់តាំងពីបុគ្គលិកជួរមុខក្នុងវិស័យទេសចរណ៍ រហូតដល់អ្នកគ្រប់គ្រងថ្នាក់កណ្តាលនិងជាន់ខ្ពស់ ម្ចាស់អាជីវកម្ម និងប្រតិបត្តិករ ក៏ដូចជាមន្ត្រីមកពីក្រសួង និងទីភ្នាក់ងារពាក់ព័ន្ធរបស់រដ្ឋាភិបាល។ វគ្គបណ្តុះបណ្តាលនេះអាចរៀបចំធ្វើឡើងដែលមានកម្មវិធីរយៈពេលមួយថ្ងៃពេញ ឬបំបែកជាវគ្គតូចៗ សម្រាប់អំឡុងពេលជាក់លាក់ណាមួយក៏បាន។ បើគិតទៅលើតថភាពជាក់ស្តែងក្នុងប្រតិបត្តិការអាជីវកម្ម គេក៏អាចបង្ហាញសារសំខាន់ៗ ក្នុងវគ្គសិក្សាខ្លី ដែលមានរយៈពេលមួយម៉ោង ឬពីរម៉ោងផងដែរ។

ឧបករណ៍នេះ ត្រូវបានសរសេរឡើងដោយប្រើប្រាស់ភាសាសាមញ្ញ ដើម្បីឱ្យអ្នកអានទូទៅងាយស្រួលយល់។ ដើម្បីអាចទទួលប្រយោជន៍ទាំងស្រុងពីខ្លឹមសារឯកសារនេះ អ្នកសម្របសម្រួលគួរអានកញ្ចប់ឧបករណ៍នេះឲ្យយល់ច្បាស់មុនដល់ពេលកម្មវិធីបណ្តុះបណ្តាល ហើយត្រូវប្រើកញ្ចប់ឧបករណ៍នេះជាជំនួយក្នុងការរៀបចំការបណ្តុះបណ្តាល។ អ្នកអាចកែសម្រួល និងបន្ថែមបន្ថយថែមទៀត ដើម្បីឲ្យសមស្របទៅតាមអ្នកចូលរួមក្រុមនីមួយៗ។ ឯកសារអេឡិចត្រូនិច អាចបើកមើលបាននៅ  http://www.childsafetourism.org និង http://wvi.org/asiapacific/childsafetourism.

# របៀបប្រើប្រាស់កញ្ចប់ឧបករណ៍

កញ្ចប់ឧបករណ៍នេះ ចែកចេញជាបីផ្នែក៖

## ផ្នែកទី១ ៖ ការចាប់ផ្តើម

ផ្នែកនេះផ្តល់នូវព័ត៌មានដែលអ្នកសម្របសម្រួលត្រូវដឹង ដើម្បីត្រៀមខ្លួនមុនពេលបណ្តុះបណ្តាល។ ផ្នែកនេះផ្តល់ដំបូន្មានដែលមានសារៈប្រយោជន៍ ស្តីពីការជ្រើសរើសអ្នកចូលរួម ទីកន្លែង និងការរៀបចំត្រៀមឧបករណ៍ វិធីសាស្រ្តបង្រៀន ការណែនាំសំខាន់ៗនានាដើម្បីឆ្លើយតបនឹងប្រធានបទដែលងាយរសើបនៃការការពារកុមារ ព្រមទាំងមានគន្លឹះល្អៗដើម្បីជួយដល់ការអនុវត្តន៍ការបណ្តុះបណ្តាលប្រកបដោយជោគជ័យ។

## ផ្នែកទី២៖ ការណែនាំតាមរយៈស្លាយ

ផ្នែកនេះ ផ្តល់នូវការណែនាំមួយជំហានម្តងៗ ដើម្បីជួយសម្រួលដល់អ្នកសម្របសម្រួលក្នុងការបង្រៀន លើគ្រប់ទិដ្ឋភាពទាំងអស់ដែលមាននៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពានក្នុងវិស័យទេសចរណ៍។ អ្នកអាចទាញយក បទបង្ហាញផៅវើភ័ញសម្រាប់វិស័យទេសចរណ៍ ពីគេហទំព័រ http://www.childsafetourism.org និង http://wvi.org/asiapacific/childsafetourism ហើយគួរតែអាន និងកែសម្រួលខ្លឹមសារឯកសារទាំងនេះមុនពេលបណ្តុះបណ្តាល ដើម្បីដាក់បញ្ចូលនូវខ្លឹមសារដែលពាក់ព័ន្ធនានានៅកម្រិតជាតិ និង/ឬមូលដ្ឋាន។ ប្រសិនបើមិនអាចមានលទ្ធភាពរកម៉ាស៊ីនបញ្ចាំងស្លាយ ឬឧបករណ៍ដែលពាក់ព័ន្ធដូចជាម៉ាស៊ីនសម្រាប់បោះពុម្ពសន្លឹកធំទេនោះ អ្នកសម្របសម្រួលអាចប្រើផ្នែកនេះជាកំណត់សម្គាល់សម្រាប់និយាយក៏បាន។ គោលការណ៍ណែនាំនេះ ក៏ស្នើឡើងនូវសកម្មភាពបែបការចូលរួម និងគន្លឹះមួយចំនួនទៀត ដើម្បីឱ្យអ្នកសម្របសម្រួលអាចឆ្លើះអ្នកចូលរួមឱ្យពិភាក្សា និង/ឬឆ្លុះបញ្ចាំងដោយផុសផុលថែមទៀត។

## ផ្នែកទី៣៖ ឧបសម្ព័ន្ធ

ក្នុងឧបសម្ព័ន្ធមានឧបករណ៍បន្ថែមទៀត ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល ក៏ដូចជាដើម្បីវាយតម្លៃកម្មវិធីសម្រាប់ការរៀនសូត្រនាពេលអនាគត។ ឧបករណ៍ទាំងនេះមាន៖

- គំរូរបៀបវារៈវគ្គបណ្តុះបណ្តាល
- កាតយកតាមខ្លួនសម្រាប់អ្នកចូលរួម
- ទម្រង់បញ្ជីវត្តមានអ្នកចូលរួម
- សំណួរមុនចូលមេរៀន និងសំណួរក្រោយមេរៀន
- សេណារីយ៉ូករណីសិក្សាសម្រាប់បុគ្គលិកទេសចរណ៍
- សេណារីយ៉ូករណីសិក្សាសម្រាប់អ្នកគ្រប់គ្រងផ្នែកទេសចរណ៍
- ទម្រង់អំពីទស្សនៈរបស់ខ្ញុំ
- គំរូវិញ្ញាបនប័ត្រ
- ទម្រង់របាយការណ៍ក្រោយវគ្គបណ្តុះបណ្តាល

# កំណត់ត្រា

# ផ្នែកទី១៖

# ការចាប់ផ្តើម



# សេចក្ដីផ្ដើម

## តើនរណាអាចសម្របសម្រួលវគ្គបណ្ដុះបណ្ដាលនេះបាន ?

ដោយហេតុថា វគ្គបណ្ដុះបណ្ដាលនេះ លើកឡើងនូវបញ្ហាងាយរសើបស្ដីពីភាពងាយរងគ្រោះរបស់កុមារ ជាពិសេស គឺភាពងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទនោះ វាជាការសំខាន់ណាស់ដែលត្រូវ ជ្រើសរើសអ្នកសម្របសម្រួលដោយប្រុងប្រយ័ត្ន រកនរណាដែលមានសមត្ថភាព និងជំនាញសមស្របដើម្បីដំណើរការវគ្គបណ្ដុះបណ្ដាល។

តាមការរំពឹងទុក អ្នកសម្របសម្រួលសម្រាប់វគ្គបណ្ដុះបណ្ដាលនេះ ត្រូវមានទាំងចំណេះដឹង និងជំនាញ ដូចរៀបរាប់ខាងក្រោម៖

- ចំណេះដឹងជាអ្នកជំនាញអំពីបញ្ហាការពារកុមារ ដោយមានការយល់ដឹងជាក់លាក់អំពីការរំលោភបំពានលើកុមារក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។
- បទពិសោធន៍ច្រើន ក្នុងការបង្រៀន និងការបណ្ដុះបណ្ដាល
- សមត្ថភាពក្នុងការប្រាស្រ័យទាក់ទងច្បាស់លាស់ ប្រកបដោយប្រសិទ្ធិភាព និងសម្រេចបាននូវលទ្ធផលនៃការសិក្សាតាមរយៈការប្រើប្រាស់វិធីបណ្ដុះបណ្ដាលដែលមានការចូលរួម។

អ្នកសម្របសម្រួល មិនត្រឹមតែអាចពិភាក្សាអំពីប្រធានបទនៃការកេងប្រវ័ញ្ចលើកុមារ ជាពិសេសការរំលោភបំពានផ្លូវភេទបានដោយងាយស្រួលតែប៉ុណ្ណោះទេ ក៏ប៉ុន្ដែត្រូវតែមានសមត្ថភាពគ្រប់គ្រងស្ថានភាពលំបាកនានាដែលកើតមាន នៅក្នុងវគ្គបណ្ដុះបណ្ដាលប្រភេទនេះ។ ស្ថានភាពលំបាកទាំងនេះ រួមមានសំណួរផ្នែកខាងបច្ចេកទេស និងបញ្ហាដែលមិនអាចដោះស្រាយបាននៅឡើយ របស់អ្នកចូលរួមដែលធ្លាប់រងនូវការរំលោភបំពាន។ អាស្រ័យដោយកម្មវត្ថុសិក្សារបស់វគ្គបណ្ដុះបណ្ដាលនេះ ទាក់ទងនឹងបញ្ហាការរំលោភបំពានផ្លូវភេទ ហេតុនេះវាចាំបាច់ត្រូវទាក់ទងនឹង ទំនាក់ទំនងផ្លូវភេទរវាងមនុស្សនិងមនុស្ស ទោះជាទំនាក់ទំនងដោយមានការ ព្រមព្រៀង ឬគ្មានការព្រមព្រៀងក្ដី។ អ្នកសម្របសម្រួល ចាំបាច់ត្រូវយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីធានា ឱ្យបានថាខ្លួនមិនបញ្ចេញឥរិយាបទ ឬទស្សនៈបែបរើសអើង ទោះបីជាដោយផ្ទាល់ ឬដោយប្រយោលក្ដី ដូចជាពាក់ព័ន្ធនឹងបញ្ហាទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រជាដើម។ ការប្រព្រឹត្តនូវទស្សនៈរើសអើងផ្នែកយេនឌ័រ ទំនោរផ្លូវភេទ ពូជសាសន៍ជាដើម គឺមិនអនុលោមទៅតាមគោលការណ៍សិទ្ធិកុមារអន្តរជាតិឡើយ ហើយក៏ជាការចូលរួមចំណែកធ្វើឱ្យមានភាពងាយរងគ្រោះ ដែលជម្រុញកុមារឱ្យធ្លាក់ក្នុងគ្រោះថ្នាក់ ឬការរំលោភបំពានផងដែរ។ គោលការណ៍ណែនាំពិសេសស្ដីពីរបៀបផ្ដល់ការបណ្ដុះបណ្ដាលការការពារកុមារ គឺមាននៅក្នុងកញ្ចប់ឧបករណ៍នេះ។

> *អ្នកសម្របសម្រួលប្រកបដោយសមត្ថភាព គឺជាកត្តាដ៏សំខាន់មួយដែលកំណត់នូវជោគជ័យរបស់កម្មវិធី។ ប្រសិនបើអ្នកសម្របសម្រួលខ្វះចំណេះដឹង ឬជំនាញបណ្ដុះបណ្ដាល នឹងបង្កើតឱ្យមានលទ្ធផលទាប។ ហេតុនេះ វាជាការសំខាន់ខ្លាំងណាស់ដែលអង្គការដែលរៀបចំវគ្គបណ្ដុះបណ្ដាលនេះ ត្រូវតែជ្រើសរើសអ្នកសម្របសម្រួលដែលមានសមត្ថភាពខ្ពស់ ធ្លាប់ផ្ដល់ការបណ្ដុះបណ្ដាលប្រកបដោយប្រសិទ្ធិភាពកន្លងមក។*

# តើនរណាគួរចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ?

កម្មវិធីសិក្សាស្តីពី *រក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពាននៅក្នុងវិស័យទេសចរណ៍* ត្រូវបានតាក់តែងឡើងសម្រាប់ភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍។ ភាគីពាក់ព័ន្ធទាំងនេះ មានដូចខាងក្រោម៖

| | | |
|---|---|---|
| **ឧស្សាហកម្ម** | បុគ្គលិកជួរមុខក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ | • អ្នកបើករថយន្តតាក់ស៊ី/បុគ្គលិកក្រុមហ៊ុនដឹកជញ្ជូន<br>• មគ្គុទ្ទេសក៍ទេសចរណ៍<br>• បុគ្គលិកសន្តិសុខសណ្ឋាគារ និងកន្លែងនានា<br>• បុគ្គលិកផ្នែកសេវាកម្មរបស់សណ្ឋាគារ និងផ្ទះសំណាក់ (បុគ្គលិកបញ្ជរមុខ អ្នកជួយយួរវ៉ាន់ អ្នករៀបចំបន្ទប់ អ្នកបោសសំអាត។ល។)<br>• ម្ចាស់ភោជនីយដ្ឋាន និងក្លឹបរាត្រី និងបុគ្គលិករបស់ពួកគេ។ |
| | អ្នកគ្រប់គ្រងផ្នែកទេសចរណ៍ និងការធ្វើដំណើរ និងម្ចាស់អាជីវកម្ម | • ប្រធានផ្នែកធនធានមនុស្ស<br>• ប្រធានផ្នែកការទទួលខុសត្រូវសង្គម<br>• អ្នកចាត់ការទូទៅ<br>• ម្ចាស់អាជីវកម្ម |
| | ស្ថាប័នថ្នាក់ខ្ពស់ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ | • សមាគមន៍ថ្នាក់មូលដ្ឋានដែលពាក់ព័ន្ធ<br>• សមាគមន៍ថ្នាក់ជាតិដែលពាក់ព័ន្ធ<br>• សមាគមន៍ថ្នាក់តំបន់ដែលពាក់ព័ន្ធ |
| | ដៃគូឯកជនដែលមិនស្ថិតក្នុងវិស័យទេសចរណ៍ | • អ្នកផ្តល់សេវាដល់ជនបរទេស<br>• ក្រុមហ៊ុនដឹកជញ្ជូន (អ្នកធ្វើដំណើរ បញ្ជូនទំនិញ នាវាកំសាន្ត)<br>• ក្រុមហ៊ុនសេវាសាជីវកម្ម<br>• ក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន<br>• ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយ |
| **រដ្ឋាភិបាល** | ក្រសួងទេសចរណ៍ | • បុគ្គលិកផ្នែកអភិវឌ្ឍគោលនយោបាយ<br>• បុគ្គលិកផ្នែកបណ្តុះបណ្តាលទេសចរណ៍<br>• បុគ្គលិកផ្នែកបទដ្ឋាន និងការទទួលស្គាល់គុណភាព |

ការកំណត់ពេលវេលាសម្រាប់សិក្ខាសាលាបណ្តុះបណ្តាល អ្នកសម្របសម្រួលគួរធ្វើការជាមួយអ្នករៀបចំកម្មវិធី ដើម្បីកំណត់រកអ្នកចូលរួមដែលសមស្របបំផុត។ ដោយហេតុថា អ្នកចូលរួមក្រុមផ្សេងគ្នា មានតម្រូវការទទួលព័ត៌មានផ្សេងគ្នា។ ហេតុនេះវាជាការសំខាន់ណាស់ដែលត្រូវសម្រួលខ្លឹមសារការបណ្តុះបណ្តាល ឱ្យត្រូវតាមអ្នកចូលរួម។ ឧទាហរណ៍ ព័ត៌មានដែលបុគ្គលិកជួរមុខផ្នែកទេសចរណ៍ត្រូវការ ជារឿយៗតែងតែខុសពីព័ត៌មានដែលអ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្មត្រូវការ។ អ្នកចូលរួមម្នាក់ៗ ក៏មានឱកាសផ្សេងៗគ្នា ក្នុងការធ្វើឱ្យមានឥទ្ធិពលលើបរិស្ថានទេសចរណ៍ផងដែរ ហើយអ្នកសម្របសម្រួលត្រូវទទួលស្គាល់ចំណុចនេះ។ ថ្វីបើមានវិសាលភាពសម្រាប់ការពិភាក្សាសមស្រប និងពង្រឹងការយល់ដឹងពីវិធីដ៏សម្បូរបែបជាច្រើន ដើម្បីការពារកុមារ ពេលយើងយកមនុស្សដែលមានប្រវត្តិការងារផ្សេងៗគ្នាមករួមគ្នាក្តី អ្នកសម្របសម្រួលចាំបាច់ត្រូវមានជំនាញ និងបទពិសោធន៍ខ្ពស់ជាពិសេស ដើម្បីអាចគ្រប់គ្រងអ្នកចូលរួមដែលមានបទពិសោធន៍ប្លែកៗគ្នាជាច្រើនបែបនេះបាន។




## តើអ្វីខ្លះជាលទ្ធផលរំពឹងទុក ថានឹងទទួលបានពីការរៀនសូត្រនេះ ?

*រក្សាសុវត្ថិភាពកុមារពីការរំលោភបំពាននៅក្នុងវិស័យទេសចរណ៍* ផ្ដល់ចំណេះដឹងចាំបាច់ដល់អ្នកទាំងឡាយណាដែលចាប់អារម្មណ៍ ចង់កែលំអគុណភាពទេសចរណ៍ក្នុងតំបន់អាស៊ីអាគ្នេយ៍ ឱ្យកាន់តែប្រសើរឡើង ដើម្បីឱ្យវិស័យនេះផ្ដល់អត្ថប្រយោជន៍ពិតប្រាកដដល់សេដ្ឋកិច្ច សហគមន៍ និងផ្ដល់ប្រយោជន៍ទៅវិញទៅមកដល់មនុស្សទាំងអស់គ្នា។ វគ្គសិក្សានេះ ជួយជម្រុញអ្នកចូលរួមឱ្យចេះឆ្លើយតប ជាមួយតម្រូវការកាន់តែកើនឡើងរបស់អតិថិជន ដែលចង់បានទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ និងមានសីលធម៌ខ្ពស់។ អ្វីដែលសំខាន់បំផុតនោះ វគ្គសិក្សានេះមានគោលដៅដើម្បីពង្រឹងបរិស្ថានប្រកបដោយការការពារសម្រាប់កុមារ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ និងដើម្បីបង្ការកុំឱ្យកុមារា និងកុមារីត្រូវរងការកេងប្រវ័ញ្ចផ្លូវភេទ។

នៅពេលបញ្ចប់វគ្គនេះ អ្នកចូលរួមនឹងអាច៖

- ទទួលស្គាល់នូវទំនាក់ទំនងជាទូទៅ រវាងវិស័យទេសចរណ៍ និងកុមាររងាយរងគ្រោះ។
- ស្វែងយល់ពីវិធីដែលវិស័យទេសចរណ៍ និងការធ្វើដំណើរ អាចធ្វើឱ្យមានភាពងាយរងគ្រោះដល់កុមារ ជាពិសេសការរំលោភបំពានផ្លូវភេទ។
- ស្គាល់នូវសញ្ញាចង្អុលបង្ហាញថាកុមារកំពុងស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភបំពាន និងមធ្យោបាយនៃទម្រង់ខុសៗ គ្នានៃការរំលោភបំពានជាប់ទាក់ទងគ្នាទៅវិញទៅមក។
- កំណត់នូវវិធីដែលពួកគេអាចធ្វើសកម្មភាព នៅក្នុងដែនមានសមត្ថកិច្ចរបស់ពួកគេ ដើម្បីបង្កើតឱ្យមានបរិយាកាស  និងធ្វើឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ។
- ចាប់ផ្ដើមមានអារម្មណ៍ទទួលខុសត្រូវ បានដឹង និងមានការពង្រឹងភាពម្ចាស់ការ អំពីអ្វីដែលពួកគេអាចធ្វើបានដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពាននៅក្នុងវិស័យទេសចរណ៍។

## តើវគ្គបណ្ដុះបណ្ដាលនេះ គួរមានអ្នកចូលរួមប៉ុន្មាននាក់ ?

ចំនួនអ្នកចូលរួមដែលល្អបំផុតសម្រាប់សិក្ខាសាលាបណ្ដុះបណ្ដាល គឺចន្លោះពី៣០-៤០នាក់។ ប្រសិនបើចំនួនអ្នកចូលរួមក្នុងការបណ្ដុះបណ្ដាលឡើងលើសពី៤០នាក់នោះ ការពិភាក្សាក្រុម និងការផ្ដល់យោបល់ត្រលប់នឹងមានរយៈពេលវែង ហើយត្រូវការពេលបន្ថែមទៀតសម្រាប់ការបណ្ដុះបណ្ដាល។ លទ្ធភាពនៃការចូលរួមរបស់វគ្គបណ្ដុះបណ្ដាល ក៏នឹងត្រូវថយចុះផងដែរ។

មានវិធីផ្សេងៗគ្នាជាច្រើន ដើម្បីអញ្ជើញអ្នកចូលរួម អាស្រ័យទៅតាមលក្ខណៈសម្បត្តិ និងអ្នករៀបចំវគ្គបណ្តុះបណ្តាល។ ឧទាហរណ៍ ក្នុងករណីមួយចំនួន ពេលកម្មវិធីត្រូវបានរៀបចំដោយអង្គការទេសចរណ៍ជាតិ (NTO)[1] ត្រូវមានលិខិតអញ្ជើញផ្លូវការបញ្ជូនទៅកាន់អង្គការសមាគម និងបុគ្គលជាក់លាក់។ ដើម្បីបានអ្នកចូលរួមចំនួន៣០-៤០នាក់ ប្រហែលជាចាំបាច់ត្រូវអញ្ជើញអ្នកចូលរួម៦០-៨០នាក់ ហើយទទួលយក ការចុះឈ្មោះតាមលំដាប់អ្នកដែលបានឆ្លើយតបមុន។ ក្នុងករណីមួយចំនួនទៀត អាចមានជាការផ្សព្វផ្សាយពាណិជ្ជកម្មអំពីកម្មវិធីនោះជាសាធារណៈ រួចទទួលការចុះឈ្មោះរហូតដល់គ្រប់ចំនួនដែលចង់បាន។ យើងអាចចាប់ផ្តើមបង្កើតបញ្ជីឈ្មោះរង់ចាំមួយ ដើម្បីអាចអនុញ្ញាតឱ្យអ្នកដែលមានឈ្មោះនៅក្នុងបញ្ជីរង់ចាំចូលសិក្សាក្នុងវគ្គបណ្តុះបណ្តាលនេះ បើសិនជាមានអ្នកអវត្តមានឬបដិសេធមិនចូលរួមវិញ។ អ្នកចូលរួមត្រូវការការជូនដំណឹងពីវគ្គបណ្តុះបណ្តាលឱ្យបានមុន ដើម្បីជានាចាពួកគាត់អាចមានពេលចូលរួម។ អ្នកចូលរួមត្រូវការការជូនដំណឹងយ៉ាងតិចមួយខែមុន។ ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ប្រព័ន្ធផ្សព្វផ្សាយសង្គម និងអ៊ីម៉ែលតាមបណ្តាញ និងសមាគមទេសចរណ៍ និងការធ្វើដំណើរដែលមានស្រាប់ ត្រូវបានគេឃើញថា ជាមធ្យោបាយដ៏ល្អដើម្បីផ្សព្វផ្សាយដំណឹងស្តីពីការបណ្តុះបណ្តាលនេះ។ ប៉ុន្តែ គេអាចរៀបចំជាការបណ្តុះបណ្តាលសម្រាប់បុគ្គលិកក្នុងស្ថាប័នសម្រាប់និយោជិត/អ្នកជាប់កិច្ចសន្យា ដោយក្នុងករណីបែបនេះ ស្ថាប័ននោះផ្ទាល់ត្រូវមានវិធីផ្ទៃក្នុងរបស់ខ្លួនក្នុងការជូនដំណឹង និងបញ្ជាក់ការចូលរួម ទៅដល់អ្នកចូលរួម។ ដើម្បីទាក់ទាញឱ្យបានចំនួនការចូលរួមខ្ពស់ គួរពិចារណាដាក់ពេលវេលាការបណ្តុះបណ្តាលក្នុងអំឡុង "រដូវទេសចរណ៍ចុះទាប"។



## តើវគ្គបណ្តុះបណ្តាលគួរមានរយៈពេលប៉ុន្មាន?

ការបណ្តុះបណ្តាលអាចធ្វើឡើងដែលមានកម្មវិធីរយៈពេលមួយថ្ងៃ ឬជាវគ្គជាច់ៗពីគ្នា ក្នុងអំឡុងរយៈពេលជាក់លាក់ណាមួយ។ ការបញ្ជាក់រយៈពេលសម្រាប់វគ្គនីមួយៗ មានបញ្ជាក់ជូនក្នុងផ្នែកទី២៖ គោលការណ៍ណែនាំតាមរយៈស្លាយ និងក្នុងរបៀបវារៈគំរូនៅក្នុងឧបសម្ព័ន្ធទី១។ វគ្គសិក្សានេះ អាចមានរយៈពេលវែង ឬខ្លី អាស្រ័យទៅតាមលំហាត់ និងវិធីសាស្ត្របែបចូលរួមដែលត្រូវបានជ្រើសរើសយកមកប្រើ។ ប្រសិនបើមានពេលខ្លី (ឧទាហរណ៍មួយម៉ោង ឬពីរម៉ោង) អ្នកសម្របសម្រួលត្រូវបានលើកទឹកចិត្តឱ្យផ្តល់អាទិភាពចំពោះស្លាយទាំងឡាយណាដែលមានដាក់សញ្ញ •

[1] NTO គឺជាស្ថាប័នសាធារណផ្នែកទេសចរណ៍របស់ជាតិ ទទួលខុសត្រូវលើការអភិវឌ្ឍទេសចរណ៍នៅក្នុងប្រទេស ឧ. ក្រសួងទេសចរណ៍

## ចុះចំណែកវាគ្មិនវិញ?

វាគ្មិនអាចដើរតួនាទីដ៏មានតម្លៃនៅក្នុងកម្មវិធីបណ្តុះបណ្តាល ប្រសិនបើប្រធានបទរបស់ពួកគាត់មានការពាក់ព័ន្ធល្អ និងបន្ថែមតម្លៃដល់ខ្លឹមសារនៃវគ្គបណ្តុះបណ្តាល។

គួរអញ្ជើញវាគ្មិន ប្រសិនបើវាគ្មិននឹងបន្ថែមគំនិតជំនាញដែលមានសារៈប្រយោជន៍ ដែលនឹងជួយពង្រីកការយល់ដឹងរបស់អ្នកចូលរួមលើបញ្ហានោះ។ ជំនួសមកវិញ វាគ្មិនអាចជួយផ្តល់បរិបទបរិស្ថានទេសចរណ៍ក្នុងមូលដ្ឋានបន្ថែម ដែលបញ្ជាក់បង្ហាញពីលក្ខណៈ បញ្ហា ឬគ្រោះថ្នាក់។ យោបល់មួយចំនួនលើការពិចារណាក្នុងការប្រើប្រាស់វាគ្មិនកិត្តិយសមានដូចជា៖

- សមាជិកប៉ូលីស ឬអង្គការក្រៅរដ្ឋាភិបាលក្នុងមូលដ្ឋាន អាចនិយាយអំពីស្ថានភាពក្នុងមូលដ្ឋានទាក់ទងនឹងភាពងាយរងគ្រោះរបស់កុមារនិងការកេងប្រវ័ញ្ចលើកុមារ និងករណីនានាដែលពួកគាត់ធ្លាប់ជួប។
- ជំនាញការផ្នែកច្បាប់ ឬអង្គការក្រៅរដ្ឋាភិបាលអាចនិយាយអំពីច្បាប់ទាក់ទងនឹងការរំលោភបំពានកុមារ
- អ្នកតំណាងសេវាសង្គមកិច្ចក្នុងមូលដ្ឋាន អាចនិយាយអំពីផលប៉ះពាល់នៃភាពងាយរងគ្រោះរបស់កុមារ និងការកេងប្រវ័ញ្ចលើកុមារលើជនរងគ្រោះជាកុមារ។ (វាគ្មិននេះ អាចមកពីនាយកដ្ឋានរបស់រដ្ឋាភិបាលក្នុងមូលដ្ឋាន ឬអង្គការក្រៅរដ្ឋាភិបាល)។
- តំណាងម្នាក់មកពីសហគមន៍អាជីវកម្ម អាចនិយាយអំពីវិធីនានាដែលពួកគេអាចការពារកុមារយ៉ាងសកម្មឱ្យរួចផុតពីការកេងប្រវ័ញ្ច។
- តំណាងម្នាក់មកពីក្លឹបកុមារ ឬក្លឹបយុវជន អាចនិយាយអំពីផលប៉ះពាល់របស់វិស័យទេសចរណ៍ លើជីវិតរបស់ពួកគេ និងអំពីគំនិតរបស់ពួកគេ ថាតើមនុស្សពេញវ័យអាចជួយឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ និងមនុស្សវ័យក្មេងបានដោយរបៀបណា។

### គន្លឹះដើម្បីជួយសម្រួលដល់វាគ្មិនរបស់អ្នក

នៅពេលអ្នកជ្រើសរើស និងអញ្ជើញវាគ្មិនឱ្យចូលរួម សូមចងចាំនូវគន្លឹះមួយចំនួន ដូចខាងក្រោម៖

- ផ្តល់ការជូនដំណឹងជាមុនឱ្យបានគ្រប់គ្រាន់ដល់វាគ្មិនរបស់អ្នក។ យ៉ាងហោចណាស់ ក៏ត្រូវព្យាយាមអញ្ជើញពួកគាត់ឱ្យបានយ៉ាងហោចណាស់ក៏មួយសប្តាហ៍មុនការបណ្តុះបណ្តាលដែរ។
- សូមគូសបញ្ជាក់ឱ្យច្បាស់អំពីចំណុចសំខាន់ៗ ដែលអ្នកចង់ឱ្យវាគ្មិនលើកឡើង។ ជាការល្អ ប្រសិនបើអ្នកអាចផ្តល់របៀបវារៈនៃវគ្គបណ្តុះបណ្តាលមួយច្បាប់ដល់វាគ្មិន ដើម្បីឱ្យគាត់អាចជៀសវាងមិននិយាយច្រំដែលលើប្រធានបទដែលអ្នកសម្របសម្រួលបាននិយាយរួចហើយ។
- សូមសួរពួកគាត់បញ្ជាក់ថា តើពួកគាត់មានចំណេះដឹង/ភាពប៉ិនប្រសប់/ជំនាញគ្រប់គ្រាន់ ដើម្បីលើកឡើងនូវប្រធានបទដែលបានស្នើឡើងនោះឬទេ។ ប្រសិនបើមិនបានទេ សូមស្នើឱ្យគាត់ផ្តល់យោបល់ឱ្យអ្នកវិញ ដើម្បីអ្នកអាចទៅរកអ្នកជំនាញដែលសមស្របណាម្នាក់ផ្សេងទៀត។
- ផ្តល់ការពិពណ៌នាអំពីអ្នកចូលរួមឱ្យបានច្បាស់លាស់ (តើពួកគាត់ជានរណា? តើមានមនុស្សប៉ុន្មាននាក់ចូលរួម? តម្រូវការព័ត៌មាន) ដើម្បីឱ្យវាគ្មិនអាចសម្រួលបទបង្ហាញរបស់ពួកគេស្របទៅតាមនោះ និងនាំយកឯកសារគ្រប់គ្រាន់មកឱ្យក្រុមអ្នកចូលរួម។
- ដាក់ពេលវេលាកំណត់ច្បាស់លាស់។ សូមពន្យល់ប្រាប់ថា ពេលវេលាសម្រាប់ការបណ្តុះបណ្តាលមានកម្រិតកំណត់ និងត្រូវបញ្ជាក់ថា គាត់ចាំបាច់ត្រូវបញ្ចប់បទបង្ហាញទៅតាមពេលវេលាដែលបានកំណត់។
- ជម្រាបប្រាប់ពួកគាត់អំពីបរិក្ខាដែលនឹងមាននៅក្នុងបន្ទប់បណ្តុះបណ្តាល (ឧទាហរណ៍ ម៉ាស៊ីនបញ្ចាំងទិន្នន័យ កុំព្យូទ័រយួរដៃ មីក្រូហ្វូនក្រដាសផ្ទាំងធំ។ល។)

- ត្រូវធានាថា ពួកគាត់ស្គាល់ច្បាស់អំពីបទដ្ឋានការពារកុមារ ដូចជាការចែករំលែកព័ត៌មានសម្គាល់អត្តសញ្ញាណអំពីកុមាររងគ្រោះ ឬរូបថតជាដើម។
- ស្នើសុំសំណៅបទបង្ហាញរបស់ពួកគាត់ ពីរបីថ្ងៃមុនពេលបណ្តុះបណ្តាល។ ការធ្វើបែបនេះ នឹងជួយអ្នកឱ្យពិនិត្យមើលថា តើបទបង្ហាញនោះឆ្លើយតបនឹងតម្រូវការឬទេ ព្រមទាំងមានពេលដើម្បីកែសម្រួលប្រសិនបើចាំបាច់។




# ការជ្រើសរើសទីកន្លែង

អ្នកសម្របសម្រួលគួរព្យាយាមផ្តល់បរិស្ថានដែលអំណោយផលដល់ការរៀនសូត្រ និងសមស្របទៅនឹងសកម្មភាពដែលអ្នកចូលរួមនឹងត្រូវធ្វើ។ ទំហំ ប្លង់រៀបចំ និងបរិស្ថានបន្ទប់រៀន មានឥទ្ធិពលយ៉ាងសំខាន់លើការសម្រេចបានលទ្ធផលនៃការរៀនសូត្រ។

ជាការសំខាន់បំផុត ក្នុងការជ្រើសរើសទីកន្លែងដែលមានទំហំធំគ្រប់គ្រាន់ សម្រាប់ចំនួនអ្នកចូលរួម ដើម្បីអាចចូលរួមយ៉ាងសកម្មក្នុងការងារក្រុម និងសកម្មភាពបណ្តុះបណ្តាលដទៃទៀត។ នៅពេលជ្រើសរើសទីកន្លែងបណ្តុះបណ្តាល ត្រូវធានាឱ្យបានផងដែរថា មានម៉ាស៊ីនកំដៅ/ម៉ាស៊ីនត្រជាក់ បរិក្ខារបន្ទប់ទឹក ការផ្គត់ផ្គង់អគ្គិសនីសម្រាប់មីក្រូហ្វូន និងម៉ាស៊ីនបញ្ចាំងទិន្នន័យ និងអេក្រង់បញ្ចាំង។

## ប្លង់រៀបចំទីកន្លែងបណ្តុះបណ្តាល

ដោយហេតុថា ការបណ្តុះបណ្តាលប្រើប្រាស់រូបមន្តការបណ្តុះបណ្តាលបែបការចូលរួម ដែលលើកទឹកចិត្តដល់ការចូលរួមរបស់បុគ្គល និងក្រុម ជាការល្អគួររៀបចំប្លង់ទីតាំងបណ្តុះបណ្តាលក្នុងទម្រង់ "Cabaret" (សូមមើលដ្យាក្រាមទី ១)។

*ដ្យាក្រាមទី ១ – ជម្រើសសម្រាប់ការរៀបចំប្លង់បន្ទប់បណ្តុះបណ្តាល*




ប្លង់រៀបចំ តុមូលដាច់ពីគ្នា គឺជាការរៀបចំល្អបំផុតសម្រាប់ការងារជាក្រុម។ ការរៀបចំនេះ ក៏លើកទឹកចិត្តអ្នកចូលរួមឲ្យអង្គុយលាយឡំគ្នា និងអនុញ្ញាតិឲ្យអ្នកបណ្តុះបណ្តាលអាចផ្លាស់ទីបានកាន់តែងាយស្រួលក្នុងបន្ទប់ទាំងមូលផងដែរ។ ថ្វីបើរូបខាងលើបង្ហាញរូបភាពជាតុមូលក្តី ប្លង់រៀបចំ តុមូលដាច់ពីគ្នា ក៏មានប្រសិទ្ធិភាពដូចគ្នាសម្រាប់តុរាងបួនជ្រុង។ សូមកត់សម្គាល់ថា មិនត្រូវឲ្យមានអ្នកចូលរួមបែរខ្នងទៅខាងមុខបន្ទប់ឡើយ។ អ្នកចូលរួមទាំងអស់ត្រូវតែអាចមើលឃើញអ្នកសម្របសម្រួល ដោយមិនចាំបាច់ត្រូវដកក ឬខ្នងរបស់ខ្លួនឡើយ។

ប្រសិនបើមិនអាចរៀបចំតាមទម្រង់ តុមូលដាច់ពីគ្នា ទេនោះ ប្លង់រៀបចំបែបអក្សរអ៊ុយ (U) ក៏អាចយកមកប្រើបានដែរ។ ប្រសិនបើអាចធ្វើបាន សូមជៀសវាងកុំប្រើប្លង់រៀបចំបែបផ្លូវការដូចជាប្លង់ "រោងល្ខោន" ជាដើម ព្រោះការរៀបចំបែបនេះសមស្របសម្រាប់តែបទឧទ្ទេសខ្លីៗ ព្រោះវារារាំងដល់ការចូលរួម និងការងារជាក្រុម។

ក្នុងបរិយាកាសក្រៅផ្លូវការ មិនចាំបាច់ត្រូវប្រើតុនោះទេ។ ក្នុងករណីមួយចំនួន អ្នកចូលរួមអាចនឹងចង់អង្គុយលើឥដ្ឋ ឬលើដី។










## អ្នកជំនួយការ

គួរមានអ្នកជំនួយការម្នាក់ (ឬច្រើនជាងនេះ ប្រសិនបើមានអ្នកចូលរួមច្រើន) ដើម្បីជួយសម្រួលរឿងឧបករណ៍ ផ្តល់មីក្រូហ្វូនពេលអ្នកចូលរួមចង់និយាយ។ល។ ការធ្វើបែបនេះ នឹងបង្កឱ្យមានការរំខានកម្រិតតិចតួចបំផុតដល់អ្នកសម្របសម្រួល។

## ការចំណាយសម្រាប់ទីកន្លែង

ការចំណាយសម្រាប់ទីកន្លែងអាចមានតម្លៃខ្ពស់។ ប៉ុន្តែត្រូវដឹងថា មានសណ្ឋាគារជាច្រើនដែលមានឆន្ទៈបញ្ចុះតម្លៃ ឬផ្តល់ទីកន្លែងដោយឥតគិតថ្លៃ ដើម្បីគាំទ្រចំពោះវត្ថុបំណងរបស់ការបណ្តុះបណ្តាល។ នៅពេលកក់ទីកន្លែងបណ្តុះបណ្តាល សូមកំណត់រកទីកន្លែងណា ដែលអាចនឹងមានឆន្ទៈផ្តល់ការជួយជ្រោមជ្រែង។

# តើឧបករណ៍ និងធនធានអ្វីខ្លះដែលត្រូវការ ?

ត្រូវធានាថា មានឧបករណ៍ទាំងអស់រួចរាល់ មុនពេលការបណ្តុះបណ្តាល។ យើងផ្តល់យោបល់ថា ត្រូវធ្វើតេស្តឧបករណ៍ទាំងនេះ មុននឹងវគ្គបណ្តុះបណ្តាលចាប់ផ្តើម ដើម្បីធ្វើឱ្យប្រាកដថា មិនមានបញ្ហានៅពេលបណ្តុះបណ្តា។ ខាងក្រោមនេះ គឺជាបញ្ជីផ្ទៀងផ្ទាត់សាមញ្ញមួយ ដែលអាចយកទៅប្រើដើម្បីត្រៀមនៅមុនពេលសិក្ខាសាលាបណ្តុះបណ្តាលនីមួយៗ។ សូមគូសសញ្ញា √ នៅក្នុងតារាងខាងក្រោមបើសិនជាមានឧបករណ៍ដែលអាចប្រើប្រាស់ក្នុងការងារនេះ ។

| បញ្ជីផ្ទៀងផ្ទាត់ឧបករណ៍ | ✓ |
|---|---|
| មីក្រូហ្វូន (១ x អ្នកសម្របសម្រួល, ១ x ចល័ត, ១ x អ្នកបកប្រែ) (ប្រសិនបើមានអ្នកចូលរួមច្រើន ត្រូវមានមីក្រូហ្វូនចល័តច្រើនដែរ)។ | |
| ម៉ាស៊ីនបញ្ចាំងទិន្នន័យ | |
| អេក្រង់បញ្ចាំងទិន្នន័យ | |
| កុំព្យូទ័រយួរដៃ | |
| ម៉ាស៊ីនបំពងសំឡេង (សម្រាប់តម្រូវការផ្នែកសម្លេង រួមទាំងវីដេអូផងដែរ) | |
| ស្លាយផៅវើភ័ញ | |
| ក្ដារខៀន | |
| ក្រដាសផ្ទាំងធំ | |
| ហ្វឺតសរសេរ (១២ ដើម សម្រាប់អ្នកសម្របសម្រួល និងប្រើប្រាស់ក្នុងពេលធ្វើការងារក្រុម) | |
| ស្កុតស្អិត ម្ជុល និង ដីឥដ្ឋសិប្បនិម្មិត សម្រាប់បិទក្រដាសបង្ហាញនៅលើជញ្ជាំង | |
| កន្ត្រៃ | |
| ក្រដាសស្អិតសម្រាប់បិទសម្គាល់ ក្រដាសស និងខ្មៅដៃសម្រាប់អ្នកចូលរួមកត់កំណត់ហេតុ និងក្រុមពិភាក្សា | |
| បាល់ទាត់សម្រាប់លេងក្នុងបន្ទប់ (មានជម្រើស ក្នុងសកម្មភាពណែនាំឱ្យស្គាល់គ្នាទៅវិញទៅមក) | |
| តុសម្រាប់ចុះឈ្មោះ (និងបញ្ជីវត្តមានអ្នកចូលរួម) | |
| ឯកសារសម្រាប់ចែកជូន (របៀបវារៈ សំណួរវាយតម្លៃមុន និងក្រោយវគ្គបណ្ដុះបណ្ដាល ការវាយតម្លៃចុងវគ្គ កាតយកតាមខ្លួន សេណារីយ៉ូ វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាម្នាក់១) | |

| បញ្ជីផ្ទៀងផ្ទាត់ដទៃទៀត | ✓ |
|---|---|
| ប្រមូលព័ត៌មានក្នុងមូលដ្ឋាន និងធ្វើបច្ចុប្បន្នភាពស្លាយទាំងអស់យោងទៅតាមនោះ | |
| អញ្ជើញវាគ្មិនដែលសក្ដិសម | |
| កំណត់ភ្នាក់ងារបញ្ជូនក្នុងមូលដ្ឋាន និងនាំយកព័ត៌មានលំអិតសម្រាប់ទំនាក់ទំនងទៅកាន់កន្លែងបណ្ដុះបណ្ដាល | |



# គោលការណ៍ណែនាំពិសេស សម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការការពារកុមារ

## ត្រូវយកចិត្តទុកដាក់សម្របសម្រួលការពិភាក្សាដោយការប្រុងប្រយ័ត្នខ្ពស់

ការរំលោភបំពានលើកុមារ ជាពិសេសគឺការរំលោភបំពានផ្លូវភេទ គឺជាបញ្ហាងាយរសើបមួយ ដែលចាំបាច់ត្រូវការ ការឆ្លុះបញ្ចាំង និងការពិចារណាពីអ្នកចូលរួម។ ហេតុនេះ អ្នកចូលរួមគួរទទួលបានឱកាស ដើម្បីជជែកលើ ប្រធានបទ ដែលមិនប្រឈមមុខ ដាក់គ្នា ដូចមានចែងក្នុងគោលការណ៍ណែនាំសម្រាប់ស្លាយ មុនពេលចាប់ផ្តើម ការពិភាក្សា អំពីការរំលោភបំពានលើកុមារ។ តាមរយៈការផ្តល់“សម្លេង” ដល់អ្នកចូលរួមក្នុងអំឡុងពេលធ្វើ សកម្មភាពចាប់ផ្តើមនាពេលដំបូង ពួកគេនឹងមានអារម្មណ៍ កាន់តែងាយស្រួលក្នុងការនិយាយចេញមកនូវ បញ្ហាការរំលោភបំពានលើកុមារក្នុងពេលការបណ្តុះបណ្តាលដំណើរការទៅមុខ។

*ត្រូវត្រៀមព័ត៌មានលំអិតសម្រាប់ទំនាក់ទំនងរបស់សេវាប្រឹក្សាយោបល់ ឬសេវាបញ្ជូននានាឱ្យបានស្រេចរួចរាល់*

ត្រូវដឹងថា អ្នកចូលរួមមួយចំនួនអាចជាជនរងគ្រោះនៃការរំលោភបំពាន។ វាជាការល្អ ដែលគួរចាំទុកក្នុងចិត្ត ថាមនុស្សផ្សេងគ្នា មានប្រតិកម្មខុសគ្នាចំពោះការរំលោភបំពាន។ ឧទាហរណ៍ មនុស្សមួយចំនួននឹងមិនគិតពី រឿងនោះអស់ពេលជាយូរ ហើយការ ពិភាក្សាពីរឿងនោះ អាចរំលឹកឡើងវិញនូវការចងចាំដ៏ឈឺចាប់នោះជាថ្មី។ វាជាការសំខាន់ណាស់ ដែលត្រូវគិតអំពីលទ្ធភាពនេះនៅគ្រប់ពេលទាំងអស់។ ប្រសិនបើអ្នកចូលរួមមាន បំណងចង់និយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួន សូមអញ្ជើញគាត់ឱ្យទៅ និយាយនៅក្នុងបរិយាកាសឯកជន (ក្នុងពេលសម្រាក)។ អ្នកសម្របសម្រួល គួរត្រៀមជាស្រេចនូវព័ត៌មានលំអិតសម្រាប់ ទំនាក់ទំនង របស់សេវា ប្រឹក្សាយោបល់ និងសេវាបញ្ជូនសម្រាប់អ្នកចូលរួមទាំងឡាយណា ដែលមានបំណងចង់ជជែកពិភាក្សា អំពីស្ថានភាពរបស់ខ្លួនលម្អិតបន្ថែមទៀត។

## ត្រូវរាយការណ៍ជាបន្ទាន់នូវរាល់ការលាតត្រដាងប្រាប់អំពីករណីដែលកុមារប្រហែល ជារងការរំលោភបំពាន។

ក្នុងករណីមានអ្នកចូលរួមចែករំលែកព័ត៌មានដែលជាសញ្ញាណឱ្យយើងដឹងថា ប្រហែលជាមានកុមារណា ម្នាក់កំពុងជួបការរំលោភបំពាននៅក្នុងគ្រួសាររបស់គេ ក្នុងសហគមន៍ ឬនៅកន្លែងណាមួយផ្សេងទៀត។ ត្រូវចាប់អារម្មណ៍ឱ្យបានខ្លាំង និងទាន់ពេលវេលា ចំពោះការលាតត្រដាងប្រាប់ទាំងអស់នេះ ក្នុងករណីកុមារ កំពុងប្រឈមនឹងគ្រោះថ្នាក់។ អង្គការទស្សនៈពិភពលោកប្តេជ្ញាចិត្តក្នុងការទប់ស្កាត់ការរំលោភបំពានលើ កុមារ ជាពិសេសគឺការរំលោភបំពានផ្លូវភេទ ហើយរាល់ការលាតត្រដាងអំពីករណីទាំងនេះ ចាំបាច់ត្រូវតែបញ្ជូន ទៅកាន់ភ្នាក់ងារសមស្របក្នុងមូលដ្ឋាន (រួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានផងដែរ) ឱ្យ បានឆាប់បំផុតតាមដែលអាចធ្វើបាន។ អ្នកសម្របសម្រួលចាំបាច់ត្រូវដឹង/ស្គាល់ភ្នាក់ងារ ក្នុងមូលដ្ឋាន ដែលគេអាចបញ្ជូនករណីសមស្របទៅទីនោះ ដើម្បីឱ្យគេស៊ើបអង្កេតលើការលាតត្រដាងប្រាប់ទាំងនោះ។ **ចាំបាច់ត្រូវរាយការណ៍រាល់ការលាតត្រដាងប្រាប់ទាំងអស់ជាបន្ទាន់។**

## ត្រូវឆ្លើយតបដោយប្រុងប្រយ័ត្នចំពោះសំណួរ និង/ឬអាកប្បកិរិយារំខាន

វាជាការសំខាន់ណាស់ ដែលត្រូវគោរពវប្បធម៌របស់អ្នកចូលរួម។ ទោះជាដូចនេះក្តី វប្បធម៌មិនត្រូវបានគេលើក ជាលេស ដើម្បី គាំទ្រការរំលោភបំពានលើកុមារនោះឡើយ។

អាចមានសំណួរលើកឡើងអំពីទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ អ្នកសម្របសម្រួលគួរត្រៀមខ្លួន ឆ្លើយតបនឹង ការពិភាក្សាប្រភេទនេះ ក្នុងលក្ខណៈច្បាស់លាស់ និងត្រង់ទៅត្រង់មក។ អ្នកសម្របសម្រួល គួរសង្កត់ធ្ងន់ថា កុមារទាំងអស់ មានសិទ្ធិ ទទួលបានការការពារ មិនថាគេមានទំនោរផ្លូវភេទ និងអត្តសញ្ញាណ យេនឌ័រណាមួយក៏ដោយ។ ការស្អប់ខ្ពើម ការរើសអើង ឬការស្ញៀមស្ងាត់ ចំពោះបញ្ហាទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ អាចរុញច្រានកុមារមួយចំនួនឱ្យធ្លាក់ក្នុង ស្ថានភាពងាយរងគ្រោះ ប្រសិនបើពួកគេ មិនបានទទួលការគាំទ្រពីក្នុងសហគមន៍ទេនោះ។

អ្នកសម្របសម្រួលគួរធានាឱ្យមានការឆ្លើយតបដោយប្រុងប្រយ័ត្ន លើរាល់ពាក្យសម្តីរបស់អ្នកចូលរួមទាំងឡាយណា ដែលជាជំនឿខុសឆ្គង ដែលមិនអំណោយផលដល់ការបង្កើតបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់កុមារ។ ឧទាហរណ៍ ការលើកឡើង អំពីការស្លៀកពាក់របស់កុមារី គឺមិនពាក់ព័ន្ធសម្រាប់ការពិភាក្សានោះទេ ហើយអាចសាបព្រោះឥរិយាបទ លំអៀងផ្នែកយេនឌ័រ ដែល"បន្ទោសជនរងគ្រោះ" ថែមទៀត។ អ្នកសម្របសម្រួលមិនគួរលើកទឹកចិត្តការពិភាក្សាប្រភេទនេះឡើយ ហើយត្រូវបែរមកផ្តោតលើសារសំខាន់ៗដែលមាននៅក្នុងសម្ភាររបស់យើងវិញ។

ក្នុងកាលៈទេសៈខ្លះ អ្នកសម្របសម្រួលនឹងបានជួបអ្នកចូលរួមដែលបង្ហាញអាកប្បកិរិយារំខាន (ចូលចិត្តប្រកែកតវ៉ា និយាយឥតឈប់ ឥរិយាបទអវិជ្ជមាន រំខានគេឯង ឬមនុស្សដែលជឿថាខ្លួនចេះអ្វីគ្រប់យ៉ាង)។ ដើម្បីកុំឱ្យមានជម្លោះកើតឡើង ត្រូវធ្វើយ៉ាងណាឱ្យអ្នកចូលរួមទាំងនោះ ចូលរួមក្នុងការ កំណត់រកដំណោះស្រាយចំពោះបញ្ហាដែលពួកគាត់បានលើកឡើង។ សូមកុំភ្លេចអ្នកចូលរួមដទៃទៀត ដោយសារតែអាកប្បកិរិយារបស់អ្នកចូលរួមមានចរិកពិបាកម្នាក់ឱ្យសោះ។

គ្រប់ពេលវេលាទាំងអស់ ជាការចាំបាច់ណាស់ ដែលត្រូវរំលឹកអ្នកចូលរួមថា កុមារមិនគួរទទួលការស្តីបន្ទោសដោយសារតែពួកគេបានក្លាយជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទនោះឡើយ។

# វិធីសាស្ត្របណ្តុះបណ្តាល

ការបណ្តុះបណ្តាលនេះ ទទួលស្គាល់ថា មនុស្សមានវិធីរៀនសូត្រខុសៗគ្នា។ ហេតុនេះ កម្មវិធីសិក្សាត្រូវយកវិធីបង្រៀន ច្រើនប្រភេទមកប្រើប្រាស់ដូចជាគោលវិធីបែបអន្តរកម្ម និងមានការចូលរួម ហើយមិនត្រូវអនុវត្តតាមគំរូបែបប្រពៃណី ដែលអកម្ម និងមានគ្រូជាអ្នកជម្រុញ។ អ្នកសម្របសម្រួលគួរព្យាយាមគោរពបទពិសោធន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ លើកកំពស់កិច្ចសន្ទនាទៅវិញទៅមក លើកទឹកចិត្តចំពោះការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន និងបង្កើតបរិស្ថានរៀនសូត្រដែលមាន លក្ខណៈធូរស្បើយ ប៉ុន្តែប្រកបដោយថាមពលខ្ពស់។

វគ្គនីមួយៗ រួមបញ្ចូលនូវសកម្មភាពនានាដូចជាករណីសិក្សា ការសម្តែងតួ ការពិភាក្សាក្រុម និងការងារជាក្រុម ដើម្បីលើក ទឹកចិត្តដល់អ្នកចូលរួម និងលើកកម្ពស់ដល់ការរៀនសូត្រ។ កំណត់សម្គាល់សម្រាប់ស្លាយផៅវើភ័ញ នឹងចង្អុលបង្ហាញផ្លូវដល់ អ្នកសម្របសម្រួល នៅក្នុងសកម្មភាពនីមួយៗ។





គ្រប់ពេលទាំងអស់ អ្នកសម្របសម្រួលត្រូវដឹងអំពីអ្នកចូលរួមដែលមិនអាចអាន ឬសរសេរបាន ឬអ្នកដែលមានបញ្ហាក្នុងការស្តាប់ និងការមើល ឬបញ្ហាដទៃទៀត។ អ្នកសម្របសម្រួល គួរធ្វើផែនការជាមុន អំពីវិធីដើម្បីសម្រួលដំណើរការការបណ្តុះបណ្តាល យោងទៅតាមមនុស្សដែលមានពិការភាព ឧ. ការពិចារណាទៅលើការរៀបចំកន្លែងអង្គុយ ការពិចារណាឲ្យមានការជួយមួយទល់មួយ បោះពុម្ពឯកសារដោយប្រើទំហំអក្សរធំ។ល។

ដើម្បីផ្តល់ការបណ្តុះបណ្តាលដោយជោគជ័យ អ្នកសម្របសម្រួលគួរជានាឱ្យបានថាគាត់ត្រូវ៖

- ស្តាប់អ្នកចូលរួមទាំងអស់ដោយយកចិត្តទុកដាក់ និងគោរពចំពោះបទពិសោធន៍ និងជំនាញរបស់ពួកគេ
- និយាយឱ្យច្បាស់លាស់ និងសាមញ្ញ ហើយជាការល្អ ត្រូវនិយាយភាសាដែលអ្នកចូលរួមភាគច្រើនចេះ
- ប្រើប្រាស់ឧទាហរណ៍ក្នុងស្រុក គ្រប់ពេលដែលអាចធ្វើបាន។
- លើកទឹកចិត្តឱ្យមានការទំនាក់ទំនងរវាងអ្នកចូលរួម និងអ្នកចូលរួម
- និយាយ និងធ្វើបទបង្ហាញដោយមានទំនុកចិត្តខ្ពស់
- ប្រើប្រាស់មធ្យោបាយជំនួយការមើលឃើញដោយប្រុងប្រយ័ត្ន
- ត្រៀមចំណុចគោលសម្រាប់និយាយជាមុន ហើយត្រូវហ្វឹកសមឱ្យរួចរាល់មុនពេលបណ្តុះបណ្តាល
- ធ្វើតេស្តឧបករណ៍មុនពេលវគ្គបណ្តុះបណ្តាល

# នៅថ្ងៃបណ្តុះបណ្តាល

## ការប្រើប្រាស់ស្លាយ

បទបង្ហាញផៅវើភ័ញរបស់វិស័យទេសចណ៍អាចទាញយកបានពី http://www.childsafetourism.org និង http://wvi.org/asiapacific/childsafetourism.ស្លាយផៅវើភ័ញ ត្រូវបានរៀបចំឡើង ដើម្បីជាឧបករណ៍មួយ ជួយគាំទ្រដល់វត្ថុបំណងនៃការរៀនសូត្រ និងជួយលើកកម្ពស់ ដល់ការចងចាំរបស់អ្នកចូលរួមនូវសារសំខាន់ៗក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាល។ ស្លាយនេះ មិនបានតាក់តែងឡើង ដើម្បីអ្នកសម្របសម្រួល និងអ្នកចូលរួមអានមួយស្លាយម្តងៗនោះឡើយ។ អ្នកសម្របសម្រួលត្រូវពិនិត្យ និងកែសម្រួលស្លាយឡើងវិញមុនដល់ពេលការបណ្តុះបណ្តាល ដើម្បីដាក់បញ្ចូលនូវខ្លឹមសារក្នុងប្រទេសនិង/ឬក្នុងមូលដ្ឋាន ដែលពាក់ព័ន្ធ។

ដោយហេតុថា ការបណ្តុះបណ្តាលមានបំណងឱ្យអ្នកចូលរួមយ៉ាងសកម្ម ស្លាយមានលក្ខណៈជាការបំផុសគំនិតដែលងាយស្រួលយល់ ក្នុងបំណងដើម្បីទាញចំណាប់អារម្មណ៍របស់ អ្នកចូលរួម។ អ្នកសម្របសម្រួលមានតួនាទីក្នុងការបង្កើតបរិស្ថាន រៀនសូត្រដ៏សកម្មនិងផុសផុលមួយ តាមរយៈការពិនិត្យលម្អិតទៅលើស្លាយ និងដាក់បញ្ចូលនូវសកម្មភាពនានា រាល់ចន្លោះពេលវគ្គសិក្សានីមួយៗ។ "សារគន្លឹះ" និង "កំណត់សម្គាល់" នៅក្នុងសេចក្តីណែនាំលើស្លាយ ផ្តល់នូវការពិពណ៌នា និងព័ត៌មាន លម្អិតបន្ថែមទៀត ដើម្បីជួយអ្នកសម្របសម្រួលក្នុងការផ្តល់វគ្គបណ្តុះបណ្តាល។



## ការប្រើប្រាស់កាតយកតាមខ្លួន

កាតយកតាមខ្លួន ជាឯកសារចែកជូនដល់អ្នកចូលរួម ក្នុងវគ្គបណ្តុះបណ្តាលនេះហើយដែលពួកគេអាចយកទៅជាមួយខ្លួនបាន ដើម្បីរំលឹកពួកគេ អំពីចំណុចសំខាន់ៗដែលពួកគេបានរៀនរួចហើយ ។ គួរផ្តល់កាតយកតាមខ្លួន (**ឧបសម្ព័ន្ធទី១**) ទៅឱ្យអ្នកចូលរួមនៅពេលចាប់ផ្តើមការបណ្តុះបណ្តាល ហើយត្រូវលើកឡើងអំពីខ្លឹមសារឯកសារនេះជារឿយៗ នៅក្នុងវគ្គបណ្តុះបណ្តាលទាំងមូល។ អ្នកសម្របសម្រួល គួរលើកទឹកចិត្តអ្នកចូលរួមឲ្យប្រើប្រាស់កាតទាំងនេះជាឯកសារយោង នៅពេលពួកគេត្រលប់ទៅផ្ទះ និងកន្លែងធ្វើការវិញ ហើយត្រូវចែករំលែកព័ត៌មានដែលពួកគេបានរៀនសូត្រទៅដល់មិត្តរួមការងារដទៃទៀត។ យើងខ្ញុំសូមណែនាំឲ្យថតចម្លងកាតយកតាមខ្លួននេះដោយប្រើកាតពណ៌ធម្មជាតិ ឬពណ៌ស/ខ្មៅ ក្រដាសទំហំ A៦ ទាំងសងខាង។ ការធ្វើដូចនេះ នឹងជួយឲ្យគេអាចចងចាំកាតទាំងនេះបានកាន់តែល្អ និងងាយស្រួលក្នុងការប្រើប្រាស់។




## ការប្រើប្រាស់ឯកសារចែកជូនក្នុងវគ្គបណ្តុះបណ្តាល

បន្ថែមលើនេះ ឯកសារបណ្តុះបណ្តាលសម្រាប់ចែកជូន ត្រូវបានដាក់ក្នុងទម្រង់ដែលងាយស្រួលថតចម្លងនៅខាងចុងសៀវភៅណែនាំនេះ។ ជានិច្ចកាល ត្រូវថតចម្លងសំណៅឯកសារចែកជូនឱ្យបានលើសចំនួនក្រែងលោមានអ្នកចូលរួមបន្ថែម ឬអ្នកអង្កេតការមកចូលរួមវគ្គបណ្តុះបណ្តាលនេះ។

## សម្រាកពិសារអាហារសម្រន់

អ្នកចូលរួមជាមនុស្សពេញវ័យ បានទទួលអត្ថប្រយោជន៍ពីការសម្រាកពិសារអាហារសម្រន់ដែលត្រូវបានធ្វើឡើងជាប្រក្រតី ដើម្បីរក្សាទំនាក់ទំនង និងរក្សាកម្រិតថាមពលរបស់ពួកគេ។ របៀបវារៈត្រូវបានតាក់តែងឡើង ដើម្បីដាក់បញ្ចូលនូវការសម្រាកពិសារអាហារសម្រន់តាមការគួរ ដែលស្របនៅនឹងលំដាប់លំដោយនៃវគ្គនីមួយៗ។

ជាការល្អបំផុត គួរមាន "ការសម្រាកខ្លី" រយៈពេលប្រាំនាទី បន្ទាប់ពីការបណ្តុះបណ្តាលមួយម៉ោងៗ។ ការសម្រាកខ្លីនេះ គួរត្រូវបានបំពេញបន្ថែមដោយការសម្រាករយៈពេលយូរជាងនេះ សម្រាប់ការពិសារអាហារសម្រន់ពេលព្រឹក និងពេលរសៀល។ ការសម្រាកពិសារអាហារសម្រន់នីមួយៗ គួរមានរយៈពេលដប់នាទី។ អ្នកសម្របសម្រួលគួរធានាថា វគ្គនីមួយៗត្រូវបានចាប់ផ្តើមឡើងវិញតាមពេលវេលាកំណត់ ហើយការសម្រាកមិនត្រូវបានពន្យាពេលយូរ។

អាស្រ័យដោយការរំពឹងទុកផ្នែកវប្បធម៌ទាក់ទងនឹងការកំណត់ពេលសម្រាកអាហារថ្ងៃត្រង់ អ្នកសម្របសម្រួលគួរទំនាក់ទំនងជាមួយភ្នាក់ងារដៃគូដើម្បីកំណត់ការរៀបចំដែលសមស្រប។ ប្រសិនបើអាចធ្វើបាន ត្រូវកំណត់ពេលការសម្រាកអាហារថ្ងៃត្រង់ឱ្យនៅត្រឹមមួយម៉ោង ប៉ុន្តែត្រូវដឹងថា ប្រសិនបើមិនមានការព្រមព្រៀងដោយក្រុមទាំងមូលទេ ការធ្វើបែបនេះ នឹងបណ្តាលឱ្យមានការត្រលប់មកវិញយឺតយ៉ាវ។

សូមគោរពម៉ោងដែលត្រូវបញ្ចប់ការបណ្តុះបណ្តាល។ អ្នកចូលរួម នឹងបែកអារម្មណ៍យ៉ាងខ្លាំងប្រសិនបើមានការតម្រូវឲ្យពួកគាត់ត្រូវនៅរៀនតទៅទៀត យូរជាងពេលវេលាបញ្ចប់ដែលបានសន្យាគ្នា។

## ការវាយតម្លៃ

ការវាយតម្លៃគឺជាសមាសធាតុដ៏សំខាន់មួយ ក្នុងការកំណត់ថា តើវត្ថុបំណងរបស់ការបណ្តុះបណ្តាលត្រូវបានឆ្លើយតបឬនៅ។ អង្គការទស្សនៈពិភពលោក ព្យាយាមវាស់វែងប្រតិកម្មឆ្លើយតបនឹងការរៀនសូត្រ និងបំលាស់ប្តូរអាកប្បកិរិយារបស់អ្នកចូលរួមតាមរយៈការប្រើប្រាស់ឧបករណ៍ជាច្រើន៖

*កម្រិតទី ១៖ ប្រតិកម្មតប*

*តើអ្នកចូលរួមមានអារម្មណ៍ដូចម្តេចចំពោះការបណ្តុះបណ្តាលនេះ ?* ការវាស់ប្រតិកម្មតបវិញរបស់អ្នកចូលរួម គឺជាការវាយតម្លៃភ្លាមៗ ព្រោះការវាយតម្លៃនេះ ធ្វើឡើងតាមរយៈការសង្កេត និងការសួរសំណួរដោយផ្ទាល់។ គេអាចវាស់ប្រតិកម្មតបរបស់អ្នកចូលរួម ក្នុងអំឡុងពេលបណ្តុះបណ្តាល តាមវិធីដូចខាងក្រោម៖

- ការសង្កេត៖ អ្នកសម្របសម្រួលអាចសង្កេតថា តើអ្នកចូលរួមមានប្រតិកម្មតបចំពោះសំណួរយ៉ាងដូចម្តេច ? តើពួកគាត់ចូលរួមក្នុងសកម្មភាពក្រុមយ៉ាងដូចម្តេច ? តើពួកគាត់ចាប់អារម្មណ៍វគ្គសិក្សាឬទេ ? តើពួកគាត់សួរសំណួរដែលបានគិតគូរល្អិតល្អន់ឬទេ ? អ្នកសម្របសម្រួលគួរកត់ត្រាការសង្កេតទាំងនេះក្នុងអំឡុងពេលការបណ្តុះបណ្តាល ហើយបើចាំបាច់ ត្រូវកែសម្រួលបែបបទនៃការសម្របសម្រួល ឱ្យស្របទៅតាមនោះ។ ជំនួយការក៏អាចជួយផ្តល់ព័ត៌មានល្អៗ ផ្អែកលើការសង្កេតរបស់ខ្លួន និងការទំនាក់ទំនងដែលខ្លួនមានជាមួយអ្នកចូលរួមផងដែរ។
- ការវាយតម្លៃក្រោយវគ្គបណ្តុះបណ្តាល៖ នៅចុងបញ្ចប់នៃការបណ្តុះបណ្តាល អ្នកសម្របសម្រួលអាចចេញទម្រង់វាយតម្លៃក្រោយការបណ្តុះបណ្តាលមួយ (គំរូទម្រង់វាយតម្លៃ មានភ្ជាប់នៅឧបសម្ព័ន្ធទី៨) ដែលតម្រូវ ឱ្យអ្នកចូលរួមផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់អំពីប្រតិកម្មតបរបស់ខ្លួនចំពោះការបណ្តុះបណ្តាល។

*កម្រិតទី២៖ ការរៀនសូត្រ*

តើអ្នកចូលរួមបានរៀនសូត្រអ្វីខ្លះ ជាលទ្ធផលនៃការបណ្តុះបណ្តាលនេះ ? ចំណុចនេះអាចវាស់វែងបាន តាមរយៈការប្រើប្រាស់ការវាយតម្លៃមុន និងក្រោយការបណ្តុះបណ្តាល ដែលនឹងជួយប្រៀបធៀបលទ្ធផលទទួលបានមុន និងក្រោយការបណ្តុះបណ្តាល។ គម្រោងកុមារភាព ផ្នែកបង្ការ បានតាក់តែងឡើងនូវលំហាត់មុនចាប់ផ្តើម និងលំហាត់ពេលបញ្ចប់ ដើម្បីផ្តល់ជារង្វាស់ដ៏ងាយស្រួល ក្នុងការវាស់វែងការប្រែប្រួលចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាលរបស់អ្នកចូលរួម (ឧបសម្ព័ន្ធទី៤ និងទី៥)។ ប្រសិនបើពេលវេលាមានកំណត់ លំហាត់មុនចាប់ផ្តើម និងលំហាត់ពេលបញ្ចប់អាចធ្វើឡើងតាមរយៈការលើកដៃ បើទោះបីជានេះមិនមែនជាជម្រើសល្អបំផុតក្តី។ ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំនួននៃការលើកដៃសម្រាប់សំណួរនីមួយៗ។

*កម្រិតទី៣៖ ការផ្លាស់ប្តូរអាកប្បកិរិយា*

*តើអ្នកចូលរួមនឹងធ្វើអ្វីខ្លះខុសប្លែកពីមុន ដែលជាលទ្ធផលនៃការបណ្តុះបណ្តាលនេះ ?* ការផ្លាស់ប្តូរអាកប្បកិរិយា គឺជាលទ្ធផលដែលវគ្គបណ្តុះបណ្តាលចង់បានបំផុត។ ប៉ុន្តែជាធម្មតា គេមិនអាចវាស់វែងការផ្លាស់ប្តូរអាកប្បកិរិយាបានទេ រហូតទាល់តែក្រោយពេលការបណ្តុះបណ្តាលបានបញ្ចប់ និងពេលអ្នកចូលរួមបានត្រលប់ទៅកន្លែងធ្វើការងាររបស់ខ្លួនវិញ។ ថ្វីបើការវាយតម្លៃតាមដាន តម្រូវឱ្យធ្វើការវាស់វែងការផ្លាស់ប្តូរអាកប្បកិរិយាក្នុងរយៈពេលណាមួយបន្ទាប់ពីវគ្គបណ្តុះបណ្តាលចប់ក្តី ក៏យើងនៅតែអាចវាស់វែង អំពីចេតនានៃបំលាស់ប្តូរអាកប្បកិរិយាភ្លាមៗបានដែរ។ ជាលទ្ធផល ទម្រង់ការវាយតម្លៃក្រោយពេលបណ្តុះបណ្តាល (ទស្សនៈរបស់ខ្ញុំ ក្នុងឧបសម្ព័ន្ធទី៨) រួមមានសំណួរអំពីចេតនាក្នុងការផ្លាស់ប្តូរអាកប្បកិរិយានេះ។

អ្នកសម្របសម្រួលត្រូវទទួលខុសត្រូវក្នុងការប្រមូល និងចងក្រងជាឯកសារនូវព័ត៌មានដែលបានទទួលពីប្រតិកម្មតបការរៀនសូត្រ និងការផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកចូលរួម និងចែករំលែកព័ត៌មាននេះជាមួយអ្នកគ្រប់គ្រង/អង្គការស្ថាប័ន ដើម្បីគាំទ្រដល់ការកែលំអកម្មវិធីបណ្តុះបណ្តាលនេះជាបន្តទៀត។

ទម្រង់មួយ ដើម្បីបង្រួបបង្រួមឧបករណ៍តាមដាន និងវាយតម្លៃផ្សេងៗទាំងអស់នេះបញ្ចូលគ្នា មាននៅក្នុង **ឧបសម្ព័ន្ធទី៤**។

## វិញ្ញាបនប័ត្រ

វិញ្ញាបនប័ត្រគឺជាវិធីដ៏សំខាន់មួយ ដើម្បីទទួលស្គាល់ការចូលរួម ក៏ដូចជាដើម្បីផ្តល់ឱ្យអ្នកចូលរួមនូវ "ភស្តុតាង" មួយ ដែលពួកគាត់អាចដាក់បង្ហាញនៅកន្លែងធ្វើការងាររបស់ខ្លួន នៅក្រោយពេលបណ្តុះបណ្តាល។ គួរបោះពុម្ពវិញ្ញាបនប័ត្រមុនពេលការបណ្តុះបណ្តាល ដោយមានកាលបរិច្ឆេទ និងអ្នកចុះហត្ថលេខា។ គំរូវិញ្ញាបនប័ត្រ គឺមាននៅក្នុង**ឧបសម្ព័ន្ធទី៩**។ យើងសូមណែនាំឱ្យបញ្ចូលឈ្មោះអ្នកចូលរួម នៅក្នុងវិញ្ញាបនប័ត្រមុនកម្មវិធី ឬនៅក្នុងពេលសម្រាកពិសារអាហារថ្ងៃត្រង់ ដោយផ្អែកតាមបញ្ជីវត្តមានអ្នកចូលរួម។

គួរផ្តល់វិញ្ញាបនប័ត្រ ឲ្យតែអ្នកចូលរួមណាដែលបានចូលរួមការបណ្តុះបណ្តាលតាំងពីដើមរហូតដល់ចប់តែប៉ុណ្ណោះ។ មិនគួរឱ្យមានអ្នកចូលរួមណា យកវិញ្ញាបនប័ត្រជំនួសឱ្យអ្នកចូលរួម ដែលមិនបានចូលរួមគ្រប់តាមចំនួនថ្ងៃនៃការបណ្តុះបណ្តាលមុននោះឡើយ។

បើនៅកន្លែងដែលបណ្តុះបណ្តាល បានទទួលការឧបត្ថម្ភគាំទ្រពីអាជ្ញាធរសាធារណៈ ដូចជាស្ថាប័នទេសចរណ៍ជាតិជាដើម អាចសុំការអនុញ្ញាតជាមុន ដើម្បីដាក់បញ្ចូលបន្ថែមក្នុងវិញ្ញាបនប័ត្រ នូវស្លាកសញ្ញាសម្គាល់របស់ស្ថាប័ន (និងហត្ថលេខាមន្ត្រីជាន់ខ្ពស់របស់ស្ថាប័ន)។ ម្យ៉ាងទៀត អ្នកក៏ អាចយកវិញ្ញាបនប័ត្រគំរូមួយទៅបង្ហាញដល់អ្នកចូលរួម នៅពេលចាប់ផ្តើមការបណ្តុះបណ្តាលនោះបានដែរ។ ពិធីចែកវិញ្ញាបនប័ត្រខ្លីមួយ ដឹកនាំដោយមន្ត្រីជាន់ខ្ពស់ឬអ្នកមានកិត្តយស (ប្រសិនបើអាច) ណាម្នាក់ដែលគាំទ្រចំពោះមេរៀន និងព័ត៌មានដែលយើងបានចែករំលែក។



# កំណត់ត្រា

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

# ផ្នែកទី២៖

# ការណែនាំតាមរយៈស្លាយ



# តើត្រូវប្រើប្រាស់សេចក្តីណែនាំពីស្លាយទាំងនេះដោយរបៀបណា ?

ផ្នែកនេះផ្តល់នូវការណែនាំមួយជំហានម្តងៗ ដើម្បីជួយសម្រួលដល់អ្នកសម្របសម្រួលក្នុងការបង្រៀន លើគ្រប់ទិដ្ឋភាពទាំងអស់ដែលមាននៅក្នុងវគ្គបណ្តុះបណ្តាល។ អ្នកអាចទាញយកបទបង្ហាញផៅវើភ័ញសម្រាប់វិស័យទេសចរណ៍ បានពី http://www.childsafetourism.org និង http://wvi.org/asiapacific/childsafetourism ហើយគួរតែអាន និងកែសម្រួលខ្លឹមសារឯកសារទាំងនេះ មុនពេលបណ្តុះបណ្តាល ដើម្បីធ្វើយ៉ាងណាដាក់បញ្ចូលនូវខ្លឹមសារដែលពាក់ព័ន្ធក្នុងកម្រិតជាតិ និង/ឬមូលដ្ឋាន។ បទបង្ហាញផៅវើភ័ញ គឺជាឧបករណ៍មួយដើម្បីគាំទ្រវត្ថុបំណងនៃការរៀនសូត្រ និងជម្រុញការចងចាំសារសំខាន់ៗ ក្នុងអំឡុងពេលការបណ្តុះបណ្តាល។ អ្នកសម្របសម្រួលអាចប្រើប្រាស់ស្លាយណែនាំ ជាកំណត់សម្គាល់សម្រាប់និយាយ ក្នុងករណីគាត់មិនអាចប្រើឧបករណ៍ទំនើប ដូចជានៅលើម៉ាស៊ីនបញ្ចាំងស្លាយ ឬការបោះពុម្ពលើក្រដាសផ្ទាំងធំបានទេនោះ។

អ្នកសម្របសម្រួល ត្រូវព្យាយាមធ្វើយ៉ាងណា បង្កើតបរិស្ថានរៀនសូត្រប្រកបដោយភាពរស់រវើក តាមរយៈការពន្យល់លម្អិតទៅលើស្លាយ និងដាក់បញ្ចូលសកម្មភាពនានា នៅចន្លោះពេលដែលបានណែនាំ។ ក្នុងសេចក្តីណែនាំនេះក៏មានសំណួរដែលអ្នកសម្របសម្រួលអាចសួរទៅអ្នកចូលរួម ដើម្បីលើកទឹកចិត្តឱ្យមានការពិភាក្សាក្នុងក្រុមទាំងមូល និង/ឬការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល យោងទៅតាមចំនួនអ្នកចូលរួម និង ពេលវេលា ( ដាក់សញ្ញាសម្គាល់ថា "សំណួរសម្រាប់ឆ្លុះបញ្ចាំង/ពិភាក្សា" )។ គួរផ្តល់ **កាតយកតាមខ្លួន ( ឧបសម្ព័ន្ធទី២ )** ទៅឱ្យអ្នកចូលរួមនៅពេលចាប់ផ្តើមការបណ្តុះបណ្តាល ហើយត្រូវលើកឡើងអំពីខ្លឹមសារឯកសារនេះជារឿយៗនៅក្នុងវគ្គបណ្តុះបណ្តាលទាំងមូល។ អ្នកសម្របសម្រួលគួរលើកទឹកចិត្តអ្នកចូលរួមឱ្យប្រើប្រាស់កាតទាំងនេះ ដើម្បីជាឧបករណ៍ពិគ្រោះដ៏មានប្រយោជន៍ នៅពេលពួកគេត្រលប់ទៅផ្ទះ និងទៅកន្លែងធ្វើការវិញ ហើយត្រូវចែករំលែកព័ត៌មានដែលពួកគេបានរៀនសូត្រទៅដល់មិត្តរួមការងារដទៃទៀត។ អ្នកសម្របសម្រួលក៏អាចជ្រើសរើសក្នុងការចែក "លំហាត់មុនចាប់ផ្តើម" ( **ឧបសម្ព័ន្ធទី៤** ) នៅពេលជាមួយគ្នាដែលចែកកាតយកតាមខ្លួននោះដែរ រួចប្រាប់អ្នកចូលរួមឱ្យបំពេញលំហាត់នោះនៅក្នុងចំណុចពេលដែលពាក់ព័ន្ធនៅពេលពិភាក្សា។

# វគ្គទី ១៖ សេចក្តីផ្តើម

## សង្ខេប

វគ្គសិក្សាណែនាំមានគោលបំណងធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍ប្រកបដោយផាសុកភាព ដើម្បីលើកកម្ពស់បទពិសោធន៍នៃការរៀនសូត្ររបស់ពួកគេ។

អ្នកចូលរួមនឹងកាន់តែមានអារម្មណ៍ធូរស្បើយនៅក្នុងបរិស្ថាននៃការរៀនសូត្រថ្មី ប្រសិនបើអ្នកសម្របសម្រួលផ្តល់កិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ណែនាំខ្លួនបុគ្គលិកសំខាន់ៗ ផ្តល់ឱកាសដល់អ្នកចូលរួមឱ្យណែនាំខ្លួនឯង និងបង្ហាញពីរបៀបវារៈណែនាំអំពីប្រធានបទពិភាក្សាតាមបែបសហការ និងបង្កើតច្បាប់និងវិន័យដែលព្រមព្រៀងសម្រាប់វគ្គបណ្តុះបណ្តាលទាំងមូល ។

អ្នកសម្របសម្រួលអាចបារម្ភអំពីភាពងាយរសើបនៃប្រធានបទបណ្តុះបណ្តាល។ ក្តីបារម្ភនេះនឹងត្រូវកាត់បន្ថយប្រសិនបើអ្នកសម្របសម្រួលពន្យល់អំពីខ្លឹមសារ និងគោលបំណងនៃការបណ្តុះបណ្តាល។ ជាពិសេស គឺបង្ហាញឱ្យឃើញច្បាស់ថាការបណ្តុះបណ្តាលនេះពិតជាមានការពាក់ព័ន្ធជាមួយអ្នកចូលរួម។

## លទ្ធផលរំពឹងទុកនៃវគ្គសិក្សា

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមនឹង៖

- យល់អំពីវត្ថុបំណងនៃការបណ្តុះបណ្តាលនិង ព្រមព្រៀងគ្នាគោរពទៅតាមច្បាប់និងវិន័យដែលបង្កើតសម្រាប់វគ្គសិក្សានេះ។
- មានអារម្មណ៍ផាសុកភាព ក្នុងការចូលរួមជាមួយអ្នកចូលរួមដទៃទៀត និងអ្នកសម្របសម្រួលដែលលើកកម្ពស់ដល់កិច្ចពិភាក្សាផុសផុលនៅក្នុងវគ្គបណ្តុះបណ្តាលទាំងមូល។

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
|---|---|---|
| ៣០នាទី( ដោយមិនរាប់បញ្ចូលពិធីបើកវគ្គ និងសកម្មភាពផ្សេងទៀត ) | • សំណួរមុនចូលមេរៀន( មួយច្បាប់សម្រាប់អ្នកចូលរួមម្នាក់ )<br>• របៀបវារៈ ( មួយច្បាប់សម្រាប់អ្នកចូលរួមម្នាក់ )<br>• កាតយកតាមខ្លួន | • ក្រដាសផ្ទាំងធំ<br>• ហ្វឺតសរសេរ<br>• បាល់ទន់ៗ ( អាចមានជម្រើសសម្រាប់វគ្គណែនាំខ្លួន ) |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី១**<br> | | • ស្លាយនេះអាចដាក់បង្ហាញនៅពេលអ្នកចូលរួមចូលក្នុងបន្ទប់យកមកប្រើជំនួសឱ្យការទិញ "បដាសម្រាប់ការប្រជុំ" ដែលផ្តល់ដោយកន្លែងមួយចំនួន។<br>• សូមកែសម្រួលស្លាយឱ្យសមស្របតាមបរិបទមូលដ្ឋានតាមរយៈការបន្ថែមចូលឈ្មោះសហ-អ្នកសម្របសម្រួល និងអង្គការដៃគូ និងស្លាកសញ្ញាអង្គការដៃគូទៅតាមការគួរ។ ប្រសិនបើមានពិធីបើកវគ្គដោយមានសុន្ទរកថាបើកផ្លូវការ អាចបន្ថែមស្លាយដើម្បីឆ្លុះបញ្ចាំងលើចំណុចនេះ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២** ●   | ផ្តល់ការណែនាំសង្ខេបដល់អ្នកចូលរួម៖<br>• ស្វាគមន៍អ្នកចូលរួម<br>• ណែនាំខ្លួនភ្ញៀវសំខាន់ៗ និងវាគ្មិនដែលបានអញ្ជើញមកពីខាងក្រៅដទៃទៀត<br>• ណែនាំខ្លួនឯង<br>• ពន្យល់ប្រាប់ថា សម្ភារៈបណ្តុះបណ្តាលត្រូវបានបង្កើតឡើងដោយអង្គការទស្សនៈពិភពលោក គម្រោងកុមារភាព ផ្នែកបង្ការ ដែលជាការផ្តួចផ្តើមគំនិតមួយរបស់ប្រទេសអូស្ត្រាលី ក្នុងការបង្ការការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ | ចំណាប់អារម្មណ៍ដំបូងមានសារៈសំខាន់ណាស់។ សូមផ្តល់ការណែនាំដំបូងពីការណែនាំដល់អ្នកចូលរួមសម្រាប់ស្លាយទាំងអស់នេះដើម្បីឱ្យពួកគាត់មានអារម្មណ៍ថាមានភាពងាយស្រួលចិត្តជាមួយផែនការបណ្តុះបណ្តាលដែលបានគ្រោងទុក និងមានទំនុកចិត្តលើសមត្ថភាពអ្នកសម្របសម្រួល។ |
| **ស្លាយទី៣**   | *សកម្មភាព៖ សេចក្តីផ្តើម*<br>• វគ្គបណ្តុះបណ្តាលថ្ងៃនេះមានអ្នកចូលរួមដែលមកពីកន្លែងផ្សេងៗក្នុងវិស័យទេសចរណ៍។ ឯកឧត្តម អស់លោក លោកស្រី អ្នកនាង កញ្ញាមួយចំនួនប្រហែលជាស្គាល់គ្នារួចហើយ ប៉ុន្តែមានឯកឧត្តម អស់លោក លោកស្រី អ្នកនាង កញ្ញាខ្លះទៀត ដែលនៅមិនទាន់ធ្លាប់ជួបគ្នានៅឡើយ។ ដើម្បីឱ្យយើងអាចស្គាល់គ្នាទៅវិញទៅមកសូមអ្នកចូលរួមម្នាក់ៗណែនាំខ្លួនឯងដោយសង្ខេប ដោយការឆ្លើយសំណួរបីនេះ៖<br>– តើអ្នកឈ្មោះអ្វី ?<br>– តើអ្នកធ្វើការនៅកន្លែងណា ?<br>– តើអ្នកធ្វើការក្នុងវិស័យទេសចរណ៍អស់រយៈពេលប៉ុន្មានឆ្នាំហើយ ?<br>• នៅចុងបញ្ចប់នៃការណែនាំខ្លួនទាំងអស់៖<br>– សូមលើកឡើងពីប្រភេទអាជីវកម្មដែលខុសៗគ្នាឬប្រហាក់ប្រហែលគ្នាដែលមានវត្តមាន។<br>– សូមផ្តល់ការគោរព លើបទពិសោធន៍នៅក្នុងវិស័យទេសចរណ៍សរុបដែលមានក្នុងបន្ទប់។ | • ដើម្បីធ្វើឱ្យវគ្គនេះកាន់តែមានភាពរស់រវើក យើងអាចចាប់ផ្តើមការណែនាំខ្លួនតាមរយៈការដោះបាល់កៅស៊ូទន់ៗទៅឱ្យអ្នកចូលរួមម្នាក់។ បន្ទាប់ពីអ្នកចូលរួមនោះណែនាំខ្លួនរួចហើយ ពួកគេអាចជ្រើសរើសអ្នកចូលរួមបន្ទាប់ទៀតតាមរយៈការបោះបាល់ទៅឱ្យអ្នកនោះ។ សូមលើកទឹកចិត្តអ្នកចូលរួមឱ្យបោះបាល់ទៅអ្នកដែលពួកគាត់មិនធ្លាប់បានជួបពីមុនមក។<br>• បន្ទាប់ពីបុគ្គលម្នាក់ៗបានណែនាំខ្លួនរួចហើយ សូមសរសេរចំនួនឆ្នាំ និងបទពិសោធន៍ក្នុងវិស័យទេសចរណ៍របស់អ្នកនៅលើក្តារខៀន។ ស្នើសុំឱ្យអ្នកចូលរួមម្នាក់ៗគិតចំនួនឆ្នាំសរុប។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | – ណែនាំដល់អ្នកចូលរួមថា វគ្គបណ្ដុះបណ្ដាលនឹងអាចមានអត្ថប្រយោជន៍កាន់តែច្រើន ប្រសិនបើពួកគាត់ចែករំលែកបទពិសោធន៍ដ៏មានសារៈសំខាន់របស់ពួកគាត់នៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ។ | |
| **ស្លាយទី៤**  | *សកម្មភាព៖ សំណួរមុនចូលមេរៀន*<br>• សូមពន្យល់អំពីសារៈសំខាន់ទៅលើសារប្រយោជន៍ និងប្រសិទ្ធិភាពនៃវគ្គបណ្ដុះបណ្ដាល។<br>• ណែនាំប្រាប់អ្នកចូលរួម ឱ្យជួយសម្រួលដល់ដំណើរការនេះបានតាមរយៈការបំពេញលំហាត់ខ្លីមួយ មុនពេលផ្ដើមមេរៀន និងនៅពេលបញ្ចប់វគ្គបណ្ដុះបណ្ដាល។ សូមផ្ដល់ប្រធានបទលំហាត់ និងផ្ដល់ពេលវេលាដល់អ្នកធ្វើលំហាត់នោះ។<br>• ផ្ដល់លំហាត់ និងផ្ដល់ពេល ៣-៥ នាទី ឱ្យអ្នកចូលរួមបំពេញ។<br>• ស្នើសុំឱ្យអ្នកចូលរួមដែលបានបញ្ចប់មុនគេ ជួយប្រមូលលំហាត់របស់អ្នកដទៃទៀតនៅពេលដែលពួកគាត់ធ្វើរួច។ | *សំណួរមុនចូលមេរៀនអាចរកបាននៅក្នុងឧបសម្ព័ន្ធទី៤*<br>មានពេលវេលាតិចអ្នកសម្របសម្រួលអាចធ្វើសំណួរមុនចូលមេរៀននេះតាមរយៈការឱ្យអ្នកចូលរួមលើកដៃ។ កត់ត្រាចំនួនដៃដែលអ្នកចូលរួមលើកសម្រាប់សំណួរនីមួយៗ។ |
| **ស្លាយទី៥**  | ផ្ដល់ទិដ្ឋភាពទូទៅមួយនៃប្រធានបទសំខាន់ៗដែលយើងនឹងត្រូវសិក្សាដោយយោងទៅតាមស្លាយនៅថ្ងៃនេះ។ ពន្យល់ប្រាប់ថា ព័ត៌មាន និងមេរៀននេះ មិនត្រឹមតែជួយការពារកុមារតែប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចជួយពង្រឹងអាជីវកម្មរបស់ពួកគេ និងឧស្សាហកម្មទេសចរណ៍ទាំងមូលបានផងដែរ។ | សូមយោងលើរបៀបវារៈការ បណ្ដុះបណ្ដាល (មានគំរូនៅក្នុង**ឧបសម្ព័ន្ធទី១**)។<br>សូមយោងទៅលើ **កាតយកតាមខ្លួន** ("**ការការពារកុមារគឺជាតួនាទីរបស់មនុស្សគ្រប់រូប**")<br> |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៦**<br><br> | ពន្យល់អំពីដំណើរនៃការបណ្ដុះបណ្ដាលសម្រាប់ថ្ងៃនេះ៖<br>• ខ្ញុំដឹងថាអ្នកទាំងអស់គ្នាសុទ្ធតែមានការងាររវល់រៀងៗខ្លួន ប៉ុន្តែដោយសារយើងមានពេលតិចសម្រាប់ថ្ងៃនេះ ហេតុនេះសូមបិទសម្លេងទូរស័ព្ទ ហើយសូមចេញទៅខាងក្រៅនិយាយ ប្រសិនបើអ្នកត្រូវលើកទូរស័ព្ទសម្រាប់ករណីបន្ទាន់ណាមួយ។<br>• សូមអ្នកទាំងអស់គ្នាចូលរៀន និងត្រលប់ពីសម្រាកវិញឱ្យទាន់ពេលវេលា ដើម្បីឱ្យយើងអាចបញ្ចប់ការបណ្ដុះបណ្ដាលរបស់យើងតាមពេលកំណត់។<br>• អ្នកចូលរួមគួរចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលតាំងពីដើមដល់ចប់ (ជាការប្ដេជ្ញាចិត្តដើម្បីកុមារ) ហើយវិញ្ញាបនប័ត្រនឹងត្រូវផ្ដល់ជូនតែចំពោះអ្នកដែលបានចូលរួមពេញលេញតែប៉ុណ្ណោះ។<br>• សូមផ្ដល់តម្លៃចំពោះការចូលរួមរបស់អ្នកទាំងអស់គ្នា លើប្រធានបទនេះ។ សូមផ្ដល់ការគោរពចំពោះអ្នកដទៃពេលគេនិយាយ។<br>• ប្រសិនបើអ្នកមិនយល់អ្វីម្យ៉ាង សូមលើកឡើង ហើយកុំមានអារម្មណ៍ខ្មាសអៀន។ ប្រហែលជាអាចមានមនុស្សមួយចំនួនទៀតមិនយល់ដូចយើង ឬបើអ្នកគិតថាជួបខ្ញុំស្រួលជាងការនិយាយនៅក្នុងចំណោម សូមជួបខ្ញុំពេលក្រោយចប់ម៉ោង។<br>• ប្រសិនបើអ្នកបារម្ភថា មានកុមារណាម្នាក់កំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ សូមប្រាប់ឱ្យខ្ញុំបានដឹងនៅក្រោយពេលចប់ម៉ោងរៀន នោះយើងនឹងអាចធ្វើសកម្មភាពដើម្បីការពារកុមារនោះ។<br>• មិនត្រូវចែកចាយបទពិសោធន៍របស់អ្នកដទៃដែលមានលក្ខណៈងាយរសើបទៅខាងក្រៅថ្នាក់រៀនឡើយ។ | |

## វគ្គទី២៖ តើ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ពាក់ព័ន្ធនឹងខ្ញុំដូចម្តេចខ្លះ ?

### សង្ខេប

*វគ្គនេះ ណែនាំពីគោលការណ៍នៃសិទ្ធិកុមារ ជាពិសេសសិទ្ធិរបស់កុមារា និងកុមារី ក្នុងការទទួលបានការការពារពីការរំលោភបំពាន និងពន្យល់ថាមនុស្សពេញវ័យទាំងអស់ (រួមទាំងភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍) គឺមានតួនាទីយ៉ាងសំខាន់ក្នុងការការពារកុមារា និងកុមារី។*

### លទ្ធផលរំពឹងទុកនៃវគ្គសិក្សា

នៅពេលបញ្ចប់វគ្គនេះ អ្នកចូលរួមនឹងអាច៖

- យល់ច្បាស់ថា មានការរំលោភបំពានលើកុមារជាច្រើនទម្រង់ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។
- ទទួលស្គាល់កាន់តែខ្លាំងនូវផលប៉ះពាល់នៃការរំលោភបំពាន ដែលមានមកលើកុមារ និងសហគមន៍។
- ពិចារណាថា តើវគ្គបណ្តុះបណ្តាលនេះពាក់ព័ន្ធដូចម្តេចខ្លះចំពោះតួនាទីរបស់ពួកគេក្នុងវិស័យទេសចរណ៍។
- យល់ច្បាស់អំពីការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងការទទួលខុសត្រូវក្នុងការងាររបស់ខ្លួន ដើម្បីការពារកុមារ។
- ចាប់ផ្តើមមានអារម្មណ៍ទទួលខុសត្រូវក្នុងការជួយរក្សាសុវត្ថិភាពកុមារ។

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
| --- | --- | --- |
| ៤៥ នាទី | • កាតយកតាមខ្លួន | • ក្រដាសផ្ទាំងធំ<br>• ហ្វឺតសរសេរ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៧**<br> | លោក លោកស្រីមួយចំនួនប្រហែលជាអាចមើលឃើញទំនាក់ទំនងដោយផ្ទាល់រវាងការការពារកុមារក្នុងវិស័យទេសចរណ៍ ដោយយោងទៅតាមការងាររបស់លោកអ្នក។ ប៉ុន្តែ លោក លោកស្រីមួយចំនួនទៀតប្រហែលជាឆ្ងល់ថា តើការងារនេះពាក់ព័ន្ធនឹងការងាររបស់លោកអ្នករបៀបណា ? | |
| **ស្លាយទី៨**<br> | *សកម្មភាព (ទាក់ទងទៅនឹងកុមារ)*<br>• សុំឱ្យអ្នកចូលរួមងើបឈរឡើង ប្រសិនបើពួកគេមានកូន។<br>• នៅពេលពួកគេកំពុងឈរនៅឡើយ សូមសួរអ្នកចូលរួមផ្សេងទៀត ដែលអង្គុយថា តើពួកគេមានប្អូនស្រី ប្អូនប្រុស ក្មួយស្រី ឬក្មួយប្រុសដែលមានអាយុក្រោម១៨ឆ្នាំដែរឬទេ។ បើសិនជានៅមានអ្នកមិនទាន់ក្រោកឈរទៀត សូមសួរថា តើអ្នកនៅជិតខាងផ្ទះ មានកុមារឬទេ ? និងចុងក្រោយសួរថាតើពួកគេធ្លាប់ជាកុមារឬទេ ? | នេះជាសកម្មភាពរហ័សមួយ ដែលត្រូវបានរៀបចំឡើងដើម្បីជួយឱ្យអ្នកចូលរួមមានចលនា និងមានថាមពល ដើម្បីជួយពួកគេឲ្យយល់អំពីប្រធានបទវគ្គសិក្សា។ |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr><td></td><td>
• ទីបំផុត ទាំងអស់គ្នាប្រាកដជាក្រោកឈរ។<br>
• ពួកយើងភាគច្រើនដែលមិនទាន់មានកូនក៏នៅមានសាច់ញាតិជាកុមារ។ ពួកយើងទាំងអស់ក៏ធ្លាប់ជាកុមារ ហេតុនេះយើងសុទ្ធតែដឹងពីបទពិសោធន៍របស់យើងពីស្ថានភាពរបស់កុមារ។
</td><td></td></tr>
<tr><td></td><td>
? *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖*<br>
• ផ្អែកលើមូលដ្ឋាននេះ តើហេតុអ្វីបានជាយើងត្រូវការការពារកុមារ ? បើពេលវេលាអនុញ្ញាតិ អ្នកសម្របសម្រួលអាចបង្កើតឲ្យមានក្រុមពិភាក្សាធំ ដើម្បីបំផុសគំនិតនិងរកចម្លើយទៅនឹងសំណួរនេះ។<br>
• ជំរុញអ្នកចូលរួមឱ្យឈានទៅពិនិត្យមើលការទទួលខុសត្រូវផ្នែកច្បាប់ និងផ្នែកសីលធម៌របស់ខ្លួនចំពោះកុមារ។<br>
• មនុស្សពេញវ័យទាំងអស់មានទំនួលខុសត្រូវក្នុងការការពារកុមារ។<br>
• កុមារមិនគួរទទួលខុសត្រូវក្នុងការការពារខ្លួនឯងនោះទេ។<br>
• ក្នុងនាមជាពលរដ្ឋប្រកបដោយការទទួលខុសត្រូវ (ឪពុកម្ដាយ អ្នកជិតខាង សមាជិកសហគមន៍) និងអ្នកតំណាងវិស័យទេសចរណ៍( បុគ្គលិកជួរមុខ អ្នកគ្រប់គ្រង ម្ចាស់ហាង មន្ត្រីរដ្ឋាភិបាល) យើងមានតួនាទីលើកកម្ពស់ការការពារសិទ្ធិកុមារ។
</td><td></td></tr>
<tr><td>
**ស្លាយទី៩** ●<br>


</td><td>
**តើសិទ្ធិកុមារជាអ្វី ?**<br>
• បន្ថែមទៅលើសិទ្ធិមនុស្ស ដែលមនុស្សគ្រប់គ្នាទទួលបាន កុមារក៏មានសិទ្ធិជាក់លាក់របស់ខ្លួនដែលឆ្លើយតបទៅនឹងសេចក្ដីត្រូវការជាក់លាក់របស់ពួកគេផងដែរ។<br>
• *អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ* គឺជាឯកសារផ្លូវច្បាប់អន្តរជាតិមួយដែលចែងថាកុមារគ្រប់រូបមានសិទ្ធិ។
</td><td></td></tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ប្រទេសកម្ពុជាគឺជាហត្ថលេខីមួយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ នេះមានន័យថារដ្ឋាភិបាលបានយល់ព្រមលើកកម្ពស់សិទ្ធិទាំងអស់នេះ។<br>• សិទ្ធិកុមារគឺជាសិទ្ធិរបស់កុមារគ្រប់រូប រួមទាំងកុមារចំណាកស្រុកនៅក្នុងប្រទេស កុមារជនជាតិភាគតិច កុមារី និងកុមារាក៏ដូចជាកុមារដែលមានពិការភាពផងដែរ។ កុមារគ្រប់រូប នៅគ្រប់ទីកន្លែង។<br>• សិទ្ធិកុមារអាច ចែកជាបួនក្រុមធំៗ រួមមាន៖<br>– សិទ្ធិរស់រានមានជីវិត ( ឧ.តម្រូវការជាមូលដ្ឋានដូចជាអាហារ ជម្រក ស្តង់ដាររស់នៅគ្រប់គ្រាន់ និងលទ្ធភាពទទួលបានសេវាវេជ្ជសាស្ត្រ )។<br>– សិទ្ធិទទួលការការពារ( ឧ.ការការពារពីគ្រប់ទម្រង់ទាំងអស់នៃការរំលោភបំពាន )។<br>– សិទ្ធិក្នុងការអភិវឌ្ឍន៍( ឧ. សិទ្ធិទទួលបានការអប់រំ លេងកំសាន្ត សម្រាកលំហែ ឬលទ្ធភាពទទួលបានព័ត៌មាន។ល។ )<br>– សិទ្ធិចូលរួម ( ឧ.សេរីភាពក្នុងការបញ្ចេញមតិយោបល់ សិទ្ធិក្នុងការនិយាយចេញពីបញ្ហាទាំងឡាយណាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។ល។ )<br>• ថ្ងៃនេះ យើងផ្តោតការយកចិត្តទុកដាក់លើសិទ្ធិទទួលការការពាររបស់កុមារ ប៉ុន្តែពេលយើងបន្តពិភាក្សាទៅមុខ យើងនឹងឃើញថា សិទ្ធិកុមារទាំងអស់នេះ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមកមិនអាចកាត់ផ្តាច់គ្នាបាន។ | |
| **ស្លាយទី១០ •**<br> | **តើច្បាប់ជាតិដែលពាក់ព័ន្ធមានអ្វីខ្លះ ?**<br>• សិទ្ធិកុមារត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់នានានៅក្នុងពិភពលោក។<br>• ប្រទេសកម្ពុជាយើងមានច្បាប់យ៉ាងតឹងរ៉ឹងដើម្បីការពារកុមារពីការរំលោភបំពាន។<br>• អ្នកសម្របសម្រួលគួរតែផ្តល់សេចក្តីសង្ខេបខ្លីមួយពីក្របខណ្ឌផ្នែកច្បាប់។ | អ្នកសម្របសម្រួលគួរស្រាវជ្រាវព័ត៌មានខាងក្រោមក្នុងពេលបង្រៀន។<br>• រដ្ឋធម្មនុញ្ញ១៩៩៣<br>• ក្រមព្រហ្មទណ្ឌ២០០៩<br>• នីតិវិធីព្រហ្មទណ្ឌ២០០៧<br>• នីតិវិធីរដ្ឋប្បវេណី២០០៦<br>• ក្រមរដ្ឋប្បវេណី២០០៨ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | – តើច្បាប់អ្វីខ្លះនៅក្នុងប្រទេសនេះ ?<br>– តើច្បាប់ការពារកុមារសំខាន់ៗនិងច្បាប់ព្រហ្មទណ្ឌសំខាន់ៗអ្វីខ្លះ ដែលពាក់ព័ន្ធនឹងការរំលោភបំពានលើកុមារ ?<br>– តើមានការដាក់ទណ្ឌកម្មអ្វីខ្លះចំពោះការរំលោភបំពានលើកុមារនៅក្នុងប្រទេសនេះ ?<br>• តើមានឧទាហរណ៍អ្វីខ្លះ អំពីរបៀបអនុវត្តច្បាប់ទាំងនេះនៅក្នុងប្រទេសនេះឬទេ ? | • ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ២០០៨<br>• ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ២០០៥<br>• ច្បាប់ស្តីពីការងារ១៩៩៧<br>• ច្បាប់ស្តីពីការរំលូតកូន ១៩៩៧<br>• ច្បាប់ស្តីពីសញ្ជាតិ១៩៩៦<br>• ច្បាប់ស្តីពីទេសចរណ៍២០០៩ |
| **ស្លាយទី១១** •<br> | **តើគោលការណ៍ "ឧត្តមប្រយោជន" គឺជាអ្វី ?**<br>• មានគោលការណ៍ជាមូលដ្ឋានមួយក្នុងច្បាប់អន្តរជាតិ ដែលតម្រូវឱ្យរាល់ការសម្រេចចិត្ត និងសកម្មភាពទាំងអស់ ដែលត្រូវធ្វើឡើងទាក់ទងនឹងកុមារគួរតែជាការសម្រេចចិត្តនិងសកម្មភាពដែលបម្រើឲ្យ "ឧត្តមប្រយោជន៍" របស់កុមារ។<br>• ឧទាហរណ៍ដូចជា នៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌ ប៉ូលីសត្រូវសម្រេចចិត្តរវាងការប្រមូលភស្តុតាងបន្ថែម ( កុមារត្រូវបានរំលោភបំពាន ) ឬត្រូវបញ្ឈប់ការរំលោភបំពានភ្លាមៗ។ ក្នុងករណីនេះ បើផ្អែកលើ "ប្រយោជន៍ប្រសើរបំផុត" ប៉ូលីសនឹងត្រូវជ្រើសរើសការបញ្ឈប់ការរំលោភបំពានជាបន្ទាន់ ជាជាងការចាំប្រមូលភ័ស្តុតាងដែលអាចប្រមូលតាមក្រោយបាន។<br>• យើងនឹងត្រលប់មកមើលគោលការណ៍នេះម្តងទៀត នៅពេលយើងពិចារណាលើសកម្មភាពទេសចរណ៍ ដែលនឹងផ្តល់ការពិចារណាលម្អិតបន្ថែមទៀតទៅលើផលប្រយោជន៍អ្នកទេសចរណ៍ដែលខ្ពស់ជាងប្រយោជន៍កុមារ។ | *អ្នកសម្របសម្រួលគួរស្រាវជ្រាវព័ត៌មានអំពីគោលការណ៍ដែលជា ឧត្តមប្រយោជន៍ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ជាតិជាចម្បងក្នុងវគ្គបណ្តុះបណ្តាល។*<br>• ប្រកាសលេខ៨៥៧ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរ មនុស្សៈ ក្នុងនោះមាន ៥ជំពូក និង ១៦ប្រការ។ |
| **ស្លាយទី១២** •<br> | **តើ "ការការពារកុមារ" ជាអ្វី ?**<br>• ការការពារកុមារ គឺទាក់ទងនឹងការបង្ការនិងការឆ្លើយតបចំពោះអំពើហិង្សាគ្រប់ទម្រង់ទាំងអស់ប្រឆាំងកុមារ រួមទាំងការរំលោភបំពានផងដែរ។ | |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr>
<td>

**ស្លាយទី១៣●**




</td>
<td>

**តើ "ការរំលោភបំពានកុមារ" ជាអ្វី?**

- ការរំលោភបំពានកុមារ គឺជាសកម្មភាព (ឬការមិនធ្វើសកម្មភាព) ទាំងឡាយណាដែលពុំមែនជារឿងចៃដន្យហើយដែលបង្កការឈឺចាប់ដល់កុមារ ឬដាក់កុមារឱ្យស្ថិតក្នុងគ្រោះថ្នាក់។
- ការរំលោភបំពានកុមារ អាចបង្កឱ្យមានជាគ្រោះថ្នាក់ជាក់ស្តែង ឬគ្រោះថ្នាក់ដែលអាចកើតឡើង ដល់សុខភាព ការរស់រានមានជីវិត ការអភិវឌ្ឍន៍ និង/ឬសេចក្តីថ្លៃថ្នូររបស់កុមារ។
- ការរំលោភបំពានកុមារមានបួនទម្រង់ធំៗ ហើយជារឿយៗ តែងតែកើតឡើងដំណាលគ្នានឹងការរំលោភបំពានផ្សេងទៀត។

*ការរំលោភបំពានផ្លូវកាយ*

- ការរំលោភបំពានផ្លូវកាយ គឺកើតមាននៅពេលណាមនុស្សម្នាក់បង្ករបួស ឬគម្រាមថា នឹងបង្ករបួសដល់កុមារណាម្នាក់ដោយចេតនា។
- ការរំលោភបំពាននេះរួមមានដូចជា ការវាយដំ ដាល់ អង្រន់ ធាក់ ដុត ច្រាន ធ្វើឱ្យថប់ដង្ហើម សង្កត់/ចង បំពុល ឬកំហិតលើបម្លាស់ទីរបស់កុមារ។

*ការរំលោភបំពានផ្លូវចិត្ត*

- ការរំលោភបំពានផ្លូវចិត្តគឺជាការប្រព្រឹត្តអាក្រក់ផ្នែកអារម្មណ៍ដែលបន្តអស់រយៈពេលយូរ និងធ្ងន់ធ្ងរ។
- ការរំលោភបំពានផ្លូវចិត្តវាយប្រហារដល់ការយល់ឃើញចំពោះខ្លួនឯងរបស់កុមារ។
- ការរំលោភបំពាននេះអាចលេចឡើងក្នុងទម្រង់ជាការជេរកុមារដោយពាក្យថោកទាប ឬធ្វើឱ្យឈឺចាប់ គំរាម ចំអក បំភិតបំភ័យ ឬបំបែកកុមារឱ្យនៅតែឯង។
- រាល់ទម្រង់នៃការរំលោភបំពានលើកុមារសុទ្ធតែមានផលប៉ះពាល់ផ្នែកអារម្មណ៍។

</td>
<td>

សូមយោងទៅលើ **កាតយកតាមខ្លួន** (**"តើអ្វីជាការរំលោភបំពានកុមារ?"**)




</td>
</tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | *ការមិនអើពើ*<br>• ការមិនអើពើ គឺជាការខកខានធ្ងន់ធ្ងរក្នុងការផ្តល់ឱ្យកុមារនូវទិដ្ឋភាពសំខាន់ៗនៃការថែទាំ។<br>• ឧទាហរណ៍៖ ការមិនការពារកុមារពីការប៉ះពាល់ជាមួយគ្រោះថ្នាក់ ឬមិនផ្តល់ការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ ឬមិនផ្តល់ឱ្យកុមារនូវតម្រូវការជាមូលដ្ឋាន (ដូចជាអាហារ ជម្រក ឬការមិនយកចិត្តទុកដាក់ផ្នែកអារម្មណ៍)។<br>*ការរំលោភបំពានផ្លូវភេទ*<br>• ការរំលោភបំពានផ្លូវភេទកើតឡើងនៅពេលដែលមាននរណាម្នាក់ឱ្យកុមារចូលរួមនៅក្នុងសកម្មភាពផ្លូវភេទតាមរយៈការប្រើប្រាស់អំណាចរបស់ខ្លួនទៅលើកុមារ ឬការទាញប្រយោជន៍ពីការទុកចិត្តរបស់កុមារ។<br>• ការរំលោភបំពានផ្លូវភេទកុមារ រួមមានអាកប្បកិរិយាផ្លូវភេទដែលមិនចង់បានគ្រប់ទម្រង់។ ទង្វើនេះអាចរួមមានទាំងការប៉ះពាល់ ឬការមិនប៉ះពាល់ទាល់តែសោះ។<br>• ការរំលោភបំពានផ្លូវភេទកុមាររួមមាន៖<br>  – ការប៉ះពាល់ ការបង្កើតរូបភាព/រូបថត/វីដេអូអំពីកុមារដែលមានលក្ខណៈរំលោភបំពាន<br>  – ការបង្ខំកុមារឱ្យមើល ឬចូលរួមក្នុងសកម្មភាពផ្លូវភេទ ឬ<br>  – ការបង្ខំកុមារឱ្យរួមភេទ ឬចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយកុមារដទៃ ឬជាមួយមនុស្សពេញវ័យ។<br>ជាការសំខាន់ណាស់ដែលត្រូវដឹងថា ការរំលោភបំពានទាំងបួនប្រភេទនេះ ជារឿយៗ តែងមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយពុំកើតមានដាច់តែឯងនោះឡើយ។ ឧទាហរណ៍៖ កុមារម្នាក់ដែលរងនូវការរំលោភបំពានផ្លូវចិត្ត ជារឿយៗ ក៏តែងរងនូវការមិនយកចិត្តទុកដាក់ផងដែរ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី១៤ ●**<br><br> | **តើការរំលោភបំពានកុមារមានអត្រារីករាលដាលកម្រិតណា ?**<br>• ពុំមានស្ថិតិជាក់ច្បាស់ណាមួយស្តីពីចំនួនកុមារដែលរងការរំលោភបំពាននោះឡើយ។<br>• យើងពិបាកដឹងចំនួនបាន ពីព្រោះមនុស្សភាគច្រើនពុំរាយការណ៍ពីករណីរំលោភបំពានឡើយ ហើយជារឿយៗ ពុំមានការរាប់ករណីនោះឡើយ។<br>• ប៉ុន្តែ គេបានប៉ាន់ប្រមាណថា តួលេខកុមាររងការរំលោភបំពាន គឺមានរាប់លាននាក់។<br>• កុមារទាំងនេះ គឺមាននៅគ្រប់ស្រទាប់សេដ្ឋកិច្ចសង្គម  គ្រប់អាយុ សាសនា និងវប្បធម៌ទាំងអស់។<br>• ការរំលោភបំពានកុមារ មិនមែនកើតមានតែនៅក្នុងតំបន់នេះតែមួយ ឡើយ។ បញ្ហាទាំងនេះ កើតមាននៅគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក។<br>• កុមារអាចនឹងទទួលរងនូវការរំលោភបំពានជាច្រើនទម្រង់ ជាប្រចាំ ជាជាងជាករណីការរំលោភបំពានដាច់តែឯង។ ឧទាហរណ៍ កុមារម្នាក់អាចរងការមិនយកចិត្តទុកដាក់ពីឪពុកម្តាយ រួចហើយរត់ចេញទៅរស់នៅតាមចិញ្ចើមថ្នល់ ហើយក្លាយជាជនរងគ្រោះពីការធ្វើបាបផ្លូវកាយនិងរងនូវការរំលោភបំពានផ្លូវចិត្ត។ | ការពិនិត្យឡើងវិញ នៅឆ្នាំ២០១២ ដោយអង្គការយូនីសេហ្វអាស៊ីអាគ្នេយ៍ បានរកឃើញថា:<br>• ប្រេវ៉ាឡង់នៃការ រំលោភលើរាងកាយកុមារកម្រិតធ្ងន់ធ្ងរ មានពី៩% ទៅដល់ជិត ២៥% នៅក្នុងតំបន់។<br>• ចន្លោះពី ១៤% ទៅ ៣០% ទាំងកុមារា និងកុមារីត្រូវបានរាយការណ៍ថា មានបទពិសោធន៍នៃការរំលោភបំពានផ្លូវភេទនៅក្នុងឆាកជីវិតរបស់ពួកគេ។<br>• មនុស្សជំទង់ និងមនុស្សពេញវ័យដែលធ្លាប់មានបទពិសោធន៍រងការរំលោភបំពានផ្លូវភេទ និង/ឬ ការរំលោភបំពានផ្លូវកាយកាលពីពួកគេនៅជាកុមារ មានអត្រានៃការដែលបានគិត ឬប៉ុនប៉ងធ្វើអត្តឃាតបួនដងច្រើនជាងអ្នកដែលគ្មានប្រវត្តិនៃការរំលោភបំពាន។<br>(UNICEF, ការធ្វើបាបកុមារ៖ ប្រេវ៉ាឡង់ការកើតមានថ្មី និងផលវិបាកក្នុងតំបន់ប៉ាស៊ីហ្វិច និងអាស៊ីអាគ្នេយ៍ ២០១២)<br>នៅក្នុងប្រទេស ការសិក្សាថ្មីៗបង្ហាញថា៖ |
| **ស្លាយទី១៥ ●**<br><br> | **តើការរំលោភបំពានកុមារមានផលប៉ះពាល់អ្វីខ្លះ ?**<br>• ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការរំលោភបំពានមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះកុមារ។<br>• កុមាររងនូវការប៉ះទង្គិចផ្នែកផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងររយៈពេលវែង ហើយបង្កឱ្យផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាព។<br>• កុមារមិនអាចសម្រេចនូវសក្តានុពលនៃការអភិវឌ្ឍន៍របស់ខ្លួនបានទាំងស្រុង។ ចំណុចនេះធ្វើឱ្យប៉ះពាល់ដល់គ្រួសារ និង សហគមន៍របស់ពួកគេ ពេលគេធំឡើងក្លាយជាមនុស្សពេញវ័យ។ ពួកគេអាចនឹងរងគ្រោះដោយបញ្ហាផ្នែកផ្លូវចិត្ត និងផ្លូវស្មារតីរយៈពេលវែង ដែលបង្កជាបញ្ហាសង្គមនៅក្នុងសហគមន៍របស់ពួកគេ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី១៦** ●<br><br> | **តើការរំលោភបំពានកុមារ មានផលប៉ះពាល់អ្វីខ្លះដល់វិស័យទេសចរណ៍ ?**<br>• ផលប៉ះពាល់នៃការរំលោភបំពាន កើតមានមិនត្រឹមតែចំពោះជនរងគ្រោះផ្ទាល់នោះទេ តែវាប៉ះពាល់ដល់គ្រួសារ សហគមន៍ និងវិស័យទេសចរណ៍ទាំងមូល។<br>• សហគមន៍មូលដ្ឋាន បដិសេធមិនឱ្យមានទេសចរណ៍។<br>• វិស័យទេសចរណ៍បាត់បង់អាជីវកម្មទទួលបានកេរ្តិ៍ឈ្មោះអាក្រក់ បាត់បង់ការងារ។<br>• ការស្រាវជ្រាវបានបង្ហាញថា ទេសចរដែលធ្វើដំណើរទៅកាន់តំបន់អាស៊ីអាគ្នេយ៍ រងផលប៉ះពាល់ពីជំនួបរបស់ពួកគេជាមួយកុមារងាយរងគ្រោះ។ ម្យ៉ាងទៀត ការទាក់ទងនៃការរំលោភបំពានកុមារក្នុងវិស័យទេសចរណ៍ បង្កើតឱ្យមានកេរ្តិ៍ឈ្មោះអាក្រក់សម្រាប់ទីកន្លែងទេសចរណ៍នោះ។ | អ្នកសម្របសម្រួលអាចយោងទៅលើរបាយការណ៍របស់អង្គការទស្សនៈពិភពលោក ដែលមានចំណងជើងថា The Child Safe Traveller ឆ្នាំ២០១៣ ដែលបានស្ទង់មតិលើអ្នកទេសចរណ៍ជិត ៣០០នាក់ដែលធ្វើដំណើរមកកាន់តំបន់នេះ ស្តីពីទស្សនៈយល់ឃើញរបស់ពួកគេចំពោះការរំលោភបំពានកុមារ។ ដ្យាក្រាមព័ត៌មាន ដែលសង្ខេបការរកឃើញរបស់របាយការណ៍នេះ គឺមាននៅក្នុង **កាតយកតាមខ្លួន (អ្នកធ្វើដំណើរដែលមានសុវត្ថិភាពសម្រាប់កុមារ)**។<br><br> |
| **ស្លាយទី១៧** ●<br> | • យើងដឹងថា ទីកន្លែងទេសចរណ៍ ទាក់ទាញកុមារងាយរងគ្រោះ និងគ្រួសារដែលកំពុងស្វែងរកចំណូល។<br>• កុមារនៅតាមទីកន្លែងទេសចរណ៍ អាចនឹងរងគ្រោះជាពិសេសចំពោះការរំលោភបំពាន។<br>• ពុំមានបុគ្គល ឬទីភ្នាក់ងារណាអាចការពារកុមារបានតែម្នាក់ឯងនោះឡើយ។ | |
| **ស្លាយទី១៨** ●<br><br> | • យើងទាំងអស់គ្នាសុទ្ធតែមានតួនាទីក្នុងការការពារកុមារ ហើយពួកយើងជាច្រើនសុទ្ធតែមានតួនាទីលើសពីមួយ។<br>• ក្នុងនាមជាឪពុកម្តាយ អ្នកជិតខាង បុគ្គលិកទេសចរណ៍ គ្រូបង្រៀន អង្គការក្រៅរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាលយើងមានការទទួលខុសត្រូវផ្សេងៗគ្នាក្នុងការការពារកុមារ។<br>• សូមយោងទៅលើដ្យាក្រាមនៅលើស្លាយ និងសុំឱ្យអ្នកចូលរួមគិតឆ្លុះបញ្ចាំងថា តើពួកគេស្ថិតនៅកន្លែងណានៃរូបភាពនេះ។ អ្នកចូលរួមអាចនឹងស្ថិតនៅលើចំណុចជាច្រើន។ | សូមយោងទៅលើ **កាតយកតាមខ្លួន ("ការការពារកុមារ គឺជាការងាររបស់មនុស្សគ្រប់រូប")**<br><br> |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • មានការទទួលខុសត្រូវផ្សេងៗគ្នាជាច្រើនក្រោមកម្រិតនីមួយៗនៃប្រព័ន្ធកិច្ចការពារកុមារ។<br>• ថ្ងៃនេះយើងនឹងពិភាក្សាគ្នាពីអ្វីដែលអ្នកអាចធ្វើបានក្នុងនាមជាពលរដ្ឋ ដែលមានទំនួលខុសត្រូវ និងនៅក្នុងឧស្សាហកម្មទេសចរណ៍ក្នុងស្រុក និងទូទាំងសកលលោក ដើម្បីលើកកម្ពស់សិទ្ធិកុមារ គោរពតាមច្បាប់ និងកសាងបរិស្ថានប្រកបដោយកិច្ចការពារមួយសម្រាប់កុមារ។<br>• តាមរយៈការការពារសិទ្ធិកុមារអ្នកក៏អាចរួមចំណែកជួយលើកកម្ពស់វិស័យឧស្សាហកម្មទេសចរណ៍ឱ្យកាន់តែប្រសើរ និងមាននិរន្តភាពកាន់តែខ្ពស់។ ទង្វើនេះហុចជាអត្ថប្រយោជន៍ជាច្រើន សម្រាប់យើងទាំងអស់គ្នា ដូចជាមានឱកាសការងារច្រើនរក្សាសុវត្ថិភាពចំណូល ហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរ។ល។ | |
| **ស្លាយទី១៩**<br><br> | *សកម្មភាព៖ តើអ្នកមានទំនាក់ទំនងជាមួយកុមារដោយរបៀបណា ?*<br>• សុំឱ្យអ្នកចូលរួមគិតពីកន្លែងធ្វើការរបស់ពួកគេ និងសរសេរចេញមកនូវបញ្ជីមួយស្តីពីវិធី ឬឱកាសផ្សេងៗ ដែលពួកគេ អាជីវកម្ម និងបុគ្គលិករបស់ពួកគេមានទំនាក់ទំនងជាមួយកុមារ រួមទាំងក្តីបារម្ភដែលគេមាន។<br>• សុំអ្នកចូលរួមឱ្យចែករំលែកចម្លើយរបស់ខ្លួន។ សរសេរចម្លើយនៅលើក្តាខៀន ឬក្រដាសផ្ទាំងធំ និងព្យាយាមចាត់ចំណាត់ថ្នាក់ថាតើទំនាក់ទំនងនោះជាប្រភេទទំនាក់ទំនងដោយផ្ទាល់/ដោយប្រយោលនៅតាមផ្លូវ ឬតាមរយៈអតិថិជនរបស់ពួកគេ។ល។<br>• គូសបញ្ជាក់នូវភាពជាប់ពាក់ព័ន្ធនៃបញ្ហា និងសមត្ថភាពរបស់វិស័យទេសចរណ៍ក្នុងការធ្វើឱ្យឥទ្ធិពលសមស្របទៅលើជីវិតរបស់កុមារ និងលើបរិស្ថាននេះ។ | ប្រសិនបើអ្នកចូលរួមត្រូវការសំណួរបំផុសគំនិតបន្ថែម សូមលើកពីឱកាសនានា ដែលពួកគេអាចជួប និង មានទំនាក់ទំនងជាមួយកុមារដូចជា៖<br>• ចុះបញ្ជីនៅពេលគ្រួសារមានកូនចូលមកស្នាក់នៅក្នុងផ្ទះសំណាក់ឬសណ្ឋាគារ។<br>• ជួបជាមួយកុមារនៅតាមផ្ទះដែលភ្ញៀវទេសចរទៅស្នាក់នៅជាមួយប្រជាជនក្នុងសហគមន៍។<br>• ជួបកុមារដែលលក់វត្ថុអនុ-ស្សាវរីយ៍ និងអាហារដល់ ភ្ញៀវទេសចរ នៅតាមទីតាំងទេសចរណ៍ល្បីៗនិង ភោជនីយដ្ឋាននៅពេលអ្នកកំពុងរង់ចាំដឹកជញ្ជូនអ្នកទេសចរតាមរថយន្តតាក់ស៊ី ឬម៉ូតូកង់ម៉ូតូ។<br>• ការផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរពីឱកាសធ្វើការស្ម័គ្រចិត្តជាមួយកុមារនៅក្នុងទីតាំងរបស់អ្នក។<br>• ដឹកជញ្ជូនអ្នកដំណើរទៅមើលការសម្តែងរបស់កុមារ នៅ "មណ្ឌលកុមារកំព្រា"<br>• រៀបចំដំណើរទេសចរណ៍របស់ "មណ្ឌលកុមារកំព្រា" |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | | • ស្ថានភាពដែលគេមានអារម្មណ៍មិនស្រួលក្នុងចិត្តជាមួយភាពងាយរងគ្រោះរបស់កុមារក្នុងមូលដ្ឋាន ប៉ុន្តែមិនដឹងប្រាកដថាត្រូវធ្វើដូចម្តេច (អារម្មណ៍ទាំងនេះ អាចលេចឡើងនៅក្នុងឧទាហរណ៍ណាមួយក្នុងចំណោមឧទាហរណ៍ខាងលើ។ |

## វគ្គទី៣ ៖ តើវិស័យទេសចរណ៍មានគ្រោះថ្នាក់អ្វីខ្លះចំពោះកុមារ ?

### សង្ខេប

*វគ្គនេះជួយអ្នកចូលរួមស្វែងយល់អំពីផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃវិស័យទេសចរណ៍ រួមទាំងទំនាក់ទំនងរវាងភាពងាយរងគ្រោះរបស់កុមារជាមួយនឹងវិស័យទេសចរណ៍។*

### លទ្ធផលរំពឹងទុកនៃវគ្គសិក្សា

នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងមានសមត្ថភាពអាចៈ

- ដឹងថាការលូតលាស់នៃវិស័យទេសចរណ៍មានលទ្ធផលវិជ្ជមាន និងអវិជ្ជមានដែលអាចជះឥទ្ធិពលលើកុមារ។
- ទទួលស្គាល់ និងស្វែងយល់អំពីចំណុចប្រសព្វរវាងទេសចរណ៍ និងភាពងាយរងគ្រោះរបស់កុមារទូទៅ។
- ចែកឱ្យដាច់ពីវិធីដែលវិស័យទេសចរណ៍ និងការធ្វើដំណើរ អាចជួយជម្រុញដល់ការរំលោភបំពានកុមារ ជាពិសេសគឺការរំលោភបំពានផ្លូវភេទ។
- ទទួលស្គាល់ថាការរំលោភបំពានកុមារកើតមាននៅទូទាំងសកលលោក និងក្នុងតំបន់
- អាចកំណត់បានពីធម្មជាតិនៃបញ្ហា

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
|---|---|---|
| ៨០នាទី | • កាតយកតាមខ្លួន | • ក្រដាសផ្ទាំងធំ<br>• ហ្វឺតសរសេរ<br>• រង្វាន់សម្រាប់លំហាត់ ដូចជាស្ករគ្រាប់ ប៊ិច។ល។ (តាមជម្រើស) |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២០**<br><br> | • វិស័យទេសចរណ៍ជាឧស្សាហកម្មមួយដែលរីកលូតលាស់លឿនជាងគេបំផុតក្នុងពិភពលោក។<br>• អង្គការសហប្រជាជាតិទទួលបន្ទុកទេសចរណ៍ពិភពលោក បានព្យាករថា ទ្វីបអាស៊ីនឹងមានការលូតលាស់ខ្លាំងក្លាជាងគេបំផុតនៅក្នុងពីរទសវត្សរ៍ខាងមុខ។<br>• ទេសចរណ៍បង្កប់នូវរឿងរ៉ាវល្អ និងគួរជាទីរីករាយដូចជាវិស្សមកាល ការលេងកំសាន្តពេលលំហែ ការផ្សងព្រេង និងសកម្មភាពដែលសប្បាយៗ។ ហេតុនេះយើងប្រហែលជាឆ្ងល់ថា តើការរំលោភបំពានកុមារ និងវិស័យទេសចរណ៍មានទំនាក់ទំនងគ្នាដូចម្តេច ? | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ប៉ុន្តែមានគ្រោះថ្នាក់សំខាន់ៗចំពោះកុមារដែលពាក់ពន្ធ័ដោយផ្ទាល់ជាមួយនឹងទេសចរណ៍។<br>• ពេលវិស័យទេសចរណ៍បន្តរីកលូតលាស់យ៉ាងឆាប់រហ័ស ការរំលោភបំពានកុមារក៏មានសក្តានុពលរីកធំធាត់ និងមានស្ថានភាពកាន់តែអាក្រក់ទៅៗផងដែរ ប្រសិនបើយើងមិនធ្វើសកម្មភាពពីពេលឥឡូវនេះទៅ | |
| **ស្លាយទី២១**<br><br> | *សកម្មភាព៖ លំហាត់ (តាមជម្រើស)*<br>• ធ្វើលំហាត់ទេសចរណ៍ដ៏ឆាប់មួយ ដើម្បីបង្កើនថាមពលដល់អ្នកចូលរួម និងធ្វើឱ្យពួកគេគិតអំពីភាពអស្ចារ្យនៃទេសចរណ៍ និងស្ថានភាពដោយឡែកនៅក្នុងប្រទេសរបស់ខ្លួន។<br>• លំហាត់នេះមានសំណួរធំបួនសំខាន់ៗ (អ្នកសម្របសម្រួលអាចបន្ថែមសំណួរទៀតប្រសិនបើអាច)។ ជាការសំខាន់ណាស់ដែលអ្នកសម្របសម្រួលត្រូវទទួលបានចម្លើយនៃសំណួរទាំងនេះ មុនពេលវគ្គបណ្តុះបណ្តាល។<br>១. តើមានភ្ញៀវអន្តរជាតិប៉ុន្មាននាក់ដែលមកប្រទេសកម្ពុជានៅឆ្នាំកន្លងទៅ?<br>២. តើមានហេតុផលអ្វីខ្លះដែលភ្ញៀវមកកាន់ប្រទេសកម្ពុជា?<br>៣. ចូររាប់ឈ្មោះប្រទេសសំខាន់ៗប្រាំដែលជាប្រទេសរបស់ភ្ញៀវទេសចរទាំងនេះ?<br>៤. តើកន្លែងណាខ្លះជាកន្លែងទេសចរណ៍ដែលមានប្រជាប្រិយក្នុងប្រទេសកម្ពុជា? | • នេះគឺជាស្លាយដែលមានចលនា។ មានតែសំណួរមួយ ប៉ុណ្ណោះ នឹងរត់លើផ្ទាំងបញ្ចាំងស្លាយម្តង ដើម្បីធ្វើឱ្យមានភាពភ្ញាក់ផ្អើលសម្រាប់សំណួរនីមួយៗ។<br>• ប្រសិនបើអាចធ្វើបាន អាចផ្តល់រង្វាន់តូចៗដូចជាស្ករគ្រាប់ ឬប៊ិចជាដើមចំពោះចម្លើយត្រឹមត្រូវ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២២**<br><br> | ក្នុងនាមជាឧស្សាហកម្មមួយក្នុងចំណោមឧស្សាហកម្ម ដែលរីកលូតលាស់លឿននៅក្នុងពិភពលោក វិស័យទេសចរណ៍បាននាំមកនូវអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែទេសចរណ៍ក៏អាចមានផលប៉ះពាល់ជាអវិជ្ជមានផងដែរ។<br><br>*សកម្មភាព៖ ការប្រកួតប្រជែង (តាមជម្រើស)*<br><br>• សូមពន្យល់ថា វិស័យទេសចរណ៍គឺជាឧស្សាហកម្មមួយក្នុងចំណោមឧស្សាហកម្មលូតលាស់ជាងគេនៅក្នុងពិភពលោក។ កំណើនភ្ញៀវទេសចរបាននាំមកនូវអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែក៏អាចមានចំណុចជាអវិជ្ជមានផងដែរ។<br>• សូមចែកអ្នកចូលរួមជាពីរក្រុម។ សូមផ្តល់ឱ្យក្រុមនីមួយៗនូវក្រដាសផ្ទាំងធំ និងហ្វឺត<br>• ណែនាំប្រាប់ក្រុមថាពួកគេ មានរយៈពេលបីនាទី ដើម្បីរៀបចំបញ្ជីមួយដែលគូសបញ្ជាក់អំពីផលប៉ះពាល់នៃទេសចរណ៍មកលើសហគមន៍ (រួមទាំងកុមារ)។ ក្រុមមួយនឹងផ្តោតការយកចិត្តទុកដាក់លើផលប៉ះពាល់ជាវិជ្ជមាន។ ក្រុមមួយទៀតនឹងផ្តោតការយកចិត្តទុកដាក់លើផលអវិជ្ជមាន។<br>• បន្ទាប់ពីរយៈពេលបីនាទីបានបញ្ចប់ទៅសូមចាប់ផ្តើមឱ្យក្រុមវិជ្ជមានចែករំលែកចម្លើយរបស់ខ្លួន និងជួយជម្រុញបន្ថែមទៅលើអត្ថប្រយោជន៍ ដែលវិស័យទេសចរណ៍នាំមកដល់កុមារ។ បន្ទាប់មកសូមឱ្យក្រុមអវិជ្ជមានចែករំលែកលទ្ធផលរបស់ខ្លួន ។<br>• លទ្ធផលនៃការពិភាក្សា អាចត្រូវបានប្រើប្រាស់ជាចំណុចចាប់ផ្តើមការពិភាក្សាអំពីវិធីនានា ដែលកុមារងាយរងគ្រោះអាចនឹងរងនូវការរំលោភបំពានតាមរយៈវិស័យទេសចរណ៍។ | ប្រសិនបើក្រុមត្រូវការសំណួរបំផុសគំនិតអាចលើកឧទា-ហរណ៍មួយចំនួនមានដូចជា៖<br><br>*ផលប៉ះពាល់ជាវិជ្ជមាន*<br>• បង្កើនឱកាសមុខរបរសម្រាប់ គ្រួសារដែលអាចធ្វើឱ្យជីវភាពរបស់កុមារកាន់តែមានភាពប្រសើរឡើង។<br>• ចំណូលកាន់តែច្រើន អាចនាំឱ្យមានការបង្កើនឱ្យមានហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរ (រួមមានផ្លូវថ្នល់ សាលារៀន សេវាវេជ្ជសាស្ត្រ)<br><br>*ផលប៉ះពាល់ជាអវិជ្ជមាន*<br>• ការលាយបញ្ចូលគ្នានៃមនុស្ស និងវប្បធម៌ខុសៗគ្នាអាចនាំទៅរកជម្លោះ មានការជះឥទ្ធិពលនៃអំណាច និង/ឬលុយកាក់។<br>• កុមាររងការប៉ះពាល់ឥទ្ធិពលពីអាជីវកម្មអវិជ្ជមាន។<br>• កុមារមានភាពងាយរងគ្រោះនៅពេលដែលពួកគេសុំទាន ឬលក់ដូរតាមផ្លូវថ្នល់ដើម្បីរកលុយពីទេសចរ។ ការរស់នៅ ឬការធ្វើការតាមចិញ្ចើមថ្នល់ អាចធ្វើឱ្យកុមារងាយរងគ្រោះចំពោះការរំលោភបំពានក្នុងទម្រង់ដទៃទៀត។<br>• កុមារមានភាពងាយរងគ្រោះនៅពេលទេសចរទៅទស្សនាកន្លែងនានា ដែលគួរតែជាកន្លែងកំណត់សម្រាប់មនុស្សជំដែលគួរទុកចិត្ត ដូចជាមណ្ឌលកុមារកំព្រា សាលារៀន ផ្ទះជាដើម។ |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr>
<td>

**ស្លាយទី២៣ •**




</td>
<td>

យើងឃើញថាទេសចរណ៍ ប្រសព្វជាមួយភាពងាយរងគ្រោះនៃការរំលោភបំពានកុមារតាមវិធីធំៗបី៖

**១. កុមារតាមចិញ្ចើមថ្នល់**

- ទីមួយយើងឃើញកុមារ នៅតាមផ្លូវនានាក្នុងបរិស្ថានទេសចរណ៍
- ឧទាហរណ៍ កុមារងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ ត្រូវបានទាក់ទាញទៅកាន់ទីកន្លែងទេសចរណ៍ ដើម្បីរកចំណូល
- ពេលខ្លះកុមារទាំងនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់មនុស្សពេញវ័យ មិនថាអ្នកនោះជាគ្រួសារ ឬអ្នកមិនមែនជាគ្រួសាររបស់ពួកគេនោះឡើយ។ កុមារទាំងនេះប្រហែលជាមិនបានទៅសាលារៀន ជាពិសេសប្រសិនបើពួកគេជាកុមារចំណាកស្រុក វារឹតតែធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះថែមទៀត។
- កុមារ និងយុវជនទាំងនេះ ប្រហែលជាធ្វើសម្មាភាពរកចំណូលមួយចំនួននៅតាមផ្លូវ ដូចជាសុំទាន ឬលក់តវ៉ាន់/អាហារ សម្រាប់ភ្ញៀវទេសចរ។
- គឺកុមារដែលចំណាយពេលយ៉ាងច្រើននៅតាមផ្លូវ ឬនៅតាមទី "សាធារណ:" ដទៃទៀតនេះហើយ ដែលមានភាពងាយរងគ្រោះចំពោះការរំលោភបំពានបំផុត។
- ការបណ្តោយឱ្យកុមារងាយរងគ្រោះនៅជិតជាមួយភ្ញៀវទេសចរ និងអ្នកធ្វើដំណើរដែលមានប្រាក់ មានន័យថា ភ្ញៀវទេសចរ និងអ្នកធ្វើដំណើរទាំងនេះ មានឥទ្ធិពលក្នុងការ "បង្កគ្រោះថ្នាក់ ឬជួយ" ដល់មនុស្សក្នុងសហគមន៍។
- ជារឿយៗ ភ្ញៀវទេសចរ និងអ្នកដំណើរមកពីប្រទេសអភិវឌ្ឍន៍ ពុំដែលបានឃើញកុមារនៅតាមចិញ្ចើមផ្លូវដូច្នេះឡើយ។ នៅក្នុងប្រទេសជាច្រើន (ឧ. អូស្រ្តាលី ឬចក្រភពអង់គ្លេស) ប្រសិនបើពលរដ្ឋណាម្នាក់ឃើញកុមារធ្វើការនៅតាមផ្លូវនោះ ពួកគេត្រូវរាយការណ៍ទៅសេវាការពារកុមារ ដើម្បីឲ្យមានការវាយតម្លៃលើកុមារ និងរកវិធីនានាដើម្បីជួយ។

</td>
<td>

សូមយោងទៅ **កាតយកតាមខ្លួន (តើវិស័យទេសចរណ៍មានគ្រោះថ្នាក់អ្វីខ្លះចំពោះកុមារ?)**



តើមានគ្រោះថ្នាក់អ្វីខ្លះចំពោះកុមារនៅក្នុងវិស័យទេសចរណ៍?

១ **កុមារនៅតាមចិញ្ចើមផ្លូវ ក្នុងតំបន់ទេសចរណ៍**
ឧទាហរណ៍ កុមារអាចសុំទាន ឬលក់ទំនិញ/ អាហារសម្រាប់អ្នកទេសចរ។ កុមារា និងកុមារីដែលចំណាយពេលច្រើននៅតាមផ្លូវ គឺងាយរងគ្រោះពីការរំលោភបំពានណាស់ ។

២ **កុមារដែលធ្វើការក្នុងវិស័យទេសចរណ៍ ឬ វិស័យពាក់ព័ន្ធផ្សេងៗទៀត ជារឿយៗស្ថិតនៅក្នុង ស្ថានភាពដែលត្រូវគេកេងប្រវ័ញ្ច**
ឧទាហរណ៍ កុមារអាច ធ្វើការនៅក្នុងឧស្សាហកម្មទេសចរណ៍ រួមមានមគ្គុទេសក៏ទេសចរណ៍ ធ្វើការនៅក្នុងភោជនីយដ្ឋាន បារ ខារ៉ាអូខេ។ល។ កុមារក៏អាចត្រូវបានគេកេងប្រវ័ញ្ច នៅក្នុងឧស្សាហកម្មផ្លូវភេទផងដែរ ។

៣ **អ្នកធ្វើដំណើរ ឬអ្នកទេសចរអាចចូលទៅរកកុមារបានយ៉ាងងាយ**
ឧទាហរណ៍ អ្នកប្រព្រឹត្តិបទល្មើសផ្លូវភេទកុមារនៅពេលធ្វើដំណើរនោះ ងាយស្រួលក្នុងការចូលទៅជិតកុមារា កុមារីដែលងាយរងគ្រោះដោយចូលទៅបំពីការនៅក្នុងសាលារៀន ឬ "នៅក្នុងមណ្ឌលកុមារកំព្រា" ។ និន្នាការគួរឲ្យព្រួយបារម្ភនោះ មានដូចជា៖

- "ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ការអភិវឌ្ឍ និងសុខមាលភាពរបស់កុមារ ហើយធ្វើឲ្យកុមារ ស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរំលោភបំពាន ។
- "ទេសចរណ៍ស្ម័គ្រចិត្ត" នៅក្នុងអង្គការដែលមើលថែទាំកុមារ ជាកន្លែងដែលអ្នកស្ម័គ្រចិត្តមិនត្រូវបានគេឆែកឆេរ ឬ "ត្រួតពិនិត្យ" ឲ្យបានហ្មត់ចត់។
- "ការស្នាក់នៅតាមផ្ទះ" ដោយពុំមានការកំណត់ទីកន្លែងព្រំដែនឲ្យបានសមស្របរវាងអ្នកទេសចរ និងកុមារជាក់លាក់ ។

ភាពងាយរងគ្រោះរបស់កុមារ និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន មានទំនាក់ទំនងគ្នាទៅវិញទៅមក។

អ្នកសម្របសម្រួលគួរប្រមូលឧទាហរណ៍ក្នុងមូលដ្ឋាន ដែលបង្ហាញឱ្យឃើញ ពីគ្រោះថ្នាក់ជាក់លាក់ចំពោះកុមារក្នុងវិស័យទេសចរណ៍។

អ្នកសម្របសម្រួល ក៏គួរតែទទួលស្គាល់ថា អ្នកចូលរួមអាចនឹងមានចំណេះដឹងច្រើនជាងខ្លួន អំពីរបៀបដែលកុមាររងការរំលោភបំពាននៅក្នុងវិស័យទេសចរណ៍។ ក្នុងករណីទាំងនេះ វគ្គសិក្សានេះ គឺជាទីកន្លែងមួយដែលជម្រុញដល់ការគិត និងការឆ្លុះបញ្ចាំងនូវអ្វីដែលគេប្រហែលជានឹងមិនបានគិតដល់ពីមុន ។

សូមកត់សម្គាល់ថា ភ្ញៀវទេសចរអន្តរជាតិមួយចំនួន មិនធ្លាប់ឃើញកុមារងាយរងគ្រោះឡើយ ហើយជាញឹកញយ ពួកគាត់សួរប្រតិបត្តិករទេសចរណ៍ពីស្ថានភាពទាំងនេះប្រាប់គាត់។ ជាការល្អ ប្រសិនបើអ្នកអាចសង្កេតស្វែងយល់អារម្មណ៍របស់ភ្ញៀវទាំងនោះ នៅពេលណាមួយ ដូចជាក្នុងស្ថានភាពភ្ញៀវណាម្នាក់សម្រេចចិត្តទិញក្រមាពីកុមារម្នាក់ជាដើម។

</td>
</tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៤** •<br> | **២. ការកេងប្រវ័ញ្ចលើកុមារ**<br>• ទីពីរ ពេលខ្លះ យើងឃើញកុមារធ្វើការ ក្នុងវិស័យទេសចរណ៍ ឬវិស័យពាក់ព័ន្ធ ដទៃទៀត ក្នុងស្ថានភាពដែលមានការ កេងប្រវ័ញ្ច។<br>• ឧទាហរណ៍ កុមារប្រហែលជាធ្វើការតាមផ្លូវ ជាអ្នកលក់វត្ថុអនុស្សាវរីយ៍ អាហារសម្រន់ សន្លឹកឆ្នោត បារី ឬកាតអនុស្សាវរីយ៍ ឬ ធ្វើការជាអ្នកខាត់ស្បែកជើងជាដើម<br>• កុមារក៏ធ្វើការក្នុងឧស្សាហកម្មទេសចរណ៍ តាំងពីនៅអាយុតិច ដូចជាធ្វើជាមគ្គុទ្ទេសក៏ ទេសចរណ៍ នៅក្នុងភោជនីយដ្ឋាន ហាង កាហ្វេ ក្លិបខារ៉ាអូខេ ក្លឹបរាត្រី សណ្ឋាគារ ជាដើម។<br>• ម៉្យាងទៀត មានភស្តុតាងបង្ហាញថា កុមារ ត្រូវគេកេងប្រវ័ញ្ចនៅក្នុងឧស្សាហកម្ម ផ្លូវភេទ និងក្នុងអាជីវកម្មផ្គត់ផ្គង់ចំណី អាហារ សម្រាប់ភ្ញៀវទេសចរ។ | អ្នកសម្របសម្រួលគួរប្រមូលឧទាហរណ៍ ក្នុងមូលដ្ឋាន ដែលបង្ហាញឱ្យឃើញពី គ្រោះថ្នាក់ជាក់លាក់ ចំពោះកុមារក្នុង វិស័យទេសចរណ៍។<br><br>ផ្តល់ពេលឱ្យអ្នកចូលរួមគិតឆ្លុះបញ្ចាំងលើ ស្ថានភាពទាំងនេះ និងទំនាក់ទំនងរបស់ ពួកគេជាមួយស្ថានភាពទាំងនេះ។ អាចនឹង មានអារម្មណ៍ពុះកញ្ជ្រោលមួយចំនួនកើត មានឡើង ដូចជា អារម្មណ៍សោកស្តាយ មានវិប្បដិសារី និងអារម្មណ៍មានកំហុស ជាដើម។ អ្នកសម្របសម្រួល គួររំលឹក អ្នកចូលរួមថា សកម្មភាពរបស់យើងកន្លងមក អាចជាទង្វើដែលមិនមានផលល្អដល់កុមារ ប៉ុន្តែយើងគិតថា យើងមានបំណងល្អតែ ប៉ុណ្ណោះ។ សម្តីបែបនេះ អាចជួយបន្ធូរបន្ថយ អារម្មណ៍ថប់បារម្ភ។ សូមរំលឹកប្រាប់ដល់ អ្នកចូលរួមថា វគ្គបណ្តុះបណ្តាលនេះ ជាវគ្គ ដែលជួយឱ្យពួកគេ រឹតតែមានចំណេះដឹង កាន់តែច្រើនឡើង។ |
| **ស្លាយទី២៥** •<br> | **៣. កុមារដែលងាយនឹងជួប**<br>• ចំណុចទីបីដែលគួរជាទីបារម្ភនោះគឺនៅត្រង់ ថា ភ្ញៀវទេសចរ និងអ្នកធ្វើដំណើរអាចមាន លទ្ធភាពចូលទៅរកកុមារបានដោយងាយ ស្រួល។ កុមារមិនមែនចាំបាច់តែធ្វើការនៅ ក្នុងវិស័យទេសចរណ៍ ប៉ុណ្ណោះឡើយ ប៉ុន្តែ យើងក៏ឃើញថា ពេលខ្លះឧស្សាហកម្ម ទេសចរណ៍អាចជម្រុញ បណ្តាលឱ្យមាន ការរំលោភបំពានដោយមិនដឹងខ្លួន តាមរយៈ ការធ្វើឱ្យឱកាសស្វែងកុមារី និងកុមារា កាន់តែមានភាពទូលាយ និងងាយស្រួល។<br>• ឧទាហរណ៍ ជនល្មើសផ្លូវភេទកុមារដែលជា អ្នកធ្វើដំណើរ អាចមានលទ្ធភាពចូល ទៅ រកកុមារដោយពុំមានការឃ្លាំមើលពីអ្នកដទៃ តាមរយ:ការធ្វើការងារនៅក្នុងសាលា រៀន ឬមណ្ឌលកុមារកំព្រា។ | អ្នកសម្របសម្រួលគួរប្រមូលឧទាហរណ៍ក្នុង មូលដ្ឋាន ដែលបង្ហាញឱ្យឃើញ ពីគ្រោះថ្នាក់ ជាក់លាក់ចំពោះកុមារក្នុងវិស័យទេសចរណ៍។<br><br>ការឆ្លុះបញ្ចាំងស្តីពីភ្ញៀវទេសចរ ទៅលេងនៅសាលារៀន និងមណ្ឌលកុមារកំព្រា ទំនងជានឹងធ្វើឱ្យមាន ការជជែកដេញដោលកើតឡើង។ តាមធម្មតា ការជជែកទាំងនេះ គឺគួរផ្តោតទៅលើ "ប្រយោជន៍ប្រសើរបំផុត" របស់កុមារ ជាជាងអ្វីដែលភ្ញៀវទេសចរចង់ធ្វើ។ វាជាការសំខាន់ណាស់ ដែលត្រូវឆ្លើ យតបនឹងការពិភាក្សានេះដោយទន់ ភ្លន់ ប៉ុន្តែស្របពេលជាមួយគ្នានោះ ត្រូវបញ្ជាក់ឱ្យច្បាស់ថា ផលប្រយោជន៍ប្រសើរបំផុត របស់កុមារ ចាំ បាច់ត្រូវតែជាការគិតគូរមុខគេបង្អស់។ ( សូម មើលព័ត៌មានលម្អិតនៅវគ្គបន្ទាប់ ) |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | • រឿងទាំងនេះ ក៏កើតមាននៅតាមសហគ្រាស "ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ" ឬ "ទេសចរណ៍វប្បធម៌" ផងដែរ។ | ពេលដល់ចំណុចនេះ វាជាការល្អក្នុងការរំលឹកដល់អ្នកចូលរួមពី "គោលការណ៍ឧត្តមប្រយោជន៍" ពោលគឺឧត្តមប្រយោជន៍សម្រាប់កុមារ ចាំបាច់ត្រូវតែជាការពិចារណាចំបងបំផុតនៅក្នុងគ្រប់ការសម្រេចចិត្ត និងសកម្មភាពទាំងអស់ដែលត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងកុមារ។ |
| **ស្លាយទី២៦** •<br><br> | • ឧទាហរណ៍ជាក់លាក់មួយចំនួនមានដូចជា៖<br>– "ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" ជាទីដែលគេអនុញ្ញាតិឱ្យអ្នកធ្វើដំណើរចូលទៅលេង និងប្រាស្រ័យទាក់ទងជាមួយកុមារដែលស្ថិតក្រោមការថែទាំរបស់ស្ថាប័ននោះ។<br>– "ការងារស្ម័គ្រចិត្ត" នៅក្នុងសកម្មភាពដែលពាក់ព័ន្ធជាមួយកុមារ ដែលជានិច្ចកាលមិនមានការត្រួតពិនិត្យគ្រប់គ្រាន់ លើមនុស្សពេញវ័យដែលធ្វើការជាមួយកុមារឡើយ។<br>– "ទេសចរណ៍ស្នាក់តាមផ្ទះប្រជាជន" ដែលអនុញ្ញាតិឱ្យមនុស្សពេញវ័យដែលគេមិនស្គាល់ស្នាក់នៅតាមផ្ទះប្រជាជន ជារឿយៗតែងមានការប្រាស្រ័យទាក់ទងជាមួយកុមារដោយមិនមានការឃ្លាំមើល។<br>• "សកម្មភាព" ទាំងនេះផ្តោតលើ "បទពិសោធន៍" ដល់ទេសចរ ក្នុងការបំពេញបំណងរបស់ពួកគេក្នុងការ "ជួយ" ជាជាងការផ្តោតទៅលើអត្ថប្រយោជន៍រយៈពេលវែងសម្រាប់កុមារ។<br>• ប្រទេសជាច្រើនមិនអនុញ្ញាតឱ្យមនុស្សមកប្រាស្រ័យទាក់ទងជាមួយកុមារ ដោយមិនគោរពតាមដំណើរការត្រួតពិនិត្យសារវតា និងគុណសម្បត្តិយ៉ាងតឹងរ៉ឹងនោះឡើយ។ | "ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" គឺជាក្តីបារម្ភជាពិសេសមួយក្នុងតំបន់ ហើយពុំមែនជារឿងដែលយើងត្រូវលើកទឹកចិត្តនោះឡើយ ព្រោះថាការទៅទស្សនារយៈពេលខ្លីពីសំណាក់ទេសចរ មានន័យស្មើនឹងការដកហូតពីកុមារនូវសិទ្ធិទទួលបានបរិយាកាសផ្ទះសម្បែងឯកជន និងមានសុវត្ថិភាពមួយ។ ការស្រាវជ្រាវបានបង្ហាញថា ការទៅទស្សនារយៈពេលខ្លី អាចបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍន៍ និងសុខុមាលភាពផ្លូវចិត្តរបស់កុមារផងដែរ។ ជាងនេះទៅទៀត ប្រសិនបើមិនមានការត្រួតពិនិត្យគ្រប់គ្រាន់ទៅលើភ្ញៀវទេនោះ អាចធ្វើឱ្យកុមារត្រូវប្រឈមនឹងគ្រោះថ្នាក់នៃការ រំលោភបំពាន។ "អ្នកធ្វើការផ្តល់ការថែទាំក្លែងក្លាយ" ( សំដៅលើអ្នកប្រកបវិជ្ជាជីវៈ និងអ្នកស្ម័គ្រចិត្តដែលរំលោភបំពានកុមារ ដែលខ្លួនធ្វើការជាមួយ ) គឺជាប្រភេទដែលគេស្គាល់ថាជាជនល្មើសផ្លូវភេទកុមារដែលជាអ្នកធ្វើដំណើរ។ |
| **ស្លាយទី២៧** •<br><br> | • ភ្ញៀវទេសចរស្ទើរទាំងអស់ ជួបជាមួយកុមារក្នុងស្រុកនៅពេលគេធ្វើដំណើរទៅតំបន់នានា។<br>• ការស្រាវជ្រាវបានបង្ហាញថា ការទំនាក់ទំនងជាច្រើនបានធ្វើឱ្យទេសចរមានអារម្មណ៍ក្រៀមក្រំ មានកំហុស ព្រួយបារម្ភ និងខកចិត្ត។ | អ្នកសម្របសម្រួលអាចយោង របាយការណ៍របស់អង្គការទស្សនៈពិភពលោក ដែលមានចំណងជើងថា The Child Safe Traveller ឆ្នាំ២០១៣ ដែលបានធ្វើការស្ទង់មតិអ្នកទេសចរប្រមាណជិត៣០០ នាក់ដែលធ្វើដំណើរមកកាន់តំបន់នេះ ស្តីពីទស្សនៈយល់ឃើញរបស់ពួកគេចំពោះការរំលោភបំពានកុមារ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ក្នុងករណីមួយចំនួន ទេសចរបង្ហាញពីបំណងក្នុងការផ្ដល់ការជួយឱ្យបានច្រើនថែមទៀត។ ប៉ុន្តែ ទេសចរមួយចំនួនទៀតបង្ហាញពីភាពអល់អែក ដោយសារតែគេមិនឃើញមនុស្សក្នុងស្រុក ធ្វើសកម្មភាពឱ្យបានច្រើនជាងនេះ។<br>• ទេសចរជាច្រើនរងផលប៉ះពាល់ (ផ្លូវអារម្មណ៍) ជាពិសេសនៅពេលពួកគេឃើញកុមារធ្វើការនៅតាមចិញ្ចើមផ្លូវ ឬសុំទាន។<br>• ទេសចរមួយចំនួនបានបញ្ជាក់ថា ការធ្វើដំណើររបស់ពួកគេមកកាន់តំបន់នេះ ប្រហែលជាអាចប្រសើរឡើង ប្រសិនបើពួកគេឃើញកុមារទទួលបានកិច្ចការពារប្រសើរជាងនេះ។ | ដ្យាក្រាមព័ត៌មាន ដែលសង្ខេបការរកឃើញរបស់របាយការណ៍នេះ មាននៅក្នុង **កាតយកតាមខ្លួន (អ្នកធ្វើដំណើរដែលមានសុវត្ថិភាពសម្រាប់កុមារ)**។<br><br>ជាថ្មីម្ដងទៀត អ្នកសម្របសម្រួល អាចអនុញ្ញាតឱ្យមានការសម្រាករយៈពេលខ្លី ដើម្បីផ្ដល់ពេលវេលាឱ្យអ្នកចូលរួមឆ្លុះបញ្ចាំងលើអារម្មណ៍របស់ពួកគេ ក្រោយពេលបានទទួលព័ត៌មានទាំងនេះ។ |
| **ស្លាយទី២៨** •<br> | • នៅពេលយើងពិនិត្យទៅលើភាពងាយរងគ្រោះចំពោះការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ច យើងឃើញច្បាស់ថាភាពងាយរងគ្រោះ និងការកេងប្រវ័ញ្ចទាំងនោះ មានទំនាក់ទំនងគ្នា។<br>• បញ្ហាជាច្រើនខាងលើ ផ្សារភ្ជាប់ ឬអាចបណ្ដាលឱ្យមានការរំលោភបំពានផ្លូវភេទ។<br>• ដោយផ្ដោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាក់លាក់ ស្ដីពីការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍ នាំឱ្យយើងដឹងថាជនល្មើសអាចមានលទ្ធភាពចូលទៅរកកុមារ ដែលកំពុងធ្វើការនៅតាមចិញ្ចើមផ្លូវ ឬគ្រឹះស្ថាននានា ឬពួកគេអាចចូលទៅរកកុមារងាយរងគ្រោះដទៃទៀត តាមរយៈការធ្វើការងារក្នុងសាលារៀន ឬមណ្ឌលកុមារកំព្រា។ល។<br>• ពួកគេអាចនឹងប្រើប្រាស់បណ្ដាញក្នុងស្រុក ឬមេអណ្ដើក (ពេលខ្លះអាចជាអ្នកធ្វើការក្នុងឧស្សាហកម្មទេសចរណ៍) ដើម្បីជួយរកកុមារឱ្យគេរំលោភបំពាន។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ គឺជាបាតុភូតសកលមួយដែលកើតឡើងនៅសហរដ្ឋអាមេរិក អាហ្វ្រិក អាស៊ី និងអឺរ៉ុប។ មិនមានប្រទេសណាមួយ រួចផុតពីបញ្ហានេះឡើយ។<br>• នេះគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ដែលទាមទារនូវការយកចិត្តទុកដាក់ជាបន្ទាន់។ | |
| **ស្លាយទី២៩** ●<br><br> | **តើអ្វីជាការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ ?**<br>• ដូចយើងបានដឹងហើយថា ការមកដល់របស់ភ្ញៀវអន្តរជាតិមកកាន់តំបន់នេះបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។<br>• ភ្ញៀវភាគច្រើនជាអ្នកធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ ហើយពួកគេគោរពវប្បធម៌ បរិស្ថាន និងប្រជាជនក្នុងមូលដ្ឋានពេលពួកគេធ្វើដំណើរ ឬរស់នៅក្នុងប្រទេសណាមួយ។<br>• ប៉ុន្តែ អ្នកធ្វើដំណើរមួយក្តាប់តូច ប្រើប្រាស់ការធ្វើដំណើរជាឱកាស ដើម្បីរំលោភបំពានលើកុមារ។ មនុស្សមួយចំនួនអាចជាពិរុទ្ធជននៅក្នុងប្រទេសរបស់ខ្លួនក៏មាន។<br>• ជនល្មើសដែលធ្វើដំណើរដើម្បីរួមភេទជាមួយកុមារ គឺជាទេសចរ អ្នកធ្វើដំណើរ ឬអ្នកតាំងទីលំនៅបរទេសដែលប្រព្រឹត្តការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងប្រទេសមួយ ឬប្រទេសច្រើនដែលពួកគេបានទៅទស្សនា ឬទៅរស់នៅ។ | |
| **ស្លាយទី៣០** ●<br><br> | • គ្មានអ្វីអាចកត់សម្គាល់ថានរណាម្នាក់ជាជនល្មើសរំលោភបំពានផ្លូវភេទកុមារដែលជាអ្នកធ្វើដំណើរទេ។ ជនល្មើសប្រភេទនេះគឺមកពីគ្រប់ប្រទេសទាំងអស់។<br>• ពួកគេអាចជាជនបរទេសដែលកំពុងរស់នៅក្នុងប្រទេសក្រៅ អាជីវករដែលធ្វើដំណើរ ឬទេសចររយៈពេលខ្លី។<br>• ពួកគេអាចនឹងធ្វើការនៅក្នុងវិស័យវិជ្ជាជីវៈណាមួយ (ដូចជាគ្រូបង្រៀន វេជ្ជបណ្ឌិត ឬវិជ្ជាជីវៈដែលជនល្មើសអាចកសាងទំនាក់ទំនងជាមួយកុមារមុនពេលពួកគេរំលោភបំពានលើកុមារ)។ | ក្នុងអំឡុងការពិភាក្សានេះ វាជាការសំខានដែលត្រូវកត់សម្គាល់ថា កុមារច្រើនតែត្រូវបានរំលោភបំពានដោយអ្នកដែលស្គាល់ពួកគេ ហើយបញ្ហាការរំលោភបំពានផ្លូវភេទកុមារគឺមិនមែនគ្រាន់តែជាបញ្ហា "បរទេស" នោះទេ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ពួកគេអាចជាមនុស្សប្រុស ឬជាមនុស្សស្រី។<br>• ពួកគេអាចជាមនុស្សពេញវ័យ គ្រប់អាយុទាំងអស់ ជាយុវវ័យ និងជាមនុស្សចាស់។<br>• គេមិនអាចសម្គាល់ជនល្មើសដែលរំលោភបំពានផ្លូវភេទកុមារ ដែលធ្វើដំណើរតាមរយៈរូបរាងខាងក្រៅបានឡើយ។ ផ្ទុយទៅវិញ វាជាការសំខាន់ណាស់ដែលត្រូវដឹងពីស្ថានភាពប្រថុយប្រថានសម្រាប់កុមារ និងអាកប្បកិរិយាគួរឱ្យសង្ស័យដែលមនុស្សពេញវ័យបង្ហាញចេញមក។ | |
| **ស្លាយទី៣១**<br> | • ជនល្មើសដែលរំលោភបំពានផ្លូវភេទកុមារធ្វើដំណើរទៅបណ្តាប្រទេសនានានៅក្នុងអាស៊ីអាគ្នេយ៍ដើម្បីរំលោភបំពានលើកុមារដោយសារហេតុផលជាច្រើន។<br>• ឧទាហរណ៍ មានច្បាប់ និងនីតិវិធីត្រួតពិនិត្យយ៉ាងតឹងរ៉ឹងនៅក្នុងបណ្តាប្រទេសជាច្រើនដែលទប់ស្កាត់មិនឱ្យជនល្មើសអាចមានលទ្ធភាពចូលទៅរកកុមារដែលងាយរងគ្រោះបាន។ ហេតុនេះ ជនល្មើសផ្តោតគោលដៅទៅលើបណ្តាប្រទេសដែលមានច្បាប់មិនសូវតឹងរ៉ឹង។<br>• ដូចគ្នានេះដែរ ជនល្មើសផ្តោតគោលដៅទៅលើបណ្តាប្រទេសដែលមានលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមទាបដែលធ្វើឱ្យកុមារងាយរងគ្រោះ។<br>• ជនល្មើសដែលរំលោភបំពានផ្លូវភេទកុមារប្រើប្រាស់វិធីសាស្ត្រផ្សេងៗជាច្រើនដើម្បីចូលទៅរកកុមារដូចជា៖<br>– អ្នករំលោភបំពានមួយចំនួន ធ្វើការរៀបចំទុកជាមុនដើម្បីរំលោភបំពានកុមារនៅក្នុងទីកន្លែងជាក់លាក់ណាមួយ។<br>– អ្នករំលោភបំពានមួយចំនួនទាញអត្ថប្រយោជន៍ពីបរិយាកាស វិស្សមកាលដើម្បីរំលោភបំពានកុមារ។<br>– មនុស្សមួយចំនួនធ្វើដំណើរពីបរទេសទៅកាន់ទីតាំងដែលបានរាយការថាមានកុមារសម្រាប់ការរួមភេទ។ | អ្នកសម្របសម្រួលអាចផ្តល់ឧទាហរណ៍ពាក់ព័ន្ធថ្មីៗ ដែលមានក្នុងប្រទេសរបស់ខ្លួន។<br>ឧទាហរណ៍ថ្មីៗ មានដូចជា៖ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | – អ្នករំលោភបំពានមួយចំនួន អាចនឹងធ្វើដំណើរមកប្រទេសមួយនោះជាញឹកញាប់ ហើយមួយលើកៗ អាចស្នាក់នៅជាច្រើនខែ ឬច្រើនឆ្នាំ។ ក្នុងករណីបែបនេះ គេមិនមែនជាទេសចរទេ ប៉ុន្តែជាអ្នកតាំងទីលំនៅបរទេស ដែលមានផ្ទះ ឬផ្ទះល្វែងផ្ទាល់ខ្លួន។<br>– អ្នករំលោភបំពានមួយចំនួនប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីរំលោភបំពានកុមារនៅប្រទេសផ្សេង (ឧ. តាមរយៈការប្រើ "វែបឃែម"ជាដើម)។<br>– មនុស្សមួយចំនួនធ្វើការជាអ្នកស្ម័គ្រចិត្ត/គ្រូបង្រៀន/វេជ្ជបណ្ឌិត នៅក្រៅប្រទេស និងរំលោភបំពានកុមារដែលដែលពួកគេបានជួប តាមរយៈការងារនៅក្នុងអង្គការក្រៅរដ្ឋាភិបាល មណ្ឌលកុមារកំព្រា សាលារៀន គ្លីនិកវេជ្ជសាស្ត្រ ។ល។<br>– អ្នករំលោភបំពានមួយចំនួនប្រើប្រាស់មេអណ្តើក និងបណ្តាញក្នុងស្រុក ដើម្បីជួយគេក្នុងការស្វែងរក និងរំលោភបំពានកុមារ។ ដូចយើងបាន កត់សម្គាល់រួចមកហើយថា មានមនុស្សជាច្រើនដែលអាចជួយសម្រួលដល់អ្នករំលោភបំពានឱ្យមានលទ្ធភាពចូលទៅរក និងរំលោភបំពានលកុមារ។ | |
| **ស្លាយទី៣២** ●<br><br> | តើជនរងគ្រោះជានរណា?<br>• អ្នករំលោភបំពានអាចផ្តោតគោលដៅលើកុមារគ្រប់រូប។<br>• ជនរងគ្រោះអាចជាកុមារា ឬកុមារី ។<br>• កុមារគឺជាជនទាំងឡាយណាដែលមានអាយុក្រោម១៨ ឆ្នាំ។ ជនរងគ្រោះអាចស្ថិតក្នុងអាយុណាមួយចាប់ពី ០-១៧ ឆ្នាំ។<br>• ជនរងគ្រោះអាចជាទារក កុមារតូច ឬក្មេងជំទង់។ | របស់ជនរងគ្រោះមកពីប្រទេសរបស់ខ្លួន ដើម្បីបង្ហាញពីលក្ខណៈផ្សេងៗគ្នារបស់ជនរងគ្រោះទាក់ទងនឹងអាយុ យេនឌ័រ ទីតាំង។ល។<br>ឧទាហរណ៍ដែលបានមកពីប្រព័ន្ធផ្សព្វផ្សាយ (ដោយមិនបង្ហាញអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ជនរងគ្រោះ)។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • កុមារភេទទីបី ឬកុមារកំពុងស្វែងយល់ពីអត្តសញ្ញាណភេទរបស់ខ្លួន អាចប្រឈមនឹងគ្រោះថ្នាក់កាន់តែខ្ពស់ ហើយក៏ដូចគ្នានេះដែរសម្រាប់កុមារមានពិការភាព (ពិការភាពគ្រប់ប្រភេទ)។ ពិការភាពទាំងនេះ រួមមានពិការភាពផ្នែករាងកាយ ពិការភាពផ្នែកវិញ្ញាណណាមួយ (ឧ. ការលំបាកក្នុងការស្តាប់ ឬការមើលឃើញ) ពិការភាពផ្នែកបញ្ញា និងពិការភាពផ្នែកចិត្តវិកល។<br>• កុមារជាជនរងគ្រោះនៃការរំលោភបំពានច្រើនតែជាកុមារស្ថិតក្នុងស្ថានភាពលំបាក។ ជារឿយៗ ពួកគេច្រើនតែក្រីក្រ រស់នៅតាមចិញ្ចើមថ្នល់/ឆ្នេរសមុទ្រ ពុំបានទៅសាលារៀន មកពីសហគមន៍ជនជាតិដើមភាគតិច ឬមកពីគ្រួសារបែកបាក់។ ជារឿយៗ កុមារច្រើនតែជួបការរំលោភបំពានទម្រង់ដទៃទៀត នៅផ្ទះ ឬនៅតាមផ្លូវ។<br>• ប៉ុន្តែ ជនរងគ្រោះ ក៏អាចមកពីគ្រួសារមានចំណូលមធ្យម និងចំណូលខ្ពស់ផងដែរ។ ពួកគេអាចនឹងរងឥទ្ធិពលពីសម្ភារនិយម (ជារឿយៗ ច្រើនតែរងសំពាធពីមិត្តភក្តិ)។ ម្យ៉ាងទៀត ពួកគេប្រហែលជាពុំបានដឹងពីគ្រោះថ្នាក់ទាក់ទងនឹងស្ថានភាពរបស់ខ្លួនឡើយ។<br>• កុមារក៏អាចត្រូវបានគេស្វែងរកតាមប្រព័ន្ធអ៊ីនធើណេត តាមរយៈបច្ចេកវិជ្ជាឌីជីថលផងដែរ។<br>• មិនគួរយល់ថាកុមារជាអ្នកមានកំហុស ក្នុងការបង្កឱ្យមានការរំលោភបំពានចំពោះខ្លួនឯងឡើយ។<br>• ជានិច្ចកាល កុមារគឺជាជនរងគ្រោះ។<br>• មនុស្សពេញវ័យត្រូវទទួលខុសត្រូវក្នុងការការពារកុមារពីការរំលោភបំពាននេះ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៣៣ ●**<br><br> | • ក្នុងនាមជាពលរដ្ឋដែលមានការទទួលខុសត្រូវ និងជាសមាជិកមួយរូបនៅក្នុងឧស្សាហកម្មទេសចរណ៍សកលលោក (មិនថាអ្នកកាន់មុខតំណែងអ្វី) អ្នកអាចមានឥទ្ធិពលជាវិជ្ជមានលើការកសាងបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់កុមារ។<br>• បុគ្គលិកទេសចរណ៍នៅជុំវិញពិភពលោកកំពុងជួយកសាងបរិស្ថាន "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ។<br>• ជាការសំខាន់ណាស់ដែលអ្នកត្រូវយល់ពីបញ្ហានៃការរំលោភបំពានកុមារក្នុងវិស័យទេសចរណ៍ ហើយអ្នកត្រូវដឹងពីអ្វីដែលអ្នកត្រូវធ្វើ ដើម្បីអាចការពារកុមារពីគ្រោះថ្នាក់បានប្រកបដោយប្រសិទ្ធិភាព។ | ត្រូវធានាថា គ្រប់គ្នាបានយល់អំពីពាក្យដែលមានន័យថា បរិស្ថានទេសចរណ៍អាចធ្វើឱ្យកាន់តែមានសុវត្ថិភាពចំពោះកុមារ តាមរយៈ **ការកាត់បន្ថយឱកាស**កុំឱ្យការរំលោភបំពានកើតឡើង។ |

## វគ្គទី៤ ៖ តើសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍គឺអ្វី ?

### សង្ខេប

*វគ្គសិក្សានេះ ណែនាំអ្នកចូលរួមឱ្យស្គាល់អំពីគោលគំនិត "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" និងថាតើគោលគំនិតនេះផ្តល់អត្ថប្រយោជន៍ចំពោះកុមារ និងឧស្សាហកម្មទេសចរណ៍យ៉ាងដូចម្តេចខ្លះ។*

### លទ្ធផលរំពឹងទុកនៃវគ្គសិក្សា៖

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមនឹងអាច៖

- ពន្យល់ពីទំនាក់ទំនងរវាងទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ និងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។
- កំណត់ពីភាគីពាក់ព័ន្ធសំខាន់ៗ ដែលទទួលខុសត្រូវក្នុងការកសាងសុវត្ថិភាពកុមារក្នុងវិស័យ
- ទេសចរណ៍។
- ទទួលស្គាល់ថា សុវត្ថិភាពកុមារក្នុវិស័យទេសចរណ៍ ពិតជាផ្តល់អត្ថប្រយោជន៍សំខាន់ៗចំពោះវិស័យនេះ។
- កំណត់សមាសធាតុ ដែលបង្កើតឱ្យមានបរិស្ថានដែលមានសុវត្ថិភាពសម្រាប់កុមារក្នុងវិស័យទេសចរណ៍។
- យល់អំពីការទទួលខុសត្រូវផ្ទាល់ខ្លួន និងការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈរបស់ខ្លួនក្នុងការការពារ កុមារពីការរំលោភបំពានកុមារនៅក្នុងវិស័យទេសចរណ៍។

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
|---|---|---|
| ៣០ នាទី | • កាតយកតាមខ្លួន | • ក្រដាសផ្ទាំងធំ<br>• ហ្វឺត |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៣៤** •   | • តើវិស័យទេសចរណ៍អាចធ្វើការឆ្លើយតបនឹងបញ្ហានេះដោយវិធីណា ? តើយើងអាចបង្កើត "ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ" ដោយវិធីណា ? តើ "ទេសចរណ៍<br>ដែលមានសុវត្ថិភាពចំពោះកុមារ" ជាអ្វី ?<br>តើហេតុអ្វីបានជាវាមានសារៈសំខាន់ ? | |
| **ស្លាយទី៣៥** •   | • វិស័យទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារគឺជាវិស័យទេសចរណ៍ដែល៖<br>– ទទួលស្គាល់ តួនាទី និងឥទ្ធិពលជាសក្តានុពលរបស់ខ្លួន មកលើការរំលោភបំពានកុមារ។ | ដើម្បីជំនួយដល់ការយល់ពីអត្ថន័យនៃពាក្យ "ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ" យើងអាចពន្យល់តាមវិធីខាងក្រោម។ ជំហានទី១ គឺជាគ្រឹះ ជំហានទី២ ផ្អែកលើជំហានទី១ ហើយជំហានទីបី គឺផ្អែកលើជំហានទីពីរ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | – **ទទួលខុសត្រូវ** ក្នុងការកាត់បន្ថយផលប៉ះពាល់ដែលបង្កឡើងដោយ គ្រោះថ្នាក់ (ដោយផ្ទាល់ ឬដោយប្រយោល) ទៅលើកុមារដែលងាយ រងគ្រោះ និង<br>– **ប្រកាន់យកតួនាទីសកម្ម** ក្នុងការពង្រឹង **និងរក្សាបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់កុមារទាំងអស់។** | **ការទទួលស្គាល់នូវតួនាទី និងផលប៉ះពាល់** គឺទាក់ទងនឹងការយល់អំពីទំនាក់ទំនង ដូចអ្វីដែលយើងបានធ្វើខាងលើ។ គេប្រហែលជាមើលពុំឃើញច្បាស់ ប៉ុន្តែអ្វីៗគ្រប់យ៉ាងដែលយើងធ្វើ មានផលប៉ះពាល់ដល់អ្នកផ្សេងទៀត។<br>**ការទទួលខុសត្រូវ** ទាក់ទងនឹងបំណង និងការប្តេជ្ញាចិត្តផ្ទាល់ខ្លួន ដើម្បីពិចារណាលើផលប៉ះពាល់ទាំងនេះ នៅពេលធ្វើការជ្រើសរើស និងសម្រេចចិត្ត។<br>**ប្រកាន់យកតួនាទីសកម្ម** ទាក់ទងនឹងការស្វែងរងដោយការប្តេជ្ញាចិត្ត នូវឱកាស និងលទ្ធភាពដោយមានគោលបំណងបង្កើតនូវបរិស្ថានដែលមានសុវត្ថិភាព។ ឧទាហរណ៍ដូចជា ការចាប់យកនូវការផ្តួចផ្តើមគំនិតថ្មីមួយជាដើម។ |
| **ស្លាយទី៣៦**<br> | • វិស័យទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ គឺជាផ្នែកមួយនៃ "ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ"<br>• អ្នកប្រហែលជាស្គាល់ "ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ" រួចហើយ។<br>• ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ គឺយកចិត្តទុកដាក់ក្នុងការថែរក្សាធនធានធម្មជាតិ វប្បធម៌ និងធនធានមនុស្ស ជាពិសេសគឺកុមារដែលត្រូវការកិច្ចការពារជាពិសេស។<br>• អ្នកធ្វើដំណើរកាន់តែច្រើនឡើង គាំទ្រដល់ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ។<br>• ប្រការនេះឆ្លុះបញ្ចាំងពីតម្រូវការរបស់មនុស្សមួយចំនួន ដែលគេគិតថា វាជាការចាំបាច់ក្នុងការស្វែងរកបទពិសោធន៍ "ប្រកបដោយអត្ថន័យល្អ" (ដូចជា "ការស្ម័គ្រចិត្ត") ជាដើម។<br>• ប៉ុន្តែយើងត្រូវធានាឱ្យប្រាកដថាបទពិសោធន៍ទាំងនេះមិនធ្វើឱ្យកុមារប្រឈមនឹងគ្រោះថ្នាក់ ឬមានផលប៉ះពាល់ជាអវិជ្ជមានលើសុខុមាលភាពរបស់ពួកគេឡើយ។ | អ្នកសម្របសម្រួលក៏អាចដាក់បញ្ចូលផ្នែកដែលពាក់ព័ន្ធនៅក្នុងគោលនយោបាយ ឬយុទ្ធសាស្ត្រទេសចរណ៍ជាតិ ដើម្បីឆ្លុះបញ្ចាំងអាទិភាពថ្នាក់ជាតិចំពោះគុណភាព និងការទទួលខុសត្រូវរបស់ទេសចរណ៍ផងដែរ។<br>គោលនយោបាយ និងយុត្តិសាស្ត្រពាក់ព័ន្ធផ្នែកទេសចរណ៍មានដូចជា៖<br>ប្រសិនបើមិនមានស្តង់ដារជាតិទេនោះ អ្នកអាចយោងទៅស្តង់ដារអន្តរជាតិ និងធនធានមួយចំនួនស្តីពីទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ ដូចជាអាចលើកឡើងអំពី៖<br>• ក្រមសីលធម៌សាកល អាចបើកមើលបាននៅ៖ http://www.unwto.org/ethics/index.php |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ គឺត្រូវបានគាំទ្រដោយទីភ្នាក់ងារទេសចរណ៍អន្តរជាតិ រួមមាន អង្គការសហប្រជាជាតិទទួលបន្ទុកវិស័យទេសចរណ៍ ( UNWTO ) ដែលបានបង្កើតឡើងនូវក្រមសីលធម៌ជាសកល ដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាពក្នុងវិស័យទេសចរណ៍។ នៅក្នុងក្រមសីលធម៌ជាសកលនោះបានបញ្ជាក់ថា ការកេងប្រវ័ញ្ចលើកុមារ គឺផ្ទុយទាំងស្រុងពីគោលបំណងនៃទេសចរណ៍។ អង្គការសហប្រជាជាតិទទួលបន្ទុកវិស័យទេស-ចរណ៍បានគាំទ្រនូវយុទ្ធនាការផ្សព្វផ្សាយពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នេះ។<br>• ក្រសួងទេសចរណ៍របស់បណ្តាប្រទេសអាស៊ានទាំងដប់បានចុះហត្ថលេខាលើក្រមសីលធម៌សកលរបស់ UNWTO។ តាមរយៈការចុះហត្ថលេខានេះ ប្រទេសនីមួយៗ បានធ្វើការប្តេជ្ញាចិត្តជាផ្លូវការថា បញ្ឈប់ការរំលោភបំពានលើកុមារដែលកើតឡើងដោយសារវិស័យទេសចរណ៍។ | |
| **ស្លាយទី៣៧** •<br> | • "ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ" ទាមទារនូវកិច្ចខិតខំដែលមានការសហការណ៍គ្នា ពីសំណាក់ដៃគូនានា។ វាតម្រូវឱ្យយើងយល់ មិនត្រឹមតែអំពីតួនាទីរបស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវយល់ពីតួនាទីរបស់អ្នកដទៃទៀតដែរ។ ការយល់ពីតួនាទីរបស់យើង និងតួនាទីរបស់អ្នកដទៃ ជួយយើងឱ្យអាចធ្វើការជាមួយគ្នាបាន។<br>• អ្នកសម្របសម្រួល ត្រូវយោងទៅលើដ្យាក្រាម ដើម្បីនិយាយពីតួនាទីរបស់ភាគីពាក់ព័ន្ធនីមួយៗ។<br>• នៅពេល យើងចង់ជួយកុមារ យើងចាំបាច់ត្រូវជួយគេជាលក្ខណៈរួមគ្នាជាប្រព័ន្ធ ពោលគឺត្រូវជួយគេនៅក្នុងប្រព័ន្ធគ្រួសារ ឬនៅក្នុងប្រព័ន្ធសហគមន៍របស់ពួកគេ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | • វាជាការសំខាន់ណាស់ ដែលត្រូវចងចាំថា ថ្វីបើការការពារកុមារគឺជាការងាររបស់មនុស្សទាំងអស់គ្នាក្តី ប៉ុន្តែមានវិជ្ជាជីវៈមួយចំនួនដែលបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍ក្នុងការធ្វើការងារនេះ និងដឹងច្បាស់ពីសេវានានា ដែលកុមារត្រូវការ។ យើងត្រូវទទួលស្គាល់ពីសារៈសំខាន់នៃតួនាទីរបស់ពួកគេ ហើយត្រូវប្រឹក្សាយោបល់ជាមួយពួកគេ នៅពេលណាដែលចាំបាច់។ បើពុំដូច្នោះទេ យើងប្រហែលជាធ្វើការសម្រេចចិត្តខុស ព្រោះយើងគិតថាយើងមានបំណងល្អ ប៉ុន្តែទង្វើរបស់យើងអាចមិនមានផលល្អដល់កុមារក៏ថាបាន។ បន្ថែមជាងនេះ គឺវាអាចបង្កើតឱ្យមានផលប៉ះពាល់ជាអវិជ្ជមានលើកុមារថែមទៀត។<br>• ឧទាហរណ៍ ពេលខ្លះ ពេលដែលអាជីវកម្ម ឬបុគ្គលណាមួយចង់ជួយកុមារ ពួកគេនឹកឃើញភ្លាមអំពីកុមារដែលស្ថិតក្រោមការថែទាំក្នុងស្ថាប័ន (ដូចជា "មណ្ឌលកុមារកំព្រា" ជាដើម)។ ប៉ុន្តែភស្តុតាងនៅទូទាំងពិភពលោកបង្ហាញថា កន្លែងដ៏ល្អបំផុតសម្រាប់កុមារ គឺនៅក្នុងគ្រួសាររបស់ខ្លួននោះ ដូច្នេះយើងគួរគាំទ្រប្រព័ន្ធនោះវិញទើបជាការប្រសើរ។<br>• នេះជាបរិស្ថានប្រកបដោយសុវត្ថិភាព ដែលយើងចង់បង្កើតឡើង ដើម្បីការពារកុមារប្រកបដោយនិរន្តរភាព។<br>• អាជីវកម្ម អង្គការសហគមន៍ និងភ្នាក់ងារនៅថ្នាក់មូលដ្ឋានរបស់រដ្ឋសុទ្ធតែអាចទទួលខុសត្រូវបន្ថែមទៀត ដើម្បីធានាឱ្យបានថាកុមារបានទទួលសុវត្ថិភាព ព្រមទាំងបង្កើតបរិស្ថានប្រកបដោយការការពារ។<br>• ភ្ញៀវទេសចរខ្លួនឯងផ្ទាល់ ក៏អាចដើរតួនាទីសំខាន់ ក្នុងការគោរពតម្លៃរបស់សហគមន៍ និងសន្តិសុខសង្គមរបស់កុមារ ព្រមទាំងជនងាយរងគ្រោះដទៃទៀត។<br>• ភ្ញៀវទេសចរចាំបាច់ត្រូវបានទទួលព័ត៌មាន និងជួយឱ្យមានការយល់ច្រើន ដើម្បីធ្វើការជ្រើសរើសនិងសម្រេចចិត្ត ដែលអាចជួយរក្សាសុវត្ថិភាពកុមារ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៣៨** ●<br> | តើភ្ញៀវទេសចរ និងអ្នកធ្វើដំណើរចង់ដើរតួនាទីជាអ្វី?<br>• ការស្រាវជ្រាវបានបង្ហាញថា ភ្ញៀវទេសចរដែលមកកាន់តំបន់នេះ ចង់ជួយកុមារ ដែលពួកគេជឿថាកំពុងប្រឈមគ្រោះថ្នាក់ប៉ុន្តែពួកគេប្រហែលអាចយល់ច្រលំចំពោះសកម្មភាពដែលខ្លួនគួរធ្វើ។<br>• ការស្រាវជ្រាវក៏បានបង្ហាញដែរថា ភ្ញៀវទេសចរចង់ចូលរួមចំណែកដោយបំណងល្អ និងចង់បានព័ត៌មានបន្ថែមទៀតអំពីអ្វីដែលពួកគេអាចធ្វើបាន។<br>• ភ្ញៀវទេសចរជាច្រើន គឺគាំទ្រអាជីវកម្មទេសចរណ៍ ដែលមានអនុវត្តគោលការណ៍សុវត្ថិភាពកុមារ។<br>• អ្នកធ្វើដំណើរ និងភ្ញៀវទេសចរ ដែលមកកាន់តំបន់នេះ ចង់បានទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ។<br>• ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារគឺងាយស្រួលអនុវត្ត។<br>• ជាការពិតណាស់ ជាការសំខាន់ដែលត្រូវសង្កត់ធ្ងន់ថា អ្នកទេសចរណ៍ និងអ្នកធ្វើដំណើរម្នាក់ៗ គឺមិនដូចគ្នាទេ។<br>• ភ្ញៀវទេសចរ និងអ្នកធ្វើដំណើរ មានទិដ្ឋភាពផ្សេងៗចម្រុះគ្នា មិនខុសអ្វីពីពិភពលោកនេះឡើយ! | អ្នកសម្របសម្រួលអាចនិយាយយោងទៅលើរបាយការអង្កេតស្តីអំពីអ្នកដំណើរដែលរក្សាសុវត្ថិភាពកុមាររបស់អង្គការទស្សនៈពិភពលោក ដែលមានចំណងជើងថា The Child Safe Traveller<br>ឆ្នាំ២០១៣ ដែលបានធ្វើការស្ទង់មតិអ្នកទេសចរប្រមាណជិត៣០០ នាក់ដែលធ្វើដំណើរមកកាន់តំបន់នេះ ស្តីពីទស្សនៈយល់ឃើញរបស់ពួកគេចំពោះការរំលោភបំពានកុមារ។<br>ដ្យាក្រាមព័ត៌មាន ដែលសង្ខេបការរកឃើញរបស់របាយការណ៍នេះ មាននៅក្នុង**កាតយកតាមខ្លួន (អ្នកធ្វើដំណើរដែលមានសុវត្ថិភាពសម្រាប់កុមារ)**។<br> |
| **ស្លាយទី៣៩** ●<br> | មានឧទាហរណ៍ស្តីពីការបង្កើតថ្មីនៃទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារជាច្រើននៅជុំវិញពិភពលោក។ ការបង្កើតថ្មីទាំងនេះមានដូចជាៈ<br>• ក្រុមហ៊ុនទេសចរណ៍ ដែលបង្ហាញដល់អតិថិជនរបស់ខ្លួនថា អំពីវិធីដែលពួកគេអាចគាំទ្រដល់សហគមន៍មូលដ្ឋាន តាមរយៈ ការធ្វើខ្លួនឱ្យមានការទទួលខុសត្រូវ គោរពវប្បធម៌ក្នុងមូលដ្ឋាន និងការផ្តល់ "ការលើកដៃឡើង" តែមិនមែន "ការលាដៃទៅ" នោះឡើយ។ | អ្នកសម្របសម្រួលអាចបន្ថែមឧទាហរណ៍ល្អ ដែលមាននៅក្នុងប្រទេស ដើម្បីចង្អុលបង្ហាញពីការអនុវត្តន៍ល្អៗ<br>អ្នកសម្របសម្រួល ត្រូវបញ្ជាក់ពីភាពខុសគ្នារវាងគំនិតផ្តួចផ្តើម។គំនិតផ្តួចផ្តើមខ្លះ ផ្តល់ជាគំនិត ខ្លះទៀតផ្តល់នូវការអប់រំ និងខ្លះទៀតគឺជាគំនិតផ្តួចផ្តើម ដែលណែនាំពីសកម្មភាពជាក់ស្តែងតែម្តង។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ក្រុមហ៊ុនទេសចរណ៍ រួមទាំងប្រព័ន្ធផ្សព្វផ្សាយ ដែលចែករំលែកព័ត៌មានជាមួយអតិថិជនរបស់ខ្លួនអំពីរបៀបធ្វើយ៉ាងណាដើម្បីក្លាយជាអ្នកធ្វើដំណើរដែលមានសុវត្ថិភាពចំពោះកុមារ។ | |
| **ស្លាយទី៤០** ●<br> | ឧទាហរណ៍ផ្សេងទៀត អាចមានដូចជា៖<br>• អាជីវកម្ម និងអង្គការទាំងឡាយណាដែលដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពី ការការពារកុមារសម្រាប់ជាការតម្រង់ទិសនិងការអភិវឌ្ឍន៍វិជ្ជាជីវៈដល់បុគ្គលិករបស់ខ្លួន។<br>• អាជីវកម្ម និងអង្គការទាំងឡាយណា ដែលមានគោលនយោបាយការពារកុមារច្បាស់លាស់ ដោយចែងពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះការការពារកុមារ និងមាននីតិវិធីរាយការណ៍ច្បាស់លាស់ ប្រសិនបើមានការរកឃើញ ឬសង្ស័យលើស្ថានភាពណាមួយ។ | អ្នកសម្របសម្រួលអាចបន្ថែម ឬដាក់បញ្ចូលឧទាហរណ៍ក្នុងមូលដ្ឋាន ដើម្បីជាឧទាហរណ៍ បង្ហាញអំពីការអនុវត្តល្អៗដែលកំពុងកើតមាន។ |
| **ស្លាយទី៤១** ●<br> | មានឧទាហរណ៍ស្តីពីគំនិតបង្កើតថ្មី ដើម្បីការពារកុមារផងដែរ ដូចជា៖<br>• ភោជនីយដ្ឋានដែលទទួលយកអតីតជនរងគ្រោះ និង/ឬគ្រួសាររបស់ពួកគេឲ្យធ្វើការងារ។<br>• សហគ្រាសសង្គមដែលផ្តល់ជាជម្រើសនានាដល់មនុស្សវ័យក្មេងដែលងាយរងគ្រោះ និង/ឬគ្រួសាររបស់ពួកគេ។<br>• ផ្សព្វផ្សាយពីទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ កិច្ចពិភាក្សា និងជជែកដេញដោលអំពីប្រធានបទនេះ នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ។ | អ្នកសម្របសម្រួលអាចបន្ថែមឧទាហរណ៍ល្អ ដែលមាននៅក្នុងប្រទេស ដើម្បីចង្អុលបង្ហាញពីការអនុវត្តន៍ល្អៗ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤២**<br> | *សកម្មភាព៖ ការពិភាក្សាក្រុមតូច*<br>• ចែកអ្នកចូលរួមទៅជាក្រុមតូចៗ ទៅតាមក្រុមឯកទេសរបស់ពួកគេ ( ឧទាហរណ៍ បុគ្គលិកសណ្ឋាគារ ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ ភ្នាក់ងារធ្វើដំណើរ និងមគ្គុទ្ទេសន៍ទេសចរណ៍ បុគ្គលិកអាកាសចរណ៍ អ្នកលក់វត្ថុអនុស្សាវរីយ៍ ។ល។ )។<br>• ស្នើឱ្យក្រុមនីមួយៗ គិតពីអត្ថប្រយោជន៍នានា ដែលអាជីវកម្មរបស់ពួកគេ អាចទទួលបានពីវិស័យទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ។<br>• ផ្តល់រយៈពេលប្រាំនាទីសម្រាប់ក្រុមពិភាក្សា។ បន្ទាប់មកសូមអនុញ្ញាតិឱ្យក្រុមនីមួយៗ ចែករំលែកការរកឃើញរបស់ខ្លួន។ | សូមផ្តល់ក្រដាសផ្ទាំងធំដល់ក្រុមដើម្បីកត់ត្រាចម្លើយរបស់ពួកគេ។ |
| **ស្លាយទី៤៣ •**<br> | "ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ" ធ្វើឱ្យអាជីវកម្មទទួលបានផលល្អ។<br>• វាជួយឱ្យក្រុមហ៊ុនអ្នករក្សាបាននូវភាពឈានមុខគេ ក្នុងការឆ្លើយតបនឹងតម្រូវការ នានា<br>• វាឆ្លើយតបនឹងតម្រូវការកាន់តែធំឡើងៗរបស់អ្នកធ្វើដំណើរ និងភ្ញៀវទេសចរដែលចាប់អារម្មណ៍នឹងតំបន់ដែលពួកគេទៅលេង។<br>• វាជួយក្រុមហ៊ុនអ្នកឱ្យរក្សាបាននូវកេរ្តិ៍ឈ្មោះ និងម៉ាកយីហោដ៏គួរឱ្យទាក់ទាញ និងគួរជាទីចូលចិត្ត។<br>• វាជួយឱ្យក្រុមហ៊ុនរបស់អ្នកមានលក្ខណៈខុសប្លែក និងពិសេសជាងបណ្តាក្រុមហ៊ុន និងអាជីវកម្មដទៃទៀត។<br>• វាជួយបង្កើនកេរ្តិ៍ឈ្មោះក្រុមហ៊ុនអ្នក និងកាត់បន្ថយគ្រោះថ្នាក់ក្នុងការមានឈ្មោះអវិជ្ជមាន។<br>• វាជួយឱ្យក្រុមហ៊ុនអ្នកបានទទួលមតិវាយតម្លៃល្អៗពីអតិថិជន។<br>• វាជួយផ្តល់មូលដ្ឋានល្អប្រសើរ ក្នុងការកំណត់តម្លៃខ្ពស់ពីអតិថិជន។<br>• ភាគីពាក់ព័ន្ធផ្នែកអាជីវកម្មដទៃទៀត ទំនងជានឹងជួយផ្សព្វផ្សាយអំពីអាជីវកម្មរបស់អ្នកតាមបណ្តាញរបស់ពួកគេ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ចំណុចទាំងអស់ខាងលើ សុទ្ធតែផ្តល់ឱ្យនូវប្រាក់ចំណេញ និងគាំទ្រដល់ការលូតលាស់រយៈពេលវែងសម្រាប់ក្រុមហ៊ុនអ្នក។<br>ទេសចរណ៍ដែលមានសុវត្ថិភាពសម្រាប់កុមារ គឺជាទស្សនៈទានមួយ នឹងជាបទពិសោធន៍ផ្នែកទេសចរណ៍គួរជាទីចាប់អារម្មណ៍ ដែលធ្វើឲ្យមនុស្សចង់ស្វែងយល់អំពីវា។ វាអាចជួយឲ្យអតិថិជនឱ្យមានអារម្មណ៍ល្អ។ ក្រុមហ៊ុនអាចទទួលបានប្រាក់ចំណេញ តាមរយៈការផ្តល់បទពិសោធន៍ទាំងនេះ (ដោយសុឆន្ទៈ) ដល់អតិថិជនដោយខ្លួនឯង បើពុំដូច្នោះទេ អ្នកដទៃគេនឹងធ្វើមុនយើង។ | |
| **ស្លាយទី៤៤** ●<br><br> | "ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ" ក៏ជួយដល់ក្រុមហ៊ុនអ្នកឱ្យអាចបំពេញការទទួលខុសត្រូវផ្នែកសង្គមរបស់សាជីវកម្មផងដែរ។<br>• វាទាក់ទាញអ្នកធ្វើដំណើរដែលយកចិត្តទុកដាក់ចំពោះសង្គម (អតិថិជនបច្ចុប្បន្នស្វែងរកក្រុមទាំងឡាយណាដែលការពារកុមារ និងបរិស្ថាន។ យើងអាចបង្វែរអ្នកធ្វើដំណើរទាំងអស់នេះឱ្យចេញពីបទពិសោធន៍ដូចជា "ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" ដែលបង្កគ្រោះថ្នាក់ដល់កុមារ។ ការធ្វើដូចនេះ អាចលើកកំពស់ក្រុមហ៊ុនឧស្សាហកម្មទេសចរណ៍ដែលគាំទ្រដល់សេដ្ឋកិច្ចសហគមន៍ជំនួសវិញ)។<br>• លើកកំពស់ការផ្សាយពាណិជ្ជកម្មពីមាត់មួយទៅមាត់មួយ(អតិថិជនដែលមានការយកចិត្តទុកដាក់ផ្នែកសង្គម នឹងណែនាំអ្នកទៅឱ្យមិត្តភក្តិរបស់ពួកគេ)។<br>• រដ្ឋាភិបាល និងសហគមន៍ចង់បានក្រុមហ៊ុនដែលមានការទទួលខុសត្រូវ (រដ្ឋាភិបាលចង់ជួលអាជីវកម្មទាំងឡាយណា ដែលគាំទ្រកម្មវិធីការពារកុមារថ្នាក់ជាតិ)។<br>• ស្រដៀងគ្នានេះដែរ សហគមន៍តែងចង់បានក្រុមហ៊ុនទាំងឡាយណាដែលបង្ហាញការទទួលខុសត្រូវរបស់ខ្លួន ក្នុងការរក្សាកុមារឲ្យមានសុវត្ថិភាពពីការរំលោភបំពាន)។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • នាំឱ្យមានអ្នកវិនិយោគ ដែលយកចិត្តទុកដាក់ផ្នែកសង្គម (អ្នកវិនិយោគមានចំណាប់អារម្មណ៍កាន់តែច្រើនចំពោះក្រុមហ៊ុនទាំងឡាយណាដែលបង្ហាញឲ្យឃើញការទទួលខុសត្រូវផ្នែកសង្គមរបស់អាជីវកម្មបានល្អ)<br>• អាចជួយដល់អាជីវកម្មឱ្យជ្រើសរើស និងរក្សាទុកបុគ្គលិក (ដោយហេតុថាបុគ្គលិកចូលចិត្តធ្វើការនៅក្នុងអាជីវកម្មដែលផ្តោតត្រឡប់ទៅឲ្យសហគមន៍វិញ)។<br>• ធ្វើឲ្យគុណភាពវិស័យទេសចរណ៍កាន់តែប្រសើរឡើង (ទេសចរណ៍មានគុណភាពកាន់តែប្រសើរឡើងមានន័យថា គ្មានការបំផ្លាញវប្បធម៌ ហេដ្ឋារចនាសម្ព័ន្ធ និងសេវានានាកាន់តែប្រសើរឡើង មុខរបរ និងអាជីវកម្មកាន់តែច្រើន និងបរិស្ថានការងារដែលមានសុវត្ថិភាពនិងមានការអភិវឌ្ឍន៍ទៅមុខ)។ | |

## វគ្គទី៩ ៖ តើបុគ្គលម្នាក់ៗ អាចធ្វើដូចម្តេចខ្លះ ដើម្បីឱ្យកុមារមានសុវត្ថិភាពក្នុងវិស័យទេសចរណ៍ ?

### សង្ខេប

*វគ្គនេះនឹងផ្តល់ឱ្យអ្នកចូលរួមនូវឧទាហរណ៍នានាស្តីពីសកម្មភាពជាក់ស្តែងដែលពួកគេអាចធ្វើបានក្នុងនាមជាបុគ្គលដើម្បីការពារកុមារក្នុងវិស័យទេសចរណ៍។*

**សម្គាល់៖ ក្នុងករណីការបណ្តុះបណ្តាលនេះ ផ្តោតគោលដៅលើថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និង/ឬមន្ត្រីរដ្ឋាភិបាល អ្នកអាចបង្រៀនមេរៀននេះដោយសង្ខេប ឬអាចសង្ខេបខ្លីៗបាន រួចអ្នកសម្របសម្រួលអាចបន្តទៅមេរៀនទីប្រាំមួយ ឬប្រាំពីរបានតែម្តង។**

### លទ្ធផលសិក្សាដែលរំពឹងទុក

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមនឹងមានសមត្ថភាពអាច៖

- ពិចារណាថា តើសកម្មភាពអ្វីខ្លះ ដែលពួកគេអាចធ្វើបានក្នុងនាមជាបុគ្គល ដើម្បីការពារកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍។
- យល់អំពីអត្ថប្រយោជន៍នៃការធ្វើសកម្មភាពជួយ ជាជាងការព្រងើយកណ្តើយក្នុងពេលដែលកុមារអាចប្រឈមទៅនឹងគ្រោះថ្នាក់។
- កំណត់នូវកម្រងសកម្មភាពដែលពួកគេអាចធ្វើ ដើម្បីការពារកុមារនៅក្នុងសេណារីយ៉ូករណីសិក្សា ដែលនឹងផ្តល់ជូនក្នុងវគ្គសិក្សានេះ។

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
|---|---|---|
| ៧៥ នាទី | • កាតយកតាមខ្លួន ទីបួន<br>• បុគ្គលិកទេសចរណ៍ ករណីសិក្សា និងការសម្តែងតួ ( **ឧបសម្ព័ន្ធទី៦** ) | • ក្រដាសផ្ទាំងធំ<br>• ហ្វឺត |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤៥**<br><br> | មិនថាយើងជាបុគ្គល សមាជិកសហគមន៍ អាជីវកម្មខ្នាតតូច ឬក្រុមហ៊ុនធំៗនោះឡើយ យើងទាំងអស់គ្នាសុទ្ធតែអាចចូលរួមចំណែក ដើម្បីធ្វើឱ្យទេសចរណ៍មានសុវត្ថិភាព សម្រាប់កុមារ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤៦**<br> | ក្នុងនាមជាមនុស្សធ្វើការក្នុងអាជីវកម្ម មានសកម្មភាពជាច្រើនដែលយើងអាចធ្វើបាន ដើម្បីធ្វើឱ្យវិស័យទេសចរណ៍ក្លាយជាមានសុវត្ថិភាពសម្រាប់កុមារ ហើយដែលអាចរក្សាឱ្យបាននគង់វង្សនៃអាជីវកម្ម ដែលអ្នកកំពុងដំណើរការផងដែរ។ សកម្មភាពទាំងនេះអាចអាស្រ័យលើករណី និងកុមារម្នាក់ៗ និងពីវិធីដែលយើងអាចជួយការការពារ នៅក្នុងសហគមន៍របស់យើង។<br><br>**១. គោរពកុមារ**<br>ជាដំបូង យើងអាចគោរពកុមារដោយចាប់ផ្ដើមពីខ្លួនយើងមុន។ ត្រូវធានាឲ្យបានថាអាកប្បកិរិយារបស់អ្នកមានភាពសមស្របចំពោះកុមារ។ ការធ្វើដូចនេះគឺអាចការពារកុមារផង និងការពារខ្លួនឯងផង។<br>ឧទាហរណ៍៖<br>• ជានិច្ចកាលត្រូវប្រព្រឹត្តចំពោះកុមារដោយក្ដីគោរព<br>• មិនត្រូវឱ្យលុយកុមារដែលសុំទាន (ចូរជ្រើសរើសជម្រើសសមស្របផ្សេងទៀត ដូចជាជួយគាំទ្រដល់ឪពុកម្ដាយកុមារជំនួសវិញ។ អ្នកអាចធ្វើដូច្នេះបានតាមវិធីជាច្រើន ហើយវិធីដែលងាយស្រួលបំផុតគឺតាមរយៈការបរិច្ចាគទៅដល់ស្ថាប័នមនុស្សធម៌ណាមួយ ដែលផ្ដល់ការជួយជ្រោមជ្រែងដល់គ្រួសារប្រឈមនឹងគ្រោះថ្នាក់ និងគ្រួសារងាយរងគ្រោះ។<br>• ត្រូវជៀសវាងនូវការប៉ះពាល់ផ្នែករាងកាយដែលមិនចាំបាច់ចំពោះកុមារដែលមិនមែនជាសមាជិកគ្រួសាររបស់អ្នក<br>• សូមស្ដាប់សម្ដីរបស់កុមារដោយប្រុងប្រយ័ត្ន | សូមយោងទៅលើ **កាតយកតាមខ្លួន (តើយើងអាចធ្វើអ្វីបានខ្លះ ដើម្បីធ្វើឲ្យបរិស្ថានទេសចរណ៍មានសុវត្ថិភាពសម្រាប់កុមារ?)**<br> |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤៧**<br><br> | **២. លើកកំពស់ការយល់ដឹង**<br>• អ្នកអាចលើកកម្ពស់ការយល់ដឹងបាន តាមរយៈការនិយាយប្រាប់គ្រួសារ មិត្តភក្តិ មិត្តរួមការងារ អតិថិជន របស់អ្នកក៏ដូចជាសហគមន៍របស់អ្នកស្តីពីគ្រោះថ្នាក់ចំពោះកុមារនិងលើកទឹកចិត្តឱ្យពួកគេការពារកុមារផងដែរ។<br>• អ្នកក៏អាចចែកកាតយកតាមខ្លួន និងសម្ភារផ្សព្វផ្សាយផ្សេងទៀត នៅក្នុងថ្ងៃបណ្តុះបណ្តាលនេះ។<br>• បើកមើលគេហទំព័រ www.childsafetourism.org រួចជួយផ្សព្វផ្សាយដល់អ្នកដទៃ។<br>• ការដែលយើងនាំគ្នានិយាយកាន់តែច្រើនពីបញ្ហានេះ យើងនឹងឃើញថាមានសន្ទុះកាន់តែច្រើនក្នុងការឆ្លើយតបក្នុងសហគមន៍។ | |
| **ស្លាយទី៤៨**<br><br> | **៣. ត្រូវប្រុងប្រយ័ត្ននិងស្គាល់សញ្ញាដែលបង្ហាញថា កុមារអាចស្ថិតនៅក្នុងគ្រោះថ្នាក់**<br>• ចំណុចនេះទាក់ទងនឹងការយកចិត្តទុកដាក់ចំពោះអ្វីដែលកំពុងកើតឡើងនៅជុំវិញខ្លួនអ្នក និងការគិតគូរពិចារណា អំពីស្ថានភាពដែលកុមារអាចងាយរងគ្រោះ។<br>• ចំណុចនេះពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ចំពោះអារម្មណ៍ខាងក្នុងខ្លួនយើងចំពោះកុមារងាយរងគ្រោះ។ ជារឿយៗយើងច្រើនតែបិទភ្នែកមើលរំលង ការឃើញកុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះ (កុមារសុំទានតាមផ្លូវ) ព្រោះយើងពិបាកក្នុងចិត្ត និងមិនចង់ឃើញកុមារនៅក្នុងស្ថានភាពលំបាកបែបនោះ។<br>• នៅកន្លែងដែលមានកុមារប្រឈមនឹងគ្រោះថ្នាក់ច្រើន អ្នកអាចលើកពីក្តីបារម្ភរបស់អ្នកនៅក្នុងកម្មវិធីជួបជុំ របស់សហគមន៍ និង នៅក្នុងការប្រជុំនានារបស់អាជ្ញាធរមូលដ្ឋាន។ | ជាការសំខាន់ណាស់ដែលត្រូវជួយសម្រាលក្តីបារម្ភរបស់អ្នកចូលរួម ដោយបញ្ជាក់ថាចំណុចនេះមិនមែនមានន័យថាពួកគាត់ត្រូវទទួលខុសត្រូវចំពោះស្ថានភាពរងគ្រោះរបស់កុមារតែម្នាក់ឯងនោះឡើយ។ ផ្ទុយទៅវិញត្រូវយល់អំពីលទ្ធភាពរបស់ខ្លួន។ សូមបញ្ជាក់ឱ្យច្បាស់ៗថា យើងពិតជាមានដែនកំណត់ក្នុងការធ្វើអ្វីដែលយើងអាធ្វើបាន ឬមិនអាចធ្វើបាន ប្រសិនបើយើងមិនមានតួនាទីការងារដែលមានសមត្ថកិច្ចទេនោះ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤៩**<br><br> | ៤. សូមធ្វើសកម្មភាព ប្រសិនបើអ្នកឃើញកុមារម្នាក់កំពុងប្រឈមនឹងគ្រោះថ្នាក់<br>សកម្មភាពទាំងនេះអាចរួមមាន៖<br>• ប្រាប់អ្នកគ្រប់គ្រង ឬប្រធានរបស់អ្នក។<br>• គោរពតាមគោលការណ៍ណែនាំដែលមានចែងក្នុងគោលនយោបាយការពារកុមាររបស់ក្រុមហ៊ុនអ្នក (ប្រសិនបើមាន)<br>• សរសេរចេញមកនូវព័ត៌មានលម្អិតនូវអ្វីដែលអ្នកបានឃើញ ប្រសិនបើអាចកន្លែង និងពេលវេលាដែលអ្នកបានឃើញ (ដើម្បីជានាថាអ្នកនឹងមិនភ្លេច)។<br>• ធ្វើការរាយការណ៍ជាផ្លូវការ។ | ប្រការនេះតម្រូវឱ្យមានការយល់ដឹងថា យើងអាចធ្វើសកម្មភាព ខ្លះទៅតាមសិទ្ធិអំណាច និងសមត្ថភាពផ្ទាល់ខ្លួនរបស់យើង។ |
| **ស្លាយទី៥០**<br><br> | • ជាការចាំបាច់ណាស់ដែលអ្នកត្រូវធ្វើសកម្មភាព ប្រសិនបើមានកុមារកំពុងប្រឈមនឹងគ្រោះថ្នាក់។<br>• បើយើងព្រងើយកន្តើយចំពោះបញ្ហានេះ កុមារនឹងប្រឈមគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះការរំលោភបំពាន។<br>• ប្រសិនបើអ្នកជ្រើសរើសយកការរាយការណ៍ អាជ្ញាធរមានសមត្ថកិច្ចអាចស្រាវជ្រាវដោយយកចិត្តទុកដាក់ ដើម្បីកំណត់ថាតើមានបញ្ហាអ្វីឬទេ ហើយពេលនោះ កុមារអាចនឹងបានទទួលការការពារពីការរំលោភបំពាន។ | |
| **ស្លាយទី៥១**<br><br> | • មានវិធីជាច្រើនដើម្បីរាយការណ៍៖<br>– ជូនដំណឹងដល់អ្នកគ្រប់គ្រងរបស់អ្នកអំពីស្ថានភាពនោះ។<br>– ទូរសព្ទ័ទៅទូរសព្ទ័ទាន់ហេតុការណ៍ការពារកុមារថ្នាក់ជាតិ<br>– ទំនាក់ទំនងទៅអាជ្ញាធរមូលដ្ឋាន<br>– ទាក់ទងទៅភ្នាក់ងារការពារកុមារដែលធ្លាប់មានកេរ្តិ៍ឈ្មោះល្អក្នុងការជួយសង្គ្រោះកុមារ | មុនពេលបណ្តុះបណ្តាល អ្នកសម្របសម្រួលគួររកព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងនូវរាល់កន្លែងដែលអ្នកចូលរួមអាចរាយការណ៍បានពីករណីសង្ស័យ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ជាការសំខាន់ណាស់ នៅពេលអ្នកធ្វើរបាយការណ៍មួយ អ្នកចាំបាច់ត្រូវផ្តល់ព័ត៌មានឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានព័ត៌មានទាំងអស់នេះរួមមាន៖<br>– តើអ្នកបានឃើញអ្វី ?<br>– តើអ្នកបានឃើញនៅទីណា ?<br>– តើអ្នកបានឃើញនៅពេលណា ?<br>– តើមាននរណាខ្លះពាក់ព័ន្ធ ?<br>– តើព័ត៌មានលម្អិតអ្វីខ្លះដែលអ្នកដឹងអំពីបុគ្គលដែលប្រហែលជាកំពុងតែកេងប្រវ័ញ្ចលើកុមារ ? (ភេទ អាយុ រូបរាង សញ្ជាតិ។ល។)<br>– តើព័ត៌មានលម្អិតអ្វីខ្លះ ដែលអ្នកដឹងអំពីកុមារដែលប្រហែលជាកំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពាន (ភេទ អាយុ រូបរាង)។<br>– ក្នុងនាមជាភាគីពាក់ព័ន្ធមួយក្នុងវិស័យទេសចរណ៍ អ្នកពុំមែនជាប៉ូលីសនោះឡើយ។ កាតព្វកិច្ចរបស់យើងគឺមិនមែនទៅចោទប្រកាន់ ឬធ្វើអន្តរាគមន៍នៅក្នុងលក្ខណៈមិនសមស្របនោះឡើយ។ ការធ្វើបែបនេះអាចធ្វើឱ្យអ្នកមានគ្រោះថ្នាក់។<br>• ផ្ទុយទៅវិញជាការសំខាន់ណាស់ដែលត្រូវរាយការណ៍ទៅឱ្យអាជ្ញាធរដែលពាក់ពន្ធ័ ដោយហេតុថាពួកគាត់បានទទួលការបណ្តុះបណ្តាល ក្នុងការធ្វើសកម្មភាពដោយសមស្រប។ | សូមយោងទៅលើ **កាតយកតាមខ្លួន** ( **តើខ្ញុំត្រូវរាយការណ៍ដោយរបៀបណា** ? )<br><br> |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr><td>

**ស្លាយទី៥២**




</td><td>

*សកម្មភាពៈ ការសម្តែងតួទេសចរណ៍*

- ចែកសំណៅសាច់រឿង "សម្រាប់សម្តែងតួឲ្យអ្នកចូលរួមទាំងអស់"( **ឧបសម្ព័ន្ធទី៦** )។
- អញ្ជើញអ្នកចូលរួមបួននាក់ឱ្យចូលរួមជាតួខុសៗគ្នា។ ណែនាំអ្នកផ្សេងទៀតថាពួកគាត់ត្រូវមើលការសំដែងតួ និងត្រូវឆ្លើយតបទៅនឹងសំណួរនៅពេលបញ្ចប់ការសម្តែង។
- អនុញ្ញាតឱ្យអ្នកចូលរួមទាំងបួននាក់ចាកចេញពីបន្ទប់រយៈពេលបីនាទី ដើម្បីត្រៀមខ្លួន។ សូមអ្នកចូលរួមដទៃទៀតពិចារណាថាតើពួកគាត់នឹងធ្វើដូចម្តេចប្រសិនបើពួកគាត់ជាអ្នកទទួលភ្ញៀវនៅសណ្ឋាគារ។
- អញ្ជើញអ្នកស្មគ្រ័ចិត្តឱ្យចាប់ផ្តើមសម្តែងតួ។ ក្រោយពីការសម្តែងតួហើយ សូមសួរសំណួរដែលមាននៅក្នុង ( **ឧបសម្ព័ន្ធ៦** )។

</td><td></td></tr>
<tr><td>

**ស្លាយទី៥៣** •




</td><td>

*សកម្មភាពៈ ខ្សែរឿងករណីសិក្សា*

- ចែកអ្នកចូលរួមក្នុងថ្នាក់ទៅជាក្រុមតូចៗ។ ប្រសិនជាអាចសូមចែកពួកគាត់ទៅតាមប្រភេទការងារប្រហាក់ប្រហែលគ្នា ( ឧ. បុគ្គលិកសណ្ឋាគារ មគ្គុទេសក៏នាំភ្ញៀវទេសចរ អ្នកបើកតាក់ស៊ី )
- ចែកសំណៅ "ខ្សែរឿងករណីសិក្សាសម្រាប់បុគ្គលិកទេសចរណ៍" ( **នៅក្នុងឧបសម្ព័ន្ធទី៦** ) ទៅឱ្យក្រុមនីមួយៗ។
- សូមឱ្យក្រុមនីមួយៗពិភាក្សាករណីសិក្សា និងត្រៀមខ្លួនឆ្លើយតបទៅនឹងសំណួរដែលមាននៅក្នុងឯកសារចែកជូនរបស់ពួកគេ។ ពិភាក្សាទៅលើការឆ្លើយតបរបស់ក្រុមនីមួយៗ។

</td><td></td></tr>
</table>

## វគ្គទី ៦ ៖ តើអាជីវកម្មអាចធ្វើយ៉ាងណា ដើម្បីឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ? (សម្រាប់អ្នកគ្រប់គ្រង ម្ចាស់អាជីវកម្មតែប៉ុណ្ណោះ)

### សង្ខេប

*វគ្គសិក្សានេះ នឹងផ្តល់ឱ្យអ្នកចូលរួមនូវសកម្មភាពងាយៗ និងមិនអស់ថវិកាច្រើន) ដែលពួកគេ អាចការពារនិងរក្សាសុវត្ថិភាពកុមារ នៅក្នុងអាជីវកម្មរបស់ពួកគេ។*

**សម្គាល់៖ ប្រសិនបើការបណ្តុះបណ្តាល ផ្តោតគោលដៅលើបុគ្គលិកទេសចរណ៍ ដែលមានតួនាទីសាមញ្ញៗនោះ ដូចនេះមេរៀននេះ គឺមិនត្រូវនឹងយកមកបង្រៀនទេ។ អ្នកសម្របសម្រួលគួរបន្តទៅផ្នែកសន្និដ្ឋាន។ ប្រសិនបើការបណ្តុះបណ្តាលនេះ ផ្តោតគោលដៅចំពោះមន្ត្រីរដ្ឋាភិបាល អ្នកគួរបន្តទៅមេរៀនទីប្រាំពីរតែម្តង។**

### លទ្ធផលរំពឹងទុកនៃវគ្គសិក្សា:

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមនឹងអាច៖

- បញ្ជាក់អំពីវិធីនានា ដែលពួកគាត់អាចធ្វើសកម្មភាព នៅក្នុងដែនសមត្ថកិច្ចរបស់ពួកគេ ដើម្បីធ្វើឱ្យបរិស្ថានទេសចរណ៍កាន់តែមានសុវត្ថិភាពសម្រាប់កុមារ (អាស្រ័យនៅលើមុខតំណែងរបស់ពួកគេនៅក្នុងវិស័យទេសចរណ៍ រាប់បញ្ចូលទាំងសកម្មភាពផ្ទាល់ខ្លួនជាលក្ខណៈបុគ្គល ការបង្កើតគោលនយោបាយ យុទ្ធនាការផ្សព្វផ្សាយជាដើម។ល។)
- ទទួលបានការជម្រុញទឹកចិត្តផុសផុល ក្នុងការនិយាយអំពីភាពងាយរងគ្រោះពីការកេងប្រវ័ញ្ចរបស់កុមារ នៅក្នុងសហគមន៍របស់ពួកគេ។

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
|---|---|---|
| ៦០ នាទី | • កាតយកតាមខ្លួន<br>• "សេណារីយ៉ូករណីសិក្សាសម្រាប់អ្នកគ្រប់គ្រងផ្នែកទេសចរណ៍" (**ឧបសម្ព័ន្ធទី៧**) | • ក្រដាសផ្ទាំងធំ<br>• ហ្វឺត |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៥៤**<br><br> | • មិនថាជាលក្ខណៈបុគ្គល អាជីវកម្មខ្នាតតូច ឬជាក្រុមហ៊ុនធំក្តី ក៏យើងទាំងអស់គ្នាអាចធ្វើ ឱ្យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ។<br>• មានសកម្មភាពសាមញ្ញៗជាច្រើន ដែលអាជីវកម្មទេសចរណ៍អាចជះឥទ្ធិពលជាវិជ្ជមានចំពោះទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ ហើយដែលនឹងផ្តល់អត្ថប្រយោជន៍ដល់អាជីវកម្មរបស់អ្នកផងដែរ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៥៥**<br><br> | *សកម្មភាព៖ តើអាជីវកម្មទេសចរណ៍របស់ខ្ញុំមានសុវត្ថិភាពសម្រាប់កុមារកម្រិតណា ?*<br>• ចែកកាតយកតាមខ្លួន "តើអាជីវកម្មរបស់ខ្ញុំមានសុវត្ថិភាពសម្រាប់កុមារកម្រិតណា ?"<br>• ប្រាប់អ្នកចូលរួមឱ្យបំពេញការស្ទង់មតិ និងបូកពិន្ទុរបស់ពួកគេ។<br>• ឱ្យអ្នកចូលរួមលើកដៃឡើង ប្រសិនបើពួកគេទទួលបានពិន្ទុ "៥"។ សូមលើកសរសើរដល់អាជីវកម្មទាំងនេះ ចំពោះកិច្ចខិតខំរបស់ពួកគេ ក្នុងការការពារកុមារ។ សួរសំណួរទៅពួកគេ ថា "តើពួកគេអនុវត្តវិធានការការពាររបស់ពួកគេដោយរបៀបណា និងលទ្ធផលជោគជ័យដែលកើតចេញមក។<br>• សុំឱ្យអ្នកចូលរួមដែលបានពិន្ទុ "៤" ឬ តិចជាងនេះឱ្យលើកដៃឡើង។ ពន្យល់ប្រាប់ពួកគេថា ពួកគេកំពុងស្ថិតក្នុងទីតាំងដ៏ល្អបំផុត ក្នុងការធ្វើសកម្មភាពសមស្រប ដើម្បីការពារកុមារពីការរំលោភបំពាន។ | សូមយោងទៅលើ **កាតយកតាមខ្លួន ("តើអាជីវកម្មទេសចរណ៍របស់ខ្ញុំមានសុវត្ថិភាពចំពោះកុមារកម្រិតណា ?")**<br><br> |
| **ស្លាយទី៥៦**<br><br> | **វិធីសាមញ្ញៗ ដែលអ្នកអាចធ្វើឱ្យអាជីវកម្មរបស់អ្នកមានសុវត្ថិភាពចំពោះកុមារ**<br>• ជារឿយៗ អាជីវកម្មច្រើនតែគិតថាការការពារកុមារជារឿងពិបាក។<br>• តាមពិតជំហានទាំងនោះគឺងាយស្រួល ហើយវាមិនត្រឹមតែជួយការពារកុមារតែប៉ុណ្ណោះទេ តែថែមទាំងជួយអាជីវកម្មរបស់ខ្លួន ឱ្យកាន់តែប្រសើរថែមទៀតផង។<br>• អាជីវកម្មរបស់អ្នកអាចការពារកុមារបានដោយរបៀបណា គឺអាស្រ័យទៅលើធម្មជាតិនៃការងាររបស់អ្នក និងគំនិតបង្កើតថ្មីរបស់អ្នកមានប្រសិទ្ធិភាពកំរិតណា។<br>• មានសកម្មភាពច្រើន ដែលអ្នកអាចធ្វើបាននៅក្នុងអាជីវកម្មរបស់អ្នក ជាមួយអតិថិជន/អ្នកផ្គត់ផ្គង់របស់អ្នក និងជាមួយសហគមន៍ដែលអ្នកកំពុងប្រតិបត្តិការ។ | សូមយោងទៅលើ **កាតយកតាមខ្លួន (" វិធីដើម្បីធ្វើឱ្យអាជីវកម្មខ្ញុំមានសុវត្ថិភាពចំពោះកុមារ")**<br><br> |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | *១. នៅក្នុងអាជីវកម្មរបស់អ្នក*<br>• បង្កើត និងអនុវត្តគោលនយោបាយការពារកុមារ។<br>• ផ្តល់ការបណ្តុះបណ្តាលស្តីពីការការពារកុមារសម្រាប់បុគ្គលិកទាំងអស់។ បង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិករបស់អ្នក។ អ្នកអាចប្រើសម្ភារបណ្តុះបណ្តាលទាំងនេះ ឬអញ្ជើញអ្នកជំនាញឱ្យទៅជួយអ្នកក្នុងការបណ្តុះបណ្តាល។<br>• លើកទឹកចិត្តដល់បុគ្គលិករបស់អ្នក ឱ្យធ្វើសកម្មភាព និងគោរពតាមគោលនយោបាយការពារកុមារ។ ផ្តល់ឱ្យបុគ្គលិកនូវចំណេះដឹង និងជំនាញ ដើម្បីឆ្លើយតបក្នុងករណីពួកគេសង្កេតឃើញមានគ្រោះថ្នាក់ចំពោះកុមារ។ សូមផ្តល់រង្វាន់ដល់បុគ្គលិកណាដែលនិយាយចេញមក និងគោរពតាមគោលនយោបាយ។<br>• សរសេរលេខទូរស័ព្ទធំៗ និងច្បាស់ៗសម្រាប់ការរាយការណ៍ពីកង្វល់ និងរាយការណ៍បន្ត។ ការបញ្ជូននេះ អាចជាប៉ូលីសក្នុងស្រុក សេវាសង្គមកិច្ច ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន។ គួរត្រួតពិនិត្យបែបបទនៃការបញ្ជូន យ៉ាងហោចណាស់ប្រាំមួយខែម្តង។ | គោលនយោបាយការពារកុមារ យ៉ាងហោចណាស់ ក៏ត្រូវចែងអំពីស្តង់ដារ និងគោលការណ៍របស់ក្រុមហ៊ុន ទាក់ទងនឹងការរំលោភបំពានកុមារដែរ។ បន្ថែមលើនេះទៀត គួរចែងពីអាកប្បកិរិយា ទង្វើ និងព្រឹត្តិការណ៍បែបណា ដែលគួររាយការណ៍ ប្រសិនបើមានការសង្ស័យ។ គួរពន្យល់ឱ្យច្បាស់ អំពីដំណាក់កាលតាមលំដាប់លំដោយ ពីរបៀបរាយការណ៍ករណីសង្ស័យទាំងនោះ។ គួរធ្វើឱ្យនិយោជិតទាំងអស់ មានអារម្មណ៍ទុកចិត្តថា អ្នកគ្រប់គ្រងរបស់ខ្លួនគាំទ្រគោលនយោបាយនេះ។ ( សូមមើលស្លាយខាងក្រោមដើម្បីទទួលបានព័ត៌មានបន្ថែមទៀត )។ វត្តនេះ ព្យាយាមជម្រុញឱ្យមានគោលនយោបាយការពារកុមារ។ |
| **ស្លាយទី៥៧**<br> | *២. ជាមួយអតិថិជន/អ្នកផ្គត់ផ្គង់របស់អ្នក*<br>• ជម្រាបជូនអតិថិជន និងក្រុមហ៊ុនដទៃទៀត អំពីការប្តេជ្ញាចិត្តរបស់អ្នក។ ដាក់បញ្ចូលព័ត៌មានអំពីការប្តេជ្ញាចិត្តរបស់អ្នកលើទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ នៅក្នុងឯកសាររបស់ក្រុមហ៊ុនអ្នក រួមទាំងការផ្សាយពាណិជ្ជកម្ម គេហទំព័រ សម្ភារផ្សព្វផ្សាយ និងវិក្កយប័ត្រ។<br>• លើកកំពស់ការយល់ដឹងអំពីទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ តាមរយៈការដាក់តាំងបង្ហាញនូវសារផ្សព្វផ្សាយនៅតាមការិយាល័យចុះឈ្មោះ ពេលគឺនៅតាមទីតាំងចំហ នៅក្នុងអាជីវកម្មរបស់អ្នក។ អ្នកអាចទាញយកសារផ្សព្វផ្សាយពីគេហទំព័រ៖ www.childsafetourism.org. | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៥៨**<br><br> | *៣. ក្នុងសហគមន៍របស់អ្នក*<br>• គាំទ្រដល់កម្មវិធីកុមារ ដែលមានប្រវត្តិល្អក្នុងការជួយកុមារ។ ស៊ើបរកកម្មវិធីនានាដែលកំពុងផ្តល់ការគាំទ្រដល់កុមារក្នុងតំបន់របស់អ្នក។ សូមរកវិធីងាយស្រួលដែលអ្នកអាចគាំទ្រកម្មវិធីទាំងនេះបាន (ឧ. ការចូលជាថវិកា ការបរិច្ចាគអាហារ ឬសម្លៀកបំពាក់)។<br>• ផ្តល់ឱកាសការងារ/បង្ហាត់បង្រៀនដល់គ្រួសារកុមារប្រឈមគ្រោះថ្នាក់។ ផ្តល់និងបង្កើតឱកាសថ្មីៗសម្រាប់គ្រួសារស្ថិតក្នុងការលំបាក ជារឿយៗតែងជួយកាត់បន្ថយគ្រោះថ្នាក់ដែលកុមារជួបប្រទះ។ សូមពិចារណាលើរាល់វិធីទាំងឡាយណា ដែលអ្នកអាចជួយសម្រួលដល់ឪពុកម្តាយក្នុងតំបន់របស់អ្នក ដោយផ្តល់ឱកាសការងារសមស្របដល់ពួកគាត់។<br>• លើកឡើងនូវបញ្ហាទូទៅ ស្តីពីភាពងាយរងគ្រោះរបស់កុមារនៅក្នុងសហគមន៍មូលដ្ឋាន តាមរយៈការនិយាយទៅកាន់បណ្តាញគណកម្មការនានា អភិបាល មន្ត្រីរដ្ឋាភិបាល ចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ និងអ្នកតំណាងដទៃទៀត។<br>• ត្រូវមានគំនិតច្នៃប្រឌិតខ្ពស់។ តើអ្នកអាចធ្វើអ្វីបានខ្លះ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរល្អក្នុងជីវិតកុមារ ? បាក្រដជាមានសកម្មភាពអ្វីម៉្យាង ដែលអ្នកអាចធ្វើបាននៅក្នុងអាជីវកម្មអ្នក ដែលអាចជះឥទ្ធិពលជាវិជ្ជមានដល់ការកសាងបរិស្ថានមួយដែលមានសុវត្ថិភាពចំពោះកុមារ។ យើងលើកទឹកចិត្តអ្នកឱ្យមានភាពច្នៃប្រឌិតខ្ពស់។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៥៩**<br> | តើត្រូវសរសេរគោលនយោបាយការពារកុមារដូចម្ដេច?<br>• អ្នកគ្រប់គ្រងជាច្រើនគិតថា ការសរសេរគោលនយោបាយគឺជារឿងពិបាក។ ប៉ុន្តែការរៀបចំគោលនយោបាយការពារកុមារសម្រាប់អាជីវកម្មរបស់អ្នក គឺជារឿងមួយដ៏សាមញ្ញ។<br>• គោលនយោបាយការពារកុមារ គឺជាឯកសារជាលាយលក្ខណ៍អក្សរដ៏សាមញ្ញមួយ (អាចតិចជាងមួយទំព័រផងក៏មាន) ដែលឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖<br>– តើអ្វីជាការប្ដេជ្ញាចិត្តរបស់ក្រុមហ៊ុនខ្ញុំក្នុងការការពារកុមារ? ប្រយោគនេះអាចជាប្រយោគដ៏សាមញ្ញមួយ ដែលពន្យល់ថា អ្នកនឹងមិនអត់ទ្រាំចំពោះការរំលោភបំពានឡើយ ហើយអ្នករំពឹងថាបុគ្គលិក និងអ្នកគ្រប់គ្រងទាំងអស់នឹងគោរពតាមគោលនយោបាយនេះ។<br>– តើអ្នកនឹងអនុវត្តនីតិវិធីអ្វី ដើម្បីការពារកុមារពីការរំលោភបំពាន? ចំណុចនេះពន្យល់អំពីសកម្មភាពដែលអ្នកនឹងធ្វើ ដើម្បីការពារកុមារពីការកេងប្រវ័ញ្ច។ ចំណុចនេះ អាចរួមបញ្ចូលនូវ៖<br>» ការបណ្ដុះបណ្ដាលសម្រាប់បុគ្គលិកទាំងអស់ ដើម្បីឱ្យពួកគេអាចឆ្លើយតបទៅនឹងការការពារកុមារ។<br>» ការរំពឹងទុកថា បុគ្គលិកទាំងអស់នឹងរាយការណ៍អំពីកង្វល់ផ្នែកការពារកុមារទាំងអស់ទៅថ្នាក់គ្រប់គ្រង។<br>» ការប្ដេជ្ញាចិត្ត ដែលថ្នាក់គ្រប់គ្រងនឹងស៊ើបអង្កេតទៅលើការរាយការណ៍ និងជូនដំណឹងដល់អាជ្ញាធរដែលពាក់ព័ន្ធ។<br>• សូមចងចាំថា៖ គោលនយោបាយរបស់អ្នកត្រូវតែសាមញ្ញ ងាយស្រួលអនុវត្ត និងអាចធ្វើបានងាយៗ។<br>• អ្វីដែលសំខាន់បំផុតនោះគឺថាគោលនយោបាយរបស់អ្នកមិនគ្រាន់តែជាពាក្យនៅលើក្រដាសតែប៉ុណ្ណោះទេ ប៉ុន្តែគួរតែចែងឱ្យច្បាស់ អំពីគោលការណ៍ណែនាំនានាដែលអ្នកគ្រប់គ្រង និងបុគ្គលិកទាំងអស់ត្រូវអនុវត្តតាមយ៉ាងសកម្ម។ | អ្នកសម្របសម្រួល គួរព្យាយាមលុប បំបាត់នូវគំនិតយល់ខុសឆ្គងអំពីដំណើរការនៃការសរសេរគោលនយោបាយ។ អ្នកគ្រប់គ្រងជាច្រើន មិនមានបទពិសោធន៍សរសេរគោលនយោបាយកាលពីមុនមកទេ។ ពួកគេនឹងរីករាយ ហើយស្វាគមន៍នូវការដឹងពីវិធីងាយៗក្នុងការរៀបចំគោលនយោបាយការពារកុមារ។<br>សូមយោងតាម **កាតយកតាមខ្លួន** (**"ការសរសេរគោលនយោបាយការពារកុមារ"**)<br> |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៦០**<br><br> | *សកម្មភាព៖ ការសរសេរគោលនយោបាយការពារកុមារ (តាមជម្រើស)*<br>• សុំឱ្យអ្នកចូលរួមសរសេរគោលនយោបាយការពារកុមារសម្រាប់កន្លែងធ្វើការងាររបស់ពួកគេ។ សូមលើកទឹកចិត្តពួកគេឱ្យសរសេរគោលនយោបាយនេះ ដោយលក្ខណៈជាក់ស្តែង និងសមស្របបំផុតតាមដែលអាចធ្វើទៅបាន។<br>• ផ្តល់ពេល ១០ នាទីដល់ការសរសេរគោលនយោបាយ។ បន្ទាប់មក សុំឱ្យអ្នកចូលរួមពិភាក្សាលើគោលនយោបាយរបស់ពួកគេនៅក្នុងក្រុម ដែលរួមមានមនុស្សមកពីកន្លែងធ្វើការងារប្រហាក់ប្រហែលគ្នា (ឧ.ផ្ទះសំណាក់ សេវាដឹកជញ្ជូន)។ សូមលើកទឹកចិត្តអ្នកចូលរួមឱ្យ "ចម្លងតាម" គំនិតដែលអ្នកដទៃបានប្រើ ប្រសិនបើគំនិតទាំងនោះសមស្របសម្រាប់យកទៅប្រើនៅក្នុងអាជីវកម្មរបស់ពួកគេដែរ។<br>• បន្ទាប់ពីការពិភាក្សាក្រុមមក សូមសួរថាតើមានក្រុមណាមួយ ដែលអាចកំណត់ឃើញនូវគោលនយោបាយដ៏ល្អមួយ ដែលពួកគេបានឮនៅក្នុងក្រុមរបស់ពួកគេឬទេ ហើយសូមអញ្ជើញបុគ្គលនោះឱ្យឡើងអាន / ពន្យល់ឱ្យអ្នកដទៃទៀតស្តាប់។ | |
| **ស្លាយទី៦១ ●**<br><br> | *សកម្មភាព៖ ខ្សែរឿងករណីសិក្សា*<br>• ចែកអ្នកចូលរួមនៅក្នុងថ្នាក់ទៅជាក្រុមតូចៗ។ ប្រសិនបើអាច សូមចែកអ្នកចូលរួមទៅតាមក្រុមប្រភេទការងារដែលប្រហាក់ប្រហែលគ្នា (ឧ. បុគ្គលិកសណ្ឋាគារ មគ្គុទ្ទេសក៏នាំភ្ញៀវទេសចរ អ្នកបើកតាក់ស៊ី)<br>• ចែកសំណៅ "ខ្សែរឿងករណីសិក្សាអំពីអ្នកគ្រប់គ្រងផ្នែកទេសចរណ៍" (នៅក្នុងឧបសម្ព័ន្ធទី៧) ទៅដល់ក្រុមនីមួយៗ។<br>• ឲ្យក្រុមនិមួយៗពិភាក្សាលើករណីសិក្សានីមួយៗ និងរៀបចំចម្លើយតបទៅនឹងសំណួរដែលផ្តល់ឲ្យ នៅក្នុងឯកសារដែលចែកជូន។<br>• ពិភាក្សាលើចម្លើយរបស់ក្រុមនីមួយៗ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៦២**<br><br> | *សកម្មភាព៖ ដំណោះស្រាយអាជីវកម្ម (តាមជម្រើស)*<br>• សកម្មភាពនេះចាប់ផ្តើមជាលក្ខណៈបុគ្គល។ ប្រាប់អ្នកចូលរួមឱ្យគិតអំពីអាជីវកម្មរបស់ខ្លួនផ្ទាល់ និងពិចារណាថាតើមានសកម្មភាពងាយៗ ដែលពួកគេអាចអនុវត្ត ដើម្បីធ្វើឲ្យវិស័យទេសចរណ៍មានសុវត្ថិភាពសម្រាប់កុមារ។<br>• ផ្តល់ពេលប្រាំនាទី ឱ្យអ្នកចូលរួមគិត។<br>• ប្រាំនាទីក្រោយមក សូមប្រាប់ពួកគាត់ឲ្យគិតអំពីការអនុវត្តគំនិតទាំងនេះ( តើពួកគាត់នឹងធ្វើការងារនោះដោយរបៀបណា ? ពេលណា ? តើមាននរណាខ្លះដែលនឹងពាក់ព័ន្ធ តើពួកគេត្រូវការធនធានអ្វីខ្លះ ? )។<br>• បន្ទាប់មកទៀត សូមលើកទឹកចិត្តអ្នកចូលរួមឲ្យប្រើប្រាស់លំហាត់នេះជាផែនការអាជីវកម្មការពារកុមាររបស់ពួកគេ។ សូមស្នើទៅអ្នកចូលរួម ឲ្យដាក់លេខរៀងទៅតាមលំដាប់លំដោយនៃភាពសំខាន់របស់ចំណុចនីមួយៗ ជាពិសេសត្រូវកំណត់ថាតើចំណុចណាមួយដែលត្រូវធ្វើជាបន្ទាន់។<br>• សួរទៅអ្នកចូលរួមថា តើមាននរណាមានបំណងចង់ចែករំលែកនូវអ្វីដែលពួកគេនឹងធ្វើជាមួយក្រុមឬទេ។សូមទះដៃឲ្យអ្នកចូលរួមម្នាក់ៗដែលបានចែករំលែកគំនិតរបស់ពួកគេ។ សូមអញ្ជើញអ្នកចូលរួមដទៃទៀតឲ្យចម្លងតាមគំនិតទាំងឡាយណាដែលសមស្រប ដែលអ្នកចូលរួមដទៃទៀតបានចែករំលែក។ | |

## វគ្គទី៧ ៖ តើរដ្ឋាភិបាលអាចធ្វើយ៉ាងណាខ្លះ ដើម្បីឱ្យវិស័យទេសចរណ៍មានសុវត្ថិភាព ចំពោះកុមារ? (សម្រាប់តែមន្ត្រីរដ្ឋាភិបាល)

### សង្ខេប

*វគ្គនេះណែនាំអ្នកចូលរួមឱ្យដឹងច្បាស់ពីតួនាទីដ៏សំខាន់របស់រដ្ឋាភិបាល ក្នុងការធ្វើឱ្យកុមាររួចផុតពីការរំលោភបំពានរួមទាំងក្នុងវិស័យទេសចរណ៍ និងសមាសជាតុនានា ដែលបង្កើតឱ្យមានប្រព័ន្ធការពារកុមារដែលមានសុវត្ថិភាព។ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឱ្យពិនិត្យប្រព័ន្ធការងាររបស់ខ្លួនផ្ទាល់ និងលើកឧទាហរណ៍អំពីការអនុវត្តន៍ល្អៗដែលមាន។*

**សម្គាល់៖ មេរៀននេះ គឺត្រូវប្រើសម្រាប់កម្មវិធីបណ្ដុះបណ្ដាលសម្រាប់មន្ត្រីរដ្ឋាភិបាលប៉ុណ្ណោះ។ ប្រសិនបើកម្មវិធីបណ្ដុះបណ្ដាលមានអ្នកចូលរួមភាគច្រើនមកពីវិស័យទេសចរណ៍នោះ អ្នកសម្របសម្រួលគួររំលងទៅវគ្គសន្និដ្ឋានតែម្ដង។**

### លទ្ធផលរំពឹងទុកនៃវគ្គសិក្សា៖

នៅចុងបញ្ចប់វគ្គនេះ អ្នកចូលរួមនឹងអាច៖

- យល់អំពីតួនាទីរបស់រដ្ឋាភិបាលថ្នាក់ជាតិ/ខេត្តក្នុងការការពារកុមារ ឲ្យមានសុវត្ថិភាពពីកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងវិស័យទេសចរណ៍ដោយផ្ដោតការយកចិត្តទុកដាក់ពិសេសទៅលើក្រសួង/មន្ទីររបស់ខ្លួនផ្ទាល់។
- កំណត់នូវសមិទ្ធិផលផលរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហានេះ។
- ស្គាល់ឧទាហរណ៍នៃការអនុវត្តល្អៗ ពីបណ្ដាប្រទេសដទៃទៀត និងលទ្ធភាពក្នុងការអនុវត្តន៍នៅក្នុងប្រទេសរបស់ខ្លួន។
- ពិនិត្យទៅលើវិស័យនានាដែលទាមទារឲ្យមានការកែលំអ និងសកម្មភាពជាក់លាក់ដែលអាចធ្វើបាននៅ កម្រិតជាតិ/ខេត្ត ដើម្បីការពារកុមារឲ្យបានកាន់តែប្រសើរ។
- គោរពទទួលស្គាល់ថា ការការពារកុមារក្នុងវិស័យទេសចរណ៍ទាមទារឲ្យមានកិច្ចសហប្រតិបត្តិការណ៍រវាងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត ហើយក្នុងនោះរដ្ឋាភិបាលជាអ្នកដើរតួនាទីយ៉ាងសំខាន់។

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
|---|---|---|
| ៦០នាទី – ២.៥ម៉ោង (អាស្រ័យទៅលើការជ្រើសរើសសកម្មភាព) | • កាតយកតាមខ្លួន | • ក្រដាសផ្ទាំងធំ<br>• ហ្វឺតសរសេរ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៦៣**<br><br> | • ការរក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ឬ គឺជាការទទួលខុសត្រូវរួមគ្នារបស់ភាគីពាក់ព័ន្ធជាច្រើន ដូចជាឪពុកម្ដាយ អ្នកថែទាំ អាជ្ញាធរ សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន គឺសុទ្ធតែមានតួនាទីសំខាន់ក្នុងការការពារកុមារ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ប៉ុន្តែ រដ្ឋាភិបាលមានការទទួលខុសត្រូវយ៉ាងធំធេង ទៅលើការការពារសិទ្ធិកុមាររួមទាំងកិច្ចការពារទៅលើការរំលោភបំពានផ្លូវភេទកុមារ។ ថ្វីបើក្រសួង ឬមន្ទីរណាមួយមានតួនាទីឈានមុខគេក្នុងការងារនេះក្តី ប៉ុន្តែក្រសួង និងមន្ទីររដ្ឋាភិបាលជាច្រើនសុទ្ធតែដើរតួនាទីក្នុងការងារនេះ។ | |
| **ស្លាយទី៦៤**<br><br> | • មិនថាអ្នកធ្វើការនៅក្នុងរដ្ឋាភិបាលថ្នាក់ជាតិ ឬថ្នាក់ខេត្តនោះឡើយ ក៏អ្នកមានតួនាទីការពារកុមារពីគ្រោះថ្នាក់ និងការរំលោភបំពាននានាដែរ។<br>• ប្រទេសកម្ពុជាគឺជាហត្ថលេខីមួយនៅក្នុងអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធកុមារ។ រដ្ឋាភិបាលកម្ពុជាមានការទទួលខុសត្រូវក្នុងការប្តេជ្ញាចិត្តក្នុងការធានាការពារសិទ្ធិកុមារ ហើយរដ្ឋាភិបាលក៏បានព្រមព្រៀងថានឹងទទួលខុសត្រូវចំពោះការប្តេជ្ញាចិត្តនេះចំពោះមុខសហគមន៍អន្តជាតិផងដែរ។<br>• មិនខុសពីរដ្ឋដទៃទៀតនៅក្នុងអនុសញ្ញានេះទេ ប្រទេសកម្ពុជា មានកាតព្វកិច្ចអនុវត្តន៍សកម្មភាព និងគោលនយោបាយទាំងអស់ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ | • ប្រសិនបើសមស្រប សូមចែកសំណៅអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិកុមារ ដែលមានមួយទំព័រ និងរំលឹកដល់តំណាងរដ្ឋាភិបាលពីសិទ្ធិជាក់លាក់ដែលឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចលើកុមាររួមទាំងការរំលោភបំពានផ្លូវភេទផងដែរ។<br>• ប្រសិនបើអាចធ្វើបាន សូមចែកអត្ថបទសង្ខេបនៃរដ្ឋធម្មនុញ្ញរបស់ជាតិ/ច្បាប់ជាតិស្តីអំពីសិទ្ធិកុមារ និងការការពារកុមារ។ |
| **ស្លាយទី៦៥**<br><br> | *សកម្មភាព៖ តើវិស័យទេសចរណ៍ក្នុងប្រទេសរបស់ខ្ញុំមានសុវត្ថិភាពសម្រាប់កុមារកម្រិតណា?*<br>• សូមយើងពិចារណាអំពីវិធានការសុវត្ថិភាពដែលបានអនុវត្តដោយរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន ដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពានក្នុងវិស័យទេសចរណ៍ ពិសេសគឺការរំលោភបំពានផ្លូវភេទ។<br>• សូមយោងទៅកាតយកតាមខ្លួន "តើទេសចរណ៍នៅប្រទេសរបស់ខ្ញុំមានសុវត្ថិភាពកម្រិតណាចំពោះកុមារ?" និង សូមស្នើទៅអ្នកចូលរួមឱ្យបំពេញលើសន្លឹកស្ទង់មតិ និងគណនាពិន្ទុរបស់ពួកគេ។ | សូមយោងទៅ **កាតយកតាមខ្លួន "តើទេសចរណ៍នៅប្រទេសរបស់ខ្ញុំមានសុវត្ថិភាពកម្រិតណាចំពោះកុមារ?"**<br><br> |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | • ឲ្យអ្នកចូលរួមលើកដៃ ឡើងប្រសិនបើពួកគេបានទទួលពិន្ទុចាប់ពី "១១" ឡើង។<br>• សូមសរសើរអ្នកតំណាងទាំងអស់នេះ ចំពោះកិច្ចខិតខំរបស់រដ្ឋាភិបាលពួកគេក្នុងការការពារកុមារ។ ជាមួយគ្នានេះផងដែរ សូមសួរសំណួរ អំពីវិធី ដែលពួកគេអនុវត្តវិធានកិច្ចការពារកុមាររបស់ខ្លួន និងពីជោគជ័យដែលពួកគេបានទទួល។<br>• សូមឲ្យអ្នកចូលរួមដែលបានពិន្ទុ "១០" ឬតិចជាងនេះលើកដៃឡើង។ សូមពន្យល់ប្រាប់ទៅពួកគេថា ពួកគេស្ថិតក្នុងទីតាំងល្អបំផុតដើម្បីធ្វើសកម្មភាពសមស្របក្នុងការការពារកុមារពីការរំលោភបំពាន។<br>• សូមពន្យល់ប្រាប់ អ្នកចូលរួមថា ពួកគេអាចនឹងមិនដឹងចំលើយទាំងអស់នោះទេ។ សូមនិយាយបន្តថា "ហេតុដូចនេះ ដល់ពេលដែលត្រូវស្រាវជ្រាវបន្ថែម ដើម្បីពិនិត្យមើលថាតើរបស់ប្រទេសយើង បានធ្វើអ្វីខ្លះ និងដល់កម្រិតណា"។ | • មុនពេលវគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលគួរប្រមូលចម្លើយ ពីការធ្វើតេស្តនេះជាមុនសិន។ សូមប្រើចម្លើយទាំងអស់នេះសម្រាប់ជាមគ្គុទេសក៏សម្រាប់មន្ត្រីរដ្ឋាភិបាល នៅពេលពួកគេកំពុងពិចារណារកសកម្មភាពសមស្របសម្រាប់រដ្ឋាភិបាលទាំងនៅកម្រិតជាតិ និងកម្រិតខេត្ត។<br>• សូមគូសបញ្ជាក់ថា ការការពារកុមារពីគ្រោះថ្នាក់មានន័យថា ការពារពួកគេឲ្យរួចផុតពីការរំលោភបំពានគ្រប់ប្រភេទ។ ប្រសិនបើយើងផ្តោតតែទៅលើ "ការរំលោភបំពានផ្លូវភេទ" យើងនឹងបរាជ័យនៅក្នុងការការពារកុមារឱ្យបានគ្រប់គ្រាន់ព្រោះថាមានមូលហេតុ និងឫសគល់នៃរំលោភបំពានដទៃទៀត។<br>• វិធានការទប់ស្កាត់ការពារទាមទារនូវវិធានការឆ្លើយតប ដែលមានលក្ខណៈទូលំទូលាយជាងនេះ។ |
| **ស្លាយទី៦៦**<br><br> | សូមយោងទៅ **កាតយកតាមខ្លួន "វិធីដែលរដ្ឋាភិបាលអាចធ្វើឲ្យទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ"**<br>ពន្យល់ប្រាប់អំពីជំហានសំខាន់ៗដែលរដ្ឋាភិបាលអាចធ្វើបាន ដើម្បីការពារកុមារពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍។ សូមផ្តល់ឧទាហរណ៍ក្នុងស្រុកអំពីអ្វីដែលបានធ្វើរួចហើយ។<br><br> | • ប្រសិនបើអាច សូមអញ្ជើញមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលឱ្យមកផ្តល់បទបង្ហាញរយៈពេល ៥នាទី។<br>• វត្ថុបំណងសំខាន់សម្រាប់បទបង្ហាញនេះ គឺដើម្បីសង្កត់ធ្ងន់ថារដ្ឋាភិបាលថ្នាក់ជាតិយកចិត្តទុកដាក់ខ្លាំងចំពោះការការពារកុមារក្នុងវិស័យទេសចរណ៍ ជាពិសេសគឺការរំលោភបំពានផ្លូវភេទ និងរំពឹងថាក្រសួង និងនាយកដ្ឋានពាក់ព័ន្ធរបស់រដ្ឋាភិបាល(នៅកម្រិតជាតិនិងកម្រិតខេត្ត) អនុវត្តតាមការប្តេជ្ញាចិត្តទាំងអស់នេះ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | | • បទបង្ហាញនេះគួរលើកឡើងដោយសង្ខេបបំផុតនូវចំនុចដូចខាងក្រោម៖<br>១. តើប្រទេសរបស់យើងចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅពេលណា?<br>២.តើនរណាជាទីភ្នាក់ងាររដ្ឋាភិបាលដែលនាំមុខគេក្នុងការរក្សាកុមារឲ្យមានសុវត្ថិភាពក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ? តើក្រសួងដទៃណាទៀតដែលទទួលខុសត្រូវ?<br>៣. តើយើងមានផែនការសកម្មភាពជាតិដែលពាក់ព័ន្ធឬទេ? ប្រសិនបើមានសូមពិពណ៌នាជាសង្ខេបពីការប្តេជ្ញាចិត្តដែលមាននៅក្នុងនោះ? ប្រសិនបើមិនមានទេសូមពិពណ៌នាជាសង្ខេបអំពីយុទ្ធសាស្រ្ត/គោលនយោបាយដទៃទៀត របស់រដ្ឋាភិបាល ដែលឆ្លើយតប ទៅនឹងបញ្ហាកិច្ចការពារកុមាររួម ទាំងនៅក្នុងវិស័យទេសចរណ៍ផងដែរ។<br>៤. លើកកម្ពស់វិស័យទេសចរណ៍ដែលមាននិរន្តភាព និងមានសុវត្ថិភាពសម្រាប់កុមារ។<br>៥. សង្កត់ធ្ងន់ថារដ្ឋាភិបាលថ្នាក់ជាតិយកចិត្តទុកដាក់ខ្ពស់លើការការពារកុមារពីការកេងប្រវ័ញ្ចក្នុងវិស័យទេសចរណ៍ និងរំពឹងថាក្រសួងនិងមន្ទីដែលពាក់ព័ន្ធរបស់រដ្ឋាភិបាល (នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត)គោរពតាមការប្តេជ្ញាចិត្តនេះ។<br>៦. លើកទឹកចិត្តអ្នកចូលរួមឱ្យបន្តផ្តល់គំនិតណា ដែលរដ្ឋាភិបាលអាចធ្វើឲ្យសកម្មភាពរបស់ខ្លួនក្នុងការរក្សាកុមារឱ្យមានសុវត្ថិភាពកាន់តែប្រសើរឡើង។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៦៧**<br><br> | • ក្រសួង និងមន្ទីរជាច្រើន អាចចូលរួមវិភាគទាន ដើម្បីធ្វើឱ្យមានបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់កុមារ។<br>? *សំណួរឆ្លុះបញ្ចាំង/ការពិភាក្សា*<br>• តើមន្ទីរ និងក្រសួងណាខ្លះ ដែលទទួលខុសត្រូវក្នុងការការពារកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍នៅប្រទេសកម្ពុជា ?<br>• តើនាយកដ្ឋានទាំងនេះមានតួនាទី និងការទទួលខុសត្រូវជាក់លាក់អ្វីខ្លះ ទាក់ទងនឹងការការពារកុមារ ?<br>• តើគ្រប់គ្នាយល់ច្បាស់អំពីទំនាក់ទំនងរវាងការងារមួយទៅការងារមួយ ដើម្បីធ្វើការរួមគ្នាក្នុងការការពារកុមារឬទេ ? | អ្នកសម្របសម្រួល ចាំបាច់ត្រូវដឹងអំពីភាគីពាក់ព័ន្ធផ្នែករដ្ឋា-ភិបាលសំខាន់ៗ និងគួរលើកទឹក ចិត្តអ្នកចូលរួមឱ្យនិយាយអំពីក្រសួង/មន្ទីរនានានៅថ្នាក់ជាតិ និងថ្នាក់ខេត្ត រួមទាំងក្រសួង/មន្ទីរ ដែលទាក់ទងនឹងវិស័យទេសចរណ៍ មហាផ្ទៃ យុត្តិធម៌ ជម្រុញការអនុវត្តន៍ សុខុមាលភាពសង្គម អប់រំ សុខភាព កិច្ចការពារកុមារ។ សូមពិចារណាផងដែរទៅលើអង្គការមិនមែនរដ្ឋាភិបាល និងសេវាដែលគាំទ្រដោយរដ្ឋាភិបាលដទៃទៀត។ |
| **ស្លាយទី៦៨**<br><br> | • ការការពារកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍ ជាពិសេសគឺការរំលោភបំពានផ្លូវភេទ ទាមទារនូវប្រព័ន្ធការពារកុមារជាច្រើនកម្រិត ដែលរួមបញ្ចូលនូវៈ<br>– អាកប្បកិរិយាផ្នែកសង្គម<br>– ប្រព័ន្ធផ្នែកច្បាប់ និងបទបញ្ញត្តិ<br>– ប្រព័ន្ធសុខុមាលភាពសង្គម<br>• វិស័យទាំងនេះគឺមានទំនាក់ទំនងគ្នាទៅវិញទៅមក និងបង្កើតជាយន្តការសម្រាប់ប្រព័ន្ធការពារកុមារប្រកបដោយប្រសិទ្ធិភាព។ ធាតុទាំងអស់នេះរួមគ្នា អាចបង្កើតជាបរិស្ថានប្រកបដោយការការពារសម្រាប់កុមារ។<br>• នៅពេលយើងនិយាយអំពី "ប្រព័ន្ធ" យើងមិនមែនចង់និយាយអំពីរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតឡើងនោះទេ។ ផ្ទុយទៅវិញ នេះគឺជាវិធីមួយ ក្នុងការរៀបចំនូវអ្វីដែលចាំបាច់តែប៉ុណ្ណោះ។ (អង្គការយូនីសេហ្វ ឆ្នាំ២០០៩ កញ្ចប់ឧបករណ៍យុទ្ធសាស្ត្រកម្មវិធីការពារកុមារ) | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | • អ្នកសម្របសម្រួលគួរពិពណ៌នាសមាសធាតុនីមួយៗ នៃប្រព័ន្ធការពារកុមារ៖<br>• **អាកប្បកិរិយាសង្គម៖** គឺជាឥរិយាបថ និង អាកប្បកិរិយារបស់បុគ្គល ក្រុម និង ស្ថាប័ន។ ឥរិយាបថ និងអាកប្បកិរិយាទាំងនេះ រួមទាំងចំណេះដឹង និងប្រព័ន្ធជំនឿផ្លូវការ និងក្រៅផ្លូវការ។<br>• **ប្រព័ន្ធផ្នែកច្បាប់និងបទបញ្ញត្តិ៖** ច្បាប់ គោលនយោបាយ និងយន្តការជម្រុញការអនុវត្តន៍ (រួមទាំងយុត្តិធម៌)។<br>• **ប្រព័ន្ធសុខមាលភាពសង្គម៖** សេវាសង្គមជាច្រើន ជុំវិញសុខមាលភាព ការអភិវឌ្ឍន៍ និងការការពារកុមារ (រួមទាំងសេវានានាដែលផ្តោតទិសដៅចំពោះកុមារ) (អង្គការយូនីសេហ្វ ឆ្នាំ ២០០៩ កញ្ចប់ឧបករណ៍យុទ្ធសាស្ត្រកម្មវិធីការពារកុមារ) | |
| **ស្លាយទី៦៩**<br><br> | *សកម្មភាព ប្រព័ន្ធការពារកុមារ*<br>• បែងអ្នកចូលរួមជាបីក្រុម។ ក្រុមនីមួយៗ នឹងត្រូវផ្តោតលើប្រធានបទណាមួយ ក្នុងចំណោមប្រធានបទខាងក្រោម៖<br>– អាកប្បកិរិយាសង្គម<br>– ច្បាប់ និងបទបញ្ញត្តិ<br>– សុខុមាលភាពសង្គម<br>• នៅក្នុងក្រុមពិភាក្សា សូមស្នើឱ្យអ្នកចូលរួមធ្វើបញ្ជីឈ្មោះ និងតួនាទីរបស់ក្រសួង និង មន្ទីរដែលទទួលខុសត្រូវ និងកំពុងបំពេញភារកិច្ច ក្នុងវិស័យនេះ ដែលផ្សារភ្ជាប់ជាពិសេសជាមួយនឹងការរំលោភបំពាន (ជាពិសេសគឺលើការរំលោភបំពានផ្លូវភេទ) ចំពោះកុមារក្នុងវិស័យទេសចរណ៍ (មិនថាតាមយន្តការដោយផ្ទាល់ ឬដោយប្រយោលក្តី)។ | • ដើម្បីជួយជម្រុញការគិត អ្នកសម្របសម្រួលត្រូវផ្តល់ឧទាហរណ៍ខាងក្រោមនេះ ដើម្បីបង្ហាញពីការងារក្រោមចំណាត់ប្រភេទនីមួយៗ៖<br>– បំលាស់ប្តូរអាកប្បកិរិយាសង្គម៖ យុទ្ធនាការអប់រំសម្រាប់កុមារ គ្រួសារ ឬសាធារណជន បណ្តាញទូរស័ព្ទជំនួយ ការផ្តល់ព័ត៌មាន ដូចជាព័ត៌មានអំពីគ្រោះថ្នាក់ចំពោះកុមារ ការលើកទឹកចិត្តឱ្យមានការទទួលខុសត្រូវកាន់តែច្រើនពីសមាជិកសហគមន៍នៅក្នុងការការពារកុមារ បង្កើនកិច្ចសន្ទនាតាមរយៈប្រព័ន្ធផ្សព្វផ្សាយអំពីការការពារកុមារ។<br>– ច្បាប់ និងបទបញ្ញត្តិ៖ បទដ្ឋានទេសចរណ៍សម្រាប់ សណ្ឋាគារ និង សេវានានា នីតិវិធីត្រួតពិនិត្យ សម្រាប់មនុស្សពេញវ័យដែលធ្វើការជាមួយកុមារ ប្រព័ន្ធយុត្តិធម៌សម្រាប់ការការពារកុមារ ការរាយការណ៍អំពីកង្វល់ និងសំណុំរឿងផ្នែកការការពារកុមារ ការទទួលខុសត្រូវជាផ្លូវការចំពោះសេវាការពារកុមារ ទៅកាន់ប៉ូលីស ឬអាជ្ញាធរមូលដ្ឋាន។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | • ផ្តល់ពេលដប់នាទី ដើម្បីឲ្យអ្នកចូលរួមកត់ត្រាការឆ្លើយតបរបស់ពួកគេ។ សុំឱ្យក្រុមនីមួយៗចាត់តាំងអ្នកតំណាងម្នាក់ ដើម្បីចែករំលែកអំពីគំនិតរបស់ក្រុមខ្លួន។ ផ្តល់ឱកាសសម្រាប់ឲ្យសមាជិកក្រុមដទៃទៀត ធ្វើការពិភាក្សា និងបន្ថែមនូវចំណុចថែមទៀត។ | – សុខុមាលភាពសង្គម៖ អ្នកមានវិជ្ជាជីវៈដែលធ្វើការងារផ្ទាល់ជាមួយកុមារ ការបញ្ជូន ការកសាងសមត្ថភាពដល់បុគ្គលិកសង្គមកិច្ច ការថែទាំកាន់តែប្រសើរសម្រាប់កុមារប្រឈមនឹងគ្រោះថ្នាក់ការគាំទ្រកាន់តែប្រសើរដល់គ្រួសារដែលប្រឈមនឹងគ្រោះថ្នាក់ ឱកាសអភិវឌ្ឍផ្នែកមុខរបរសម្រាប់ឪពុកម្តាយដែលងាយរងគ្រោះ។ |
| **ស្លាយទី៧០**<br><br> | *ឧទាហរណ៍ពីការអនុវត្តន៍ល្អៗ*<br>• រដ្ឋាភិបាលជុំវិញពិភពលោក កំពុងណែនាំឲ្យមានប្រព័ន្ធជាផ្លូវការ ដើម្បីការពារកុមារពីអ្នកដែលអាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់ពួកគេ។<br>• ក្នុងប្រទេសជាច្រើន តម្រូវឱ្យអ្នកទាំងឡាយណាដែលធ្វើការ ឬស្ម័គ្រចិត្តធ្វើការងារជាមួយកុមារត្រូវទទួលការ "ត្រួត ពិនិត្យ" ឬ "វាយតម្លៃ" ជាមុន។ និយោជកទៅសាកសួរប៉ូលីសក្នុងស្រុក/ថ្នាក់ជាតិ ដើម្បីដឹងថាតើអនាគតនិយោជិតនោះធ្លាប់ទទួលការចោទប្រកាន់ឬការសម្រេចឱ្យជាប់ទោសអ្វី ដែលធ្វើឱ្យគេមិនសក្តិសមធ្វើការជាមួយកុមារឬទេ ? ( ឧទាហរណ៍៖ តើធ្លាប់មានបទល្មើសប្រឆាំងកុមារ បទល្មើសថ្នាំញៀន បទល្មើសការវាយដំ ឬអំពើហិង្សា ឬទេ។ )<br>• ដើម្បីឱ្យប្រព័ន្ធនេះមានប្រសិទ្ធិភាពទៅបាន ប៉ូលីសជាតិចាំបាច់ត្រូវតែមានប្រព័ន្ធផ្ទុកទិន្នន័យមួយ ដែលកត់ត្រានូវប្រវត្តិបទឧក្រិដ្ឋរបស់ប្រជាជនក្នុងប្រទេសខ្លួន។<br>• ថ្វីបើមានការទទួលស្គាល់ថា ភាគច្រើននៃជនល្មើសផ្លូវភេទលើកុមារមិនមានកំណត់ត្រាបទឧក្រិដ្ឋ ( ព្រោះបទឧក្រិដ្ឋរបស់ពួកគេមិនត្រូវបានគេចាប់បាន/មិនត្រូវបានរាយការណ៍ ) ក្តី ប៉ុន្តែវិធានការនេះ ក៏នៅតែជាវិធានការដ៏មានប្រសិទ្ធិភាព ក្នុងការទប់ស្កាត់កុំឱ្យជនរំលោភបំពានផ្លូវភេទលើកុមារមានលទ្ធភាពអាចចូលទៅរកកុមារបាន។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | នេះក៏ជាវិធីល្អមួយផងដែរ ដើម្បីឱ្យដឹងថាតើមនុស្សណាម្នាក់អាចនឹងបង្កគ្រោះថ្នាក់ណាមួយចំពោះកុមារឬទេ ? ឧទាហរណ៍ តើពួកគេធ្លាប់បានប្រព្រឹត្តិអំពើហិង្សា ជាពិសេសគឺបទល្មើសហិង្សាចំពោះកុមារឬទេ។<br>**?** *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖*<br>ប្រសិនបើរដ្ឋាភិបាលរបស់អ្នក មិនទាន់មានប្រព័ន្ធទិន្នន័យជាផ្លូវការទេនោះ តើមានយន្តការត្រួតពិនិត្យអ្វី ដែលអាចបង្កើតឲ្យមានការត្រួតពិនិត្យនិយោជិតដែលធ្វើការជាមួយកុមារ ? | ចម្លើយអាចរួមមាន៖<br>• រដ្ឋាភិបាលមួយចំនួនមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីធ្វើការត្រួតពិនិត្យប្រវត្តិរបស់ជនល្មើសនៅឡើយ។<br>• ពេលដែលមិនទាន់មានប្រព័ន្ធត្រួតពិនិត្យរបស់ប៉ូលីស អង្គការនានាដែលធ្វើការជាមួយកុមារ ក៏នៅតែអាចធ្វើការត្រួតពិនិត្យនិយោជិត ដោយការស៊ើប សួរទៅកាន់និយោជកមុនៗ។<br>• រដ្ឋាភិបាល អាចតម្រូវឲ្យបណ្ដាអង្គការទាំងឡាយដែលធ្វើការជាមួយកុមារ ត្រូវត្រួតពិនិត្យប្រវត្តិរបស់និយោជិត ឲ្យបានម៉ត់ចត់។ |
| **ស្លាយទី៧១**<br> | • ប៉ូលីសចក្រភពអង់គ្លេសបានបង្កើតមជ្ឈមណ្ឌលការពារការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត (CEOP)។ មជ្ឈមណ្ឌលនេះផ្ដោតលើការលុបបំបាត់ការរំលោភបំពានចំពោះកុមារ។<br>• CEOP ធ្វើការក្នុងភាពជាដៃគូដោយផ្ទាល់ជាមួយនាយកដ្ឋានរដ្ឋាភិបាល ភ្នាក់ងារប៉ូលីសអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជនដទៃទៀត (រួមទាំងក្រុមហ៊ុនធំៗដូចជា វីសា និងម៉ាយក្រូសុស ជាដើម)<br>• CEOP បង្កើតគេហទំព័រឈ្មោះ ThinkUKnow ដែលផ្ដល់ព័ត៌មាន និងសេវារាយការណ៍បែបអនាមិក សម្រាប់កុមារ ឪពុកម្ដាយ អាណាព្យាបាល គ្រូបង្រៀន និងសាធារណជនដែលយកចិត្តទុកដាក់ចំពោះសុវត្ថិភាពកុមារ។<br>• CEOP ក៏ធ្វើការជាដៃគូជាមួយប៉ូលីសនៅអាស៊ីអាគ្នេយ៍ ដើម្បីគាំទ្រដល់កិច្ចខិតខំរបស់ពួកគេក្នុងការប្រយុទ្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ដោយផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើវិស័យទេសចរណ៍។<br>• យុទ្ធនាការប្រហាក់ប្រហែលគ្នានេះ ក៏ត្រូវបានធ្វើឡើងនៅបណ្ដាប្រទេសដទៃទៀតផងដែរ។ | សម្រាប់ព័ត៌មានបន្ថែមអំពី ThinkUKnow អាចរកបាននៅ៖<br>http://www.thinkuknow.co.uk/ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖*<br>• តើអ្នកអាចផ្តល់ឧទាហរណ៍ អំពីវិធីដែលអ្នកធ្វើដំណើរអន្តរជាតិ អាចប្រើប្រាស់អ៊ីនធើណេត មុននិងក្នុងពេលធ្វើដំណើររបស់ពួកគេ ដើម្បីសម្រួលដល់ការរំលោភបំពានផ្លូវភេទកុមារឬទេ ?<br>• តើរដ្ឋាភិបាលរបស់អ្នក ផ្តល់សេវាអ្វីខ្លះដើម្បីការពារកុមារពីគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទតាមរយៈអ៊ីនធើណេត ? | *សំណួរទីមួយ ចម្លើយអាចរួមមាន៖*<br>• កំណត់ទីតាំង/តំបន់ ដែលកុមារងាយមានភាពរងគ្រោះ<br>• ប្រាស្រ័យទាក់ទងជាមួយបណ្តាញជនល្មើសផ្លូវភេទ ដើម្បីកំណត់ទីកន្លែងទេសចរណ៍ដែលពួកគេអាចប្រព្រឹត្តបទល្មើសដោយគ្មានទោស<br>• ធ្វើជាមិត្តជាមួយកុមារតាមអ៊ីនធើណេត<br>• ឆ្លើយឆ្លងជាមួយភ្នាក់ងារធ្វើដំណើរ/ក្រុមហ៊ុនទេសចរណ៍ ដែលជួយសម្រួលដល់ការកេងប្រវ័ញ្ចលើកុមារ។<br>• ឆែកមើលប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធើណេតដើម្បីកំណត់ទីតាំងដែលមិនមានសុវត្ថិភាពសម្រាប់ការរំលោភបំពានកុមារ ( ផ្អែកលើភស្តុតាងនៃការចាប់ខ្លួនកន្លងមក )<br>• អ្នកសម្របសម្រួលអាចផ្តល់ឧទាហរណ៍ជាក់ស្តែង។<br>*សំណួរទីពីរ សូមផ្តល់សំណូមពរមួយចំនួន៖*<br>• សូមឲ្យមានការបណ្តុះបណ្តាល/ផ្សព្វផ្សាយនៅតាមសាលារៀនអំពីគ្រោះថ្នាក់ដែលអាចកើតមានតាមប្រព័ន្ធអិនធើណេត<br>• សូមឲ្យមានការបណ្តុះបណ្តាល/ផ្សព្វផ្សាយសម្រាប់ឪពុកម្តាយ និងគ្រូបង្រៀនអំពីសុវត្ថិភាពប្រព័ន្ធអ៊ីនធើណេត<br>• យុទ្ធនាការជាក់លាក់ ដែលបង្រៀនកុមារអំពីគ្រោះថ្នាក់តាមប្រព័ន្ធអ៊ីនធើណេត<br>• កិច្ចសហការជាមួយក្រសួងទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីពង្រឹងបណ្តាញសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធើណេតសម្រាប់កុមារ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៧២**<br><br> | • នាយកដ្ឋានកិច្ចការបរទេសរបស់រដ្ឋាភិបាលអូស្ត្រាលី បានបង្កើតគេហទំព័រ Smart Travellers (អ្នកធ្វើដំណើរដ៏ឆ្លាតវៃ) ដែលផ្តល់ព័ត៌មាន និងដំបូន្មានសម្រាប់អ្នកធ្វើដំណើរជនជាតិអូស្ត្រាលី មុនពេលពួកគេចេញដំណើរទៅបរទេស។<br>• គេហទំព័រ "អ្នកធ្វើដំណើរដ៏ឆ្លាតវៃ" ផ្ទុកនូវសារដាស់តឿនដល់អ្នកធ្វើដំណើរជនជាតិអូស្ត្រាលី អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរគឺជាបទឧក្រិដ្ឋមួយក្នុងប្រទេសអូស្ត្រាលី និងនៅបរទេស។ | • សម្រាប់ព័ត៌មានបន្ថែមអំពី Smart Traveller អាចរកបាននៅ៖ http://www.smartraveller.gov.au/ |
| **ស្លាយទី៧៣**<br><br> | • គេហទំព័ររបស់ក្រសួងទេសចរណ៍នៅប្រទេសនីមួយៗ ត្រូវបានអ្នកដំណើរអន្តរជាតិប្រើប្រាស់ ដើម្បីស្វែងរកព័ត៌មានផ្សេងៗ។ ក្រសួងទេសចរណ៍ប្រទេសកម្ពុជា មានសារស្វាគមន៍ភ្ញៀវអន្តរជាតិ ប៉ុន្តែក៏បានបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការការពារកុមារ តាមរយៈការរួមបញ្ចូលសារការពារកុមារមួយនៅលើទំព័រមុខនៃគេហទំព័ររបស់ខ្លួន។<br><br>*សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖*<br><br>១. តើគេហទំព័ររដ្ឋាភិបាលរបស់អ្នក ផ្តល់ព័ត៌មានអ្វីខ្លះ ដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពានក្នុងវិស័យទេសចរណ៍?<br><br>២) តើធ្វើយ៉ាងណាទើបអ្នកអាចលើកកំពស់ការប្តេជ្ញាចិត្តរបស់អ្នក ក្នុងការរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពានក្នុងវិស័យទេសចរណ៍? | • ដើម្បីមើលគេហទំព័ររបស់ក្រសួងទេសចរណ៍កម្ពុជា សូមបើកមើល៖ http://www.tourismcambodia.org/<br><br>*សំណួរទីពីរ ចម្លើយអាចរួមមាន៖*<br><br>• ដាក់សារយុទ្ធនាការការពារកុមារលើគេហទំព័រទេសចរណ៍របស់អ្នក។<br>• លើកទឹកចិត្តក្រុមហ៊ុនទេសចរណ៍ឱ្យផ្សព្វផ្សាយអំពីយុទ្ធនាការការពារកុមារនៅលើគេហទំព័ររបស់ខ្លួន។<br>• ធ្វើយុទ្ធនាការជាសាធារណៈ ដែលផ្តោតសំខាន់លើភ្ញៀវអន្តរជាតិ ដែលមានភាគរយច្រើនជាងគេ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៧៤**<br><br> | • រដ្ឋាភិបាលប្រេស៊ីល គាំទ្រគម្រោងសង្គមមួយ ដែលផ្តល់ឱកាសការងារដល់មនុស្សវ័យក្មេង ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចនៅក្នុងវិស័យទេសចរណ៍។<br>• ច្បាប់ការងារនៅប្រទេសវៀតណាម ហាមឃាត់ការជួលកុមារឱ្យធ្វើការនៅក្នុងមុខរបរមួយចំនួន (រួមមាន ខារ៉ាអូខេ ម៉ាស្សា សណ្ឋាគារ និងឌីស្កូ) យោងតាមការកំណត់អំពីអាយុអប្បរមា។<br>**?** *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖*<br>តើរដ្ឋាភិបាលរបស់អ្នក កំពុងធ្វើអ្វីខ្លះ ដើម្បីការពារកុមារពីមុខរបរប្រកបដោយគ្រោះថ្នាក់ នៅក្នុងឧស្សាហកម្មទេសចរណ៍ ដែលអាចនាំឲ្យពួកគេប្រឈមនឹងការរំលោភបំពានផ្លូវភេទ? | • មុនពេលបណ្តុះបណ្តាល អ្នកសម្របសម្រួលគួរដឹងថាតើរដ្ឋាភិបាលកំពុងធ្វើអ្វីខ្លះ ដើម្បីការពារកុមារឱ្យមានសុវត្ថិភាពពីការកេងប្រវ័ញ្ចក្នុងវិស័យទេសចរណ៍។ |
| **ស្លាយទី៧៥**<br><br> | ប៉ូលីសសហព័ន្ធរបស់ប្រទេសអូស្ត្រាលី ផ្តល់ទម្រង់របាយការណ៍តាមប្រព័ន្ធអ៊ីនធើណេតមួយ ដែលអនុញ្ញាតឱ្យសាធារណជនរាយការណ៍ជាអនាមិក ពីករណីដែលកុមារអាចប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភ បំពានផ្លូវភេទក្នុងវិស័យទេសចរណ៍។<br>**?** *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖*<br>• ផល់ឱ្យសាធារណជននូវសេវារាយការណ៍តាមអ៊ីនធើណេត អំពីស្ថានភាព ដែលកុមារប្រឈមជាមួយគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ មានអត្ថប្រយោជន៍អ្វីខ្លះ?<br>• តើការផ្តល់ឱ្យសាធារណជននូវទីកន្លែងមួយ ដើម្បីធ្វើរបាយការណ៍អនាមិក មានគុណសម្បត្តិអ្វីខ្លះ?<br>• តើធ្វើយ៉ាងណា ទើបរដ្ឋាភិបាលអាចលើកទឹកចិត្តដល់សាធារណជនឱ្យប្រើប្រាស់ទម្រង់រាយការណ៍តាមប្រព័ន្ធអ៊ីនធើណេតបាន? | សម្រាប់ព័ត៌មានបន្ថែមទៀតស្តីពីទម្រង់រាយការណ៍តាមអ៊ីនធើណេតរបស់ AFP សូមមើល៖ https://forms.afp.gov.au/online_forms/cst_form<br>*សំណួរទីមួយ ចម្លើយអាចរួមមាន៖*<br>• ងាយស្រួល និងអាចរកបាន សម្រាប់សាធារណជន ក្នុងការរាយការណ៍អំពីកង្វល់របស់ពួកគេ។<br>• សាធារណជន ប្រហែលជាមិនមានឆន្ទៈក្នុងការទៅកាន់ប៉ុស្តិ៍ប៉ូលីសនោះទេ ប៉ុន្តែពួកគេនឹងប្រើប្រាស់ទម្រង់រាយការណ៍តាមអ៊ីនធើណេត។<br>*សំណួរទីពីរ ចម្លើយអាចរួមមាន៖*<br>• អាស្រ័យដោយភាពងាយសើបនៃបទឧក្រិដ្ឋផ្លូវភេទ កុមារ សាធារណៈជនអាចនឹងខ្លាចគេស្គាល់អត្តសញ្ញាណរបស់ខ្លួន។<br>*សំណួរទីបី ចម្លើយអាចរួមមាន៖*<br>• ត្រូវធានាឲ្យបានថា សាធារណៈជនដឹងពីទម្រង់រាយការណ៍តាមអ៊ីនធឺណិត តាមរយៈការផ្សព្វផ្សាយទម្រង់នេះ នៅក្នុងយុទ្ធនាការការពារកុមារ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៧៦**<br> | • លទ្ធផលការពារកុមារ អាចសម្រេចបាន នៅពេលប្រទេសនានាសហការគ្នា។ ថ្មីៗនេះ ប្រទេសអាល្លឺម៉ង់ អូស្ត្រាលី និង ស្វ៊ីស បានរួមកម្លាំងគ្នា ដើម្បីធ្វើយុទ្ធនាការ ទប់ស្កាត់ការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ របស់ពលរដ្ឋក្នុងបណ្ដាប្រទេសនិយាយ ភាសាអាល្លឺម៉ង់។<br>**?** *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖*<br>• តើរដ្ឋាភិបាលអន្តរជាតិណាខ្លះ ដែលជាដៃគូ សំខាន់របស់អ្នក នៅក្នុងការរក្សាកុមារឲ្យ មានសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទ ក្នុងវិស័យទេសចរណ៍?<br>• តើអ្នកសហការគ្នាយ៉ាងដូចម្ដេច? តើធ្វើ យ៉ាងណា ទើបអ្នកអាចធ្វើឱ្យកិច្ចសហការ កាន់តែប្រសើរនាពេលអនាគត? | |
| **ស្លាយទី៧៧**<br> | • ស្របពេលដែលរដ្ឋាភិបាលនៃប្រទេស កម្ពុជាកំពុងខិតខំ ដើម្បីរក្សាកុមារឲ្យមាន សុវត្ថិភាពពីការរំលោភបំពានក្នុងវិស័យ ទេសចរណ៍ វាជាបញ្ហាមួយ ដែលកំពុងតែ រីករាលដាលនៅជុំវិញពិភពលោក។<br>• ខណៈដែលទេសចរណ៍រីកលូតលាស់យ៉ាង ឆាប់រហ័ស បច្ចេកវិទ្យាកំពុងមានភាពប្រសើរ ឡើង សកម្មភាពឧក្រិដ្ឋកម្មក៏កាន់តែមាន សភាពស្មុគស្មាញឡើង វាធ្វើឱ្យកុមារត្រូវ ប្រឈមនឹងគ្រោះថ្នាក់កាន់តែច្រើន។<br>• ក្នុងនាមជារដ្ឋាភិបាល យើងចាំបាច់ត្រូវតែ ខិតខំ ដើម្បីឆ្លើយតបទៅនឹងការកេងប្រវ័ញ្ច លើកុមារ។ ថ្វីបើយើងបានធ្វើសកម្មភាពល្អ ប្រសើរហើយក្តី ប៉ុន្តែនៅតែចាំបាច់ក្នុងការ៖<br>– បង្កើនកិច្ចខិតខំរបស់យើងឱ្យកាន់តែ ខ្លាំងថែមទៀត<br>– បំពេញការខ្វះខាតដែលមាននៅក្នុង ប្រព័ន្ធការពារកុមាររបស់យើង<br>– ធ្វើឱ្យសកម្មភាពការពារកុមាររបស់យើង កាន់តែមានភាពប្រសើរឡើង<br>– បង្កើត និងអនុវត្តសកម្មភាពថ្មីៗ<br>– កែសម្រួលវិធីដែលយើងសហការគ្នា | ជាការសំខាន់ណាស់ដែលអ្នកសម្របសម្រួល ត្រូវប្រើប្រាស់សកម្មភាពនេះ ដើម្បី រួមសរុប នូវអ្វីដែលបានរៀនសូត្រពីវគ្គបណ្ដុះបណ្ដាល នេះ និងបំផុសអ្នកចូលរួមឱ្យពិចារណាយ៉ាង យកចិត្តទុកដាក់ លើការកែលំអនៅថ្នាក់ជាតិ/ខេត្ត។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៧៨**<br><br> | • ការរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពានក្នុងវិស័យទេសចរណ៍ គឺមិនមែនជាការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធតែមួយនោះទេ។ ការងារនេះទាមទារនូវការសហការរបស់ដៃគូជាច្រើន។ បើសិនជាអាជ្ញាធរទទួលបន្ទុកការពារកុមារ មិនសហការ និងធ្វើការរួមគ្នាទេនោះ វានឹងធ្វើឱ្យមានភាពទន់ខ្សោយនៅក្នុងប្រព័ន្ធការពារកុមារ ហើយកុមារត្រូវបន្តប្រឈមនឹងគ្រោះថ្នាក់ រួមទាំងការរំលោភបំពានផ្លូវភេទផងដែរ។<br>*សកម្មភាព*<br>*បង្កើនកិច្ចសហប្រតិបត្តិការ*<br>• ចែកអ្នកចូលរួមទៅជាបីក្រុម។ ចែកប្រធានបទមួយក្នុងចំណោមប្រធានបទទាំងបីខាងក្រោម ដល់ក្រុមនីមួយៗ៖<br>– ក្រុមមួយ៖ កម្រិតអន្តរជាតិ<br>– ក្រុមពីរ៖ កម្រិតជាតិ<br>– ក្រុមបី៖ ថ្នាក់មូលដ្ឋាន (ខេត្ត)<br>• ឲ្យក្រុមនីមួយៗពិចារណាលើសំណួរខាងក្រោម៖<br>– តើនរណាខ្លះជាដៃគូដែលរដ្ឋាភិបាលនៃប្រទេសកម្ពុជាគួរសហការជាមួយនៅក្នុងកម្រិតនេះ (អន្តរជាតិ ជាតិ ឬមូលដ្ឋាន)?<br>– តើអ្នកអាចសហការបានតាមរបៀបណា?<br>– តើយើងអាចធ្វើសកម្មភាពអ្វីខ្លះបាន ដើម្បីឱ្យកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើង?<br>• ពិភាក្សាលើចម្លើយរបស់ក្រុម និងលើកទឹកចិត្តអ្នកចូលរួមឱ្យព្យាយាមរកកិច្ចខិតខំនានា ដើម្បីកែលំអកិច្ចសហប្រតិបត្តិការឲ្យកាន់តែប្រសើរឡើងនៅគ្រប់កម្រិតទាំងអស់។<br>• រដ្ឋាភិបាល ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទនៅក្នុងវិស័យទេសចរណ៍។ មិនថាអ្នកធ្វើការនៅកម្រិតជាតិ ឬកម្រិតខេត្តនោះឡើយ យើងសូមលើកទឹកចិត្តឱ្យអ្នកធ្វើសកម្មភាពដូចជាអ្វីដែលយើងបានពិភាក្សាគ្នានៅថ្ងៃនេះ ដើម្បីការពារកុមារ និងលើកកំពស់វិស័យទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ។ | • សូមលើកទឹកចិត្តអ្នកចូលរួមឲ្យគិតពីដៃគូដែលពាក់ព័ន្ធទាំងអស់ មកពីរដ្ឋាភិបាល វិស័យឯកជន សហគមន៍ កុមារ អង្គការមិនមែនរដ្ឋាភិបាល។ល។<br>• សូមពិចារណារកវិធីប្រកបដោយភាពច្នៃប្រឌិត ដើម្បីសហការគ្នា (រួមទាំងការបង្កើតឲ្យមានក្រុមការងារស្នូលថ្នាក់ជាតិ កិច្ចប្រជុំនៅថ្នាក់សហគមន៍ ការចូលរួមរបស់កុមារ។ល។) |

## វគ្គទី៨ ៖ សន្និដ្ឋាន

### សង្ខេប៖

*វគ្គបញ្ចប់នេះ នឹងអញ្ជើញអ្នកចូលរួម ឱ្យផ្តល់យោបល់ត្រលប់ និងរលឹកឡើងវិញនូវសារគន្លឹះរបស់វគ្គបណ្តុះបណ្តាល ដើម្បីលើកទឹកចិត្តឱ្យមានសកម្មភាពល្អប្រសើរ ក្រោយវគ្គបណ្តុះបណ្តាល ដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាព។*

### លទ្ធផលរំពឹងទុកនៃវគ្គសិក្សា៖

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមនឹងអាច៖

- ផ្តល់យោបល់ត្រលប់ ដោយគូសបញ្ជាក់អំពីយោបល់ត្រលប់របស់ពួកគេចំពោះវគ្គបណ្តុះបណ្តាល។
- ដោះស្រាយសំណួរទាំងឡាយណាដែលមានក្នុងវគ្គបណ្តុះបណ្តាលទាំងមូល។
- រំលឹកឡើងវិញនូវមេរៀនដែលបានរៀននៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

| រយៈពេល | ឯកសារដែលត្រូវការ | សម្ភារផ្សេងទៀត |
|---|---|---|
| ៤៥នាទី | • សំណួរក្រោយមេរៀន<br>• ទស្សនៈរបស់ខ្ញុំ (ការវាយតម្លៃក្រោយវគ្គសិក្សា)<br>• វិញ្ញាបនប័ត្រ | សម្ភារយុទ្ធនាការផ្សព្វផ្សាយសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ដែលមានសម្រាប់ចែកឲ្យអ្នកចូលរួម។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៧៩**<br><br> | សន្និដ្ឋានដោយនិយាយថា៖<br>• កុមារទាំងអស់មានសិទ្ធិ ជាពិសេស ពួកគេមានសិទ្ធិទទួលបានសុវត្ថិភាពពីការរំលោភបំពាន។<br>• យើងម្នាក់ៗសុទ្ធតែមានការទទួលខុសត្រូវទាំងលក្ខណៈបុគ្គល និងវិជ្ជាជីវៈ ដើម្បីការពារកុមារពីការរំលោភបំពាន ។<br>• វាសំខាន់ខ្លាំងណាស់ ដែលយើងត្រូវដឹងអំពីរបៀបចូលរួមវិភាគទាននៅក្នុងបរិស្ថានប្រកបដោយសុវត្ថិភាព និងឆ្លើយតបនៅពេលណាដែលកុមារកំពុងប្រឈមនឹងគ្រោះថ្នាក់។<br>សកម្មភាពរបស់អ្នក នឹងជួយបង្ការកុំឱ្យគ្រោះថ្នាក់កើតឡើងចំពោះកុមារ និងជួយកសាងវិស័យទេសចរណ៍ឱ្យមានលក្ខណៈកាន់តែប្រសើរនៅក្នុង ប្រទេសកម្ពុជា និងក្នុងតំបន់។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៨០**<br> | *សកម្មភាព៖ ទស្សនៈរបស់ខ្ញុំ*<br>• យោបល់ត្រលប់របស់អ្នក មានតម្លៃណាស់សម្រាប់ពួកយើង។<br>• តាមរយៈការចែករំលែកគំនិតរបស់អ្នកអំពីការបណ្តុះបណ្តាលនេះ អ្នកអាចជួយឲ្យយើងអាចធ្វើឱ្យការងារការពារកុមាររបស់យើងកាន់តែប្រសើរឡើង។<br>• ឥឡូវនេះ ខ្ញុំនឹងចែកទម្រង់វាយតម្លៃដល់អ្នក ហើយសូមអរគុណអ្នកចំពោះការផ្តល់យោបល់ត្រលប់ដោយស្មោះពីចិត្ត។<br>*សកម្មភាព៖ សំណួរក្រោយមេរៀន*<br>• ចែកទម្រង់ **សំណួរក្រោយមេរៀន** (**ក្នុងឧបសម្ព័ន្ធទី៥**) | ចែក **សំណួរក្រោយមេរៀន/ទម្រង់អំពីទស្សនៈរបស់ខ្ញុំ**<br>ប្រសិនបើមានពេលខ្លី អ្នកសម្របសម្រួលអាចធ្វើ ការស្ទាបស្ទង់មតិបញ្ចប់នេះបានតាមរយៈការលើកដៃ។ ត្រូវធានាថា ចំនួនការលើកដៃត្រូវបានកត់ត្រាទុក។ |
| **ស្លាយទី៨១**<br> | *ការប្រគល់វិញ្ញាបនប័ត្រ*<br>• អបអរសាទរអ្នកចូលរួមដែលបានរៀនចប់វគ្គបណ្តុះបណ្តាល<br>• ពន្យល់ប្រាប់ថាអ្នកចូលរួមទាំងអស់ដែលបានបញ្ចប់វគ្គសិក្សានេះដោយជោគជ័យ នឹងបានទទួលវិញ្ញាបនប័ត្របញ្ជាក់ការបញ្ចប់ការបណ្តុះបណ្តាល ដែលទទួលស្គាល់នូវសារៈសំខាន់នៃវគ្គសិក្សាអំពីការការពារកុមារ ដែលពួកគេបានបញ្ចប់។<br>• លើកទឹកចិត្តអ្នកចូលរួម ឲ្យដាក់តាំងវិញ្ញាបនប័ត្រនេះនៅកន្លែងធ្វើការរបស់ពួកគេ និងផ្តល់ដំបូន្មានដល់អនាគតនិយោជក ពីវគ្គបណ្តុះបណ្តាល។ ពួកគេនឹងគិតថាអាជីវកម្មទេសចរណ៍របស់អ្នកប្រកបដោយការទទួលខុសត្រូវ។<br>• ហៅឈ្មោះអ្នកចូលរួមឲ្យមកទទួលវិញ្ញាបនប័ត្ររបស់ពួកគេ។ ក្នុងករណីមានក្រុមធំ អាចទះដៃបន្តរហូតដល់អស់វិញ្ញាបនប័ត្រ។ | • ថតរូបអ្នកចូលរួមទាំងអស់ជុំគ្នាដោយឲ្យពួកគេកាន់វិញ្ញាបនប័ត្ររបស់ពួកគេនៅក្នុងដៃ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៨២**<br> | *អរគុណ សម្រាប់ព័ត៌មានបន្ថែម*<br>• អរគុណអ្នកចូលរួមចំពោះការយកចិត្តទុកដាក់ និងការចូលរួមរបស់ពួកគេ។<br>• លើកទឹកចិត្តអ្នកចូលរួមឱ្យធ្វើសកម្មភាពនៅក្នុងអាជីវកម្មរបស់ពួកគេ ដើម្បីកសាងទេសចរណ៍ប្រកបដោយសុវត្ថិភាព។<br>• អញ្ជើញអ្នកចូលរួមឱ្យទស្សនាគេហទំព័រសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ (www.childsafetourism.org) និង សូមរក្សាទំនាក់ទំនងជាមួយគ្នាតាមហ្វេសប៊ុក (www.facebook.com/ChildSafeTourism) និង twitter (www.twitter.com/ChildSafeTravel) | |

# កំណត់ត្រា

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

ផ្នែកទី៣៖

# ឧបសម្ព័ន្ធ



# ឧបសម្ព័ន្ធទី១៖ គំរូរបៀបវារៈនៃការបណ្តុះបណ្តាលមួយថ្ងៃពេញ

រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍របៀបវារៈ

| ចំណងជើងមេរៀន | មាតិកា | រយៈពេល ( សូមបន្ថែមពេលវេលាជាក់ស្តែងនៅក្នុងក្រឡោននេះ ) |
|---|---|---|
| សេចក្តីផ្តើម | ការណែនាំខ្លួនអ្នកចូលរួម<br>របៀបវារៈនៃការបណ្តុះបណ្តាល<br>សំណួរមុនចូលមេរៀន មុនចាប់ផ្តើម | ៣០ នាទី |
| តើ“ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ”ពាក់ព័ន្ធនឹងខ្ញុំដូចម្តេចខ្លះ ? | ការការពារកុមារ និងវិស័យទេសចរណ៍<br>សិទ្ធិកុមារ<br>ក្របខណ្ឌផ្នែកច្បាប់ការពារកុមារ<br>ទីកន្លែងរបស់ខ្ញុំក្នុងប្រព័ន្ធការពារកុមារ | ៤៥ នាទី |
| តើក្នុងវិស័យទេសចរណ៍មានគ្រោះថ្នាក់ អ្វីខ្លះចំពោះកុមារ ? | ស្ថានភាពទេសចរណ៍ជាតិ<br>ផលប៉ះពាល់នៃវិស័យទេសចរណ៍លើការរំលោភបំពានផ្លូវភេទកុមារ<br>ភាពងាយរងគ្រោះរបស់កុមារក្នុងវិស័យទេសចរណ៍<br>ទំនាក់ទំនងរវាងវិស័យទេសចរណ៍និងការរំលោភបំពានផ្លូវភេទកុមារ | ៨០ នាទី |
| តើអ្វីជា“ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ”? | ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ និងទេសចរណ៍ ដែលមានសុវត្ថិភាពចំពោះកុមារ<br>តើនរណាខ្លះអាចចូលរួមវិភាគទានក្នុងវិស័យទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ ?<br>អត្ថប្រយោជន៍នៃទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ<br>ការអនុវត្តល្អៗ ក្នុងទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ។ | ៣០ នាទី |
| តើបុគ្គលម្នាក់ៗអាចធ្វើយ៉ាងណាខ្លះ ដើម្បីឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ ? | វិធីនានាដែលបុគ្គលម្នាក់ៗអាចការពារកុមារបាន៖<br>• ផ្តល់ការគោរពចំពោះកុមារ<br>• លើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ដែលអាចកើតមានចំពោះកុមារ<br>• ទទួលស្គាល់គ្រោះថ្នាក់ដែលអាចកើតមានចំពោះកុមារ<br>• ធ្វើសកម្មភាពដើម្បីការពារកុមារ។ | ៧៥ នាទី |

| | | |
|---|---|---|
| **តើអាជីវកម្មទាំងឡាយ អាចធ្វើយ៉ាងណាខ្លះ ដើម្បីឲ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ ? ( សម្រាប់តែអ្នកគ្រប់គ្រង/ម្ចាស់អាជីវកម្ម/អ្នកប្រតិបត្តិការប៉ុណ្ណោះ )** | វិធីនានាដែលអាជីវកម្មអាចការពារកុមារបាន៖<br>• នៅក្នុងអាជីវកម្មរបស់អ្នក<br>• ជាមួយអតិថិជន និងអ្នកផ្គត់ផ្គង់<br>• ក្នុងសហគមន៍របស់អ្នក | ៦០ នាទី |
| **តើរដ្ឋាភិបាលអាចធ្វើយ៉ាងណាខ្លះ ដើម្បីឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ ( សម្រាប់តែរដ្ឋាភិបាលប៉ុណ្ណោះ )** | វិធីនានាដែលរដ្ឋាភិបាលអាចការពារកុមារពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍<br>• តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង/មន្ទីរនានា<br>• ឧទាហរណ៍អំពីការអនុវត្តន៍ល្អៗ<br>• ការពង្រឹងកិច្ចសហការណ៍ | ៦០ នាទី |
| **សន្និដ្ឋាន** | សំណួរ និងបូកសរុបវគ្គសិក្សា<br>ការវាយតម្លៃ<br>ផ្តល់វិញ្ញាបនប័ត្រ<br>បិទវគ្គ | ៤៥ នាទី |

# ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន

សូមផ្តល់កាតនេះ ទៅឱ្យអ្នកចូលរួមម្នាក់ៗ។ អ្នកចូលរួមអាចយកកាតនេះទៅផ្ទះបាន ដើម្បីពួកគេអាចរំលឹកពីចំណុចសំខាន់ៗដែលពួកគេបានរៀន។ គួរតែថតចម្លងកាតយកតាមខ្លួននេះលើកាតទំហំ A5 ឬA6 ដោយព្រីនសងខាង។ ការធ្វើដូចនេះ នឹងជួយឱ្យគេអាចចងចាំកាតទាំងនេះបានកាន់តែល្អ និងអាចក្លាយជាធនធានដែលអាចប្រើប្រាស់បាន នៅពេលអ្នកចូលរួមត្រលប់ទៅផ្ទះ ឬកន្លែងធ្វើការរបស់ខ្លួនវិញ។



# ដំណោះស្រាយសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍

ដើម្បីទប់ស្កាត់ការរំលោភបំពានកុមារក្នុងវិស័យទេសចរណ៍

www.childsafetourism.org

# ការការពារកុមារ គឺជាកាតព្វកិច្ចរបស់មនុស្សគ្រប់រូប

យើងទាំងអស់គ្នាសុទ្ធតែទទួលបានប្រយោជន៍ពីវិស័យទេសចរណ៍ប្រកបដោយការទទួលខុសត្រូវក្នុងការការពារសម្បត្តិធម្មជាតិ វប្បធម៌ មនុស្សជាតិ និងជាពិសេសគឺកុមាររបស់យើង។ ប៉ុន្តែស្របពេលដែលវិស័យទេសចរណ៍រីកចម្រើននៅជុំវិញពិភពលោក កុមារក៏មានភាពងាយរងគ្រោះដោយការរំលោភបំពានដែរ។

កុមារត្រូវការការការពារជាពិសេស។ វាមិនមែនជាការទទួលខុសត្រូវរបស់អង្គភាពណាមួយតែម្នាក់ឯងនោះឡើយ។ យើងទាំងអស់គ្នាសុទ្ធតែមានទំនួលខុសត្រូវក្នុងការការពារកុមារ។




**អ្នកអាចជួយកសាងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍បាន**
**យើងទាំងអស់គ្នា សុទ្ធតែមានតួនាទីក្នុងការការពារកុមារពីការរំលោភបំពាន។**

# តើអ្វីទៅជាការរំលោភបំពានកុមារ ?

"កុមារ" គឺជាមនុស្សដែលមានអាយុក្រោម ១៨ឆ្នាំ។ ការរំលោភបំពានកុមារ គឺជាសកម្មភាពណាមួយ (ឬ មិនមែនសកម្មភាព) ដែលធ្វើឡើងមិនមែនដោយចៃដន្យ ហើយធ្វើឲ្យកុមារឈឺចាប់ ឬធ្វើឲ្យកុមារមានគ្រោះថ្នាក់។

មានកុមាររាប់លាននាក់ នៅជុំវិញពិភពលោក បានទទួលរងគ្រោះដោយសារការរំលោភបំពានជារៀងរាល់ថ្ងៃ។ ការរំលោភបំពានកុមារកើតឡើងនៅគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។

## ប្រភេទនៃការរំលោភបំពានកុមារ

ការរំលោភបំពានកុមារមាន៤ប្រភេទសំខាន់ៗ។ ជាញឹកញាប់ការរំលោភបំពានលើសពីមួយប្រភេទបានកើតឡើងក្នុងពេលដំណាលគ្នា ។

- ការរំលោភបំពានផ្លូវកាយ
- ការរំលោភបំពានផ្លូវភេទ
- ការរំលោភបំពានផ្លូវចិត្ត
- ការមិនអើពើ

## ផលប៉ះពាល់នៃការរំលោភបំពានកុមារ

ការរំលោភបំពានមានផលប៉ះពាល់ធ្ងន់ធ្ងរលើកុមារ ហើយអាចបណ្តាលឲ្យកុមារមានបញ្ហាទាំងផ្លូវកាយ និងផ្លូវចិត្តក្នុងរយៈពេលវែង។

ផលវិបាកនៃការរំលោភបំពានគឺមិនត្រឹមតែប៉ះពាល់ទៅលើជនរងគ្រោះប៉ុណ្ណោះទេប៉ុន្តែវាក៏ជះឥទ្ធិពលទៅដល់គ្រួសារ សហគមន៍ និងវិស័យទេសចរណ៍ផងដែរ ។

# ប្រភេទនៃការរំលោភបំពានកុមារ


រំលោភបំពានដោយប្រើ
ពាក្យសម្ដីមិនល្អចំពោះកុមារ


និយាយលួកលាន់លើ
កុមារដែលមិនចាំបាច់


ប៉ះពាល់លើកុមារនៅផ្នែកណា
មួយនៃរាងកាយដែលកុមារ
មិនចង់ឲ្យប៉ះ


មិនស្ដាប់សម្ដីកុមារ


នាំឲ្យកុមារឃើញ
សកម្មភាព ឬរូប
អាសអាភាសផ្លូវភេទ


បង្ខំកុមារឲ្យប៉ះពាល់ផ្នែកណា
មួយនៃរាងកាយរបស់ខ្លួន


ធ្វើឲ្យកុមារបាត់បង់ទំនុកចិត្ត
លើខ្លួនឯង


វាយដំ ឬធ្វើឲ្យកុមារឈឺចាប់
ជារឿយៗ ដើម្បីរំសាយ
កំហឹងខ្លួនឯង


បោកបញ្ឆោតកុមារ


មិនយកចិត្តទុកដាក់ថែទាំកុមារ
ដូចជាមិនសម្អាត ស្លៀកពាក់
និងឲ្យចំណីអាហារ


ប្រើប្រាស់កុមារធ្វើ
ជាអ្នកបម្រើ


មិនយកចិត្តទុកដាក់
លើសេចក្ដីត្រូវការផ្នែក
សតិអារម្មណ៍របស់កុមារ


ធ្វើឲ្យកូនរបស់ខ្លួនក្លាយជា
"អ្នកបម្រើ" ដោយមិនឲ្យមាន
ពេលលំហែរនិងសិក្សា


វាយដំ និងសើចចំអក
ឲ្យកុមារនៅសាលារៀន


មិនយកចិត្តទុកដាក់លើ
តម្រូវការផ្នែកសុខភាព
រាងកាយរបស់កុមារ


មិនយកចិត្តទុកដាក់លើតម្រូវការ
ផ្នែកអប់រំរបស់កុមារ


ទុកកុមារចោលគ្មាន
អ្នកមើលថៃ

រូបភាព និងអត្ថបទដកស្រង់ចេញពីផ្ទាំងរូបភាព " តើអ្វីទៅជាការរំលោភបំពានលើកុមារ "
ដែលផលិតដោយ *Childline Thailand Foundation.* ក្នុងគេហទំព័រ *http://childlinethailand.org*

# អ្នកធ្វើដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ

## ទ្វីបអាស៊ី

ត្រូវបានព្យាករណ៍ទុកថានឹងមាននូវកំណើនភ្ញៀវទេសចរច្រើនជាងគេបំផុតនៅក្នុងវិស័យទេសចរណ៍នៅក្នុងរយៈពេល ២ ទសវត្សខាងមុខនេះ។

**៣,៦ លាន** អ្នកទេសចរទៅប្រទេស**កម្ពុជា**

**៣,៣ លាន** អ្នកទេសចរទៅប្រទេស**ឡាវ**

**២២,៣ លាន** អ្នកទេសចរទៅប្រទេស**ថៃ**

**៦,៨ លាន** អ្នកទេសចរទៅប្រទេស**វៀតណាម**



## អ្នកទេសចរជាង ៣៦លាននាក់

**បានមកប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមនៅក្នុងឆ្នាំ២០១២**

## កុមារនៅក្នុងវិស័យទេសចរណ៍

**ងាយទទួលរងគ្រោះ ពីការកេងប្រវ័ញ្ច និងការរំលោភបំពាន**



**៦០%** នៃអ្នកធ្វើដំណើរបានឃើញកុមារគ្មានអ្នកថែទាំដើរនៅតាមដងផ្លូវ។

**៣៣%** នៃអ្នកធ្វើដំណើរបានឃើញកុមារធ្វើការនៅទីកន្លែងបម្រើសេវា ទេសចរណ៍ ដែលមានដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ។ល។

**១៨%** នៃអ្នកធ្វើដំណើរបានឃើញកុមារធ្វើការនៅមណ្ឌលកំសាន្តពេលរាត្រី ។

**៩៥%** នៃអ្នកធ្វើដំណើរបានឃើញកុមារនៅតាមមូលដ្ឋាន ធ្វើការនៅក្នុងវិស័យទេសចរណ៍។ ការទំនាក់ទំនងគ្នាជាច្រើនបានធ្វើឲ្យអ្នកទេសចរមានអារម្មណ៍ សោកស្តាយ មានកំហុស ព្រួយបារម្ភ និងខកបំណង ។



## អ្នកទេសចរ ទៅកាន់តំបន់អាស៊ីអាគ្នេយ៍ចង់បាន៖

១ ព័ត៌មានច្បាស់លាស់អំពីរបៀបក្លាយជាអ្នកធ្វើដំណើរដែលមានសុវត្ថិភាពចំពោះកុមារ

២ ជម្រើសសម្រាប់អ្នកប្រើប្រាស់ដែលស្របគ្នានឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

៣ ក្លាយជាផ្នែកមួយ ដើម្បីឲ្យមានការផ្លាស់ប្តូរ ដែលដឹកនាំដោយរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍ ។

## អ្នកធ្វើដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ មិនធ្វើឲ្យកុមារទទួលរងគ្រោះពីការរំលោភបំពានឡើយ។

**សកម្មភាពដែលធ្វើឲ្យកុមារទទួលរងគ្រោះថ្នាក់**




“ ការការពារកុមារ គឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា ”

— អ្នកចូលរួមក្នុងការស្រាវជ្រាវ

**ប្រភព៖** របកគំហើញពីការសិក្សាស្រាវជ្រាវជាមួយអ្នកធ្វើដំណើរ ២៦៨នាក់ មកពី ៣៩ប្រទេស មកកាន់អាស៊ីអាគ្នេយ៍ ខែមេសា ដល់ឧសភា ឆ្នាំ២០១៣។ អង្គការទស្សនៈពិភពលោក។ អ្នកធ្វើដំណើរដែលមានសុវត្ថិភាពចំពោះកុមារ ២០១៣។

# តើមានគ្រោះថ្នាក់អ្វីខ្លះចំពោះកុមារនៅក្នុងវិស័យទេសចរណ៍?

**១ កុមារនៅតាមចិញ្ចើមផ្លូវ ក្នុងតំបន់ទេសចរណ៍**

ឧទាហរណ៍ កុមារអាចសុំទាន ឬលក់ទំនិញ/ អាហារសម្រាប់អ្នកទេសចរ។ កុមារា និង កុមារីដែលចំណាយពេលច្រើននៅតាមផ្លូវ គឺងាយរងគ្រោះពីការរំលោភបំពានណាស់ ។

**២ កុមារដែលធ្វើការក្នុងវិស័យទេសចរណ៍ ឬ វិស័យពាក់ព័ន្ធផ្សេងៗទៀត ជារឿយៗស្ថិតនៅក្នុង ស្ថានភាពដែលត្រូវគេកេងប្រវ័ញ្ច**

ឧទាហរណ៍ កុមារអាច ធ្វើការនៅក្នុងឧស្សាហកម្មទេសចរណ៍ រួមមានមគ្គុទេសក៍ទេសចរណ៍ ធ្វើការនៅក្នុងភោជនីយដ្ឋាន បារ ខារ៉ាអូខេ។ល។ កុមារក៏អាចត្រូវបានគេកេងប្រវ័ញ្ច នៅក្នុងឧស្សាហកម្មផ្លូវភេទផងដែរ ។

**៣ អ្នកធ្វើដំណើរ ឬអ្នកទេសចរអាចចូលទៅរកកុមារបានយ៉ាងងាយ**

ឧទាហរណ៍ អ្នកប្រព្រឹត្តិបទល្មើសផ្លូវភេទកុមារនៅពេលធ្វើដំណើរនោះ ងាយស្រួលក្នុងការចូលទៅជិតកុមារា កុមារីដែលងាយរងគ្រោះដោយចូលទៅបំរើការនៅក្នុងសាលារៀន ឬ "នៅក្នុងមណ្ឌលកុមារកំព្រា" ។ និន្នាការគួរឲ្យព្រួយបារម្ភនោះ មានដូចជា៖

- "ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ការអភិវឌ្ឍ និងសុខមាលភាពរបស់កុមារ ហើយធ្វើឲ្យកុមារ ស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរំលោភបំពាន ។
- "ទេសចរណ៍ស្ម័គ្រចិត្ត" នៅក្នុងអង្គការដែលមើលថែទាំកុមារ ជាកន្លែងដែលអ្នកស្ម័គ្រចិត្តមិនត្រូវបានគេឆែកឆេរ ឬ "ត្រួតពិនិត្យ" ឲ្យបានហ្មត់ចត់។
- "ការស្នាក់នៅតាមផ្ទះ" ដោយពុំមានការកំណត់ទីកន្លែងព្រំដែនឲ្យបានសមស្របរវាងអ្នកទេសចរ និងកុមារជាក់លាក់ ។

ភាពងាយរងគ្រោះរបស់កុមារ និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន មានទំនាក់ទំនងគ្នាទៅវិញទៅមក។

# តើខ្ញុំអាចធ្វើអ្វីបានខ្លះ ដើម្បីធ្វើឲ្យទេសចរណ៍មានសុវត្ថិភាពចំពោះកុមារ

## ១ គោរពកុមារ

ធានាថាអាកប្បកិរិយារបស់ខ្ញុំផ្ទាល់មានភាពសមរម្យចំពោះកុមារា និងកុមារី។

## ២ ផ្សព្វផ្សាយ

ប្រាប់ដល់គ្រួសារ មិត្តរួមការងារ អតិថិជន និងសហគមន៍អំពីគ្រោះថ្នាក់ចំពោះកុមារ និងអំពីវិធីដែលពួកគេអាចធានាបានថាកុមារមានសុវត្ថិភាព ក្នុងវិស័យទេសចរណ៍។

## ៣ ប្រយ័ត្ន និងស្គាល់សញ្ញាណដែលបង្ហាញថាកុមារមានគ្រោះថ្នាក់

ត្រូវប្រយ័ត្នចំពោះអ្វីដែលកំពុងកើតឡើងនៅក្នុង បរិយាកាសជុំវិញអ្នក។ សូមពិនិត្យមើល ស្ថានភាពដែលកុមារា និងកុមារីអាចមានគ្រោះថ្នាក់ដោយការរំលោភបំពាន។

## ៤ ចាត់វិធានការ ប្រសិនបើអ្នកឃើញកុមារមានគ្រោះថ្នាក់

ខ្ញុំប្រាប់អ្នកគ្រប់គ្រង ឬថ្នាក់លើរបស់ខ្ញុំ។ អនុវត្តតាមគោលនយោបាយការពារកុមាររបស់ក្រុមហ៊ុន( ប្រសិនបើមាន )។ សរសេររៀបរាប់លំអិតទាំងអស់នូវអ្វីដែលខ្ញុំបានឃើញ។ បន្ទាប់មកធ្វើរបាយការណ៍ផ្លូវការ ( សូមបើករកលេខទូរស័ព្ទទំនាក់ទំនង )។





# តើខ្ញុំត្រូវរាយការណ៍ដោយរបៀបណា ?

**សូមកុំព្រងើយកន្តើយចំពោះស្ថានភាពដែលកុមារ អាចមានគ្រោះថ្នាក់ពីការរំលោភបំពាន។ តាមរយៈការធ្វើរបាយការណ៍ នោះអ្នកអាចជួយទប់ស្កាត់ការរំលោភបំពានបាន។**

- ជូនដំណឹងដល់អ្នកគ្រប់គ្រងរបស់អ្នក

  ..........................................................................

- ទូរសព្ទ័ទៅបណ្តាញទូរសព្ទ័ទាន់ហេតុការណ៍ការពារកុមារថ្នាក់ជាតិ

  **១២៨៨**

- ទាក់ទងអាជ្ញាធរមូលដ្ឋាន

  ..........................................................................

- ទំនាក់ទំនងទីភ្នាក់ងារការពារកុមារ ដែលមានកេរ្តិ៍ឈ្មោះល្អ:

  **០៩២ ៣១១ ៥១១**

សម្រាប់អ្នកគ្រប់គ្រង /ម្ចាស់អាជីវកម្មតែប៉ុណ្ណោះ

# តើអាជីវកម្មទេសចរណ៍របស់ខ្ញុំ មានសុវត្ថិភាពចំពោះកុមារកម្រិតណា ?

## សូមធ្វើតេស្តិ៍ខាងក្រោម៖

**សូមគូសសញ្ញា ✓ ចំពោះចម្លើយដែល ត្រឹមត្រូវ**

| | បាទ/ចាស | ទេ |
|---|---|---|
| ១. បុគ្គលិកនៅក្នុងអាជីវកម្មរបស់ខ្ញុំ មានការយល់ដឹងអំពីបញ្ហារំលោភបំពានកុមារនៅក្នុងវិស័យទេសរចរណ៍ | | |
| ២. បុគ្គលិកនៅក្នុងអាជីវកម្មរបស់ខ្ញុំដឹង ពីរបៀបកំណត់ថាកុមារមានគ្រោះថ្នាក់ពីការរំលោភបំពាន | | |
| ៣.បុគ្គលិកនៅក្នុងអាជីវកម្មរបស់ខ្ញុំដឹងអំពីរបៀបឆ្លើយតប និងរាយការណ៍ពីករណីរំលោភបំពានកុមារជាពិសេសការរំលោភបំពានផ្លូវភេទ | | |
| ៤. អាជីវកម្មរបស់ខ្ញុំ គាំទ្រគ្រួសារ ងាយរងគ្រោះនៅតាមមូលដ្ឋានសាលារៀន និង/ឬកម្មវិធីសង្គមដែលជួយកុមារ | | |
| ៥.បុគ្គលិកនៅក្នុងអាជីវកម្មរបស់ខ្ញុំ ទទួលបានការបណ្តុះបណ្តាលអំពី បញ្ហារំលោភបំពានកុមារនៅក្នុងវិស័យទេសចរណ៍ | | |
| ៦.អាជីវកម្មរបស់ខ្ញុំមានគោលនយោបាយការពារកុមារដែលយើងអនុវត្តយ៉ាងសកម្មដើម្បីទប់ស្កាត់ការរំលោភបំពានកុមារ | | |
| ៧.អាជីវកម្មរបស់ខ្ញុំ បានជូនដំណឹងដល់អតិថិជន/ក្រុមហ៊ុនដៃគូអំពីការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារកុមារ | | |
| ៨. អាជីវកម្មរបស់ខ្ញុំ ជួយផ្សព្វផ្សាយអំពី បញ្ហាកង្វល់ទូទៅអំពីការរំលោភបំពានកុមារ នៅតាមសហគមន៍ និងវេទិកាទេសចរណ៍ ។ | | |

**លទ្ធផល ៖**

បើអ្នកជ្រើសរើសចម្លើយ "បាទ/ចាស" នូវសំណួរ ទាំងអស់ខាងលើ នោះអាជីវកម្មរបស់អ្នកកំពុងតែចាត់វិធានការដ៏ល្អដើម្បីការពារកុមារ។ សូមបន្តរក្សាការងារដ៏ល្អនេះ!

បើអ្នកជ្រើសរើសចម្លើយ "ទេ" នូវសំណួរណាមួយ នោះសូមត្រឡប់ទៅមើលខ្នងប័ណ្ណឡើងវិញដើម្បីពិនិត្យមើលនូវវិធីសាស្រ្តដែលអ្នកអាចធ្វើឲ្យមានបរិយាកាសវិជ្ជមានសម្រាប់កុមារបាន ។

សម្រាប់អ្នកគ្រប់គ្រង /ម្ចាស់អាជីវកម្មតែប៉ុណ្ណោះ

# វិធីសាស្រ្តដែលធ្វើឲ្យអាជីវកម្មរបស់អ្នក មានសុវត្ថិភាពចំពោះកុមារបាន

## ១ នៅទីតាំងធ្វើអាជីវកម្ម ៖

- បង្កើតនិងអនុវត្តគោលនយោបាយការពារកុមារ
- បណ្តុះបណ្តាលបុគ្គលិកទាំងអស់ អំពីការការពារកុមារ
- ផ្តល់សិទ្ធិឲ្យបុគ្គលិកធ្វើសកម្មភាព
- បង្កើតប្រព័ន្ធច្បាស់លាស់ សម្រាប់ការបញ្ជូនសំណុំរឿង កង្វល់ ឬរបាយការណ៍ ។

## ២ ជាមួយអតិថិជន/អ្នកផ្គត់ផ្គង់ ៖

- ជូនដំណឹងអតិថិជន និងក្រុមហ៊ុនផ្សេងៗអំពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនអ្នក ។
- បញ្ចូលព័ត៌មានស្តីពីសុវត្ថិភាពកុមារក្នុង វិស័យទេសចរណ៍ ទៅក្នុងឯកសារក្រុមហ៊ុនរបស់អ្នក រួមមានការផ្សាយពាណិជ្ជកម្ម គេហទំព័រ សម្ភារផ្សព្វផ្សាយពាណិជ្ជកម្ម និងវិក្កយបត្រ ។
- ផ្សព្វផ្សាយការយល់ដឹងអំពីសុវត្ថិភាពកុមារ តាមរយៈការចែកផ្សាយសម្ភារយុទ្ធនាការនៅទីកន្លែងសាធារណៈនៃអាជីវកម្មរបស់អ្នក ។

## ៣ នៅក្នុងសហគមន៍ ៖

- គាំទ្រកម្មវិធីកុមារដែលមានកេរ្តិ៍ឈ្មោះ
- ផ្តល់ឱកាសការងារ និងបណ្តុះបណ្តាល មុខរបរដល់គ្រួសារកុមារដែលងាយរងគ្រោះ។
- លើកពីបញ្ហាកុមារងាយរងគ្រោះទូទៅនៅក្នុងសហគមន៍មូលដ្ឋាន តាមរយៈ បណ្តាញសហគមន៍សមស្រប ។
- ត្រូវមានគំនិតច្នៃប្រឌិត។ តើអ្នកអាចធ្វើអ្វីបានដើម្បីនាំមកនូវការផ្លាស់ប្តូរចំពោះកុមារ ?

សម្រាប់អ្នកគ្រប់គ្រង /ម្ចាស់អាជីវកម្មតែប៉ុណ្ណោះ

# ការសរសេរគោលនយោបាយការពារកុមារ

គោលនយោបាយដែលសរសេរជាលាយលក្ខណ៍អក្សរ បញ្ជាក់យ៉ាងច្បាស់ថាក្រុមហ៊ុនរបស់អ្នកនឹងមិនអត់ឱនឲ្យចំពោះការរំលោភបំពានកុមារណាមួយនោះឡើយ ។ គោលនយោបាយនេះដាក់បញ្ចូលនូវដំណើរការយ៉ាងច្បាស់ក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះការរំលោភបំពានកុមារ។ គោលនយោបាយត្រូវមានភាពសាមញ្ញ សមស្រប និងអាចសម្រេចគោលដៅបាន ។

អ្វីដែលសំខាន់នោះ គឺគោលនយោបាយរបស់ អ្នកមិនមែនមានតែនៅលើក្រដាសនោះទេ ប៉ុន្តែជាគោលការណ៍ណែនាំពេញលេញដែលទាំងថ្នាក់អ្នកគ្រប់គ្រង និងបុគ្គលិកទាំងអស់ត្រូវគោរពតាមឲ្យបានយ៉ាងសកម្ម ។

ឧទាហរណ៍



## ផ្ទះសំណាក់ឆ្នេរមាស គោលនយោបាយការពារកុមារ

ផ្ទះសំណាក់ឆ្នេរមាស ជឿជាក់ថាកុមារទាំងអស់ ត្រូវមានសុវត្ថិភាពពីគ្រោះថ្នាក់។ យើងខ្ញុំនឹងមិនអត់ឱនចំពោះទម្រង់ណាមួយនៃការរំលោភបំពានកុមារឡើយ។ ផ្ទុយមកវិញ យើងខ្ញុំការពារកុមារតាមរយៈការអនុវត្ត (គោលនយោបាយ) នៃអាជីវកម្មរបស់យើងខ្ញុំ។

- យើងផ្តល់នូវការបណ្តុះបណ្តាលដល់បុគ្គលិក ទាំងអស់ដើម្បីឲ្យពួកគេមានសិទ្ធិចាត់វិធានការ នៅក្នុងស្ថានភាពដែលកុមារប្រឈមមុខនឹងការរំលោភបំពាន។
- យើងរំពឹងទុក និងសូមលើកទឹកចិត្តបុគ្គលិក ទាំងអស់របស់យើងឲ្យរាយការណ៍អំពីកង្វល់ពីការការពារកុមារដល់ថ្នាក់គ្រប់គ្រង ។
- ថ្នាក់គ្រប់គ្រងប្តេជ្ញាចិត្តធ្វើការតាមដាន និងរាយការណ៍ ព្រមទាំងបញ្ជូនព័ត៌មានអំពីការរំលោភបំពានកុមារទៅអាជ្ញាធរពាក់ព័ន្ធ។
- យើងសុទ្ធតែបានបង្ហាញយ៉ាងសកម្មនូវយុទ្ធនាការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៅក្នុងអាជីវកម្មរបស់យើងដូច្នេះអតិថិជនរបស់យើងសុទ្ធតែបានដឹងអំពីជំហររបស់យើង។
- យើងខ្ញុំបានចូលរួមនៅក្នុងឱកាសជាច្រើនដើម្បីគាំទ្រយ៉ាងសកម្មដល់កុមារតាមមូលដ្ឋាននៅក្នុងសហគមន៍របស់យើង រួមមានការលើកអំពីបញ្ហាទូទៅពាក់ព័ន្ធនឹងភាពងាយរងគ្រោះរបស់កុមារទៅកាន់អាជ្ញាធរមូលដ្ឋាន និងសមាគមតាមសហគមន៍។

សម្រាប់អ្នកគ្រប់គ្រង /ម្ចាស់អាជីវកម្មតែប៉ុណ្ណោះ

# អតិថិជនចូលចិត្តអាជីវកម្មមានការទទួលខុសត្រូវក្នុងការរក្សាសុវត្ថិភាពកុមារ

ការស្រាវជ្រាវបានបញ្ជាក់ថា អ្នកទេសចរ និងអ្នកធ្វើដំណើរមកកាន់អនុតំបន់ទន្លេមេគង្គ និយមចូលចិត្តអាជីវកម្មមានការទទួលខុសត្រូវក្នុងការរក្សាសុវត្ថិភាពកុមារពីការរំលោភបំពាន។ ដូច្នេះ សូមឲ្យអតិថិជន អ្នកវិនិយោគនិងក្រុមហ៊ុនដៃគូ ដឹងថាអាជីវកម្មរបស់អ្នកមានការប្តេជ្ញាចិត្តចំពោះការការពារកុមារ ។

## ចូលរួមនៅក្នុងយុទ្ធនាការផ្សព្វផ្សាយអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

- ផ្សព្វផ្សាយយុទ្ធនាការនៅលើ គេហទំព័រ និងទីកន្លែង ធ្វើការរបស់អ្នក ។
- ដាក់បញ្ចូលសារសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ នៅក្នុងខិត្តប័ណ្ណផ្សព្វផ្សាយ សារព័ត៌មាន និងការផ្សាយពាណិជ្ជកម្ម ។
- សុំអញ្ជើញអតិថិជនឲ្យជួយអ្នកក្នុងការខិតខំប្រឹងប្រែងដើម្បីការពារកុមាររបស់អ្នក។ សូមផ្តល់ព័ត៌មានដល់អ្នកធ្វើដំណើរអំពីរបៀបធ្វើជាអ្នកដំណើរដែលរក្សាសុវត្ថិភាពកុមារ។




*សូមទាក់ទងមកយើងខ្ញុំ ដើម្បីស្នើសុំសម្ភារៈផ្សព្វផ្សាយសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ឬពិភាក្សាអំពីឱកាសនៃការផ្សព្វផ្សាយពាណិជ្ជកម្មរួមគ្នាតាមរយៈ:*
*childsafetourism@wvi.org*

w: childsafetourism.org and wvi.org/asiapacific/childsafetourism
f: facebook.com/ChildSafeTourism t: twitter.com/childsafetravel

**Child Safe Tourism**
Take action against abuse

សម្រាប់តែរដ្ឋាភិបាលប៉ុណ្ណោះ

# តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យកុមារមានសុវត្ថិភាពក្នុងវិស័យទេសចរណ៍នៅក្នុងប្រទេសរបស់ខ្ញុំ?

## សូមធ្វើតេស្ដ៏ខាងក្រោម៖

**សូមគូសសញ្ញា ✓ ចំពោះចម្លើយដែល ត្រឹមត្រូវ**

| | បាទ/ចាស | ទេ |
|---|---|---|
| ១. រដ្ឋាភិបាលរបស់ខ្ញុំ គឺជាហត្ថលេខីចំពោះអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ | | |
| ២. រដ្ឋាភិបាលរបស់ខ្ញុំមានគោលនយោបាយ យុទ្ធសាស្ត្រថ្នាក់ជាតិ ឬផែនការសកម្មភាពក្នុងការពង្រឹងប្រព័ន្ធការពារកុមារ ។ | | |
| ៣. រដ្ឋាភិបាលរបស់ខ្ញុំទទួលស្គាល់ថាកុមារមានសិទ្ធិពិសេសក្នុងការទទួលបានការការពារ ។ | | |
| ៤.រដ្ឋាភិបាលរបស់ខ្ញុំមានប្រព័ន្ធច្បាប់មានប្រសិទ្ធភាពក្នុងការដោះស្រាយការរំលោភបំពានកុមារ ជាពិសេសការរំលោភបំពានផ្លូវភេទ។ | | |
| ៥. រដ្ឋាភិបាលរបស់ខ្ញុំ អនុវត្តបទដ្ឋានសម្រាប់ឧស្សាហកម្មទេសចរណ៍ ដោយបញ្ជាក់អំពីកាតព្វកិច្ចក្នុងការការពារកុមារ។ | | |
| ៦. រដ្ឋាភិបាលរបស់ខ្ញុំបានបណ្ដុះបណ្ដាលមន្ត្រីពាក់ព័ន្ធអំពីរបៀបការពារកុមារ និងឆ្លើយតបទៅនឹងករណីរំលោភបំពានកុមាររួមទាំងការរំលោភបំពានផ្លូវភេទ ។ | | |
| ៧. រដ្ឋាភិបាលរបស់ខ្ញុំ មានខ្សែទូរស័ព្ទបន្ទាន់សម្រាប់រាយការណ៍អំពីកង្វល់នៃការការពារកុមាររួមទាំងការរំលោភបំពានផ្លូវភេទ ។ | | |
| ៨. រដ្ឋាភិបាលរបស់ខ្ញុំ គាំទ្រឲ្យមានខ្សែទូរស័ព្ទផ្ដល់ជំនួយសម្រាប់កុមារ ឪពុក ម្ដាយ និងអ្នកថែទាំ ដើម្បីទាក់ទងសុំការប្រឹក្សាយោបល់។ | | |
| ៩. រដ្ឋាភិបាលរបស់ខ្ញុំ គាំទ្រឲ្យមានការអប់រំជាសាធារណៈ និងការពិភាក្សាសង្គមអំពីការការពារកុមាររួមទាំងការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍។ | | |
| ១០. នាយកដ្ឋានសំខាន់ៗនៅក្នុងរដ្ឋាភិបាលរបស់ប្រទេសខ្ញុំសហការគ្នាក្នុងការការពារកុមារពីការរំលោភបំពានរួមទាំងការរំលោភបំពានផ្លូវភេទ។ | | |
| ១១. រដ្ឋាភិបាលរបស់ខ្ញុំ សហការជាមួយវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ ដើម្បីបញ្ឈប់ការរំលោភបំពានកុមារក្នុងវិស័យទេសចរណ៍ ។ | | |

សម្រាប់តែរដ្ឋាភិបាលប៉ុណ្ណោះ

# មធ្យោបាយនានាដែលរដ្ឋាភិបាលអាចធ្វើបាន ដើម្បីកសាងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

**១ រៀបចំ និងដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការថ្នាក់ជាតិអំពីការការពារកុមារ ៖**

- គោលនយោបាយជាតិឆ្លើយតបទៅនឹងការរំលោភបំពានកុមារ រួមទាំងការរំលោភបំពានផ្លូវភេទ ។
- ប្រព័ន្ធច្បាប់
- បទដ្ឋានសម្រាប់ប្រតិបត្តិករទេសចរណ៍

**២ ចាត់វិធានការបញ្ឈប់ការរំលោភបំពានកុមារក្នុងវិស័យទេសចរណ៍ ៖**

- យុទ្ធនាការដើម្បីការផ្លាស់ប្តូរឥរិយាបថ ការអប់រំសាធារណៈ និងកិច្ចពិភាក្សាសង្គម។
- លេខទូរស័ព្ទរាយការណ៍បន្ទាន់ និងខ្សែទូរស័ព្ទសម្រាប់ផ្តល់ជំនួយដល់កុមារ។
- បណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល ។
- ពិនិត្យមើលប្រវត្តិអ្នកដែលធ្វើការជាមួយកុមារផ្ទាល់។

**៣ សហប្រតិបត្តិការដើម្បីការពារកុមារ ៖**

- កិច្ចសហប្រតិបត្តិការអន្តរជាតិ
- កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ
- កិច្ចសហប្រតិបត្តិការតាមមូលដ្ឋាន (ការបញ្ជូន/ ការសម្របសម្រួល)



# ឧបសម្ព័ន្ធទី៣៖ ទម្រង់បញ្ជីវត្តមានអ្នកចូលរួម

ទីតាំងការបណ្តុះបណ្តាល៖ ______________________________

កាលបរិច្ឆេទការបណ្តុះបណ្តាល៖ ______________________________

| គោត្តនាម/នាម | ភេទ | តំណែង/ក្រុមហ៊ុន | អ៊ីម៉ែល/ទូរស័ព្ទ | ហត្ថលេខា |
| --- | --- | --- | --- | --- |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# ឧបសម្ព័ន្ធទី៤៖ សំណួរមុនចូលមេរៀន

| សូមអានសំណួរនីមួយៗ និងជ្រើសរើសយកចម្លើយណាមួយ ដោយគូសសញ្ញា ✓ | | បាទ/ចាស | ទេ | មិនដឹង |
|---|---|---|---|---|
| ១ | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះពីការរំលោភបំពានផ្លូវភេទ ? | | | |
| ២ | តើនៅតាមកន្លែងទេសចរណ៍នានា កុមារអាចប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានឬទេ ? | | | |
| ៣ | តើនៅក្នុងប្រទេសយើង ធ្លាប់មានករណីការរំលោភបំពានកុមារនៅតាមកន្លែងទេសចរណ៍ដែរឬទេ ? | | | |
| ៤ | តើអ្នកយល់អំពីទំនាក់ទំនងរវាងការរំលោភបំពានកុមារ នឹងវិស័យទេសចរណ៍ដែលអ្នកកំពុងបម្រើការងារដែរឬទេ ? | | | |
| ៥ | តើអ្នកដឹងថា មានសកម្មភាពអ្វីខ្លះដែលអ្នកអាចធ្វើបាន ដើម្បីរក្សាសុវត្ថិភាពកុមារពីការរំលោភបំពាននៅតាមទីកន្លែងទេសចរណ៍ ? | | | |
| ៦ | តើអាជីវកម្មទេសចរណ៍អាចធ្វើអ្វីខ្លះ ដើម្បីការពារកុមារពីការរំលោភបំពាន ? | | | |
| ៧ | តើអ្នកស្គាល់មនុស្ស និងទីកន្លែងដែលត្រូវទាក់ទង ដើម្បីរាយការណ៍ពីករណីសង្ស័យណាមួយនៃការរំលោភបំពានកុមារដែរឬទេ ?ប្រសិនបើស្គាល់ សូមសរសេរឈ្មោះ និង/ឬលេខទូរស័ព្ទ នៅទីនេះ<br>..........................................................................................<br>.......................................................................................... | | | |
| ៨ | តើមានតែកុមារដែលសុំទាន ឬរស់នៅតាមចិញ្ចើមថ្នល់តែប៉ុណ្ណោះ ដែលប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ មែនឬទេ ? | | | |

# ឧបសម្ព័ន្ធទី៥៖ សំណួរក្រោយមេរៀន

| សូមអានសំណួរនីមួយៗ និងជ្រើសរើសយកចម្លើយណាមួយ ដោយគូសសញ្ញា ✓ | | បាទ/ចាស | ទេ | មិនដឹង |
|---|---|---|---|---|
| ១ | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះពីការរំលោភបំពានផ្លូវភេទ ? | | | |
| ២ | តើនៅតាមកន្លែងទេសចរណ៍នានា កុមារអាចប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានឬទេ ? | | | |
| ៣ | តើនៅក្នុងប្រទេសយើង ធ្លាប់មានករណីការរំលោភបំពានកុមារនៅតាមកន្លែងទេសចរណ៍ដែរឬទេ ? | | | |
| ៤ | តើអ្នកយល់អំពីទំនាក់ទំនងរវាងការរំលោភបំពានកុមារនឹងវិស័យទេសចរណ៍ដែលអ្នកកំពុងបម្រើការងារដែរឬទេ ? | | | |
| ៥ | តើអ្នកដឹងថា មានសកម្មភាពអ្វីខ្លះដែលអ្នកអាចធ្វើបាន ដើម្បីរក្សាសុវត្ថិភាពកុមារពីការរំលោភបំពាននៅតាមទីកន្លែងទេសចរណ៍ ? | | | |
| ៦ | តើអាជីវកម្មទេសចរណ៍អាចធ្វើអ្វីខ្លះ ដើម្បីការពារកុមារពីការរំលោភបំពាន ? | | | |
| ៧ | តើអ្នកស្គាល់មនុស្ស និងទីកន្លែងដែលត្រូវទាក់ទង ដើម្បីរាយការណ៍ពីករណីសង្ស័យណាមួយនៃការរំលោភបំពានកុមារដែរឬទេ ?ប្រសិនបើស្គាល់ សូមសរសេរឈ្មោះ និង/ឬលេខទូរស័ព្ទ នៅទីនេះ<br>.......................................................................................................<br>....................................................................................................... | | | |
| ៨ | តើមានតែកុមារដែលសុំទាន ឬរស់នៅតាមចិញ្ចើមថ្នល់តែប៉ុណ្ណោះ ដែលប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ មែនឬទេ ? | | | |

# ឧបសម្ព័ន្ធទី៦ ៖ សេណារីយ៉ូករណីសិក្សា និងការសម្ដែងពី បុគ្គលិកវិស័យទេសចរណ៍

## ការសម្ដែងតួ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

១. ចែកសំណៅឯកសារ "សេណារីយ៉ូការសម្តែងតួ" ដល់អ្នកចូលរួមទាំងអស់ (ទំព័របន្ទាប់)។

២. អញ្ជើញអ្នកស្ម័គ្រចិត្តបួននាក់ឲ្យសម្តែងតួផ្សេងៗគ្នា។ ជម្រាបដល់អ្នកចូលរួមនៅក្នុងវេទិកាឲ្យសង្កេតមើលការសម្តែងតួ រួចឆ្លើយតបនឹងសំណួរនៅចុងបញ្ចប់ការសម្តែង (បារម្ភអំពីកុមារ បារម្ភអំពីការងាររបស់ខ្លួន បារម្ភអំពីប្រតិកម្មរបស់អតិថិជន)។

៣. អនុញ្ញាតិឲ្យអ្នកចូលរួមទាំងបួននាក់ចេញពីបន្ទប់រយៈពេលបីនាទី ដើម្បីត្រៀមខ្លួនសម្តែង។

៤. ប្រាប់អ្នកចូលរួមដទៃទៀតឲ្យអានសេណារីយ៉ូ និងពិចារណាថា តើពួកគាត់នឹងធ្វើដូចម្តេច បើសិនជាពួកគេជាបុគ្គលិកស្វាគមន៍ភ្ញៀវម្នាក់។

៥. អញ្ជើញអ្នកស្ម័គ្រចិត្តឲ្យចាប់ផ្តើមការសម្តែងតួ។

៦. បន្ទាប់ពីការសម្តែងតួចប់ សូមសួរនូវសំណួរខាងក្រោម៖

- តើបុគ្គលិកស្វាគមន៍ភ្ញៀវមានប្រតិកម្មយ៉ាងដូចម្តេច?
- តើអ្នកគិតថា បុគ្គលិកស្វាគមន៍ភ្ញៀវម្នាក់អាចនឹងមានអារម្មណ៍ដូចម្តេច ប្រសិនបើនេះជាស្ថានភាពកើតឡើងជាក់ស្តែង? (ដែលបារម្ភពីកុមារពីការងាររបស់នាង និងពីអតិថិជនផ្សេងៗទៀត)?
- តើការឆ្លើយតបរបស់បុគ្គលិកស្វាគមន៍ភ្ញៀវសមស្របឬទេ? (ក្នុងប្រទេសជាច្រើន ភ្ញៀវត្រូវផ្តល់សំណៅលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណមួយច្បាប់ ពេលគេចុះឈ្មោះចូលស្នាក់នៅសណ្ឋាគារ ឬផ្ទះសំណាក់។ល។ វិធីមួយនេះ គឺដើម្បីធានាឲ្យបានថា ជានិច្ចកាលកុមារមានការអមដំណើរពីឪពុកម្តាយ ឬអ្នកថែទាំ ពេលគេស្នាក់នៅតាមកន្លែងស្នាក់នៅនានា។)
- តើអ្នកគ្រប់គ្រងសណ្ឋាគារអាចធ្វើអ្វីបាន ដើម្បីជួយដល់បុគ្គលិកស្វាគមន៍ភ្ញៀវនៅក្នុងស្ថានភាពនេះ? (ផ្តល់ការបណ្តុះបណ្តាលមូលដ្ឋានដល់អ្នកបំរើការនៅបញ្ជរស្វាគមន៍ភ្ញៀវ អំពីរបៀបដែលត្រូវអនុវត្តគោលនយោបាយរបស់សណ្ឋាគារ ដាក់តាំងបង្ហាញគោលនយោបាយសណ្ឋាគារយ៉ាងច្បាស់ៗ ពីតម្រូវការនានាពេលចុះឈ្មោះចូលស្នាក់នៅ ក៏ដូចជាគោលនយោបាយទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ។)
- តើបុរសបរទេសមានប្រតិកម្មដូចម្តេចចំពោះការបដិសេធរបស់បុគ្គលិកស្វាគមន៍ភ្ញៀវ?
- តើអ្នកគិតថា បុរសនោះបានដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ដែលនឹងកើតមាន ដោយសារការរួមភេទជាមួយកុមារឬទេ?
- តើអ្នកគិតថា គាត់នឹងធ្វើអ្វីនៅពេលនេះ? ហេតុអ្វី?
- តើអ្នកគិតថាកុមារមានអារម្មណ៍ដូចម្តេចនៅក្នុងស្ថានភាពនេះ?
- តើអ្នកគិតថា ហេតុអ្វីបានជាកុមារស្ថិតក្នុងស្ថានភាពនេះ?
- តើមនុស្សជុំវិញខ្លួន (ដូចជាភ្ញៀវទេសចរដទៃទៀតជាដើម) អាចជួយដល់កុមារ? (ពួកគេអាចសាកសួរទៅកុមារ ដើម្បីដឹងថាតើកុមារមិនអីទេឬយ៉ាងណា)។

- តើអ្នកគិតថាភ្ញៀវទេសចរដទៃទៀតមានអារម្មណ៍ដូចម្តេច ?
- តើភ្ញៀវទេសចរដទៃគួរតែធ្វើដូចម្តេច ?
- តើភ្ញៀវទេសចរអាចធ្វើអ្វីបាន៖
  – ក្នុងអំឡុងពេលសន្ទនា ?
  – ក្រោយមកនៅពេលការសម្រាកវិស្សមកាលរបស់ពួកគេ ? ( បង្ហាញក្តីបារម្ភរបស់ខ្លួនប្រាប់ទៅថ្នាក់គ្រប់គ្រងសណ្ឋាគារ និងស្នើឲ្យសណ្ឋាគារមានបទដ្ឋានច្បាស់លាស់ ដើម្បីធានាថាកុមារមានសុវត្ថិភាពពីការរំលោភបំពាន ) ។
  – បន្ទាប់ពីពួកគេត្រលប់ទៅផ្ទះវិញ ? ( និយាយជាមួយមិត្តភក្តិ និងគ្រួសាររបស់ពួកគេអំពីការជ្រើសរើសកន្លែងស្នាក់នៅ និងអ្នកផ្តល់សេវាទេសចរណ៍ណាដែលផ្តល់អាទិភាពចំពោះទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ។ )
- តើមានចម្លើយណាមួយរបស់អ្នកនឹងផ្លាស់ប្តូរឬទេ ប្រសិនបើ "បុរស" នោះអាយុ ២៥ឆ្នាំ ? ( ចម្លើយមិនគួរផ្លាស់ប្តូរទេ។ អ្នករំលោភបំពានអាចជានរណាក៏បាន ស្ថិតក្នុងអាយុណាមួយក៏បាន។
- តើមានចំលើយណាមួយរបស់អ្នកនឹងផ្លាស់ប្តូរឬទេ ប្រសិនបើ "បុរស" នោះគឺជាមនុស្ស "ស្រី" ឬប្រសិនបើកុមារនោះជា "កុមារា" ? ( ចម្លើយមិនគួរផ្លាស់ប្តូរទេ។ ជាការសំខាន់ដែលត្រូវចងចាំថា ទាំងបុរស និងស្ត្រីគឺសុទ្ធតែអាចរំលោភបំពានកុមារ។ ដូចគ្នានេះដែរ ទាំងកុមារី និងកុមារាសុទ្ធតែមានភាពងាយរងគ្រោះចំពោះការរំលោភបំពាន )។
- តើមានចំលើយណាមួយរបស់អ្នកនឹងផ្លាស់ប្តូរឬទេ ប្រសិនបើកុមារនោះជាកុមារចំណាកស្រុក/ជនជាតិដើមភាគតិច ? ( ចម្លើយមិនគួរផ្លាស់ប្តូរទេ។ ជាការសំខាន់ដែលត្រូវចងចាំថា កុមារទាំងអស់សុទ្ធតែមានសិទ្ធិទទួលការការពារពីការរំលោភបំពានផ្លូវភេទ។ ក្នុងករណីមួយចំនួន កុមារចំណាកស្រុកឬកុមារជនជាតិដើមភាគតិចអាចមានភាពងាយរងគ្រោះជាង ហេតុនេះពួកគេត្រូវការការថែទាំជាពិសេសដើម្បីធានាឱ្យបានថាពួកគេមានសុវត្ថិភាព។



# សេណារីយ៉ូសម្តែងតួ

## ស្ថានភាព

បុគ្គលិកស្វាគមន៍ភ្ញៀវម្នាក់ កំពុងធ្វើការនៅខាងក្រោយតុស្វាគមន៍ភ្ញៀវក្នុងសណ្ឋាគារមួយ។ មានភ្ញៀវទេសចរម្នាក់ កំពុងឈរនៅកន្លែងទទួលភ្ញៀវ។ បុរសបរទេសម្នាក់ទៀត អាយុប្រហែល ៤៥-៥០ឆ្នាំ ដើរចូលមក ដោយកាន់ដៃក្មេងស្រីម្នាក់ អាយុប្រហែល១៣ ឬ១៤ឆ្នាំ។ ពួកគេទាំងពីរ ដើរជាមួយគ្នាទៅរកតុស្វាគមន៍ភ្ញៀវ ហើយបុរសនោះសួររកបន្ទប់មួយ។ បើទោះបីជាបុគ្គលិកទទួលភ្ញៀវ នោះមិនសូវដឹងច្បាស់អំពីគោលនយោបាយរបស់សណ្ឋាគារក្តី ប៉ុន្តែពួកគេមានអារម្មណ៍ថាពេស្យាចារកុមារ គឺជារឿងខុសច្បាប់ និងចង់បដិសេធមិនឲ្យភ្ញៀវទេសចរ និងក្មេងស្រីនោះចូលឡើយ។

## ការណែនាំ៖

អ្នកចូលរួមបួននាក់ ត្រូវបានស្នើសុំឲ្យស្ម័គ្រចិត្តសម្តែងតួដូចខាងក្រោម។

| តួសម្តែង | សកម្មភាព |
|---|---|
| **បុគ្គលិកទទួលភ្ញៀវ** | បដិសេធមិនឲ្យភ្ញៀវបរទេស និងកុមារនោះចូលសណ្ឋាគារ។ |
| **បុរសបរទេស** | ទទូចចង់បានបន្ទប់មួយ ដោយលើកឡើងថានឹងផ្តល់លុយបន្ថែម ខឹង និងសុំជួបនិយាយជាមួយអ្នកគ្រប់គ្រង។ |
| **កុមារ** | នៅខាងជនបរទេស ឆ្លើយសំណួរប្រសិនបើគេសួរ។ |
| **ភ្ញៀវទេសចរម្នាក់ទៀត** | ឈរសង្កេតការសន្ទនា។ សូមគិតអំពីអារម្មណ៍ ដែលភ្ញៀវទេសចរជាក់ស្តែងម្នាក់អាចនឹងគិតនៅក្នុងករណីនេះ។ |

# សេណារីយ៉ូករណីសិក្សា អំពីប្រតិបត្តិករទេសចរណ៍

**សេណារីយ៉ូទី ១**

អ្នកធ្វើការងារជាមគ្គុទ្ទេសក៏នាំភ្ញៀវទេសចរក្នុងក្រុមហ៊ុនទេសចរណ៍មួយ ដែលមានជំនាញផ្នែកទេសចរណ៍ខ្នាតតូច ទៅកាន់សហគមន៍ជនជាតិភាគតិច។ ឥឡូវនេះ អ្នកកំពុងអមដំណើរទេសចរបរទេសមួយក្រុម ដែលមានគ្នាប្រាំបួននាក់ ទៅកាន់សហគមន៍ជនបទមួយ ដោយអ្នកបានចំណាយពេលបីថ្ងៃកន្លងមក ដើម្បីដើរលេងជុំវិញភ្នំ និងត្រលប់មកភូមិវិញ ដើម្បីស្នាក់នៅផ្ទះសំណាក់តាមផ្ទះអ្នកភូមិនៅពេលយប់។ កុមារក្នុងមូលដ្ឋានរកលុយ ដោយការលក់វត្ថុអានុស្សាវរីយ៍ដល់ភ្ញៀវទេសចរ។ ជារឿយៗ កុមារទាំងនោះតែងមិនចូលសាលា ហើយដើរតាមភ្ញៀវទេសចរនៅពេលពួកគេដើរកំសាន្ត (ដោយសង្ឃឹមថាភ្ញៀវទាំងនោះនឹងទិញវត្ថុអានុស្សាវរីយ៍)។ អ្នកបានសង្កេតឃើញភ្ញៀវទេសចរម្នាក់ក្នុងចំណោមទាំង ៩នាក់នោះ (៣០ឆ្នាំប្លាយ) បានបង្កើតភាពស្និទ្ធស្នាលជាមួយកុមារីនៅភូមិនោះម្នាក់ (៨-១០ ឆ្នាំ)។ កុមារីនោះដើរកៀកគាត់ នៅពេលថ្ងៃ ហើយពួកគេនិយាយលេងសើចសប្បាយជាមួយគ្នា។ គាត់បានថតរូបកុមារីនោះជាច្រើន។ ពេលរសៀលនេះ អ្នកបានឃើញពួកគេត្រលប់មកពីដើរកំសាន្តតែពីរនាក់ នៅក្រៅភូមិ។

*១. តើអ្នកនឹងធ្វើដូចម្តេច?*

*២.តើក្រុមហ៊ុនទេសចរណ៍របស់អ្នកគួរធ្វើយ៉ាងណាក្នុងពេលខាងមុខ?*

**សេណារីយ៉ូទី ២**

អ្នកជាអ្នករត់រឺម៉កម៉ូតូ។ អ្នកចំណាយពេលភាគច្រើន ដើម្បីរង់ចាំភ្ញៀវ នៅកន្លែងទេសចរណ៍ដើរកំសាន្ត និងនៅតាមតៀមកាហ្វេ និងបារទេសចរណ៍ល្បីៗ។ នៅពេលអ្នកកំពុងរង់ចាំ អ្នកឃើញមានក្មេងលក់ឥវ៉ាន់ និងក្មេងរស់នៅតាមចិញ្ចើមថ្នល់ជាច្រើន។ នៅពេលអ្នកព្យាយាមហៅភ្ញៀវឲ្យជិះរឺម៉កម៉ូតូរបស់អ្នក ក្មេងៗក៏មកលក់វត្ថុអនុស្សាវរីយ៍ លក់អាហារញ៉ាំលេង ឬសុំលុយពីភ្ញៀវទាំងនោះដែរ។ យប់នេះបុរសបរទេសម្នាក់ចំណាយពេលដ៏យូរនិយាយជាមួយកុមារាៗទាំងនោះ (ប្រហែលអាយុ ១០ឆ្នាំ)។ អ្នកបានឮបុរសនោះនិយាយហៅកុមារាៗទាំងនោះឱ្យទៅលេងវីដេអូហ្គេមនៅសណ្ឋាគាររបស់គាត់។ ពេលនេះបុរសនោះសួរអ្នកថា តើអ្នកយកថ្លៃប៉ុន្មាន ដើម្បីដឹកកុមារៗទៅសណ្ឋាគាររបស់គាត់។

*១. តើអ្នកនឹងធ្វើដូចម្តេច?*

**សេណារីយ៉ូទី ៣**

អ្នកជាមគ្គុទ្ទេសក៏នាំភ្ញៀវទេសចរម្នាក់។ ក្នុងផ្នែកមួយនៃការធ្វើដំណើរកំសាន្ត ក្នុងតំបន់អភិរក្សមួយ តាមធម្មតាអ្នកតែងឈប់នៅក្នុងភូមិកុលសម្ព័ន្ធមួយ ដែលមានមនុស្សលក់តែ និងអាហាញ៉ាំលេង ក៏ដូចជារបស់សិប្បកម្មធ្វើដោយដៃឲ្យអតិថិជនជាភ្ញៀវទេសចររបស់អ្នកទិញ។ គ្រប់ពេលដែលអ្នកឆ្លងកាត់ភូមិ កុមារៗតែងរត់មករកអតិថិជនរបស់អ្នកយ៉ាងកកកុញជុំវិញភ្ញៀវ និងសុំលុយ អាហារ និងអំណោយដទៃទៀត។ ជារឿយៗ អតិថិជនមានអារម្មណ៍មិនដឹងត្រូវធ្វើយ៉ាងណាជាមួយក្មេងៗ ហើយទីបំផុតក៏ឲ្យលុយ អាហារ បង្អែម ក៏ដូចជារបស់របរដទៃទៀតដល់កុមារ។ អ្នកបានសង្កេតឃើញថា មានកុមារកាន់តែច្រើនឡើងៗ ចូលមករកអតិថិជនរបស់អ្នកដើម្បីសុំលុយ។

*១. តើអ្នកគិតដូចម្តេចចំពោះរឿងនេះ? តើបញ្ហានេះបង្ហាញឲ្យឃើញអំពីគ្រោះថ្នាក់អ្វីចំពោះកុមារ?*

*២. តើក្រុមហ៊ុនធ្វើដំណើររបស់អ្នកគួរធ្វើយ៉ាងណាក្នុងរយៈពេលវែង ដើម្បីផ្តល់អត្ថប្រយោជន៍ដល់កុមារ និងឆ្លើយតបនឹងបំណងប្រាថ្នារបស់អតិថិជន?*

# កំណត់សម្គាល់អ្នកសម្របសម្រួល ៖ បញ្ហាដែលត្រូវពិចារណា

## សេណារីយ៉ូទី ១

១. សាកសួរ៖ តើក្មេងស្រីនោះមិនអីទេ/មានសុវត្ថិភាពឬទេ ? តើបុរសនោះបានដឹងឬទេថា វាជាការមិនសមស្របទេក្នុងការនាំកុមារចេញទៅដោយពុំមានការមើលខុសត្រូវ/ការអនុញ្ញាតសមស្រប ? ប្រសិនបើស្ថានភាពនៅមានភាពមិនច្បាស់លាស់ ហើយអ្នកមានក្តីបារម្ភក្រែងកុមាររងការរំលោភបំពាន ឬកំពុងប្រឈមនឹងគ្រោះថ្នាក់នោះ សូមនិយាយទៅកាន់អ្នកគ្រប់គ្រងរបស់អ្នក និង/ឬរាយការណ៍ទៅកាន់ អង្គការ/អាជ្ញាធរដែលទទួលបន្ទុកការពារកុមារ។

២. ក្រុមហ៊ុនអាចសរសេរ និងអនុវត្តគោលនយោបាយការពារកុមារ ដើម្បីបង្កើតឲ្យមានដំណើរការច្បាស់លាស់ ( ឧ. តើបុគ្គលិកគួររាយការណ៍ពីកង្វល់ស្តីពីការការពារកុមារដោយរបៀបណា និងរាយការណ៍ទៅនរណា ? )។ ក្រុមហ៊ុនអាចផ្តល់ការបណ្តុះបណ្តាល និងផ្តល់ភាពអង់អាចដល់បុគ្គលិក ដើម្បីឲ្យគេយល់អំពីរបៀបការពារកុមារ នៅក្នុងបរិបទនៃការងាររបស់ខ្លួន។ ក្រុមហ៊ុនអាចផ្សព្វផ្សាយ ឬចែករំលែកសំណៅគោលនយោបាយការពារកុមាររបស់ខ្លួនទៅអតិថិជន ( ភ្ញៀវទេសចរ ) ដើម្បីឲ្យពួកគេបានដឹងអំពីអាកប្បកិរិយា ដែលពួកគេគួរប្រព្រឹត្តជាមួយកុមារក្នុងមូលដ្ឋាន ក្នុងអំឡុងពេលពួកគេធ្វើដំណើរ។ ក្រុមហ៊ុនអាចអប់រំអតិថិជនអំពីទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ។

## សេណារីយ៉ូទី ២

មិនត្រូវយល់ព្រមដឹកគាត់ទៅសណ្ឋាគាររបស់គាត់ឡើយ។ ធ្វើការសាកសួរ៖ តើកុមារានោះមិនអីទេ/មានសុវត្ថិភាពឬទេ ? ត្រូវរាយការណ៍ទៅកាន់អង្គការ/អាជ្ញាធរ ដែលទទួលបន្ទុកការពារកុមារ។ សូមចងចាំភិនភាគ និងរូបរាងរបស់បុរសនោះ ដើម្បីជួយប៉ូលីសក្នុងការកំណត់អត្តសញ្ញាណគាត់។

## សេណារីយ៉ូទី ៣

១. អាចមានគ្រោះថ្នាក់ដោយកុមារកាន់តែច្រើនឡើងៗនឹងទៅរកភ្ញៀវនោះដោយផ្ទាល់ដើម្បីបានអំណោយជាលុយ។ ចំណុចនេះអាចធ្វើឲ្យកុមារមិនបានទៅរៀនសូត្រ មិនមានសុវត្ថិភាព និងធ្វើឲ្យពួកគេមានភាពងាយរងគ្រោះចំពោះការរំលោភបំពាន។

២. ក្រុមហ៊ុនអាចសរសេរ និងអនុវត្តគោលនយោបាយការពារកុមារ ដើម្បីបង្កើតឲ្យមានដំណើរការច្បាស់លាស់ ( ឧ. តើបុគ្គលិកគួររាយការណ៍អំពីកង្វល់ស្តីពីការការពារកុមារដោយរបៀបណា និងរាយការណ៍ទៅនរណា ? តើក្រុមហ៊ុននឹងគាំទ្រសហគមន៍ក្នុងមូលដ្ឋានឲ្យការពារកុមារដោយរបៀបណា ? ) ក្រុមហ៊ុនអាចផ្តល់ការបណ្តុះបណ្តាល និងផ្តល់ភាពអង់អាចដល់បុគ្គលិក ដើម្បីឲ្យគេយល់អំពីរបៀបការពារកុមារ នៅក្នុងបរិបទនៃការងាររបស់ខ្លួន។ ក្រុមហ៊ុនអាចផ្សព្វផ្សាយ ឬចែករំលែកសំណៅគោលនយោបាយការពារកុមាររបស់ខ្លួនទៅអតិថិជន ( ភ្ញៀវទេសចរ ) ដើម្បីឲ្យពួកគេបានដឹងអំពីអាកប្បកិរិយាដែលពួកគេគួរប្រព្រឹត្តជាមួយកុមារក្នុងមូលដ្ឋាន ក្នុងអំឡុងពេលពួកគេធ្វើដំណើរ។ ក្រុមហ៊ុនអាចអប់រំអតិថិជន អំពីទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ រួមទាំងជម្រើសដទៃផ្សេងទៀត ក្នុងការផ្តល់លុយ ឬអំណោយផ្សេងៗដល់កុមារដោយផ្ទាល់ដៃ។ ក្រុមហ៊ុនក៏អាចពិនិត្យផងដែរថា តើខ្លួនគួរធ្វើយ៉ាងណាដើម្បីគាំទ្រគ្រួសារក្នុងមូលដ្ឋាន និង/ឬការផ្តួចផ្តើមគំនិតផ្សេងៗ ដើម្បីផ្តល់ការជួយសមស្របសម្រាប់កុមារងាយរងគ្រោះ។

# ឧបសម្ព័ន្ធទី៧៖ សេណារីយ៉ូករណីសិក្សាអំពីអ្នកគ្រប់គ្រងផ្នែកទេសចរណ៍

✄

**សេណារីយ៉ូទី ១**

អ្នកគឺជាម្ចាស់ផ្ទះសំណាក់មួយ។ ផ្ទះសំណាក់របស់អ្នកមាន ១៦បន្ទប់ ដែលសក្តិសមសម្រាប់អ្នកធ្វើដំណើរដែលមានថវិកាតិចតួច។ អ្នកមានបុគ្គលិកមួយក្រុមតូច រួមមានបុគ្គលិកទទួលស្វាគមន៍ភ្ញៀវបីនាក់ (ម្នាក់ធ្វើការជារៀងរាល់យប់) អ្នកបោសសំអាតម្នាក់ និងបុរសម្នាក់ដែលផ្តល់សេវាសន្តិសុខនៅពេលយប់។ ដោយសារអ្នកមានអាជីវកម្មផ្សេងទៀត អ្នកមកមើលផ្ទះសំណាក់តែ ១-២ ដងក្នុងមួយសប្តាហ៍ ដើម្បីពិនិត្យមើលរបៀបរៀបរយ ការរៀបចំ និងការថែនាំនានា។ រសៀលនេះ ពេលអ្នកមកដល់ផ្ទះសំណាក់ អ្នកសង្កេតឃើញមានកុមារក្មេងនៅភូមិជិតនោះពីរនាក់ (១២-១៤ឆ្នាំ) ចេញពីបន្ទប់មួយរបស់បុរសបរទេសម្នាក់។ នេះជាលើកទីមួយហើយ ដែលអ្នកបានឃើញទិដ្ឋភាពបែបនេះ។ ពីមុនមក អ្នកមិនដែលបង្កើតឲ្យមានការផ្តួចផ្តើមគំនិតការពារកុមារណាមួយនៅក្នុងកន្លែងធ្វើការរបស់អ្នកឡើយ។

*១. តើអ្នកមានអារម្មណ៍ដូចម្តេចចំពោះស្ថានភាពនេះ? តើមានគ្រោះថ្នាក់អ្វីចំពោះកុមារឬទេ?*

*២.តើភ្លាមៗនោះអ្នកនឹងធ្វើអ្វី?*

*៣.តើអ្នកមានមធ្យាបាយណាមួយនាពេលអនាគត?*

✄

**សេណារីយ៉ូទី ២**

អ្នកគឺជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនធ្វើដំណើរមួយ។ នៅឆ្នាំកន្លងទៅថ្មីៗនេះ អ្នកបានសង្កេតឃើញថា ទេសចរបរទេសចង់បង្កើនបទពិសោធន៍ការធ្វើដំណើររបស់ខ្លួន តាមរយៈ"ការចូលរួម" ជាមួយមនុស្សក្នុងមូលដ្ឋាន និងសហគមន៍មូលដ្ឋាន។ នៅពេលគេកក់ការដំណើរទេសចរណ៍របស់ខ្លួន ភ្ញៀវបរទេសតែងចង់បាន មិនត្រឹមតែកន្លែងល្បីៗប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ចង់ចូលរួមជាមួយប្រជាជនក្នុងមូលដ្ឋាន ហើយពេលខ្លះពួកគេថែមទាំងចង់ផ្តល់សេវាស្ម័គ្រចិត្ត ដើម្បីគាំទ្រសហគមន៍ក្រីក្រផងដែរ។ មណ្ឌលកុមារកំព្រាតូចមួយក្នុងមូលដ្ឋានបានស្នើថា (ដើម្បីប្រាក់កម្រៃតិចតួច) អ្នកអាចនាំក្រុមភ្ញៀវទេសចរបរទេសចូលទៅកាន់មជ្ឈមណ្ឌលរបស់ខ្លួន ដើម្បីទៅទស្សនកិច្ចនៅពេលថ្ងៃជាមួយកុមាររបស់ខ្លួន។ ប្រសិនបើចង់ទេសចរអាចនាំកុមារទៅដើរលេងបានដែរ តែម្នាក់ឯងក៏បាន។

*១. តើអ្នកមានអារម្មណ៍ដូចម្តេចចំពោះស្ថានភាពនេះ? តើមានគ្រោះថ្នាក់អ្វីចំពោះកុមារឬទេ?*
*២.តើភ្លាមៗនោះអ្នកនឹងធ្វើអ្វី?*
*៣.តើអ្នកមានមធ្យាបាយណាមួយនាពេលអនាគត?*
*៤. តើសកម្មភាពអ្វីដែលអ្នកអាចផ្តល់ជូនអតិថិជនរបស់អ្នកបាន ជំនួសឱ្យការទៅទេសចរណ៍នៅមណ្ឌលកុមារកំព្រា? តើអ្នកនឹងផ្តល់ដំបូន្មានដូចម្តេចទៅមណ្ឌលកុមារកំព្រាក្នុងមូលដ្ឋាន និងមានវិធីអ្វីប្រសើរជាងនេះដែលអ្នកអាចគាំទ្រដល់ពួកគេបាន?*

✄

**សេណារីយ៉ូទី ៣**

អ្នកជាម្ចាស់ភោជនីយដ្ឋាន/បារមួយ។ អតិថិជនជាច្រើនរបស់អ្នក គឺជាទេសចរ ហើយជារឿយៗពួកគេច្រើនតែមកដល់កន្លែងអ្នកនៅពេលល្ងាច។ អ្នកសង្កេតឃើញថា នៅពេលយប់ជ្រៅ ពេលខ្លះរហូតដល់ម៉ោង ១១យប់ មានក្មេងស្រីលក់ផ្កាម្នាក់ (៨ឆ្នាំ) តែងចូលមកក្នុងបរិវេណកន្លែងរបស់អ្នក ដើម្បីព្យាយាមលក់ផ្កាឲ្យអតិថិជន។ ជារឿយៗ មានបុរសម្នាក់រង់ចាំនាងនៅខាងក្រៅ។

*១. តើអ្នកមានអារម្មណ៍ដូចម្តេចចំពោះស្ថានភាពនេះ? តើមានគ្រោះថ្នាក់អ្វីចំពោះកុមារឬទេ?*

*២.តើភ្លាមៗនោះអ្នកនឹងធ្វើអ្វី?*

*៣. តើអ្នកជ្រើសរើសយកដំណោះស្រាយអ្វីនាពេលអនាគត?*

# កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖

## សកម្មភាពដែលត្រូវធ្វើបន្ទាន់

### សេណារីយ៉ូទី ១

- ការសាកសួរផ្ទៃក្នុង (និយាយជាមួយបុគ្គលិក និងពិនិត្យកំណត់ហេតុ ធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ)
- តើកុមារានោះចុះឈ្មោះចូលស្នាក់នៅជាមួយមនុស្សពេញវ័យឬទេ? តើអត្តសញ្ញាណប័ណ្ណអ្វី ដែលគេបានផ្តល់ឲ្យពេលចុះឈ្មោះស្នាក់នៅ? តើភ្ញៀវរបស់សណ្ឋាគារជានរណា? តើកុមារានោះជានរណា?
- មិនគួរអនុញ្ញាតឲ្យកុមារាត្រលប់ទៅកាន់បន្ទប់វិញឡើយ រហូតទាល់តែការត្រួតពិនិត្យជាមូលដ្ឋាននេះត្រូវបានធ្វើឡើងរួចរាល់ហើយ។
- ប្រសិនបើស្ថានភាពនៅតែមិនទាន់ច្បាស់លាស់ សូមរាយការណ៍ទៅកាន់អាជ្ញាធរមូលដ្ឋាន។

### សេណារីយ៉ូទី ២

- មិនត្រូវឲ្យមានទស្សនកិច្ចពេលថ្ងៃ ទៅកាន់មណ្ឌលកុមារកំព្រាឡើយ
- ការពិចារណាដើម្បី៖
  - ពិនិត្យកេរ្តិ៍ឈ្មោះ និងសុខមាលភាពរបស់កុមារនៅក្នុងមណ្ឌលកុមារកំព្រាក្នុងមូលដ្ឋាន
  - វិភាគលើបុគ្គលិក និងភ្ញៀវ
  - ភាពញឹកញាប់ និងលក្ខណៈសម្បត្តិនៃការទៅទស្សនកិច្ច

### សេណារីយ៉ូទី ៣

- មិនត្រូវអនុញ្ញាតិឲ្យកុមារីនោះចូលមកក្នុងភោជនីយដ្ឋានដើម្បីលក់ផលិតផលឡើយ
- សាកសួរអំពីកុមារីនោះ ដូចជា៖ តើនាងជានរណា? និងតើនាងមានទំនាក់ទំនងដូចម្តេចជាមួយបុរសដែលនៅខាងក្រៅ?
- ប្រសិនបើមានកង្វល់ សូមរាយការណ៍ទៅកាន់អាជ្ញាធរមូលដ្ឋាន។

### សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ចំណុចខាងក្រោមនេះ អាចមានសក្តានុពលពាក់ព័ន្ធនឹងសេណារីយ៉ូ៖

- សរសេរ និងអនុវត្តគោលនយោបាយការពារកុមារ ដើម្បីបង្កើតឲ្យមានដំណើរការច្បាស់លាស់ (ឧ. តើបុគ្គលិកគួររាយការណ៍អំពីកង្វល់ស្តីពីការការពារកុមារដោយរបៀបណា និងរាយការណ៍ទៅនរណា?)
- អប់រំ និងផ្តល់ភាពក្លាហានដល់បុគ្គលិក ដើម្បីអនុវត្តគោលនយោបាយ
- ផ្សព្វផ្សាយអំពីគោលការណ៍ការពារកុមារឲ្យភ្ញៀវបានដឹងជាសាធារណៈ
- អប់រំភ្ញៀវអំពី (យុទ្ធនាការ) ទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ
- គាំទ្រដល់គ្រួសារ និង/ឬការផ្តួចផ្តើមគំនិតក្នុងមូលដ្ឋាន ដែលធ្វើការងារដើម្បីផ្តល់លទ្ធផលជាវិជ្ជមានដល់កុមារដែលងាយរងគ្រោះ។
- លើកបញ្ហាឡើង និងពិភាក្សាជាមួយសហការីក្នុងវិស័យទេសចរណ៍។

# ឧបសម្ព័ន្ធទី៨៖ ទម្រង់ទស្សនៈរបស់ខ្ញុំ

ត្រូវរៀបចំទម្រង់នេះ សម្រាប់អ្នកចូលរួមម្នាក់ៗ។ ត្រូវចែកជូនទម្រង់ទាំងនេះដល់អ្នកចូលរួម នៅក្នុងម៉ោងសរុបមេរៀន។ ក្រៅពីនេះ អ្នកសម្របសម្រួលអាចកំណត់កម្រិតចម្លើយរបស់អ្នកចូលរួមដោយការនិយាយតាមរយៈការសួរសំណួរងាយៗមួយចំនួនដូចជា តើម៉ោងសិក្សានេះមានប្រយោជន៍ឬទេ? តើថ្ងៃនេះអ្នកបានដឹងព័ត៌មានដែលមានប្រយោជន៍អ្វីខ្លះ? តើមានអ្វីដែលយើងគួរផ្លាស់ប្ដូរសម្រាប់ម៉ោងសិក្សាក្រោយៗឬទេ?

## ទស្សនៈរបស់ខ្ញុំ

យើងឲ្យតម្លៃលើទស្សនៈរបស់អ្នក! ត្រូវផ្ដល់ព័ត៌មានត្រឡប់វិញដោយស្មោះត្រង់របស់អ្នក ដើម្បីជួយដល់យើងក្នុងការលើកកម្ពស់កិច្ចការពារកុមាររបស់យើង។

**១. តើអ្នកធ្វើការនៅក្នុងវិស័យអ្វី?**

- ○ រដ្ឋាភិបាល
- ○ អាជីវកម្ម
- ○ សហគមន៍
- ○ បើផ្សេងពីនេះ សូមបញ្ជាក់

**២. តើភេទរបស់អ្នកជាអ្វី?**

- ○ ស្រី
- ○ ប្រុស
- ○ ផ្សេងពីនេះ

**៣. សូមដាក់កម្រិតវាយតម្លៃដូចខាងក្រោម ៖**

| | | | |
|---|---|---|---|
| អ្នកសម្របសម្រួលពន្យល់ច្បាស់លាស់ ហើយមេរៀនមានភាពងាយស្រួលអនុវត្ត។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |
| សម្ភារទាំងឡាយសុទ្ធតែមានប្រយោជន៍។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |
| ការពិភាក្សា ជួយលើកកម្ពស់ការយល់ដឹងរបស់ខ្ញុំពីបញ្ហានេះ។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |
| ការពិភាក្សាបានលើកទឹកចិត្តខ្ញុំឲ្យបង្កើនសកម្មភាពការពារកុមារ។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |

៤.តើផ្នែកណាមួយនៃមេរៀនក្នុងវគ្គបណ្តុះបណ្តាលនេះមានសារៈប្រយោជន៍បំផុតសម្រាប់អ្នក ក្នុងការងារ/ជីវិតរបស់អ្នក ?

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

៥. តើយើងគួរធ្វើអ្វីខ្លះ ដើម្បីឲ្យវគ្គបណ្តុះបណ្តាលនេះកាន់តែប្រសើរឡើង ?

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

៦.សូមកំណត់សកម្មភាពមួយដែលអ្នកនឹងធ្វើដើម្បីរួមចំណែកក្នុងកិច្ចការពារកុមារបន្ទាប់ពីការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

៧. តើអ្នកមានយោបល់ផ្សេងទៀតដែរឬទេ ?

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

…………………………………………………………………………………………………….

# ឧបសម្ព័ន្ធទី៩៖ គំរូវិញ្ញាបនប័ត្រ

Child Safe Tourism

## វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា

សូមបញ្ជាក់ថា

**ឈ្មោះអ្នកចូលរួម**

បានបញ្ចប់វគ្គសិក្ខាសាលាបណ្តុះបណ្តាលស្តីពី

**សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**

វគ្គបណ្តុះបណ្តាលសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍បានផ្តល់អោយអ្នកចូលរួមមានការការពារកាន់តែ
ប្រសើរឡើងពីការរំលោភបំពាននិងកេងប្រវញ្ច័កុមារ ក្នុង វិស័យទេសចរណ៍និងធ្វើដំណើរ
www.childsafetourism.org

Australian Aid

World Vision

# ឧបសម្ព័ន្ធទី១០៖ គំរូវិភាគលទ្ធផលលើសំណួរមុនចូលមេរៀន និងសំណួរក្រោយមេរៀន

| | សំណួរ | សំណួរចូល | | | សំណួរចេញ | | | សំណួរចូល | សំណួរចេញ | ការប្រែប្រួល | ចម្លើយដែលចង់បាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | | បាទ/ចាស | ទេ | មិនដឹង | បាទ/ចាស | ទេ | មិនដឹង | % នៃចម្លើយត្រឹមត្រូវ | % នៃចម្លើយត្រឹមត្រូវ | | |
| ១ | តើមានតែកុមារីទេឬដែលជាជនងាយរងគ្រោះពីការរំលោភបំពានផ្លូវភេទ ? | | | | | | | | | | ទេ |
| ២ | តើកុមារអាចមានគ្រោះថ្នាក់នៃការរំលោភបំពានក្នុងវិស័យទេសចរណ៍ដែរឬទេ ? | | | | | | | | | | ចាស |
| ៣ | តើធ្លាប់មានករណីនៃការរំលោភបំពានកុមារក្នុងវិស័យទេសចរណ៍ក្នុងប្រទេសរបស់អ្នកដែរឬទេ ? | | | | | | | | | | ចាស |
| ៤ | តើអ្នកស្គាល់ពីទំនាក់ទំនងរវាងការរំលោភបំពានកុមារ និងវិស័យទេសចរណ៍នៅកន្លែងការងាររបស់អ្នកដែរឬទេ ? | | | | | | | | | | ចាស |
| ៥ | តើអ្នកស្គាល់សកម្មភាពអ្វីខ្លះដែលអាចធ្វើបានដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍ ? | | | | | | | | | | ចាស |
| ៦ | តើមានរឿងអ្វីខ្លះដែលអាជីវកម្មទេសចរណ៍អាចធ្វើបាន ដើម្បីការពារកុមារពីការរំលោភបំពាន ? | | | | | | | | | | ចាស |
| ៧ | តើអ្នកស្គាល់នរណាដែលអាចទំនាក់ទំនងក្នុងការរាយការករណីសង្ស័យនៃការរំលោភបំពានលើកុមារ ? (ប្រសិនបើស្គាល់ សូមសរសេរឈ្មោះ និងលេខទូរសព្ទ័ទំនាក់ទំនងនៅទីនេះ .................................... | | | | | | | | | | ចាស |
| ៨ | តើមានតែកុមារសុំទាន ឬកុមារដែលរស់នៅតាមចិញ្ចើមថ្នល់ទេឬដែលអាចមានគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ ? | | | | | | | | | | ទេ |
| | **សរុបចំនួននៃទម្រង់ដែលប្រមូលបាន** | | | | | | | **សរុបមធ្យមភាគកើន** | | | |

# ឧបសម្ព័ន្ធទី១១៖ ទម្រង់គំរូរបាយការណ៍ក្រោយការបណ្តុះបណ្តាល

គួរប្រើប្រាស់ទម្រង់គំរូនេះក្នុងការពង្រឹងឧបករណ៍ងាយៗសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ នៅក្នុងវេទិកាពិភាក្សានេះ។ អ្នកសម្របសម្រួលគួរតែជាអ្នកត្រូវបំពេញទម្រង់គំរូ និងចែកជូនទៅឲ្យអ្នកគ្រប់គ្រង/អង្គការនានា ដែលពាក់ព័ន្ធ ដើម្បីអាចប្រើប្រាស់លទ្ធផលតាមដានការសិក្សានេះ និងដើម្បីលើកកម្ពស់សកម្មភាពនានាក្នុងពេលអនាគត។

## ក. សំណួរមុនចូលមេរៀន និងក្រោយមេរៀន

*ត្រូវបញ្ចូលខ្លឹមសារសង្ខេបនៃ **ឧបសម្ព័ន្ធទី១០** ៖ ការវិភាគសំណួរមុនចូលមេរៀន និងរំឭកមេរៀនឡើងវិញ*

## ខ. ទស្សនៈរបស់ខ្ញុំ

*ចូរត្រួតពិនិត្យមើល ទម្រង់ស្តីពី "ទស្សនៈរបស់ខ្ញុំ" ដែលបានទទួល ដើម្បីធ្វើការសង្ខេបដូចតទៅ ៖*

**១. តារាងលម្អិតតាមវិស័យ និង ភេទ**

| វិស័យ | ចំនួនសរុប | ស្ត្រីសរុប | បុរសសរុប | ផ្សេងៗ សរុប |
|---|---|---|---|---|
| រដ្ឋាភិបាល | | | | |
| អាជីវកម្ម | | | | |
| សហគមន៍ | | | | |
| ផ្សេងពីនេះ | | | | |

**២. កម្រិតវាយតម្លៃ**

| | យល់ស្របលេខ និង % | | អព្យាក្រឹតលេខ និង % | | មិនយល់ស្របលេខ និង % | |
|---|---|---|---|---|---|---|
| អ្នកសម្របសម្រួលពន្យល់ច្បាស់លាស់ហើយមេរៀនមានភាពងាយស្រួលអនុវត្ត។ | | | | | | |
| សម្ភារៈទាំងឡាយសុទ្ធតែមានប្រយោជន៍។ | | | | | | |
| ការពិភាក្សា ជួយលើកកម្ពស់ការយល់ដឹងរបស់ខ្ញុំពីបញ្ហានេះ។ | | | | | | |
| ការពិភាក្សាបានលើកទឹកចិត្តខ្ញុំ ឲ្យបង្កើនសកម្មភាពការពារកុមារ។ | | | | | | |

៣. សូមដកស្រង់ចម្លើយដែលឆ្លើយតបនឹងសំណួរ "តើផ្នែកណានៅក្នុងការបណ្តុះបណ្តាលនេះ ដែលមានសារៈប្រយោជន៍បំផុតសម្រាប់អ្នកនៅក្នុងការងារ/ជីវិតរបស់អ្នក?"

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៤. សូមដកស្រង់ចម្លើយដែលឆ្លើយតបនឹងសំណួរ "តើយើងគួរធ្វើអ្វីខ្លះ ដើម្បីកែលម្អការបណ្តុះបណ្តាលនេះឲ្យកាន់តែប្រសើរថែមទៀត ?"

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៥. សូមដកស្រង់ចម្លើយដែលឆ្លើយតបនឹងសំណួរ "សូមកំណត់នូវអ្វីមួយដែលអ្នកនឹងធ្វើខុសពីមុន ដែលជាលទ្ធផលកើតចេញពីព័ត៌មាន និងធនធានដែលអ្នកបានទទួលពីកម្មវិធីបណ្តុះបណ្តាលនេះ។"

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៦. សូមផ្តល់យោបល់ដទៃផ្សេងទៀតដែលអ្នកមាន

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

## គ. ការសង្កេតរបស់អ្នកសម្របសម្រួល

*ការសង្កេតរបស់អ្នកសម្របសម្រួល គឺជាផ្នែកមួយដ៏សំខាន់នៃការវាយតម្លៃ និងសកម្មភាពកែលម្អ។ អ្នកសម្របសម្រួល គួរអង្កេតមើលថាតើអ្នកចូលរួមឆ្លើយតបសំណួរដោយរបៀបណា ? តើពួកគេចូលរួមក្នុងសកម្មភាពក្រុមយ៉ាងណាខ្លះ ? តើពួកគេមានចំណាប់អារម្មណ៍ឬទេ ?  និងតើពួកគេសួរសំណួរបំផុសដល់ការគិតឬទេ ?  នេះគឺជាវិធីមួយដើម្បីវាស់ប្រតិកម្មតបរបស់អ្នកចូលរួម ការរៀនសូត្រ និងបំលាស់ប្តូរអាកប្បកិរិយា។*

១. សូមពន្យល់អំពីចំណាប់អារម្មណ៍ទូទៅរបស់អ្នកលើកម្មវិធីបណ្តុះបណ្តាល។

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

២. សូមពន្យល់ថា តើអ្នកបានជួបប្រទះបញ្ហាណាខ្លះ ?

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

៣. តើមានការលើកឡើងអំពីបញ្ហាការការពារកុមារដែរឬទេ ?

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

……………………………………………………………………………………………………….

៤. សូមផ្តល់យោបល់អំពីកម្រិតការយល់ដឹង និងការចូលរួមរបស់អ្នក

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

៥. តើអ្នកយល់ឃើញថា មេរៀននេះផ្តល់សារៈសំខាន់អ្វីខ្លះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំកម្មវិធីបែបនេះនៅពេលខាងមុខ ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

៦. តើយើងគួរតែកែលម្អការបណ្តុះបណ្តាល និងសម្ភារសម្រាប់បណ្តុះបណ្តាលនេះដូចម្តេចខ្លះ ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

៧. តើចាំបាច់ត្រូវការការបណ្តុះបណ្តាលបន្ថែមទៀតឬទេ ? តើសម្រាប់នរណា ? ហេតុអ្វី ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

# កំណត់ត្រា

# កំណត់ត្រា

# កំណត់ត្រា

សម្ភារអប់រំផ្សេងទៀត ដែលត្រូវបានបង្កើតឡើងសម្រាប់គម្រោងកុមារភាព ផ្នែកបង្ការ រួមមាន ៖



**រក្សាសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទ៖**
កញ្ចប់ឧបករណ៍អ្នកសម្របសម្រួល សម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង



**រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ៖**
កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់វេទិកាពិភាក្សា ជាមួយឪពុកម្តាយ និងអ្នកថែទាំ



**រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ៖**
កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់វេទិកាពិភាក្សាជាមួយអ្នកតំណាងសហគមន៍

ឯកសារនេះក៏មានជាភាសាខ្មែរ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឲ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ រួមមានការទទួលស្គាល់គ្រោះថ្នាក់ដែលអាចកើតមានចំពោះកុមារនៅក្នុងវិស័យទេសចរណ៍ និងចូលរួមដើម្បីកាត់បន្ថយគ្រោះថ្នាក់ទាំងនោះ។ វិស័យទេសចរណ៍ មានឥទ្ធិពលដោយផ្ទាល់លើបរិស្ថានទេសចរណ៍ និងមានសក្តានុពលអាចទទួលបានអត្ថប្រយោជន៍ដ៏ធំធេងពីការអនុវត្តនូវគោលការណ៍មួយចំនួនដើម្បីរក្សាសុវត្ថិភាពកុមារ និងចូលរួមវិភាគទានឆ្ពោះទៅរកទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ។

កញ្ចប់ឧបករណ៍ ដែលមានចំណងជើងថា រក្សាសុវត្ថិភាពកុមារពីការរំលោភបំពាន៖ កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់ការបណ្តុះបណ្តាលវិស័យទេសចរណ៍ គឺជាមគ្គុទ្ទេសន៍ ដ៏ទូលំទូលាយមួយ និងជាពហុឧបករណ៍ ដើម្បីជួយជម្រុញអ្នកសម្របសម្រួលក្នុងការផ្តល់ការបណ្តុះបណ្តាល ដល់ភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ ចាប់ពីបុគ្គលិកជួរមុខ រហូតដល់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់។ ក្នុងនោះ ក៏មានមេរៀនជាក់លាក់មួយចំនួនសម្រាប់មន្ត្រីរដ្ឋាភិបាលផងដែរ។ ការបណ្តុះបណ្តាលនេះ គឺមានសារៈសំខាន់ណាស់សម្រាប់ភាគីពាក់ព័ន្ធវិស័យទេសចរណ៍ទាំងឡាយណា ដែលយកចិត្តទុកដាក់ ចង់បង្កើនគុណភាពទេសចរណ៍ និងចង់ឆ្លើយតបនឹងតម្រូវការអតិថិជនដែលចង់បានទេសចរណ៍ប្រកបដោយការទទួលខុសត្រូវកាន់តែច្រើនឡើងៗ។

ឯកសារនេះក៏មានជាភាសាអង់គ្លេស ឡាវ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឱ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

**Child Safe Tourism**

Take action against abuse

គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (២០១១-២០១៤)។ គម្រោងកុមារភាពនេះ បាននាំមកនូវកិច្ចសហការគ្នារវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម។ កម្មវិធីបានផ្តោតទៅលើទាំងផ្នែកទប់ស្កាត់ និងការការពារ។

Australian Aid

World Vision®